សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ តុលា ឆ្នាំ 2014

# លីអាហូណា



## សាមគ្គីភាពក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ ទំព័រ 14


អ្វីដែលខ្ញុំបានរៀនពីការថប់បារម្ភ ទំព័រ 26

ពរជ័យទាំងបីនៃភាពថ្លៃថ្នូរ ទំព័រ 36

របៀប 5 យ៉ាងដែលយុវវ័យកំពុងធ្វើពង្សប្រវត្តិ ទំព័រ 58



*« ឯស្ត្រីគ្រប់លក្ខណ៍ តើអ្នកណានឹងរកបាន ? ដ្បិតស្ត្រីយ៉ាងនោះមានតម្លៃជាជាងត្បូងទទឹមទៅទៀត » ។*

សុភាសិត 31:10 ។

# លីអាហូណា ខែ តុលា ឆ្នាំ 2014



7

## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ: ការអធិស្ឋានដោយសេចក្ដីជំនឿ**
ដោយ ប្រធាន ហិនរី ប៊ី អាវរិង

7 **សារលិខិតបង្រៀនសួរសុខទុក្ខ: បេសកកម្មដ៏ទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ ៖ នំប៉័ងនៃជីវិត**


## អត្ថបទពិសេស។


14 **កិច្ចការផ្សព្វផ្សាយសាសនា ពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ**
ដោយ អែលឌើរ ដាវីឌ អេ បែដណា
*ការផ្សាយដំណឹងល្អ និង ការស្វែងរកដូនតាយើងដែលបានចែកឋានទៅគឺត្រូវដើរទន្ទឹមគ្នា ។*

20 **គេហដ្ឋាន ៖ កន្លែងដ៏សំខាន់នៃការរៀនសូត្រ**
*ដែលបានរៀនសូត្រនៅក្នុងផ្ទះនឹងនៅជាមួយយើងពេញមួយជីវិត និងដ៏អស់កល្បជានិច្ច*

26 **នៅលើផ្ទៃទឹក**
ដោយ ចូន វែនន័រ
*ទោះជាខ្ញុំមានអារម្មណ៍ថាត្រូវគ្របសង្កត់ដោយរលកនៃការបាក់ទឹកចិត្ត និង កង្វល់ក្តី ក៏ព្រះបន្ទធ្វើឲ្យខ្ញុំអណ្តែតឡើង ហើយរំកិលទៅរកដែនដីសន្យារបស់ខ្ញុំដែរ ។*

28 **អ្នកត្រួសត្រាយផ្លូវនៅគ្រប់ដែនដី: ការប្រែចិត្តជឿ និង ការផ្លាស់ប្តូរនៅក្នុងប្រទេសស៊ីលី**
ដោយ ណេស្ទ័រ ខឺរបើឡូ
*សព្វថ្ងៃនេះ ប្រហែលជាមានម្នាក់ ក្នុងចំណោមប្រជាជនស៊ីលី 30 នាក់ គឺជាសមាជិកនៃសាសនាចក្រ ។*

36 **ភាពក្លាហានដើម្បីជ្រើសយកភាពថ្លៃថ្នូរ**
ដោយ ខារ៉ុល អេហ្វ ម៉ាកខន់ឃី
*តើគោលលទ្ធិ និង ពរជ័យនៃភាពថ្លៃថ្នូរមានអ្វីខ្លះ ?*


## ផ្នែកទាំងឡាយ


8 **ការបម្រើនៅក្នុងសាសនាចក្រ: អរគុណបងប្រុស ជេ**
ដោយ គ្រីស្ទីន ភើរសេល

9 **ពួកព្យាការីគម្ពីរសញ្ញាចាស់: យេរេមា**

10 **យើងនិយាយអំពីព្រះគ្រីស្ទ: ថ្មើមថ្មចម្លាក់រូបស្ពែ**
ដោយ អេលឡិន ស៊ី ជេនស៊ិន

12 **គេហដ្ឋាន និង ក្រុមគ្រួសាររបស់យើង: បេះដូងរបស់លីហ្សកា**
ដោយ ម៉ារីណា ប៉េត្រូវ៉ា

40 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

80 **លុះត្រាយើងជួបទៀត: សេចក្តីបំភាន់**
ដោយ អែលឌើរ អិម រ័សុល បាឡឺដ
*សាតាំងប្រើអន្ទាក់ក្លែងក្លាយ—ប្រៀបបាននឹងនុយរបស់អ្នកនេសាទត្រី—ដើម្បីទាញយើងឲ្យចូលមកជិត ។*


**នៅលើគម្រប**
ខាងមុខ ៖ រូបថតដោយ ឡេសលី និលសុន ។ ខាងក្នុងគម្រប
ខាងមុខ ៖ រចនារូបថតដោយ

## មជ្ឈិមវ័យវ័យក្មេង


44


44 **ការឈរការពារអ្វីដែលយើងជឿ**
*ពួកមជ្ឈិមវ័យវ័យក្មេងចែកចាយពីរបៀបដែលពួកគេបានការពារយ៉ាងម៉ឺងម៉ាត់ចំពោះជំនឿរបស់ពួកគេ ។*

48 **ដំណឹងល្អនៅក្នុងជីវិតរបស់ខ្ញុំ: ទីបន្ទាល់រួមគ្នាតែមួយរបស់ខ្ញុំ**
ដោយ អាយរី ណូឆេ
*ការគ្មានទីបន្ទាល់ពីព្រះគម្ពីរមរមនបានធ្វើឲ្យខ្ញុំចោទសួរពីជំនឿរបស់ខ្ញុំនៅក្នុងសាសនាចក្រ ។*




*ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ នៅពេលណាជាពេលល្អសម្រាប់ការបម្រើ ?*


58

## យុវវ័យ


50 **សិទ្ធិសេរីភាពជ្រើសរើស និង សិទ្ធិជ្រើសរើសខាងសីលធម៌ ?**
ដោយ ម៉ៃគល អរ ម៉ូរីស
*មិត្តខ្ញុំបានធ្វើឲ្យខ្លួនគាត់បាត់បង់គុណសម្បត្តិដើម្បីបម្រើបេសកកម្ម ។ តើខ្ញុំនឹងមានសេរីភាពដែរឬទេ ប្រសិនបើខ្ញុំជ្រើសយកបេសកកម្មនោះ ?*

52 **សំណួរ និង ចម្លើយទាំងឡាយ**
*ខ្ញុំកំពុងព្យាយាមគ្រប់គ្រងគំនិតរបស់ខ្ញុំ ប៉ុន្តែមានការល្បួងច្រើនពេក ។ តើខ្ញុំអាចសម្អាតគំនិតខ្ញុំបានដោយរបៀបណា ?*

54 **របៀបសួរសំណួរដែលសំខាន់ៗ**
ដោយ ដេវីឌ អេ អេដវួដ
*រៀនពីរបៀបសួរសំណួរណាដែលនឹងជួយអ្នកដទៃ ឲ្យរៀនដំណឹងល្អបានប្រសើរជាងមុន ។*

57 **របៀបស្វែងរកកម្លាំង និង ជោគជ័យ**
ដោយ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន
*យើងអាចមានបទពិសោធន៍នូវសុវត្ថិភាព ភាពជោគជ័យ និង សុភមង្គលតាមរយៈការធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។*

58 **ពង្សប្រវត្តិ—ខ្ញុំកំពុងធ្វើកិច្ចការនេះ**
*យុវវ័យទាំងនេះបានរកឃើញពរជ័យមួយចំនួនដែលមិនបានរំពឹងទុកជាមុនតាមរយៈការធ្វើពង្សប្រវត្តិ ។*

61 **ប័ណ្ណប្រកាស ៖ ស្វែងយល់ពីពួកគេ ស្វែងយល់ពីខ្លួនឯង**

62 **ឧបសគ្គធំទាស់នឹងបេសកកម្មខ្ញុំ**
ដោយ អាល់សេនឿ ដេ ស៊ូស្សា

64 **ការរៀនសូត្របន្ថែមទៀតពីអ្វីដែលមាន**
ដោយខាទ្រីន អាពេលសេដ្ឋ-អាណេនសេន
*ជីវិតជាអ្នកផ្សាយសាសនាពេញម៉ោងម្នាក់គឺមានភាពខុសប្លែក ។ យុវវ័យនៅក្នុងទីក្រុងអូស្លូ ប្រទេស ន័រវែស បានចំណាយពេលពេញមួយថ្ងៃរៀបចំសម្រាប់ដំណើរផ្លាស់ប្តូរ ។*


## កុមារ


78


66 **ការបម្រើនៅពេលនេះ ដើម្បីបម្រើនៅពេលក្រោយ**
ដោយ មិចឈី បារបូសា
*ហេតុអ្វីបានជាមរមនសម្រេចចិត្តជួយសម្អាតព្រះវិហារ ជាជាងការលេងបាល់ទាត់ជាមួយនឹងមិត្តគាត់ ?*

68 **ម៉ាធីលដេ រៀបចំខ្លួនជាស្រេចសម្រាប់ថ្នាក់យុវនារី**
ដោយ ជេន វិលកស៍
*រៀនពីបរិយាកាសនៅក្នុងថ្នាក់យុវនារី !*

70 **តន្ត្រី: គ្រាយើងត្រូវក្លាហាន**
ដោយ ជេន ភីនបូរ៉ាហ្វ និង ចេននីស ខាប ភែរី

71 **សាក្សីពិសេស: តើខ្ញុំអាចជួយកិច្ចការពង្សប្រវត្តិតាមវិធីណា ?**
ដោយ អែលឌើរ ឃ្វីនធិន អិល ឃុក

72 **ការនាំថ្នាក់កុមារមកក្នុងលំនៅដ្ឋាន: « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » មកពីព្រះដើម្បីជួយក្រុមគ្រួសារខ្ញុំ**
ដោយ អេរីន សាន់ឌើរសុន និង ជីន ប៊ីងហាំ

74 **ការបង្កើតមិត្តភាពនៅជុំវិញពិភពលោក: ខ្ញុំឈ្មោះបាបារ៉ាមកពីប្រទេសស៊ីលី**
ដោយ អេមី ជេន ឡីវិត

76 **ទំព័ររបស់យើង**

77 **សម្លឹងមើលទៅលើ**
ដោយអែលឌើរ អេឌ្រាន អូឆារ
*យើងបានវង្វេងនៅក្រោមដំណក់ភ្លៀង ហើយសេះរបស់យើងបានរត់ទៅបាត់ ។*

78 **សម្រាប់កុមារតូចៗ: ក្រុមក្នុងគ្រួសារ**
ដោយ ស្សេរ៉ាលី ហាឌី

**ខែ តុលា ឆ្នាំឆ្នាំ 2014 វ៉ុល 13 លេខ 5**
**លីអាហូណា 10990 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង,ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** បិយដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កុត, រ៉ូប៊ឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** ក្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** សមើរវីន ប៊ី អាណុល, ឡារី អ័រ ឡរ៉ិន, ជេមស៍ ប៊ី ម៉ាទីណូ, យ៉ូសែប ដបុលយូ ស៊ីតាទី គ្រីស្ទហ្វែល ហ្គូលឌិន

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉ នើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយបិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** បែរិន ខារ
**ជំនួយការផ្នែកបោះពុម្ព ៖** លីស្សា ស៊ី ឡប៉េស្ស
**និពន្ធ និងកែសម្រួល ៖** ប្រ៊ីតថានី ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. អែដវ៉ដ, ម៉ាថាយ ឌី. ហ្វលិតតុន, ឡារី ហ្វលទ្បើរ ហ្គែរី អេច. ហ្គាហ្វ, ឡារិននេ ផតធើរ ហ្គន, មីនឌី អាន់ ឡេវិត ម៉ៃឃើល អ័រ. ម៉ូរីស, សាលី ចនសុន អូឌេឃីក, យ៉ូស្វេ ជេ ភឺគី, ជេន ភីនប៊ូវ៉ាហ្វ, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនបើជ, ម៉ារីស្សា វឺឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កុត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ចាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី. អាន់ត្រូស, មែនឌី អឹម. ប៉ែនលី, ស៊ី. ឃឹមបឹល បុត, ថូម៉ាស ឆាល, ណាត ហ៊ីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស៊ូសាន ឡហ្វ្រីន, ស្កុត អិម. ម៉ូយ, ម៉ាក ដបុលយូ. រ៉ូប៊ីសុន, ប្រាត ផៀរ, ឃេ. នីកូល វែកឃិនហ្វូស

**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខេវិន ស៊ី. បេ៊ងស៍, ខននី ប៊ូស្រូប ប្រ៊ីដ, ជូលី បើរដែត, ប្រាយអែន ដបុលយូ. ជីគី, ដេនីស គើបៃ, ជិន្នីស ឌីប៊ី, ជីន្នី ហ៊ីននី ជេ. នីលសុន, ហ្គេលី ថេត វ៉ាហ្វើធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្តេហ្វិន អ័រ គ្រីស្ទិនសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona,* Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2014 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
October 2014 Vol. 13 No. 5. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ នៅខាងក្រោមជាគំនិតចំនួនពីរ ។*



« **ពង្សប្រវត្តិ—ខ្ញុំកំពុងធ្វើកិច្ចការនេះ** » ទំព័រ 58 ៖ បង្កើតសម្មភាពជាសៀវភៅកំណត់ហេតុមួយ ! សូមលើកទឹកចិត្តឲ្យសមាជិកគ្រួសារកត់ត្រារឿងគ្រប់យ៉ាងពីជីវិតរបស់ពួកគេ—ជាការចងចាំជាច្រើនឆ្នាំកន្លងទៅ ឬអ្វីមួយដែលបានកើតឡើងចំពោះពួកគេនៅថ្ងៃនោះ ។ សូមជួយគ្រួសារអ្នកឲ្យយល់ថាមានវិធីជាច្រើនដើម្បីសរសេរសៀវភៅកំណត់ហេតុ ។ ពួកគេអាចសរសេរ វាយជាអក្សរ ឬគូររូបនៅក្នុងសៀវភៅកំណត់ហេតុរបស់ពួកគេ ឬពួកគេក៏អាចប្រើប្រដាប់ថតសំឡេង ដើម្បីថតដោយខ្លួនឯងប្រាប់ពីដំណើររឿងមួយផងដែរ ។ សូមលើកទឹកចិត្តគ្រួសារឲ្យបន្តកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុរបស់ពួកគេឲ្យបានញឹកញាប់ ។

« **ការរៀនសូត្របន្ថែមទៀតពីអ្វីដែលមាន** » ទំព័រ 64 ៖ សូមគិតពីការធ្វើជាសកម្មភាពរៀបចំខ្លួនសម្រាប់បេសកកម្មមួយដូចវួដនៅប្រទេសន័រវេបានធ្វើ ។ អ្នកអាចបង្រៀនរឿងដូចគ្នាដែលពួកគេបានធ្វើ — ដូចជារបៀបចាប់ផ្ដើមការសន្ទនាពីដំណឹងល្អ ឬរបៀបអ៊ុតអាវពណ៌-ស—ឬ អ្នកអាចផ្ដោតលើជំនាញផ្សេងទៀតដែលអ្នកជឿថា សមាជិកគ្រួសារអ្នកអាចប្រើប្រាស់វាបាននៅក្នុងតំបន់បេសកកម្ម ។

---

## ជាភាសារបស់អ្នក

*លីអាហូណា* និងឯកសារផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសានៅ languages.lds.org ។

---

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទនេះ ។*

*ការតមអាហារ 4*
*ការធ្វើឲ្យសកម្ម,ការបង្រៀន 20, 36, 54*
*ការបម្រើ 8, 66*
*ការបាក់ទឹកចិត្ត 26, 42*
*ការយកឈ្នះលើសេចក្ដីល្បួង 43, 44, 52, 80*
*ការសាកល្បង 12, 26, 62*
*ការហៅ 8*
*ការអធិស្ឋាន 4, 40, 71*
*កិច្ចការផ្សព្វផ្សាយសាសនា 14, 28, 62, 64*
*កិច្ចការព្រះវិហារបរិសុទ្ធ 14, 58*
*គ្រួសារ 12, 20, 61, 72, 78*
*ដង្វាយធួន 10, 80*
*ថ្នាក់យុវនារី 68*
*ទីបន្ទាល់ 48*
*ប្រទេសស៊ីលី 28, 74*
*ប្រវត្តិសាស្ត្ររបស់សាសនាចក្រ 28*
*ផែនការនៃសេចក្ដីសង្គ្រោះ 14, 20, 54, 58, 62, 64*
*ពង្សប្រវត្តិ 14, 58, 71*
*ព្រះគម្ពីរមរមន 48*
*ព្រះគុណ 10*
*ព្រះយេស៊ូវគ្រីស្ទ 7, 57*
*ភាពទន់ខ្សោយ 10*
*ភាពរមទម្យ 36*
*យេរេមា 9*
*សិទ្ធិជ្រើសរើស 50*
*សេចក្ដីជំនឿ 4, 26*
*សេចក្ដីស្រឡាញ់ 8, 41*



ដោយ ប្រធាន ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

# ការអធិស្ឋាន ដោយសេចក្ដីជំនឿ

ការអធិស្ឋានគឺលើសពីពាក្យសម្ដីដែលយើងនិយាយទៅកាន់ព្រះទៅទៀត ។ វាគឺជាទំនាក់ទំនងទៅវិញទៅមករវាងព្រះ និង កូនចៅរបស់ទ្រង់ ។

កាលណាការអធិស្ឋានដំណើរការតាមរបៀបរបស់វា នោះយើងសម្ដែងអារម្មណ៍ក្នុងដួងចិត្តយើងជាពាក្យសម្ដីដ៏សាមញ្ញ ។ ជាធម្មតា ព្រះវរបិតាសួគ៌ឆ្លើយតបដោយការដាក់គំនិតនៅក្នុងចិត្តយើង ព្រមជាមួយនឹងអារម្មណ៍ ។ ទ្រង់តែងស្ដាប់ការអធិស្ឋានដ៏ស្មោះដែលយើងធ្វើឡើង កាលណាយើងអធិស្ឋានដោយការតាំងចិត្តមួយ ដើម្បីគោរពប្រតិបត្តិតាមទ្រង់ មិនថាចម្លើយរបស់ទ្រង់ជាអ្វី ហើយវាមកនៅពេលណានោះឡើយ ។

ព្រះអម្ចាស់ធ្វើការសន្យានេះដល់មនុស្សទាំងអស់ដែលអាន ហើយអធិស្ឋានពីព្រះគម្ពីរមរមនថា ៖

« ហើយកាលណាអ្នករាល់គ្នាទទួលនូវការណ៍ទាំងនេះ នោះខ្ញុំសូមទូន្មានដល់អ្នករាល់គ្នាឲ្យសូមសួរដល់ព្រះជាព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច ដោយនូវព្រះនាមនៃព្រះគ្រីស្ទ បើសិនជាការណ៍ទាំងនេះមិនពិត ហើយបើសិនជាអ្នករាល់គ្នាសូមសួរដោយចិត្តស្មោះសគី ដោយស្មោះអស់ពីចិត្ត ដោយមានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ នោះទ្រង់នឹងសម្ដែងសេចក្ដីពិតនៃការណ៍នេះដល់អ្នកដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។

« ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នាអាចស្គាល់សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ »។ ( មរ៉ូណៃ 10:4–5 ) ។

ការសន្យានោះគឺច្បាស់លាស់ណាស់ ។ មានមនុស្សរាប់លាននាក់បានសាកល្បង ហើយបានរកឃើញពីការសន្យាដ៏អស្ចារ្យនោះស្ដីពីការអធិស្ឋានតាមរយៈការទទួលពរជ័យមួយដែលបានបំពេញជីវិតរបស់ពួកគេជាមួយនឹងសេចក្ដីអំណរ និង សុភមង្គលជារៀងរហូត ។ ការសន្យានោះអនុវត្តនៅរាល់ការអធិស្ឋានរបស់យើង ដើម្បីឲ្យដឹងពីព្រះតំរិះ និង ព្រះហឫទ័យរបស់ព្រះចំពោះយើង ។ យើងអាចអនុវត្តវានៅពេលណាយើងទទួលការប្រឹក្សាពីអ្នកបម្រើម្នាក់របស់ព្រះដែលត្រូវបានផ្ដល់សិទ្ធិឲ្យដើម្បីផ្ដល់ការណែនាំដល់យើង ។ ឧទាហរណ៍ យើងអាចពឹងផ្អែកលើការប្រឹក្សានោះ នៅពេលយើងបានស្ដាប់ដល់ការបង្រៀនមួយនៅក្នុងសន្និសីទទូទៅ ។ យើងអាចអនុវត្តការប្រឹក្សានោះនៅពេលយើងត្រូវបានបង្រៀនដោយពួកអ្នកផ្សព្វផ្សាយសាសនាដ៏រាបសារ ដែលត្រូវបានហៅដោយព្រះតាមរយៈព្យាការីនៅរស់ ។ ការប្រឹក្សានោះក៏អនុវត្តចំពោះការប្រឹក្សាដែលយើងទទួលពីប៊ីស្សព ឬប្រធានសាខារបស់យើងផងដែរ ។

ដើម្បីធ្វើឲ្យការអធិស្ឋានដំណើរការនៅក្នុងជីវិតយើង វិធីគឺសាមញ្ញ ។ យើងត្រូវទូលសូមដើម្បីដឹងពីអ្វីដែលពិត តាមរយៈការអធិស្ឋានទៅព្រះវរបិតានៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ។ យើងត្រូវទូលសូមដោយចិត្តស្មោះ ដែលមានន័យថាយើងត្រូវមានបំណងស្មោះត្រង់ ដើម្បីធ្វើអ្វីៗដែលចម្លើយរបស់ព្រះតម្រូវឲ្យយើងធ្វើ ។ ហើយបំណងដ៏ពិតរបស់យើងត្រូវតែកើតចេញពីសេចក្ដីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ។

អ្នករៀនថ្មីដែលអានព្រះគម្ពីរមរមនពីមុនបានទទួលពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់អាចទទួលបានការអះអាងថា ព្រះគម្ពីរនេះពិត និងជាសាក្សីមួយថាយ៉ូសែប ស្ម៊ីធ បានបកប្រែព្រះគម្ពីរនេះដោយព្រះចេស្ដានៃព្រះ ។ ក្រោយពីត្រូវបានបញ្ជាក់ជាសមាជិកសាសនាចក្រហើយ យើងអាចមានព្រះវិញ្ញាណបរិសុទ្ធជាដៃគូរបស់យើងដើម្បីបញ្ជាក់ពីសេចក្ដីពិតផ្សេងទៀត ។ បន្ទាប់មក នៅពេលណាយើងអធិស្ឋានដោយសេចក្ដីជំនឿ នោះយើងអាចរំពឹងទុកថា ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើទីបន្ទាល់ដល់យើងថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ថាព្រះជា



ព្រះវរបិតាមានព្រះជន្មរស់ ហើយថា ទ្រង់ទាំងពីរអង្គស្រឡាញ់យើង និងកូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌ ។

នោះគឺជាហេតុផលមួយ ទើបមានការសន្យាមួយនៅក្នុងព្រះគម្ពីរមរមនថា យើងនឹងមានសេចក្ដីសប្បុរសនៅក្នុងចិត្តយើង កាលព្រះវិញ្ញាណបរិសុទ្ធថ្លែងជាសាក្សីដល់យើងថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ៖ « បើសិនជាមនុស្សនោះស្លូតបូត ហើយសុភាពរាបសា ហើយទទួលស្គាល់ដោយនូវព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ អ្នកនោះត្រូវតែមានសេចក្ដីសប្បុរស » ( មរ៉ូណៃ 7:44 ) ។

នៅរាល់អាទិត្យតមអាហារមាននូវឱកាសដ៏អស្ចារ្យមួយដើម្បីរីកចម្រើនខាងវិញ្ញាណ ។ ថ្ងៃអាទិត្យតមអាហារអាចជួយយើងឲ្យមានបទពិសោធន៍ស្រដៀងគ្នានឹងអាលម៉ា និង ពួកបុត្រារបស់ម៉ូសាយ ដែលបានអធិស្ឋាន ហើយតមអាហារដើម្បីឲ្យដឹងពីសេចក្ដីពិតដ៏អស់កល្ប ដើម្បីពួកគេអាចបង្រៀនដល់សាសន៍លេមិនដោយព្រះចេស្ដាសិទ្ធិអំណាច និង សេចក្ដីស្រឡាញ់ ( សូមមើល អាលម៉ា 17:3,9 ) ។

នៅអាទិត្យតមអាហារយើងដាក់គ្នានូវការអធិស្ឋាន និង ការតមអាហារបញ្ចូលគ្នា ។ ដើម្បីជាពរជ័យដល់អ្នកក្រីក្រ យើងផ្ដល់ដង្វាយតមអាហារដ៏សប្បុរសមួយដល់ប៊ីស្សព ឬ ប្រធានសាខាដែលវាស្មើយ៉ាងហោចណាស់នឹងតម្លៃនៃអាហារពីរពេលដែលយើងមិនបានបរិភោគ ។ គំនិត និង ការអធិស្ឋានរបស់យើងត្រូវបានងាកទៅរកព្រះអង្គសង្គ្រោះ និង ទៅរកជនដែលទ្រង់សព្វព្រះហឫទ័យឲ្យយើងបម្រើតាមរយៈការជួយដល់សេចក្ដីត្រូវការខាងវិញ្ញាណ និង ខាងសាច់ឈាមរបស់ពួកគេ ។

ដូច្នេះ ការអធិស្ឋាន និង បំណងរបស់យើងកាន់តែប្រែក្លាយដូចជាការអធិស្ឋាន និង ព្រះរាជបំណងរបស់ព្រះអង្គសង្គ្រោះ កាលណាយើងតមអាហារដើម្បីឲ្យមានភាពរាបសា ងាយបង្រៀន ហើយមានសេចក្ដីស្រឡាញ់កាន់តែច្រើននោះ ។ ហើយដូចដែលទ្រង់បានធ្វើ នោះយើងអធិស្ឋានដើម្បីដឹងពីព្រះហឫទ័យរបស់ព្រះវរបិតាមានសម្រាប់យើង ហើយធ្វើវា ។ ■

### ការបង្រៀនចេញពីសារលិខិតនេះ

ប្រធាន អាវរិងបង្រៀនថា ការអធិស្ឋាន និង ការតមអាហារអាចជួយយើងឲ្យ « ដឹងពីសេចក្ដីពិតអស់កល្ប » ។ សូមគិតពីរបៀបដែលទីបន្ទាល់របស់សមាជិកដែលអ្នកទៅសួរសុខទុក្ខអាចត្រូវការការពង្រឹងកន្លែង ហើយរៀបចំមេរៀនមួយពីប្រធានបទនោះ ។ ឧទាហរណ៍ ប្រសិនបើសមាជិកម្នាក់ដែលអ្នកទៅសួរសុខទុក្ខបានបាត់បង់មិត្ត ឬសមាជិកគ្រួសារជិតស្និទ្ធ សូមគិតពីការពិភាក្សាពីក្រុមគ្រួសារអស់កល្ប និងជីវិតក្រោយពីការស្លាប់ ។ អ្នកអាចសុំតមអាហារជាមួយនឹងសមាជិកដែលអ្នកទៅសួរសុខទុក្ខ ដើម្បីជួយពួកគេទទួលបានទីបន្ទាល់មួយពីគោលការណ៍នោះ ។

## សូមរៀបចំខ្លួនមុននឹងអ្នកអធិស្ឋាន

ប្រធាន អារវិងរំឭកយើងថា ការអធិស្ឋាន « គឺជាទំនាក់ទំនងទៅវិញទៅមករវាងព្រះ និង កូនចៅរបស់ទ្រង់ » ។ ការចំណាយពេលរៀបចំខ្លួនសម្រាប់ការអធិស្ឋាន នោះយើងអាចធ្វើឲ្យទំនាក់ទំនងទៅវិញទៅមកនោះអាចកើតឡើងបាន ។ អ្នកអាចប្រើសៀវភៅកំណត់ហេតុរបស់អ្នក ដើម្បីចំណាយពេលពីរបីនាទីរៀបចំខ្លួនអធិស្ឋានជារៀងរាល់ថ្ងៃ ។ អ្នកអាចធ្វើជាបញ្ជីពីពរជ័យដែលអ្នកចង់ថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ ពីមនុស្សដែលត្រូវការការអធិស្ឋានអ្នក និងពីសំណួរដែលអ្នកអាចត្រូវការចម្លើយ ។ បន្ទាប់មកអញ្ជើញព្រះវិញ្ញាណដោយការច្រៀងទំនុកតម្កើងមួយ ឬអានបទគម្ពីរពីរបីខ ។ នៅពេលអ្នកអធិស្ឋាន សូមយកចិត្តទុកដាក់ចំពោះរបៀបដែលព្រះវិញ្ញាណបរិសុទ្ធប្រាប់នូវអ្វីដែលអ្នកគួរនិយាយ ហើយយកចិត្តទុកដាក់ចំពោះអារម្មណ៍ និង គំនិតរបស់អ្នក ( សូមមើល គ. និង ស. 8:2–3)។ សូម



គិតពីការកត់ត្រានូវបទពិសោធន៍របស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ហើយមើលឡើងវិញនូវចម្លើយដែលអ្នកទទួល ។ អ្នកក៏អាចប្រើសកម្មភាពនៅទំព័រ 97–99 នៅក្នុង *ប្រកាសដំណឹងល្អរបស់យើង ៖ សៀវភៅណែនាំសម្រាប់ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា*ដើម្បីជួយអ្នកឲ្យវាយតម្លៃទៅលើការអធិស្ឋានរបស់អ្នក ហើយរៀនស្គាល់ព្រះវិញ្ញាណបរិសុទ្ធ ។



## ជំហាននៃការអធិស្ឋាន

តើអ្នកដឹងពីអ្វីដែលអ្នកត្រូវនិយាយបានដោយរបៀបណា នៅពេលអ្នកអធិស្ឋាននោះ ? អ្នកអាចចាប់ផ្តើមការអធិស្ឋានរបស់អ្នកដោយនិយាយថា « ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ » ហើយបញ្ចប់ដោយនិយាយថា « នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន » ។ អ្វីដែលអ្នកចង់និយាយនៅចន្លោះនោះ គឺជាជម្រើសរបស់អ្នក ដូចជាការជ្រើសដាក់អ្វី។នៅក្នុងនំប៉័ងសាំងវិចដូច្នោះដែរ ។

សូមជ្រើសយកគ្រឿងផ្សំដែលអ្នកចូលចិត្តនៅក្នុងនំប៉័ងសាំងវិចរបស់អ្នក ។ សូមសរសេរពីរឿងដែលអ្នកចង់អធិស្ឋាននៅក្បែរនោះ ។ អ្នកអាចនិយាយថា « សូមអរព្រះគុណ » សម្រាប់ពរជ័យទាំងឡាយ និយាយពីកង្វល់របស់អ្នក ទូលសូមពរជ័យ ឬអធិស្ឋានសួរសំណួរ ។

អ្នកអាចកាត់នំប៉័ងសាំងវិចនេះ ឬធ្វើវាមួយទៀត ។ ព្យួរវានៅក្នុងផ្ទះរបស់អ្នក ដើម្បីជួយអ្នកឲ្យចងចាំពីរឿងទាំងឡាយដែលអ្នកអាចនិយាយនៅក្នុងការអធិស្ឋានរបស់អ្នក ។



ព្រះវរបិតាសួគ៌ជាទីស្រឡាញ់

នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

រូបភាពដោយ TAICHI_K/ISTOCK/THINKSTOCK

## សារលិខិតបង្រៀនសួរសុខទុក្ខ

*សូមសិក្សាឯកសារនេះដោយការអធិស្ឋាន ហើយព្យាយាមយល់ដឹងនូវអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងពីឆាកជីវិត និង បេសកកម្មរបស់ព្រះអង្គសង្គ្រោះ នឹងពង្រឹងសេចក្ដីជំនឿរបស់អ្នកលើទ្រង់ ហើយប្រទានពរដល់ជនអ្នកទាំងឡាយដែលអ្នកមើលថែតាមរយៈការបង្រៀនតាមផ្ទះបានដោយរបៀបណា ? ចំពោះព័ត៌មានបន្ថែម សូមចូលទៅ reliefsociety.lds.org។*

**សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

# បេសកកម្មដ៏ទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ នំប៉័ងនៃជីវិត



*នេះជាផ្នែកនៃគំរូមួយអំពីសារលិខិតបង្រៀនតាមផ្ទះ ដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។*

ព្រះយេស៊ូវបានមានបន្ទូលថា « ខ្ញុំជានំប៉័ងដ៏រស់ដែលចុះពីស្ថានសួគ៌មក បើអ្នកណាបរិភោគនំប៉័ងនេះ នោះនឹងរស់នៅអស់កល្បជានិច្ច » ( យ៉ូហាន 6:51 ) ។ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា « ព្រះយេស៊ូវបង្រៀនយើង ដែលជាពួកសិស្សទ្រង់ថា យើងគួរមើលទៅព្រះរាល់ថ្ងៃសម្រាប់នំប៉័ង—ជំនួយ និង ការទ្រទ្រង់ជីវិត—ដែលយើងត្រូវការនៅក្នុងថ្ងៃនោះ » ។ « ការអញ្ជើញរបស់ព្រះអម្ចាស់ . . . ថ្លែងពីព្រះជាទីស្រឡាញ់មួយអង្គ ដែលជ្រាបសូម្បីតែសេចក្ដីត្រូវការប្រចាំថ្ងៃដ៏តូចរបស់កូនចៅទ្រង់ ហើយចង់ជួយពួកគេម្ដងម្នាក់ៗ ។ ទ្រង់កំពុងតែមានព្រះបន្ទូលថា យើងអាចសុំដោយសេចក្ដីជំនឿនៃជន ‹ ដែលប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ › ( យ៉ាកុប 1:5 ) ។[1] នៅពេលយើងដឹងថា ព្រះយេស៊ូវគ្រីស្ទនឹងបំពេញសេចក្ដីត្រូវការរបស់យើង នោះយើងនឹងងាកទៅរកទ្រង់សម្រាប់ការទ្រទ្រង់ជីវិតខាងវិញ្ញាណរបស់យើង ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់អញ្ជើញយើង « ឲ្យចូលរួមនៅក្នុងដំណើរផ្សងព្រេងនៃសិស្សរបស់ព្រះគ្រីស្ទកាលពីបុរាណ ដែលចង់បាននំប៉័ងនៃជីវិតដែរ—ជនដែលមិនត្រឡប់ថយក្រោយ ប៉ុន្តែជាជនដែលបានមករកទ្រង់ នៅជាមួយនឹងទ្រង់ ហើយដែលស្គាល់ថា សម្រាប់សុវត្ថិភាព និង សេចក្ដីសង្គ្រោះ ពួកគេមិនអាចពឹងផ្អែកទៅលើនរណាផ្សេងទៀតបានឡើយ » ។[2]

### *ព្រះគម្ពីរបន្ថែម*

យ៉ូហាន 6:32–35, អាលម៉ា 5:34, នីហ្វៃទី 3 20:3–8

### *ដកស្រង់ចេញពីព្រះគម្ពីរ*

ព្រះយេស៊ូវគ្រីស្ទបានបង្រៀនដល់ហ្វូងមនុស្សច្រើនជាង 4,000 នាក់ ។ បីថ្ងៃក្រោយមក ទ្រង់បានមានបន្ទូលទៅពួកសិស្សរបស់ទ្រង់ថា ៖ « ខ្ញុំមានចិត្តក្ដួលអាណិតដល់មនុស្សទាំងអស់នេះណាស់ ពីព្រោះគេ. . . គ្មានអ្វីបរិភោគទេ ៖

« បើខ្ញុំឲ្យគេត្រឡប់ទៅផ្ទះវិញទាំងអត់ នោះគេនឹងហេវតាមផ្លូវ ត្បិតខ្លះបានមកពីឆ្ងាយណាស់ ។ . . .

« ពួកសិស្សទូលឆ្លើយថា នៅទីស្ងាត់នេះ តើនឹងរកនំប៉័ងពីណា ដើម្បីចំអែតដល់មនុស្សទាំងនេះបាន ?

« [ ព្រះយេស៊ូវ ] សួរគេថា អ្នករាល់គ្នាមាននំប៉័ងប៉ុន្មាន ? គេទូលឆ្លើយថា មានប្រាំពីរ » ។

រួចព្រះគ្រីស្ទ « យកនំប៉័ងប្រាំពីរនោះមក ក៏អរព្រះគុណ ហើយកាច់ប្រទានដល់ពួកសិស្ស ឲ្យលើកទៅជូនដល់ហ្វូងមនុស្ស . . .

« គេក៏លើកទៅមានត្រីតូចៗខ្លះដែរ កាលទ្រង់បានប្រទានពរហើយ នោះក៏បង្គាប់ឲ្យលើកយកទៅឲ្យគេ ។

« ហើយទាំងអស់គ្នាបានបរិភោគឆ្អែត រួចគេប្រមូលចំណិតដែលសល់នៅបានប្រាំពីរកំប្រោង » ។ ( សូមមើលម៉ាកុស 8:1–9 ) ។

### *សូមពិចារណាចំណុចនេះ*

នៅពេលយើងមករកព្រះគ្រីស្ទ តើទ្រង់ចិញ្ចឹមបីបាច់យើងតាមរបៀបណា ?

**កំណត់ចំណាំ**

1. ឌី ថត គ្រីស្តូហ្វឺសិន « Recognizing God's Hand in Our Daily Blessings » *Liahona* ខែ មករា ឆ្នាំ 2012 ទំព័រ 25 ។
2. ជែហ្វ្រី អ័រ ហូឡិន « He Hath Filled the Hungry with Good Things » *Liahona* ខែ មករា ឆ្នាំ 1998 ទំព័រ 76 ។

សេចក្ដីលម្អិតពីផ្ទាំងគំនូរ *IN REMEMBRANCE OF ME* ដោយ វលធើរ រេន




# អរគុណបងប្រុស ជេ

ដោយ គ្រីស្ទីន ភើរសេល

*ខ្ញុំមានអំណរគុណយ៉ាងខ្លាំចំពោះអារម្មណ៍ ការតាំងចិត្ត ការរៀបចំ និង សេចក្ដីស្រឡាញ់នៃពួកអ្នកបម្រើដ៏ស្មោះត្រង់ជាច្រើនរាប់មិនអស់នៅទូទាំងសាសនាចក្រ ។*

ខ្ញុំបានប្រាប់កូនស្រីខ្ញុំអាយុប្រាំឆ្នាំកាលនាងអង្គុយនៅលើភ្លៅរបស់ខ្ញុំថា « ស្អែកគឺជាថ្ងៃអាទិត្យ » ។ ស្នាមញញឹមបានលេចឡើងនៅលើផ្ទៃមុខរបស់នាង ។

នាងបានតបថា « អ៊ូ ល្អណាស់ » ។ « អញ្ចឹងកូននឹងបានជួបបងប្រុសជេហើយ » ។

អំណរគុណបានមានពេញដួងចិត្តខ្ញុំ ។ ខ្ញុំមានអំណរគុណជាខ្លាំងចំពោះគ្រូបង្រៀនថ្នាក់កុមារម្នាក់ដែលមានសេចក្ដីស្រឡាញ់ ហើយចេះជួយទុក្ខធុរៈជាអ្នកដែលបានធ្វើឲ្យដំណើរផ្លាស់ប្ដូររបស់យើងទៅកាន់វួដថ្មីមួយ បន្ទាប់ពីការផ្លាស់ប្ដូរទីលំនៅមានភាពងាយស្រួល ។ ដោយចាកចេញពីផ្ទះរបស់យើងនៅភូមិភាគកណ្ដាលភាគខាងលិចនៃសហរដ្ឋអាមេរិក ហើយប្ដូរទីលំនៅថ្មីដែលមានចម្ងាយ 2,173 គ.ម.ពីគ្នា បានធ្វើឲ្យគ្រួសារទាំងមូលមានការលំបាកជាពិសេសកូនស្រីយើង ស៊ីស្សិន ។ ដោយមានភាពខ្មាស់អៀនពីកំណើតនោះនាងភ័យខ្លាចចំពោះស្ថានភាពថ្មី ហើយបារម្ភពីការទៅព្រះវិហារសម្រាប់សប្ដាហ៍ទីមួយរបស់យើងនៅក្នុងវួដថ្មីមួយ ។

បងប្រុសជេ ជាបុរសដែលសុភាព ហើយការលះបង់ ដោយប្រើពាក្យកំប្លែង លាយបញ្ចូលនឹងសេចក្ដីស្រឡាញ់ដ៏ត្រឹមត្រូវដើម្បីទាក់ទាញចិត្តស៊ីស្សិន ។ នៅថ្ងៃអាទិត្យទីមួយនោះ បានឱនចុះចាប់ដៃនាង ហើយមើលមុខនាង រួចក៏ពោលថា « តោះ ស៊ីស្សិន ។ ប្អូននឹងសប្បាយរីករាយនៅក្នុងថ្នាក់របស់យើង » ។

កាលជាច្រើនសប្ដាហ៍បានកន្លងផុតទៅ ស៊ីស្សិនបានទន្ទឹងចាំថ្ងៃអាទិត្យលើសពីថ្ងៃណាៗទាំងអស់ ។ កាលយើងបានមកដល់ព្រះវិហារភ្លាម នាងបានរកមើលគ្រូបង្រៀនរបស់នាងនៅក្នុងក្រុមជំនុំ ។ គាត់បានញញឹមរាក់ទាក់ ។

អស់រយៈពេលជាច្រើនឆ្នាំ បងប្រុសជេ បានចងចាំសិស្សម្នាក់ៗដោយផ្ដល់អំណោយបន្តិចបន្តួចសម្រាប់ថ្ងៃបុណ្យឈប់សម្រាក និង ថ្ងៃខួបកំណើត ។ កាលថ្ងៃកំណើតស៊ីស្សិនបានមកដល់ ភ្ញៀវដ៏សំខាន់បំផុតដែលនាងអញ្ជើញមកពិធីជប់លៀងរបស់នាងគឺបងប្រុសជេ ។

តើគាត់បានដឹងថាគាត់មានឥទ្ធិពលនៅក្នុងជីវិតកូនស្រីដ៏តូចរបស់យើងប៉ុណ្ណាទេ ? តើគាត់ធ្លាប់ស្មានដឹងថាពាក្យសម្ដី និង ទង្វើរបស់គាត់បានជះឥទ្ធិពលទៅលើសិស្សក្នុងថ្នាក់កុមារគាត់ដែលមានអាយុប្រាំឆ្នាំប៉ុណ្ណាដែរទេ ? តើគាត់បានដឹងថាវាមានន័យយ៉ាងណាចំពោះខ្ញុំដែរទេ ក្នុងនាមជាម្ដាយម្នាក់ ដោយមានគាត់ជាផ្នែកមួយនៃជីវិតកូនស្រីរបស់ខ្ញុំនោះ ?

ក្រោយមកទៀត ស៊ីស្សិនបានឡើងថ្នាក់ដោយចូលរៀនក្នុងថ្នាក់បងប្រុស អេដវួដ ហើយបទពិសោធន៍ដ៏អស្ចារ្យរបស់នាងក្នុងថ្នាក់កុមារបានបន្ត ។ ខ្ញុំមានអំណរគុណជាខ្លាំងចំពោះបុរសនិងស្ត្រីដែលយកចិត្តទុកដាក់ រៀបចំយ៉ាងល្អិតល្អន់ ហើយរាបសារដែលបានជះឥទ្ធិពលខាងវិញ្ញាណដ៏វិជ្ជមានមួយដល់ជីវិតរបស់ស៊ីស្សិន ។

គ្រួសារយើងទាំងមូលមានពរតាមរយៈបុគ្គលទាំងឡាយដែលបូជាលះបង់ខ្លួន ដោយបានបម្រើយើងនៅលើផ្លូវនៃការរីកចម្រើនខាងវិញ្ញាណរបស់យើង ។ ខ្ញុំនៅចងចាំពីគ្រូក្រុមកាយវិទ្ធិដ៏ឆ្នើម អ្នកប្រឹក្សាក្នុងកូរ៉ុមសង្ឃដែលមានចិត្តអត់ធ្មត់ គ្រូថ្នាក់សិក្ខាសាលា គណៈប្រធានយុវនារីដ៏អស្ចារ្យ និង ប៊ីស្សដែលយកចិត្តទុកដាក់ ។

គ្រួសារយើងមានពរជ័យយ៉ាងធំ ខ្ញុំដឹងថា យើងពុំមែនជាមនុស្សពិសេសនោះទេ ។ « បងប្រុសជេ » អាចជាមនុស្សជាច្រើន ពីព្រោះមានបងប្អូនប្រុសស្រីជាច្រើនដែលមានការលះបង់ ហើយដែលការបម្រើរបស់ពួកគេបានជួយដល់ជីវិតក្រុមគ្រួសារជាច្រើនដូចជាគ្រួសារយើងផងដែរ ។ យើងមានអំណរគុណជាខ្លាំងចំពោះអារម្មណ៍ ការតាំងចិត្ត ការរៀបចំ និង សេចក្ដីស្រឡាញ់ ។

សូមអរគុណចំពោះពួកអ្នកបម្រើដ៏ស្មោះត្រង់ជាច្រើនរាប់មិនអស់នៅទូទាំងសាសនាចក្រដែលបានជួយដល់គ្រួសារយើង ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ណាវ៉ាដា ស.រ.អា. ។*



**ខិតខំកែប្រែជីវិត**

« សូមឲ្យយើងផ្ដោតលើវិធីដ៏សាមញ្ញនានាដែលយើងបម្រើនៅក្នុងនគរព្រះដោយខិតខំកែប្រែជីវិតរួមទាំងជីវិតរបស់យើងផងដែរ » ។

**អែលឌើរ អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « O Be Wise » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2006 ទំព័រ 20 ។**

រូបថតដោយ NIKOLAI SOROKIN/HEMERA/THINKSTOCK

# យេរេមា

*« យេរេមាបានរស់នៅក្នុងគ្រា និង ទីកន្លែងមួយដ៏លំបាក ប៉ុន្តែព្រះអម្ចាស់បានអនុញ្ញាតឲ្យគាត់មើលឃើញជាមុននូវ ‹ គ្រាមួយនៃសេចក្តីសង្ឃឹមអំឡុងពេលនៃការប្រមូលសាសន៍អ៊ីស្រាអែលនៅថ្ងៃចុងក្រោយ » ។[1] —លីនដា ខេ បើតុន ប្រធានសមាគមសង្គ្រោះទូទៅ*

ខ្ញុំជាកូនប្រុសរបស់ហ៊ីលគីយ៉ា ជាសង្ឃនៅអាន៉ាថោត ក្បែរយេរូសាឡិម ។ កាលខ្ញុំនៅជាយុវវ័យ « ព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា

« មុនដែលយើងបានជប់បង្កើតអ្នកនៅក្នុងពោះម្តាយ នោះយើងស្គាល់អ្នកហើយ កាលមុនដែលអ្នកសំរាលចេញពីផ្ទៃមក នោះយើងបានញែកអ្នកជាបរិសុទ្ធផង ក៏បានតាំងអ្នកឡើងជាហោរាដល់អស់ទាំងសាសន៍ » ។

ខ្ញុំមានអារម្មណ៍ថា មិនបានរៀបចំខ្លួនសម្រាប់ការហៅនេះនៅឡើយ រួចខ្ញុំក៏ទូលទៅវិញថា « មើលទូលបង្គំគ្មានវោហារអធិប្បាយទេ ត្បិតទូលបង្គំជាមនុស្សក្មេងសុទ្ធ » ។

ព្រះអម្ចាស់មានបន្ទូលតបថា « កុំឲ្យថាអ្នកជាមនុស្សក្មេងឡើយ ត្បិតបើយើងចាត់អ្នកឲ្យទៅអ្នកណា នោះអ្នកត្រូវតែទៅ ហើយសេចក្តីអ្វីដែលយើងបង្គាប់អ្នក នោះអ្នកត្រូវតែប្រាប់ដែរ ។

« កុំឲ្យខ្លាចចំពោះគេឡើយ ត្បិតយើងនៅជាមួយដើម្បីនឹងជួយឲ្យអ្នករួច » ។ រួចព្រះអម្ចាស់ « បានលូកព្រះហស្តមកពាល់មាត់ខ្ញុំ » ហើយដាក់ពាក្យនៅក្នុងវា ។[2]

ខ្ញុំបានព្យាករនៅក្នុងយេរូសាឡិមអស់រយៈពេល 40 ឆ្នាំ ពីឆ្នាំ 626 រហូតដល់ឆ្នាំ 586 មុន គ.ស.ក្នុងរាជ្យស្តេចយ៉ូសៀល យេហូយ៉ាគីម និង សេដេគា ។[3] ខ្ញុំស្ថិតនៅជំនាន់ព្យាការីលីហៃក្នុងព្រះគម្ពីរមរមន ។ យើងទាំងពីរត្រូវបានគេថ្កោលទោស ចំពោះអំពើទុច្ចរិតរបស់ប្រជាជននៅយេរូសាឡិម ហើយបានប្រាប់ទុកជាមុនពីសេចក្តីបំផ្លិចបំផ្លាញនៃទីក្រុងដ៏ធំនោះ ។[4]

ព្រះអម្ចាស់បានត្រាស់បង្គាប់ឲ្យខ្ញុំកត់ត្រាការព្យាកររបស់ខ្ញុំនៅក្នុង « ក្រាំងមួយ » ។[5] កាលស្តេចយេហូយ៉ាគីមបានឮពីការព្យាករ នោះទ្រង់បានដុតក្រាំងនោះចោល ។ ព្រះអម្ចាស់បានត្រាស់បង្គាប់ខ្ញុំឲ្យសរសេរការព្យាករទាំងឡាយម្តងទៀត ហើយបន្ថែមការព្យាករជាច្រើនទៀតពីលើការព្យាករទាំងនោះ ។[6]

ខ្ញុំបានជួបនឹងការជំទាស់ជាបន្តបន្ទាប់ កាលខ្ញុំផ្សាយព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ ផាសហើរ ជាកូនប្រុសរបស់នាយកធំ បានវាយខ្ញុំ ហើយយកខ្ញុំទៅដាក់គុក ។ ពួកជនកំណាចចង់ផ្តាច់ជីវិតខ្ញុំដោយសារតែការផ្សព្វផ្សាយរបស់ខ្ញុំ ។ ខ្ញុំជាព្យាការីមួយរូបដែលពុំល្បីឈ្មោះ ជារឿយៗត្រូវបានគេចាប់ដាក់គុកងងឹត និងពន្ធនាគារ ។ ខ្ញុំបានរស់នៅក្នុងគ្រាមួយនៃអំពើទុច្ចរិតដ៏ធំ ។[7]



ប៉ុន្តែទោះជារស់នៅក្នុងចំណោមភាពទុក្ខព្រួយក្តី ក៏ព្រះអម្ចាស់បានអនុញ្ញាតឲ្យខ្ញុំមើលឃើញជាមុនថា សាសន៍អ៊ីស្រាអែលនឹងត្រូវបានប្រមូលមកវិញនៅថ្ងៃចុងក្រោយ ថាព្រះអម្ចាស់នឹងសរសេរក្រិត្យវិន័យទ្រង់ « នៅក្នុងចិត្តពួកគេ » ហើយថាទ្រង់នឹងនាំយក « ម្នាក់ពីក្រុងមួយ ហើយពីរនាក់ពីពូជអំបូរមួយ » ទៅកាន់ក្រុងស៊ីយ៉ូន ។[8]

កាលខ្ញុំបានបន្តផ្សាយព្រះបន្ទូលរបស់ព្រះអម្ចាស់—ទោះជាលំបាកយ៉ាងណាក្តី—ខ្ញុំបានរៀនថា ការតាំងចិត្តមួយចំពោះដំណឹងល្អដឹកនាំទៅរកសេចក្តីសុខសាន្ត ។ កាលយើងអភិវឌ្ឍការថ្វាយបង្គំដាច់ដោយឡែកជាមួយព្រះអម្ចាស់ នោះយើងទាំងអស់គ្នាអាចមានសេចក្តីសង្ឃឹមនៅក្នុងការសាកល្បង និងទុក្ខព្រួយ ។ ■

**កំណត់ចំណាំ**

1. លីនដា ខេ បើតុន « តើសេចក្តីជំនឿទៅលើដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ បានចារក្នុងដួងចិត្តយើងឬទេ ? » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 111 ។
2. សូមមើល យេរេមា 1:1–9 ។
3. សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « យេរេមា » scriptures.lds.org ។
4. សូមមើល យេរេមា 6, នីហ្វៃទី 1 1:13, 18–20 ។
5. យេរេមា 36:2 ។
6. សូមមើល យេរេមា 36:23–32 ។
7. សូមមើល យេរេមា 20:2,26:8,38:6 ។
8. យេរេមា 33:31; 3:14 ។

រូបថតផ្ទៃក្រោយដោយ DIMDIMICH/ISTOCK/THINKSTOCK, *យេរេមា* ដោយ វលធើ រ៉ាន © IRI

# ថ្លើមថ្មចម្លាក់រូបស្ពៃ

ដោយ អេលឡិន ស៊ី ផែនសិន

កាលខ្ញុំបម្រើបេសកកម្មនៅប្រទេសតៃវ៉ាន់ ដៃគូខ្ញុំ និង ខ្ញុំបានចំណាយពេលបន្តិចបន្តួចនៅថ្ងៃការរៀបចំខ្លួនមួយ នៅឯសារមន្ទីរវិមានជាតិក្នុងទីក្រុងតៃប៉ិ ។ ការទាក់ទាញដ៏សំខាន់គឺជាបំណែកសិល្បៈមួយហៅថា ថ្លើមថ្មចម្លាក់រូបស្ពៃ ។ មានមនុស្សជាច្រើនបានស្ញប់ស្ញែងពីវត្ថុនោះ ប៉ុន្តែខ្ញុំមើលឃើញវាគ្រាន់តែជាថ្លើមថ្មមួយដែលគេបានឆ្លាក់ចេញជារូបស្ពៃប៉ុណ្ណោះ ។ វាពិតជាស្អាតណាស់ ប៉ុន្តែពិតណាស់ ប្រហែលជាអ្វីមួយដែលខ្ញុំគិតមិនឃើញហើយមើលទៅ ។

កាលយើងបានបញ្ចប់ការទស្សនានៅសារមន្ទីរនោះ ខ្ញុំបានសួរដៃគូខ្ញុំថា « តើឯងគិតថា ថ្លើមថ្មចម្លាក់រូបស្ពៃនោះយ៉ាងម៉េចដែរ ? »

« ខ្ញុំស្រឡាញ់វាខ្លាំងណាស់ ! »

« ហេតុអ្វី ? ខ្ញុំបានសួរ ។ « វាគ្រាន់តែជាថ្លើមថ្មចម្លាក់រូបស្ពៃមួយប៉ុណ្ណោះ » ។

« តើឯងនិយាយលេងទេឬ ? ថ្លើមថ្មចម្លាក់រូបស្ពៃនោះគឺជានិមិត្តរូបមួយសម្រាប់ជីវិតខ្ញុំ ! » នាងបន្លឺសំឡេងឡើង ។

« ថ្លើមថ្មចម្លាក់រូបស្ពៃនោះមែនទេ ? »

« មែនហើយ ! តើឯងមិនដឹងពីដំណើររឿងរបស់វាទេឬអី ? »

« ពិតជាមិនបានដឹងមែន ។ »

នាងបានប្រាប់ខ្ញុំពីដំណើររឿងនោះ ។ ហើយនាងនិយាយត្រូវណាស់ ។ វាបានក្លាយជានិមិត្តរូបសម្រាប់បេសកកម្ម និង ជីវិតរបស់ខ្ញុំ ។

ដើម្បីឲ្យចម្លាក់មួយមានតម្លៃបំផុត ថ្លើមថ្មនោះត្រូវតែមានពណ៌តែមួយ ។ ការឆ្លាក់ថ្លើមថ្មដ៏ល្អឥតខ្ចោះនោះ មានតម្លៃខ្ពស់ណាស់ ដោយសារវាជាថ្លើមថ្មដ៏ល្អឥតខ្ចោះដែលកម្ររកមាន ។ ថ្លើមថ្មចម្លាក់រូបស្ពៃនោះមានចុងពណ៌បៃតង ហើយមានគល់ពណ៌-ស ហើយវាមានស្នាមប្រេះ និងផ្នត់ជាច្រើន ។ គ្មានជាងឆ្លាក់យ៉ាងជំនាញណាម្នាក់ចង់ចំណាយពេលឆ្លាក់ថ្លើមថ្មនេះឡើយ រហូតដល់មានមនុស្សម្នាក់បានមកដែលជនជាតិចិនហៅថា ជាងឆ្លាក់ដ៏ឆ្នើមម្នាក់ ។

ប្រសិនបើថ្លើមថ្មនេះអាចនិយាយបាន ខ្ញុំអាចស្រមៃឃើញពីការសន្ទនាដែលវាមានជាមួយនឹងជាងឆ្លាក់ថ្មីនេះ ។ ខ្ញុំស្រមៃឃើញជាងឆ្លាក់នោះលើកដុំថ្លើមថ្មនេះឡើង ។

« តើលោកចង់បានអ្វី ? » ថ្លើមថ្មនោះបានសួរ ។

ជាងឆ្លាក់នោះតបថា « ខ្ញុំកំពុងសម្លឹងមើលថ្លើមថ្មដើម្បីឆ្លាក់ » ។

« អញ្ចឹងសូមរកដុំផ្សេងទៀតចុះ ។ ខ្ញុំគ្មានតម្លៃទេ ។ ខ្ញុំមានពណ៌ពីរប្រភេទផ្សេងគ្នា ដែលលោកមិនអាចញែកវាចេញពីគ្នាបានឡើយ ។ ខ្ញុំមានស្នាមប្រេះ និងផ្នត់ជាច្រើន ។ ខ្ញុំនឹងគ្មានតម្លៃអ្វីនោះទេ ។ កុំចំណាយពេលលោកឥតប្រយោជន៍អី » ។

« អូ៎ ថ្លើមថ្មដ៏តូចអើយ ។ សូមទុកចិត្តយើងចុះ ។ យើងជាជាងឆ្លាក់ដ៏ឆ្នើម ។ យើងនឹងធ្វើឲ្យឯងមានភាពល្អឯក » ។

អ្វីដែលធ្វើឲ្យថ្លើមថ្មចម្លាក់រូបស្ពៃនោះមានភាពអស្ចារ្យគឺថា ជាងឆ្លាក់ដ៏ឆ្នើមដែលមិនស្គាល់ឈ្មោះនេះ បានប្រើចំណុចខ្សោយរបស់ថ្លើមថ្មនោះ—មានពីរពណ៌ ស្នាមប្រេះ និង ផ្នត់—ដើម្បីធ្វើជារូបស្ពៃដូចជារបស់ពិត ។ ផ្នែកពណ៌-សស្រអាប់នោះបានក្លាយទៅជាគល់ស្ពៃ ហើយស្នាមប្រេះ និងផ្នត់បានធ្វើឲ្យស្លឹកទាំងឡាយមានជីវិតរស់រវើក ។ ប្រសិនបើមិនដោយសារ « ភាពទន់ខ្សោយ » របស់ថ្លើមថ្មនោះទេ វាមិនអាចដូចជារបស់ពិតបានឡើយ ។

ដោយសារតែភាពស្រស់ស្អាតនៃវត្ថុនេះ វាបានក្លាយជាដង្វាយមួយថ្វាយដល់ព្រះមហាក្សត្រមួយ



**ព្រះអម្ចាស់មើលទៅក្នុងចិត្ត ។**

នៅក្នុងពិភពលោករបស់យើង អាកប្បកិរិយាខាងសីលធម៌ ជាញឹកញាប់ ហាក់ដូចជាអាទិភាពកម្រិតទីពីរ បន្ទាប់ពីសម្រស់ ឬ សេចក្ដីស្នេហា ។ ប៉ុន្តែជាយូរលង់ណាស់មកហើយ ព្រះអម្ចាស់ទ្រង់បានមានបន្ទូលទូន្មានដល់ព្យាការីសាំយ៉ូអែលថា៖ « ព្រះទ្រង់មិនទតចំពោះសេចក្ដីដែលមនុស្សលោកពិចារណាមើលទេ ឯមនុស្សលោកតែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ » សាំយ៉ូអែលទី 1 16:7) ។

ប្រធាន ថូម៉ាស អេស ម៉នសុន « Canaries with Gray on Their Wings » *Liahona* ខែ មិថុនា ឆ្នាំ 2010 ទំព័រ 4 ។



អង្គរបស់ប្រទេសចិន ហើយបានដាក់តាំងលំអរតាមច្រកដើរនៃវិមានដ៏ស្រស់ស្អាតជាច្រើននៅអាស៊ីរហូតដល់ចុងក្រោយត្រូវបានគេមកតាំងនៅក្នុងសារមន្ទីរប្រទេសតៃវ៉ាន់ ។

វាបានរំឭកខ្ញុំពីអេធើរ 12:27 ៖ « បើសិនជាមនុស្សលោកមករកយើង នោះយើងនឹងបង្ហាញដល់ពួកគេនូវភាពទន់ខ្សោយរបស់ពួកគេ ។ . . . គុណរបស់យើងមានគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ដែលបន្ទាបខ្លួននៅចំពោះយើង ត្បិតបើសិនជាពួកគេបន្ទាបខ្លួននៅចំពោះយើង ហើយមានសេចក្ដីជំនឿជឿដល់យើង លំដាប់នោះយើងនឹងធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះពួកគេវិញ » ។

បន្ទាប់ពីខ្ញុំបានឃើញថ្លើមថ្មចម្លាក់រូបស្ពៃនោះមក បទគម្ពីរនេះបានចាប់ផ្ដើមមានអត្ថន័យថ្មី ។ យើងប្រៀបដូចជាដុំថ្លើមថ្មនេះដែរ ប៉ុន្តែខុសគ្នាត្រង់យើងកំពុងស្ថិតនៅក្នុងដំណើរការនៃការឆ្លាក់ ។ យើងត្រូវទុកចិត្តលើជាងឆ្លាក់ដ៏ឆ្នើមម្នាក់ គឺព្រះយេស៊ូវគ្រីស្ទ ដែលនឹងធ្វើឲ្យភាពទន់ខ្សោយរបស់យើងបានខ្លាំងពូកែ ។ ក្នុងទស្សនៈមិនល្អឥតខ្ចោះរបស់យើង ពេលខ្លះ យើងផ្ដោតទៅលើភាពមិនល្អឥតខ្ចោះរបស់យើង រួចហើយកើតក្ដីអស់សង្ឃឹម ដោយសារយើងគិតថា យើងនឹងគ្មានថ្ងៃបានសក្ដិសមឡើយ ។ ប៉ុន្តែព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ ទតឃើញពីសក្ដានុពលរបស់យើង ។ កាលយើងអនុញ្ញាតឲ្យដង្វាយធួនទ្រង់មាន ចលនានៅក្នុងជីវិតរបស់យើង នោះទ្រង់នឹងធ្វើឲ្យយើងបានល្អឯក ជាអ្នកដែលនឹងរស់នៅជាមួយនឹងស្ដេចនៃអស់ទាំងស្ដេចនៅថ្ងៃណាមួយ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

**តើខ្ញុំអាចមើលឃើញខ្លួនឯងដូចជាព្រះអម្ចាស់ទតឃើញខ្ញុំតាមរបៀបណា ?**

វាជាការលំបាកមួយដោយមើលខ្លួនឯងដូចជាព្រះអម្ចាស់ទតឃើញយើង ។ ទ្រង់ទតឃើញយើងដូច ជាកូនចៅនៃព្រះដែលមានសក្ដាពុល និង តម្លៃដ៏អស្ចារ្យ ។ ប៉ុន្តែពេលខ្លះយើងសម្លឹងឃើញតែកំហុសរបស់ខ្លួនយើងប៉ុណ្ណោះ ។ ព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌មិនបានបង្កើតយើងមកឲ្យរស់នៅក្នុងកំហុសរបស់យើងឡើយ ប៉ុន្តែក្លាយទៅជាស្នាដៃឯកដ៏ស្រស់ស្អាតវិញ ។ តាមរយៈដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនទ្រង់ យើងអាចយកឈ្នះលើកំហុសរបស់យើងបាន ។

សូមពិចារណាដើម្បីអាននូវបទគម្ពីរដូចតទៅនេះ ដើម្បីរៀនពីរបៀបដែលព្រះអម្ចាស់ប្រើមនុស្សដែលមិនល្អឥតខ្ចោះ ដើម្បីសម្រេចកិច្ចការរបស់ទ្រង់ ៖ និក្ខមនំ 4:10–12, យេរេមា 1:4–10, នីហ្វៃទី 1 4:1–6, អាលម៉ា 26:12, គោលលទ្ធិ និង សេចក្ដីសញ្ញា 35:17–18 ។

# បេះដូងរបស់លីហ្សូកា

ដោយ ម៉ារីណា ប៉េត្រូវ៉ា

ស្វាមីខ្ញុំ និង ខ្ញុំបានចូលរួមក្នុងសាសនាចក្រនៅប្រទេសរុស្ស៊ីនៅឆ្នាំ 1995 ហើយត្រូវបានផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ ស្តុកខូម ស៊ុយអែត មួយឆ្នាំក្រោយមក ។ កូនស្រីតូចយើងទាំងពីរនាក់ត្រូវបានផ្សារភ្ជាប់នឹងយើងផងដែរ ។ ពីរឆ្នាំក្រោយមក យើងមានពរដោយមានកូនស្រីម្នាក់ទៀតឈ្មោះលីហ្សូកា ។ ជីវិតរបស់យើងមានភាពល្អប្រសើរ ។ យើងទាំងអស់គ្នារីករាយ ។ ប៉ុន្តែក្រោយពីនាងកើតបានពីរថ្ងៃ កូនតូចរបស់យើងបានចាប់ផ្តើមមិនសូវញ៉ាំអ្វីសោះ ។ ក្នុងមួយខែនាងឡើងទម្ងន់បានតែ 300 ក្រ. ប៉ុណ្ណោះ ។

បុគ្គលិកនៅឯមជ្ឈមណ្ឌលវេជ្ជសាស្ត្រសម្រាប់កុមារបានប្រាប់យើងឲ្យនាងញ៉ាំអាហារឲ្យបានញឹកញាប់ ។ ខ្ញុំបានឃើញថានាងចង់ញ៉ាំ ប៉ុន្តែនាងមិនអាចញ៉ាំបានសោះ ។ នៅទីបំផុត ស្វាមីខ្ញុំបាននាំនាងទៅមន្ទីរពេទ្យក្នុងទីក្រុង ។ រំពេចនោះ វេជ្ជបណ្ឌិតបានផ្តល់ការវិនិច្ឆ័យរោគមួយដល់យើង—គឺពិការភាពនៃបេះដូងពីកំណើត។ សន្ទះបិទបើកបេះដូងមួយមិនដំណើរការ ហើយមានលំហូរឈាមតិចតួចហូរចូលក្នុងសួតរបស់នាង ធ្វើឲ្យនាងពិបាកដកដង្ហើម ឬបរិភោគ ។

នាងត្រូវធ្វើការវះកាត់ ប៉ុន្តែនៅប្រទេសរុស្ស៊ីកុមារដែលអាចទទួលការវះកាត់បែបនេះ យ៉ាងហោចណាស់ត្រូវមានអាយុពីរឆ្នាំ ។ កូនស្រីយើងទើបមានអាយុបានមួយខែប៉ុណ្ណោះ ។ វេជ្ជបណ្ឌិតបានចេញវេជ្ជបញ្ជាឲ្យនាង ហើយពោលថា នៅពេលនាងធំឡើង ពួកគេនឹងធ្វើការវះកាត់ឲ្យនាង ។

មួយខែក្រោយមក សុខភាពរបស់លីហ្សូកាកាន់តែធ្ងន់ធ្ងរឡើងៗ ហើយយើងបានប្រញាប់ប្រញាល់យកនាងទៅមន្ទីរពេទ្យ ។ ខ្ញុំបានបីនាង ពេលយើងកំពុងបើកឡាន ។ នាងបានមើលមុខខ្ញុំហាក់ដូចជាកំពុងអង្វរសូមឲ្យជួយ ។ ប្រសិនបើខ្ញុំពុំមែនជាសមាជិកសាសនាចក្រ ខ្ញុំមិនដឹងថា ខ្ញុំត្រូវធ្វើអ្វីនោះទេ ។ ប៉ុន្តែស្វាមីខ្ញុំ និង ខ្ញុំទុកចិត្តលើព្រះអម្ចាស់ ហើយជឿជាក់យ៉ាងមុតមាំថា អ្វីៗនឹងបានប្រសើរឡើង ។ ខ្ញុំបានព្យាយាមលួងនាង ដោយពោលថា « កុំខ្លាចអី កូនស្រីមាសម្តាយ ។ ព្រះស្រឡាញ់យើង ។ ទ្រង់នឹងជួយយើង ហើយអ្វីៗនឹងបានប្រសើរឡើង » ។

ទីបំផុតយើងបានទៅដល់មន្ទីរពេទ្យ ។ ដោយបីនាងនៅក្នុងដៃ ខ្ញុំបានរត់កាផ្នែកទទួលអ្នកជំងឺ ។ ផ្ទៃករបស់លីហ្សូកាបានចាប់ផ្តើមបិទ ។ នាងដកដង្ហើមខ្លីៗ ។ ខ្ញុំស្ទើរតែនិយាយប្រាប់គ្រូពេទ្យមិនរួចពីកូនរបស់ខ្ញុំ ហើយបុគ្គលិកវេជ្ជសាស្ត្របានយកនាងទៅបន្ទប់សង្គ្រោះបន្ទាន់ ។ វេជ្ជបណ្ឌិតបានប្រាប់ថា សួតនាងកំពុងចាប់ផ្តើមហើម ហើយពួកគេបានដាក់ខ្យល់អុកស៊ីសែនឲ្យនាង ។

លុះស្អែកឡើង យើងបាននិយាយនឹងនាយកផ្នែកវះកាត់បេះដូង ។ គាត់បានពោលថា « ខ្ញុំធ្លាប់ធ្វើការវះកាត់បែបនេះ ប៉ុន្តែសម្រាប់តែក្មេងធំៗប៉ុណ្ណោះ ។ តើនាងមានអាយុប៉ុន្មានហើយឥឡូវនេះ ? »

យើងបានប្រាប់គាត់ថា « ពីរខែ » ។

« នាងឈឺច្រើនពេកហើយ ។ នាងតូចណាស់ ហើយសួតនាងដែលហើមនោះវាជារឿងស្មុគស្មាញណាស់ ប៉ុន្តែយើងមិនអូសបន្លាយពេលទៀតបានទេ ។ ខ្ញុំពុំធ្លាប់ធ្វើការវះកាត់បែបនេះដល់កុមារតូចពីមុនមកឡើយ ។ ខ្ញុំនឹងព្យាយាមធ្វើឲ្យអស់ពីលទ្ធភាព ។ អ្នកត្រូវទិញសន្ទះបិទបើកបេះដូងសិប្បនិម្មិតមួយ ប៉ុន្តែវាមានតម្លៃថ្លៃណាស់—ប្រហែល 2,100 ដុល្លារ ។ ការវះកាត់នឹងធ្វើឡើងនៅបួនថ្ងៃទៀត » ។

តើយើងត្រូវធ្វើអ្វីទៅ ? ទាំងយើង ឬអ្នកដែលយើងស្គាល់គ្មានប្រាក់ច្រើនបែបនេះឡើយ ។ ទោះជាយ៉ាងណា ស្ថានភាពរបស់យើងបានធ្វើឲ្យអ្នកដទៃមានចំណាប់អារម្មណ៍ ហើយតាមរយៈសេចក្តីសប្បុរសរបស់ពួកគេ និង សេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ យើងមានប្រាក់គ្រប់គ្រាន់ ។ ស្វាមីខ្ញុំបានទិញសន្ទះបិទបើកបេះដូងសិប្បនិម្មិតមួយដែលយើងត្រូវការដើម្បីជួយសង្គ្រោះដល់អាយុជីវិតកូនស្រីយើង ។

មិនត្រឹមតែមានបងប្អូនប្រុសស្រីនៅក្នុងសាខាយើងដែលបានអធិស្ឋាន ហើយតមអាហារសម្រាប់កូនស្រីតូចយើងប៉ុណ្ណោះទេ ពួកអ្នកផ្សព្វផ្សាយសាសនា និង ពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើននៅក្នុងទីក្រុងក៏បានធ្វើបែបនេះផងដែរ ។ យើងទទួលអារម្មណ៍ពីការគាំទ្ររបស់ពួកគេ ។ ដោយអង្គុយនៅច្រកដើរនៅថ្ងៃធ្វើការវះកាត់នោះ យើងមានអារម្មណ៍នូវវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធ និង ការអធិស្ឋានរបស់បងប្អូនប្រុសស្រីយើង ។ យើងបានដឹងថា ពួកគេនៅក្បែរយើង ! ហើយព្រះគង់នៅជាមួយយើង ដោយធ្វើការដឹកនាំដល់ពួកគ្រូពេទ្យវះកាត់ទាំងនោះ ។ ទ្រង់មិនបោះបង់យើងឡើយ ហើយអ្វីៗគ្រប់យ៉ាងនឹងបានប្រសើរឡើង ។

នៅពេលគ្រូពេទ្យវះកាត់បានចេញមកបន្ទាប់ពីការវះកាត់បានបញ្ចប់ គាត់បានប្រាប់យើងទំនងដូចជាមានការងឿងឆ្ងល់ថា « អ្វីៗគ្រប់យ៉ាងមិនអីទេ ។ យើងបានដាក់សន្ទះបិទបើកបេះដូងនោះចូលហើយ ។ ខ្ញុំមិនដឹងថាតាមរបៀបណានោះទេ ប៉ុន្តែវាទទួលបានជោគជ័យ » ។ ប៉ុន្តែយើងបានដឹងពីរបៀបដែលកិច្ចការនោះបានទទួលជោគជ័យ ។ ព្រះវរបិតាសួគ៌បានប្រទានពរដល់គាត់ ។

លីហ្សូកាសម្រាកនៅមន្ទីរពេទ្យបីថ្ងៃទៀត ដើម្បី



ឲ្យបេះដូង និង សួតរបស់នាងដែលហើមនោះបានស្រកមកវិញ ។ មុខរបួសនាងត្រូវទុកចំហចោលដោយបិទភ្ជាប់នឹងភ្នាសស្តើងមួយ ហើយពីរបីថ្ងៃក្រោយមកទៀត ពួកគេបានធ្វើការវះកាត់ម្តងទៀតដើម្បីដេរផ្ចិតមុខរបួសនៅលើទ្រូងរបស់នាង ។ ស្ទើរតែគ្មានគ្រូពេទ្យណាម្នាក់រំពឹងថានាងនឹងរស់ណាស់ ។ ប៉ុន្តែយើងជឿលើព្រះវរបិតាសួគ៌ និង ព្រះចេស្តាទ្រង់ ហើយយើងជឿថា ប្រសិនបើវាជាព្រះឆន្ទៈទ្រង់ នាងនឹងជាសះស្បើយវិញ ។

មានតែព្រះប៉ុណ្ណោះដែលអាចប្រទានលីហ្សកាមកឲ្យយើងវិញបាន ។ នាងបានប្រសើរឡើងវិញជារៀងរាល់ថ្ងៃ ។ នាងបានសម្រាកនៅមន្ទីរពេទ្យមួយខែទៀត ហើយឥឡូវនេះនាងបាននៅផ្ទះជាមួយនឹងយើង ។

ព្រះគឺជាព្រះនៃអព្ភូតហេតុ ។ ទ្រង់ស្តាប់ឮការអធិស្ឋានរបស់យើង ហើយនៅគ្រាដ៏លំបាករបស់យើង ទ្រង់បានជួយទ្រទ្រង់យើងឡើង ។ ការសាកល្បងបានពង្រឹងសេចក្តីជំនឿយើង ហើយបង្រៀនយើងឲ្យជឿ សង្ឃឹម ហើយស្រឡាញ់ ។ ■

*សព្វថ្ងៃអ្នកនិពន្ធរស់នៅប្រទេសបែលហ្ស៊ិក ។*



**នៅពេលការអធិស្ឋានហាក់ដូចជាមិនបានទទួលចម្លើយ**

« វាលំបាកណាស់ នៅពេលការអធិស្ឋានដ៏ស្មោះសម្រាប់អ្វីមួយដែលចង់បានជាងខ្លាំងនោះមិនបានទទួលចម្លើយដូចដែលអ្នកចង់បាន ។ វាពិបាកយល់ខ្លាំងណាស់ថា ហេតុអ្វីបានជាការអនុវត្តសេចក្តីជំនឿដ៏ជ្រាលជ្រៅ ហើយស្មោះរបស់អ្នកដោយរស់នៅក្នុងជីវិតមួយដែលមានការគោរពប្រតិបត្តិ បែរជាមិនបានទទួលលទ្ធផលដែលចង់បានទៅវិញ ។ ព្រះអង្គសង្គ្រោះបានបង្រៀនថា ‹ អ្វីក៏ដោយដែលអ្នករាល់គ្នាសូមព្រះវរបិតាដោយនូវព្រះនាមរបស់យើង នោះនឹងបានប្រទានដល់អ្នក*ដែលជាការចាំបាច់សម្រាប់អ្នក ។*› [ គ. និង ស. 88:64, ការគូសបញ្ជាក់បានបន្ថែម ។ ] ពេលខ្លះវាពិបាកស្គាល់នូវអ្វីដែល*ល្អបំផុតឬ ចាំបាច់*សម្រាប់អ្នកណាស់ ។ ជីវិតរបស់អ្នកកាន់តែមានភាពងាយស្រួលនៅពេលអ្នកទទួលយកថា អ្វីដែលព្រះធ្វើឲ្យកើតឡើងនៅក្នុងជីវិតអ្នក គឺសម្រាប់ផលប្រយោជន៍ល្អ *ដ៏អស់កល្ប* របស់អ្នក » ។

**អែលឌើរ រីឆាត ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Using the Supernal Gift of Prayer » Liahona ខែ ឧសភា ឆ្នាំ 2007 ទំព័រ 9 ។**

រូបភាពដោយ អានី ហែនរី



**ដោយ អែលឌើរ**
**ដាវីឌ អេ បែដណា**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# កិច្ចការ



នៅក្នុងការប្រមូលផ្ដុំដ៏ឱឡារិកមួយដែលធ្វើឡើងនៅព្រះវិហារបរិសុទ្ធ ខឺតឡង់ នៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 1837 ព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងថា « បន្ទាប់ពីអ្វីៗទាំងអស់ត្រូវបាននិយាយរួចហើយ កាតព្វកិច្ចដ៏ធំជាងគេហើយសំខាន់បំផុតគឺការផ្សាយដំណឹងល្អ » ។[1]

ស្ទើរតែប្រាំពីរឆ្នាំក្រោយមក នៅថ្ងៃទី 7 ខែ មេសា ឆ្នាំ 1844 លោកបានប្រកាសថា ៖ « ទំនួលខុសត្រូវដ៏ធំជាងគេបំផុតនៅក្នុងពិភពលោកនេះ ដែលព្រះប្រទានឲ្យយើងគឺការស្វែងរកដូនតាយើងដែលបានចែកឋានទៅ ។ ព្យាការីបានថ្លែងថា ‹ ពួកគាត់មិនអាចធ្វើឲ្យល្អឥតខ្ចោះដោយគ្មានយើងបានឡើយ › [ សូមមើល ហេព្រើរ 11:40 ] ត្បិតវាចាំបាច់ដែលអំណាចនៃការផ្សារភ្ជាប់គួរមាននៅក្នុងដៃយើង ដើម្បីផ្សារភ្ជាប់កូនចៅ និងដូនតាយើងសម្រាប់ភាពដ៏ពេញលេញនៃការកាន់កាប់គ្រួតត្រា—ការកាន់កាប់គ្រួតត្រាមួយដើម្បីបំពេញសេចក្ដីសន្យាដែលព្រះយេស៊ូវគ្រីស្ទបានធ្វើ ពីមុនគ្រឹះនៃពិភពលោកនេះ សម្រាប់សេចក្ដីសង្គ្រោះរបស់មនុស្ស » ។[2]

មានមនុស្សមួយចំនួនប្រហែលជាងឿងឆ្ងល់ថា តើការបង្រៀនដំណឹងល្អនិងការស្វែងរកដូនតាយើងដែលបានចែកឋានទៅអាចជាកាតព្វកិច្ច និងទំនួលខុសត្រូវដ៏ធំជាងគេបំផុត ក្នុងពេលតែមួយដែលព្រះបានដាក់ឲ្យ

# ផ្សព្វផ្សាយសាសនា ពង្សប្រវត្តិ និង ព្រះវិហារបរិសុទ្ធ



*ការប្រកាសដំណឹងល្អ និង ការខិតខំស្វែងរកដូនតាយើងដែលបានចែកឋានទៅគឺជាផ្នែកបន្ថែមនៃកិច្ចការដ៏អស្ចារ្យមួយ—ជាកិច្ចការនៃសេចក្តីស្រឡាញ់ដែលមានគោលបំណងដើម្បីផ្លាស់ប្តូរ បង្វែរ ហើយបន្សុទ្ធដួងចិត្តនៃជនដែលស្វែងរកសេចក្តីពិតដ៏ស្មោះត្រង់ ។*

កូនចៅទ្រទ្រង់តាមរបៀបណា ។ គោលបំណងរបស់ខ្ញុំគឺដើម្បីណែនាំថា ការបង្រៀនទាំងនេះគូសបញ្ជាក់ពីសាមគ្គីភាព និង ភាពតែមួយនៃកិច្ចការនៃសេចក្តីសង្គ្រោះនៅថ្ងៃចុងក្រោយ ។ កិច្ចការផ្សព្វផ្សាយសាសនា និង កិច្ចការព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិគឺជាដៃគូនឹងគ្នា ហើយជាកត្តាដែលពាក់ព័ន្ធគ្នានៃកិច្ចការដ៏អស្ចារ្យមួយ « សម្រាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញកំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ ទាំងរបស់នៅស្ថានសួគ៌ និងរបស់នៅផែនដីផង » ( អេភេសូរ 1:10 ) ។

ខ្ញុំសូមអធិស្ឋានឲ្យព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនឹងជួយអ្នក និង ខ្ញុំ កាលយើងគិតពិចារណារួមគ្នាពីកិច្ចការនៃសេចក្តីសង្គ្រោះនៅថ្ងៃចុងក្រោយដ៏អស្ចារ្យនេះ ។

### ដួងចិត្ត និង ពិធីបរិសុទ្ធនៃបព្វជិតភាព

ការផ្សាយដំណឹងល្អ និង ការស្វែងរកដូនតាយើងដែលបានចែកឋានទៅគឺជាទំនួលខុសត្រូវពីរដ៏ទេវភាពដែលបានចាត់មក ដែលវាទាក់ទងទាំងដួងចិត្ត និង ពិធីបរិសុទ្ធនៃបព្វជិតភាព ។ គោលការណ៍នៃកិច្ចការរបស់ព្រះអម្ចាស់កំពុងផ្លាស់ប្តូរ បង្វែរ ហើយបន្សុទ្ធដួងចិត្តទាំងឡាយតាមរយៈសេចក្តីសញ្ញា និង ពិធីបរិសុទ្ធដែលបានធ្វើឡើងដោយសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ ។

ពាក្យថា *ដួងចិត្ត*ត្រូវបានប្រើជាង 1,000 ដងនៅក្នុងបទដ្ឋានព្រះគម្ពីរ ហើយជាតំណាងឲ្យអារម្មណ៍នៅក្នុងចិត្តរបស់មនុស្ស ម្នាក់ ។ ដូច្នេះ ដួងចិត្តយើង—ដែលជាចំណុចប្រមូលផ្តុំនៃបំណងប្រាថ្នា សេចក្តីស្រឡាញ់ គោលដៅ ការលើកទឹកចិត្ត និង ឥរិយាបថរបស់យើង—កំណត់ថាយើងជានរណា និងសក្តានុពលនាពេលអនាគតរបស់យើង ។

ព្រះរាជបំណងរបស់ព្រះអម្ចាស់ចំពោះកិច្ចការផ្សព្វផ្សាយសាសនា គឺដើម្បីអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ ទទួលពរជ័យនៃដំណឹងល្អដែលបានស្តារឡើងវិញ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុតដោយមានជំនឿលើព្រះគ្រីស្ទ ។[3] យើងពុំមែនចែកចាយដំណឹងល្អដោយគ្រាន់តែដើម្បីបង្កើន



*ការធ្វើដ៏សាមញ្ញ និង ការគូសបញ្ចាក់រាល់កិច្ចការនៅលើបញ្ជី « កិច្ចការដែលត្រូវធ្វើ » ដ៏វែងទាក់ទងនឹងដំណឹងល្អដោយស្មោះត្រង់របស់យើងមិនអាចជួយយើងឲ្យទទួលបានរូបភាពរបស់ទ្រង់នៅលើផ្ទៃមុខរបស់យើង ឬនាំមកនូវការផ្លាស់ប្ដូរដួងចិត្តដ៏ធំនោះឡើយ ។*

ចំនួន និង កម្លាំងនៃសាសនាចក្រនៅថ្ងៃចុងក្រោយនេះប៉ុណ្ណោះទេ ។ ផ្ទុយទៅវិញ យើងខិតខំបំពេញទំនួលខុសត្រូវដ៏ទេវភាពដែលបានចាត់មក ដើម្បីប្រកាសពីភាពពិតនៃផែនការសុភមង្គលរបស់ព្រះវរបិតា ទេវភាពនៃព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ និង តម្លៃនៃពលិកម្មធួនរបស់ព្រះអង្គសង្គ្រោះ ។ ការអញ្ជើញមនុស្សទាំងអស់ឲ្យ « មករកព្រះគ្រីស្ទ » ( សូមមើល ម៉ូរ៉ូណៃ 10:30–33 ) ការមាន « ការផ្លាស់ប្ដូរដួងចិត្តដ៏ធំ » ( សូមមើល អាលម៉ា 5:12–14 ) និង ការផ្ដល់ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះដល់បណ្ដាមនុស្ស នៅក្នុងជីវិតរមែងស្លាប់មិនទាន់ស្ថិតនៅក្រោមសេចក្ដីសញ្ញា គឺជាគោលដៅដ៏សំខាន់នៃការផ្សាយដំណឹងល្អ ។

ការអនុញ្ញាតឲ្យមានភាពតម្កើងឡើងដល់អ្នកនៅរស់ និង អ្នកស្លាប់គឺជាព្រះរាជបំណងរបស់ព្រះអម្ចាស់ សម្រាប់ការសាងសង់ព្រះវិហារបរិសុទ្ធ និង ការធ្វើពិធីបរិសុទ្ធជំនួស ។ យើងមិនថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ ដើម្បីគ្រាន់តែមានបទពិសោធន៍ជាបុគ្គល ឬគ្រួសារដែលគួរឲ្យចងចាំតែប៉ុណ្ណោះនោះទេ ។ ផ្ទុយទៅវិញ យើងខិតខំដើម្បីបំពេញទំនួលខុសត្រូវដ៏ទេវភាពដែលបានចាត់មក ដើម្បីផ្ដល់ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ និង ភាពតម្កើងឡើងដល់គ្រួសារមនុស្សលោកទាំងអស់ ។ ការបណ្ដុះសេចក្ដីសន្យាដែលបានធ្វើដល់ពួកឪពុកដូចជា អ័ប្រាហាំ អ៊ីសាក និង យ៉ាកុបនៅក្នុងដួងចិត្តរបស់កូនចៅ ការបង្វែរដួងចិត្តកូនចៅទៅពួកឪពុករបស់ពួកគេផ្ទាល់ និង ការធ្វើការស្រាវជ្រាវពង្សប្រវត្តិ និង ពិធីបរិសុទ្ធជំនួសនៅក្នុងព្រះវិហារបរិសុទ្ធគឺជាការងារដែលប្រទានពរដល់បណ្ដាជននៅភពវិញ្ញាណដែលមិនទាន់ស្ថិតនៅក្រោមសេចក្ដីសញ្ញា ។

ពិធីបរិសុទ្ធនៃបព្វជិតភាពគឺជាផ្លូវទៅកាន់អំណាចនៃការគោរពព្រះ ៖

« ហើយបព្វជិតភាពដែលធំជាងគេចាត់ចែងដំណឹងល្អ ហើយកាន់កូនសោនៃសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរ គឺជាកូនសោនៃចំណេះវិជ្ជាពីព្រះ ។

« ហេតុដូច្នេះហើយ នៅក្នុងពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាពដ៏ធំជាងនេះ នោះអំណាចនៃព្រះត្រូវបានសម្ដែងឲ្យឃើញ ។

« បើសិនជាគ្មានពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាពដ៏ធំជាងនេះ និង សិទ្ធិអំណាចនៃបព្វជិតភាពទេ នោះអំណាចនៃព្រះពុំអាចបានសម្ដែងដល់មនុស្សនៅក្នុងសាច់ឈាមបានឡើយ » ( គ. និង ស. 84:19–21 ) ។

សូមពិចារណាពីសារៈសំខាន់នៃបទគម្ពីរទាំងនេះ ។ ដំបូងបុគ្គលម្នាក់*ត្រូវតែ*ឆ្លងកាត់ទ្វារនៃបុណ្យជ្រមុជទឹក ហើយទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ—រួចហើយបន្តដើរឆ្ពោះទៅមុខលើផ្លូវនៃសេចក្ដីសញ្ញា និង ពិធីបរិសុទ្ធដែលដឹកនាំទៅរកព្រះអង្គសង្គ្រោះ និង ពរជ័យនៃដង្វាយធួនរបស់ទ្រង់ ( នីហ្វៃទី 2 31 ) ។ ពិធីបរិសុទ្ធនៃបព្វជិតភាពគឺជាកត្តាដ៏ចាំបាច់ដើម្បី « មករកព្រះគ្រីស្ទ ហើយបានល្អឥតខ្ចោះនៅក្នុងទ្រង់ » ឲ្យពេញលេញ ( សូមមើល ម៉ូរ៉ូណៃ 10:30–33 ) ។ បើគ្មានពិធីបរិសុទ្ធទាំងនេះ នោះមនុស្សម្នាក់មិនអាចទទួលពរជ័យទាំងអស់ ដែលកើតមានតាមរយៈពលិកម្មធួនដ៏គ្មានទីបញ្ចប់ ហើយអស់កល្បរបស់ព្រះអម្ចាស់បានឡើយ ( សូមមើល អាលម៉ា 34:10–14 )—សូម្បីទាំងអំណាចនៃការគោរពព្រះផងដែរ ។

កិច្ចការរបស់ព្រះអម្ចាស់គឺជាកិច្ចការដ៏រុងរឿងមួយ ដែលផ្ដោតលើដួងចិត្ត សេចក្ដីសញ្ញា និង ពិធីបរិសុទ្ធនៃបព្វជិតភាព ។

**ឥទ្ធិពល**

គោលលទ្ធិដ៏ទេវភាពនេះបង្ហាញប្រាប់នូវឥទ្ធិពលពីរយ៉ាងសម្រាប់កិច្ចការរបស់យើងនៅក្នុងសាសនាចក្រ ។

ទីមួយ ជារឿយៗយើងប្រហែលជាផ្ដល់ការសង្កត់ធ្ងន់ច្រើនពេកចំពោះប្រភេទដាច់ដោយឡែកនៃកិច្ចការនៃសេចក្ដីសង្គ្រោះ និង គោលនយោបាយ និង និតិវិធីដែលពាក់ព័ន្ធ ។ ខ្ញុំខ្លាចថា មានយើងរាល់គ្នាជាច្រើនផ្ដោតយ៉ាងខ្លាំងតែទៅលើទម្រង់ការជាក់លាក់នៃកិច្ចការរបស់ព្រះអម្ចាស់រហូតយើងភ្លេចប្រមូលនូវអំណាចដ៏ពេញលេញនៃកិច្ចការដ៏ពេញលេញនៃសេចក្ដីសង្គ្រោះ ។

ខណៈដែលព្រះអម្ចាស់ខិតខំប្រមូលអ្វីៗគ្រប់យ៉ាងឲ្យរួមគ្នាតែមួយក្នុងព្រះគ្រីស្ទ ជារឿយៗយើងប្រហែលជាបែងចែក ឬផ្ដោតលើរបៀបដែលកំណត់ការយល់ដឹង និង ទស្សនៈរបស់យើង ។ កាលវាអនុវត្តហួសហេតុពេក អាទិភាពត្រូវបានផ្ដល់ទៅលើការចាត់ចែងកម្មវិធី និង ការបង្កើនស្ថិតិលើការអញ្ជើញមនុស្សឲ្យចូលទៅក្នុងសេចក្ដីសញ្ញា ហើយទទួលពិធីបរិសុទ្ធដោយសក្ដិសម ។ វិធីសាស្ត្របែបនេះជម្រុញឲ្យមាន

នូវការបន្សុទ្ធ សេចក្ដីអំណរ ការប្រែចិត្តជឿជាបន្តបន្ទាប់ ព្រមទាំងអំណាច និង ការការពារខាងវិញ្ញាណដែលកើតចេញពីការ « ប្រគល់ចិត្ត [ យើង ]ដល់ព្រះ » ( ហេលេមិន 3:35 ) ។ ការធ្វើដ៏សាមញ្ញ និង ការគូសបញ្ជប់រាល់កិច្ចការនៅលើបញ្ជី « កិច្ចការដែលត្រូវធ្វើ » ដ៏វែងទាក់ទងនឹងដំណឹងល្អដោយស្មោះត្រង់របស់យើងមិនអាចជួយយើងឲ្យទទួលបានរូបភាពរបស់ទ្រង់នៅលើផ្ទៃមុខរបស់យើង ឬនាំមកនូវការផ្លាស់ប្ដូរដួងចិត្តដ៏ធំនោះឡើយ ( សូមមើល អាលម៉ា 5:14 ) ។

ទីពីរ វិញ្ញាណរបស់អេលីយ៉ាគឺជាផ្នែកដ៏សំខាន់ចំពោះកិច្ចការនៃការប្រកាសដំណឹងល្អនេះ ។ ប្រហែលជាព្រះអម្ចាស់បានគូសបញ្ជាក់ពីសេចក្ដីពិតនេះនៅរាល់លំដាប់នៃព្រឹត្តិការណ៍ដែលបានកើតឡើងជាភាពពេញលេញនៃដំណឹងល្អត្រូវបានស្ដារឡើងវិញមកកាន់ផែនដីនៅក្នុងថ្ងៃចុងក្រោយនេះ ។

នៅក្នុងព្រៃពិសិដ្ឋ យ៉ូសែប ស្ម៊ីធ បានឃើញ ហើយនិយាយនឹងព្រះវរបិតាដ៏អស់កល្បជានិច្ច និង ព្រះយេស៊ូវគ្រីស្ទ ។ ការនិមិត្តនេះបាននាំចូលមក « សម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ » ( អេភេសូរ 1:10 ) ហើយជួយឲ្យយ៉ូសែបរៀនពីលក្ខណៈពិតនៃក្រុមព្រះ និង ពីវិវរណៈដែលមានជាបន្តបន្ទាប់ ។

ប្រមាណជាបីឆ្នាំក្រោយមក ក្នុងការឆ្លើយតបនឹងការអធិស្ឋានដ៏ស្មោះនៅល្ងាចនៃថ្ងៃទី 21 ខែ កញ្ញា ឆ្នាំ 1823 បន្ទប់ដេករបស់យ៉ូសែបបានពេញដោយពន្លឺរហូតធ្វើឲ្យវា « ភ្លឺជាងពន្លឺថ្ងៃត្រង់ទៅទៀត » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:30 ) ។ មានតួអង្គមួយបានលេចមកក្បែរលោក បានហៅឈ្មោះក្មេងប្រុសនោះ ហើយបានប្រកាសថា « លោកជាទូតដែលបានចាត់មកពីវត្តមាននៃព្រះ. . . ហើយថាឈ្មោះលោកគឺម៉ូរ៉ូណៃ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:33 ) ។ លោកបាននិយាយប្រាប់យ៉ូសែបពីការមកនៃព្រះគម្ពីរមរមន ។ រួចហើយម៉ូរ៉ូណៃបានដកស្រង់ពីគម្ពីរម៉ាឡាគីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដោយមានការប្រែប្រួលបន្តិចបន្តួចនៅក្នុងភាសាដែលបានប្រើនៅក្នុងកំណែស្ដេចជេមស៍ ៖

« មើលចុះ យើងនឹងបើកសម្ដែងដល់អ្នករាល់គ្នានូវបព្វជិតភាព ដោយដៃនៃអេលីយ៉ាដែលជាព្យាការីមុនដែលថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចនៃព្រះអម្ចាស់បានមកដល់ ។ . . . ហើយលោកនឹងដាក់នៅក្នុងចិត្តនៃកូនចៅនូវសេចក្ដីសន្យាដែលបានធ្វើដល់ពួកឪពុក ហើយចិត្តនៃកូនចៅនឹងបានបង្វែរមករកពួកឪពុករបស់ពួកគេវិញ ។ បើសិនជាមិនមែនដូច្នោះទេ នោះផែនដីទាំងមូលនឹងត្រូវកំទេចចោលសូន្យឈឹងក្នុងកាលទ្រង់យាងមក » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:38–39 ) ។



*យើងមិនមែនថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ ដើម្បីមានបទពិសោធន៍ជាបុគ្គល ឬគ្រួសារដែលគួរឲ្យចងចាំតែម្យ៉ាងប៉ុណ្ណោះនោះទេ ។ ផ្ទុយទៅវិញ យើងខិតខំដើម្បីបំពេញទំនួលខុសត្រូវដ៏ទេវភាពដែលបានចាត់មក ដើម្បីផ្ដល់ពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ និង ភាពតម្កើងឡើងដល់គ្រួសារមនុស្សលោកទាំងអស់ ។*

សេចក្ដីណែនាំរបស់ម៉ូរ៉ូណៃដល់ព្យាការីវ័យក្មេងនេះរួមមាននូវរឿងពីរសំខាន់ៗ ៖ (1) ព្រះគម្ពីរមរមន និង (2) ពាក្យរបស់ម៉ាឡាគីប្រាប់ទុកជាមុនពីតួនាទីរបស់អេលីយ៉ានៅក្នុងការស្ដារឡើងវិញនូវ « របស់ទាំងអស់ដែលព្រះបានមានបន្ទូលប្រាប់ពីគ្រានោះ ដោយសារមាត់នៃពួកហោរាបរិសុទ្ធរបស់ទ្រង់តាំងពីបុរាណមក » ( កិច្ចការ 3:21 ) ។ ដូច្នេះ ព្រឹត្តិការណ៍ចាប់ផ្ដើមនៃការស្ដារឡើងវិញបានបើកសម្ដែងនូវការយល់ដឹងត្រឹមត្រូវមួយស្ដីពីក្រុមព្រះ បានបង្កើតភាពពិតនៃវិវរណៈជាបន្តបន្ទាប់ បានគូសបញ្ជាក់ពីសារៈសំខាន់នៃព្រះគម្ពីរមរមន ហើយបានរំពឹងទុកពីកិច្ចការនៃសេចក្ដីសង្គ្រោះ និង ភាពតម្កើងឡើងសម្រាប់ទាំងអ្នកមានជីវិតរស់ និង អ្នកស្លាប់ ។

ឥឡូវនេះសូមពិចារណាពីតួនាទីរបស់ព្រះគម្ពីរមរមន នៅក្នុងការផ្លាស់ប្ដូរដួងចិត្ត—និងពីវិញ្ញាណរបស់អេលីយ៉ានៅក្នុងការបង្វែរដួងចិត្ត ។

ព្រះគម្ពីរមរមនរួមជាមួយនឹងព្រះវិញ្ញាណនៃព្រះអម្ចាស់គឺជា « ឧបករណ៍តែមួយអស្ចារ្យជាងគេបំផុត ដែលព្រះបានប្រទានឲ្យយើងដើម្បីប្រែចិត្តជឿដល់ពិភពលោកនេះ » ។[4] ព្រះគម្ពីរនៃការស្ដារឡើងវិញនេះគឺជាមូលដ្ឋាននៃសាសនារបស់យើង ហើយចាំបាច់នៅក្នុងការនាំមនុស្សមករកព្រះអង្គសង្គ្រោះ ។ ព្រះគម្ពីរមរមនគឺជាសក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ—ជាសាក្សីបញ្ជាក់ដ៏សំខាន់មួយនៃទេវភាពរបស់ព្រះដ៏ប្រោសលោះនៅក្នុងពិភពលោកមួយដែលមានសាសនា និង ភាពឥតអៀនខ្មាស់កើនឡើងយ៉ាងច្រើនដែលមិនធ្លាប់មានពីមុនមក ។ ដួងចិត្តទាំងឡាយត្រូវបានផ្លាស់ប្ដូរនៅពេលបុគ្គលម្នាក់ៗអាន ហើយ

រូបភាពប្រើប្រាស់ដោយ PESHKOVA/ISTOCK/THINKSTOCK



*ការផ្សាយដំណឹងល្អ និង ការស្វែងរកដូនតាយើង ដែលបានចែកឋានទៅគឺជាទំនួលខុសត្រូវពីរដ៏ទេវភាព ដែលបានចាត់មក ដែលវាទាក់ទងទាំងដួងចិត្ត និង ពិធីបរិសុទ្ធនៃបព្វជិតភាព ។*

សិក្សាព្រះគម្ពីរមរមន ហើយអធិស្ឋានដោយស្មោះ ដើម្បីរៀនពីសេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរនេះ ។

វិញ្ញាណរបស់អេលីយ៉ា « ការបង្ហាញឲ្យឃើញមួយពីព្រះវិញ្ញាណថ្លែងសាក្សីពីលក្ខណៈដ៏ទេវភាពនៃគ្រួសារ » ។[5] ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធដ៏វិសេសនេះ ថ្លែងជាសាក្សីដ៏អស្ចារ្យពីផែនការសុភមង្គលរបស់ព្រះវរបិតា ហើយទាក់ទាញចិត្តមនុស្សឲ្យស្រាវជ្រាវ ហើយស្រឡាញ់ដូនតាពួកគេ និង សមាជិកគ្រួសារ—ទាំងអតីតកាល និង បច្ចុប្បន្នកាល ។ វិញ្ញាណរបស់អេលីយ៉ាជះឥទ្ធិលទៅលើមនុស្សទាំងនៅខាងក្នុង និង ខាងក្រៅសាសនាចក្រ ហើយធ្វើឲ្យដួងចិត្តបង្វែរទៅរកពួកឪពុក ។

*មានវីដេអូចំនួនប្រាំមួយជាផ្នែកនៃអត្ថបទនេះ ។ សូមស្កេនលេខកូដនេះ (QR) ឬចូលទៅកាន់ lds.org/go/bednar1014 ដើម្បីមើលវីដេអូទីមួយ ស្ដីពីដំណើររឿងមួយដែលបង្ហាញពីគោលការណ៍នេះ ។.*

ពេលវេលាសម្រាប់យើងបានមកដល់ហើយ ដើម្បីទទួលបានអត្ថប្រយោជន៍ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតពីបន្សំដ៏រឹងមាំនៃការផ្លាស់ប្ដូរដួងចិត្តដ៏ធំ ដែលធ្វើឲ្យកើតមានឡើងដោយអំណាចខាងវិញ្ញាណនៃព្រះគម្ពីរមរមន និង ការបង្វែរដួងចិត្តទៅរកពួកឪពុក ដែលកើតឡើងតាមរយៈវិញ្ញាណរបស់អេលីយ៉ា ។ ការប្រាថ្នាចង់បានសម្រាប់ការតភ្ជាប់ទៅនឹងអតីតកាលរបស់យើងអាចរៀបចំមនុស្សម្នាក់ឲ្យទទួលគុណធម៌នៃព្រះបន្ទូលព្រះ ហើយពង្រឹងសេចក្ដីជំនឿរបស់គេ ។ ការបង្វែរដួងចិត្តមួយទៅរកពួកឪពុក ជួយជាពិសេសដល់មនុស្សម្នាក់ឲ្យអត់ទ្រាំនឹងឥទ្ធិពលរបស់មារសត្រូវ ហើយពង្រឹងការប្រែចិត្តជឿ ។

*សូមមើលវីដេអូទីពីរដើម្បីមើលពីដំណើររឿងមួយដែលបង្ហាញពីគោលការណ៍នេះ ។*

## គោលការណ៍ទាំងឡាយ

ឥឡូវនេះ ខ្ញុំចង់គូសបញ្ជាក់ពីគោលការណ៍ចំនួនបួនស្ដីពីអំណាចខាងវិញ្ញាណដែលកើតចេញពីការផ្លាស់ប្ដូរ និង ការបង្វែរដួងចិត្ត ។

1. **ដួងចិត្ត និង ការប្រែចិត្តជឿ ។** ការបង្វែរទៅរកពួកឪពុកបានក្រើនរំឭក ហើយរៀបចំដួងចិត្តមួយសម្រាប់ការផ្លាស់ប្ដូរដ៏ធំ ។ ហេតុដូច្នេះហើយ វិញ្ញាណរបស់អេលីយ៉ាជួយនៅក្នុងការប្រែចិត្តជឿ ។
   *សូមមើលវីដេអូទីបីដើម្បីមើលពីដំណើររឿងមួយដែលបង្ហាញពីគោលការណ៍នេះ ។*

2. **ដួងចិត្ត និង ការថែរក្សា ។** ការបង្វែរទៅរកពួកឪពុកគាំទ្រ ហើយពង្រឹងដួងចិត្តដែលធ្លាប់ជួបការផ្លាស់ប្ដូរដ៏ធំ ។ ហេតុដូច្នេះហើយ វិញ្ញាណរបស់អេលីយ៉ាជួយនៅក្នុងការថែរក្សាពួកអ្នកប្រែចិត្តជឿថ្មី ។
   *សូមមើលវីដេអូទីបួនដើម្បីមើលពីដំណើររឿងមួយដែលបង្ហាញពីគោលការណ៍នេះ ។*

3. **ដួងចិត្ត និង ការធ្វើឲ្យសកម្មភាពឡើងវិញ ។** ការបង្វែរទៅរកពួកឪពុកបន្ទន់ដួងចិត្តមួយ ដែលរឹងរូសបន្ទាប់ពីមានការផ្លាស់ប្ដូរដ៏ធំ ។ ហេតុដូច្នេះហើយ វិញ្ញាណរបស់អេលីយ៉ាគឺជាគន្លឹះនៃការធ្វើឲ្យសកម្មឡើងវិញ ។
   *សូមមើលវីដេអូទីប្រាំដើម្បីមើលពីដំណើររឿងមួយដែលបង្ហាញពីគោលការណ៍នេះ ។*

4. **ដួងចិត្ត និង ពួកអ្នកផ្សព្វផ្សាយសាសនាដ៏ក្លាហាន ។** អ្នកផ្សព្វផ្សាយសាសនាម្នាក់ដែលធ្លាប់ជួបទាំងការផ្លាស់ប្ដូរដ៏ធំ និងការបង្វែរដួងចិត្តនឹងក្លាយជាអ្នកបម្រើម្នាក់ដែលកាន់តែប្រែចិត្តជឿ បរិសុទ្ធ ហើយក្លាហាន ។
   *សូមមើលវីដេអូទីប្រាំមួយដើម្បីមើលពីដំណើររឿងមួយដែលបង្ហាញពីគោលការណ៍នេះ ។*

រួមជាមួយនឹងកម្លាំងនៃអ្នកផ្សព្វផ្សាយសាសនា កំពុងតែពង្រីកយ៉ាងឆាប់រហ័ស និង រៀបចំខ្លួនយ៉ាងល្អប្រសើរ យើងមិនគ្រាន់តែអាចពឹងផ្អែកទាំងស្រុងទៅលើជោគជ័យនៃការផ្សព្វផ្សាយសាសនាកាលពីអតីតកាល ដើម្បីកំណត់នូវផ្លូវ និង វិធីសាស្ត្ររបស់យើងសម្រាប់អនាគតតែប៉ុណ្ណោះនោះឡើយ ។ ព្រះអម្ចាស់បានបំផុសគំនិតឲ្យមានបច្ចេកវិទ្យា និង ឧបករណ៍ដែលអាចជួយឲ្យទទួលបានប្រយោជន៍ពីភាពតែមួយនៃកិច្ចការផ្សព្វផ្សាយសាសនា និង កិច្ចការព្រះវិហារបរិសុទ្ធ និង កិច្ចការពង្សប្រវត្តិ លើសពីគ្រាណាៗទាំងអស់នៅក្នុងការកាន់កាប់ត្រួតត្រានេះ ។ ហើយវាពុំមែនជាការចៃដន្យឡើយ ដែលការបង្កើតថ្មីទាំងនេះ បានកើតឡើងនៅចំពេលដែលវាត្រូវបានគេត្រូវការយ៉ាងខ្លាំងដើម្បីពន្លឿនកិច្ចការ



*វិញ្ញាណរបស់អេលីយ៉ា « ការបង្ហាញឲ្យឃើញមួយពីព្រះវិញ្ញាណថ្លែងសាក្សីពីលក្ខណៈដ៏ទេវភាពនៃគ្រួសារ » ។*

ផ្សព្វផ្សាយសាសនាជុំវិញពិភពលោក ។ កិច្ចការរបស់ព្រះអម្ចាស់គឺជាកិច្ចការដ៏អស្ចារ្យមួយផ្ដោតលើដួងចិត្តដែលផ្លាស់ប្ដូរ ហើយបង្វែរ លើសេចក្ដីសញ្ញាដ៏ពិសិដ្ឋ និង លើអំណាចនៃការគោរពព្រះដែលបើកបង្ហាញតាមរយៈពិធីបរិសុទ្ធនៃបព្វជិតភាព ។

**សេចក្ដីសង្ខេប និង ទីបន្ទាល់**

ព្រះអម្ចាស់បានប្រកាសថា « យើងអាចធ្វើកិច្ចការរបស់យើងបាន » ( នីហ្វៃទី 2 27:21 ) ហើយ « យើងនឹងពន្លឿនកិច្ចការរបស់យើងឲ្យឆាប់កើតនៅពេលកំណត់ » ( គ. និង ស. 88:73 ) ។ យើងគឺជាសាក្សីនៃការពន្លឿនរបស់ទ្រង់ទៅលើកិច្ចការរបស់ទ្រង់ ។

យើងរស់នៅ ហើយបម្រើនៅក្នុងសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ។ ដោយស្គាល់ពីសារៈសំខាន់អស់កល្បជានិច្ចនៃការកាន់កាប់ត្រួតត្រាដ៏វិសេសដែលយើងរស់នៅ គួរជះឥទ្ធិពលដល់អ្វីៗដែលយើងធ្វើ ហើយខិតខំប្រែក្លាយ ។ ដើម្បីសម្រេចកិច្ចការនៃសេចក្ដីសង្គ្រោះនៅថ្ងៃចុងក្រោយនេះគឺជារឿងដ៏ចាំបាច់ ហើយបន្ទាន់បំផុត ។ យើងម្នាក់ៗគួរមានអំណរគុណជាខ្លាំងចំពោះពរជ័យ និង ទំនួលខុសត្រូវនៃការរស់នៅក្នុងរដូវកាលនៃការកាន់កាប់ត្រួតត្រាចុងក្រោយដ៏ជាក់លាក់នេះ ។ តើយើងគួរតែមានចិត្តរាបសាខ្លាំងយ៉ាងណាទៅដោយដឹងថា « ដល់អ្នកណាដែលត្រូវបានប្រទានឲ្យច្រើន នោះក៏មានតម្រូវការជាច្រើនវិញ » ( គ. និង ស. 82:3 ) ។

ការប្រកាសដំណឹងល្អ និង ការខិតខំស្វែងរកដូនតាយើងដែលបានចែកឋានទៅគឺជាផ្នែកបន្ថែមនៃកិច្ចការដ៏អស្ចារ្យមួយ—ជាកិច្ចការនៃសេចក្ដីស្រឡាញ់ដែលមានគោលបំណងដើម្បីផ្លាស់ប្ដូរ បង្វែរ ហើយបន្សុទ្ធដួងចិត្តនៃជនដែលស្វែងរកសេចក្ដីពិតដ៏ស្មោះត្រង់ ។ បន្ទាត់ខណ្ឌដែលយើងជាញឹកញាប់បានដាក់នៅចន្លោះកិច្ចការផ្សព្វផ្សាយសាសនា និង កិច្ចការព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិនឹងត្រូវលុបចោល នេះគឺជាកិច្ចការនៃសេចក្ដីសង្គ្រោះមួយដ៏អស្ចារ្យ ។[6]

តើយើងអាចចាប់ផ្ដើមយល់ពីតួនាទីនៃកិច្ចការព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិក្នុងការជួយដល់អ្នករៀនថ្មីម្នាក់ ឬ សមាជិកមិនសូវសកម្មម្នាក់ឲ្យទទួលបាននូវការយល់ដឹងកាន់តែជ្រាលជ្រៅស្ដីពីផែនការសង្គ្រោះតាមរបៀបណា ? តើយើងស្គាល់ថាឥទ្ធិពលដ៏អស្ចារ្យបំផុតមួយចំពោះការថែរក្សាអ្នកប្រែចិត្តជឿ ជាវិញ្ញាណរបស់អេលីយ៉ាដែរឬទេ ? តើយើងអាចមានអំណរគុណដ៏ពេញលេញពីសារៈសំខាន់ នៃគ្រាបង្វែរដួងចិត្តដែលបានកើតឡើងដោយការចែកចាយដំណើររឿងគ្រួសារ ដើម្បីជាមធ្យោបាយមួយស្វែងរកមនុស្សបង្រៀនពីសំណាក់សមាជិក និង ពួកអ្នកផ្សព្វផ្សាយសាសនាដែរឬទេ ? តើយើងអាចជួយជនដែលយើងបម្រើឲ្យប្រើអំណាចនៃការគោរពព្រះឲ្យកាន់តែញឹកញាប់ តាមរយៈការចូលរួមដោយសក្ដិសមនៅក្នុងពិធីបរិសុទ្ធដូចជា ពិធីសាក្រាម៉ង់ ព្រមទាំង បុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់សម្រាប់អ្នកស្លាប់ផងដែរឬទេ ?

សូមឲ្យអ្នកមើលឃើញយ៉ាងច្បាស់ ស្ដាប់ឮដោយគ្មានការភ័ន្តច្រឡំ ហើយថែមទាំងចងចាំពីសារៈសំខាន់នៃការបម្រើរបស់អ្នក នៅក្នុងកិច្ចការរបស់ព្រះអម្ចាស់នៃការផ្លាស់ប្ដូរ ការបង្វែរ និង បន្សុទ្ធដួងចិត្ត ។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលបានធ្វើឡើង នៅក្នុងសិក្ខាសាលាសម្រាប់ប្រធានបេសកកម្មថ្មី នៅថ្ងៃទី 25 ខែ មិថុនា ឆ្នាំ 2013 ។*

**កំណត់ចំណាំ**

1. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ2007 ) ទំព័រ 330 ។
2. ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ ទំព័រ 475 ។
3. សូមមើល*ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសន៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ 2004 ) ទំព័រ 1 ។
4. អ៊ែសរ៉ា ថាហ្វ បែនសឹន « A New Witness for Christ » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1984 ទំព័រ 7 ។
5. រ័សុល អិម ណិលសុន « A New Harvest Time » *Ensign* ខែ ឧសភា ឆ្នាំ 1998 ទំព័រ 34 ។
6. សូមមើល ស្ពែនសើរ ដបុលយូ ឃីមបឹល « The Things of Eternity—Stand We in Jeopardy? » *Ensign* ខែ មករា ឆ្នាំ 1977 ទំព័រ 3 ។



# គេហដ្ឋាន

## កន្លែងដ៏សំខាន់នៃការរៀនសូត្រ

នៅពេលការរៀនសូត្រនៅសាសនាចក្រ ស្របគ្នានឹងការរៀនសូត្រនៅគេហដ្ឋាន នោះអ្នកកំពុងសង់គ្រឹះដ៏រឹងមាំមួយនៃការរស់នៅតាមដំណឹងល្អហើយ ។

« ស្មប្រាកដថា អ្នកអានកិច្ចការដែលបានដាក់ឲ្យសម្រាប់មេរៀនសប្ដាហ៍ក្រោយ » ។ តើធ្លាប់ឮពាក្យទាំងនោះទេ ? ជាញឹកញាប់ ពាក្យទាំងនោះ គឺជាពាក្យស្នើសុំរបស់គ្រូបង្រៀននៅចុងម៉ោងក្នុងថ្នាក់រៀននៅព្រះវិហារ ។

ដោយសារតែវាពិតជាសំខាន់ដើម្បីមានការរៀបចំ សម្រាប់មេរៀនថ្ងៃអាទិត្យរបស់អ្នក ពេលខ្លះ តើអ្នកគិតថា គោលបំណងចម្បងរបស់អ្នកនៅក្នុងការសិក្សា និង ការពិចារណា គឺជាអ្វីមួយដែលអ្នកមានអារម្មណ៍ថាបានត្រៀមខ្លួនជាស្រេចសម្រាប់ថ្ងៃអាទិត្យដែរទេ ?

តាមពិតទៅ វាផ្ទុយស្រឡះពីនេះ ។

គ្រប់ « ការបង្រៀន កម្មវិធី និង សកម្មភាព របស់សាសនាចក្រទាំងអស់ [ គឺ ] ផ្ដោតទៅលើគេហដ្ឋាន និង គាំទ្រសាសនាចក្រ » ។[1] នោះមានន័យថា ការប្រជុំនានារបស់សាសនាចក្រយើង គឺពិតជាគាំទ្រការរៀនសូត្ររបស់បុគ្គលម្នាក់ៗ និង គ្រួសារ ។ ដូចដែលប៊ីស្សពជាអធិបតី ហ្គេរី អ៊ី ស្ទីវ៉ែនសុន បានបង្រៀនថា « កន្លែងដ៏សំខាន់នៃការបង្រៀន និង ការរៀនសូត្រនោះគឺគេហដ្ឋាន » ។[2] នៅពេលការរៀនសូត្រ និង ការបង្រៀនត្រូវបានយកចិត្តទុកដាក់នៅក្នុងគេហដ្ឋាន នោះវាមានឥទ្ធិពលដែលអាចដឹកនាំទៅការប្រែចិត្តជឿ ។

នោះគឺជាសារលិខិតនៃការប្រជុំបំពាក់បំប៉នអង្គការជំនួយឆ្នាំ 2014 *Learning and Teaching in the Home and the Church* ( *ការរៀនសូត្រ និង ការបង្រៀននៅក្នុងគេហដ្ឋាន និង សាសនាចក្រ* ) មាននៅលើអ៊ិនធើរណែតនៅគេហទំព័រannualtraining.lds.org ។ « គ្មាននរណាម្នាក់ត្រូវបានគេគិតថាមិនសំខាន់នៅក្នុងការបង្រៀននៅក្នុងសាលប្រជុំ ឬ បន្ទប់រៀនឡើយ » ប្រសាសន៍របស់អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ « យើងទាំងអស់គ្នា បានធ្វើកិច្ចការទាំងនោះពេញមួយជីវិតយើងហើយ ប៉ុន្តែយើងចង់ឲ្យមានការបង្រៀននោះនៅគ្រប់ 24 ម៉ោងក្នុងជីវិតរស់នៅរបស់យើង » ។[3] នៅពេលអ្នកអនុវត្តនូវការរៀនសូត្រគ្រប់ 24 ម៉ោង ទៅក្នុងពេលវេលាប្រចាំថ្ងៃក្នុងជីវិតគ្រួសាររបស់អ្នក នោះអ្នកអាចស្ថាបនាគ្រឹះរឹងមាំមួយសម្រាប់ « ដំណាក់នៃការរៀនសូត្រ » ( គ. និង ស.88:119 ) ដែលនឹងផ្ដល់ជម្រក និង ការការពារខាងវិញ្ញាណសម្រាប់អ្នក និង គ្រួសារអ្នក ។

### ធនធានសម្រាប់គេហដ្ឋាននីមួយៗ

សូមប្រើវីដេអូបំពាក់បំប៉នអង្គការជំនួយឆ្នាំ 2014 នៅគេហទំព័រ annualtraining.lds.org ដើម្បី ៖

- ពង្រឹងខ្លួនអ្នក និង គ្រួសារអ្នក ។នៅពេលអ្នកមើលវីដេអូខ្លីទាំងនេះ សូមពិចារណាប្រកបដោយការអធិស្ឋានពីរបៀបដែលគេបង្រៀនគោលការណ៍ទាំងនេះ អនុវត្តចំពោះស្ថានភាពគ្រួសាររបស់អ្នក ។
- ពង្រឹងវួដរបស់អ្នក ។អ្នកអាចមើលការបំពាក់បំប៉ននេះនៅក្នុងការប្រជុំថ្នាក់ដឹកនាំស្តេកដែលនឹងមាននៅពេលខាងមុខ ការពិភាក្សាក្នុងវួដនៅសប្ដាហ៍ទីប្រាំ ឬ ការប្រជុំក្រុមប្រឹក្សា ស្របតាមការដឹកនាំរបស់ថ្នាក់ដឹកនាំស្តេក និង វួដរបស់អ្នក ។





# ការរៀនសូត្រនៅផ្ទះ

អ្នកប្រហែលជាមិនអាចឃើញលទ្ធផលភ្លាមៗជានិច្ចនោះទេ ប៉ុន្តែនៅពេលអ្នកទាញយកផលប្រយោជន៍ពី ឱកាសដ៏សាមញ្ញៗសម្រាប់ការរៀនសូត្រ និងការបង្រៀនទៅក្នុងទម្លាប់ប្រចាំថ្ងៃរបស់អ្នក នោះវាអាចមានប្រសិទ្ធិភាពយ៉ាងខ្លាំង ។ នេះគឺជារបៀបដែលគ្រួសារមួយចំនួនបានកត់សម្គាល់ពីឥទ្ធិពលនោះនៅក្នុងជីវិតរបស់ពួកគេ ។

# ឱកាសសាមញ្ញៗ

« មានពេលខ្លះ យើងអាចមានអារម្មណ៍ថា ចម្លែក ដើម្បីមានការសុន្ទនាជាផ្លូវការអំពីប្រធានបទមួយចំនួនដែលទាក់ទងនឹងដំណឹងល្អ ។ ឱកាសបង្រៀនដ៏សាមញ្ញនេះ ពិតជាបានប្រទានពរដល់យើងឲ្យ បង្រៀនមេរៀនសំខាន់ៗដល់កូនៗរបស់យើង ។ មានឱកាសបង្រៀនដ៏សាមញ្ញច្រើនជាងឱកាសបង្រៀនជាផ្លូវការផងដែរក្នុងមួយថ្ងៃៗ ដូច្នេះ យើងពិតជាអាចចាប់យកឱកាសទាំងនោះដើម្បីបង្រៀនកូនៗរបស់យើងអំពីគោលការណ៍សំខាន់ៗ ។ ឧទាហរណ៍ ខ្ញុំបង្រៀនអំពីភាពទៀងត្រង់ ពេលទិញឥវ៉ាន់ ។ កូនៗរបស់ខ្ញុំ រៀនគោលការណ៍នានាកាន់តែងាយស្រួល នៅពេលពួកគេឃើញពីរបៀបដើម្បីអនុវត្តគោលការណ៍ទាំងនោះ » ។

*ម៉ូណា វីលឡាណូអ៊ីវ៉ា ប្រទេស ហ្វីលីពីន*





## ភាពជិតស្និទ្ធនៅពេលបរិភោគអាហារសំរ៉ន់

« ឱកាសបង្រៀនដ៏សាមញ្ញនានាបានជួយខ្ញុំឲ្យមានទំនាក់ទំនងកាន់តែប្រសើរជាងមុនជាមួយកូនៗរបស់ខ្ញុំ ។ នៅពេលយើងកំពុងអង្គុយនៅតុអាហារនៅផ្ទះបាយ បរិភោគអាហារសំរ៉ន់បន្ទាប់មកពីសាលារៀនវិញ នោះយើងពិភាក្សាគ្នាពីអ្វីដែលបានកើតឡើងអំឡុងពេលទៅសាលារៀនរបស់ពួកគេ ។ ជាញឹកញាប់ មានកូនម្នាក់នឹងនិយាយអ្វីមួយដែលមិត្តភក្តិម្នាក់បាននិយាយ ឬ ពីអារម្មណ៍ដែលពួកគេមាននៅពេលនរណាម្នាក់បាននិយាយ ឬ បានធ្វើអ្វីមួយ ។ បន្ទាប់មកខ្ញុំអាចចែកចាយទីបន្ទាល់ផ្ទាល់ខ្លួនរបស់ខ្ញុំ ហើយពិភាក្សាពីរបៀបដែលកូនរបស់ខ្ញុំមានអារម្មណ៍អំពីស្ថានភាពនោះ ។ ខ្ញុំគិតថា ការពិភាក្សាដោយស្មោះត្រង់ ពេលកូនៗមានអារម្មណ៍ធូរស្បើយ នោះពួកគេនឹងមានឆន្ទៈកាន់តែខ្លាំង ដើម្បីពិភាក្សាពីចំណុចសំខាន់នានា នៅពេលមានសេចក្តីត្រូវការ ពីព្រោះពួកគេមានកម្រិតនៃការទុកចិត្ត ដោយដឹងថាឪពុកម្តាយរបស់ខ្លួននឹងស្តាប់ » ។

*អាលីសុន ហ្វ្រូស ប្រទេស ក្រិក*

## ការធ្វើដំណើរ និង ការសន្ទនា

« ខ្ញុំបានយកកូនស្រីខ្ញុំទៅសាលារៀនដោយជិះឡានក្រុងជារៀងរាល់ព្រឹក ដូច្នេះយើងមានឱកាសច្រើនដើម្បីជជែកគ្នា ។ ក្នុងឱកាសមួយក្នុងពេលថ្មីៗនេះ យើងបានកត់សម្គាល់ថា ស្វាមី និង ភរិយាមួយគូមានការឈ្លោះប្រកែកគ្នា ។ កូនស្រីរបស់ខ្ញុំ បានងាកមកខ្ញុំយ៉ាងលឿន ហើយរង់ចាំឲ្យខ្ញុំផ្តល់យោបល់ ។ ផ្ទុយទៅវិញ ខ្ញុំបានសួរពួកគេ ពីអារម្មណ៍ដែលពួកគេមានចំពោះអ្វីដែលបានកើតឡើង ។ ពួកគេបានប្រាប់ខ្ញុំថា ពួកគេបានគិតថា បុរសម្នាក់នោះពុំគួរនិយាយបែបនេះដាក់ភរិយាគាត់ទេ ។ បន្ទាប់មក យើងបានជជែកគ្នាអំពីអាពាហ៍ពិពាហ៍ និង ទំនាក់ទំនងគ្រួសារ ។ ជាលទ្ធផលការធ្វើដំណើរតាមឡានក្រុងរយៈពេល 30 នាទីរបស់យើងពិតជាបានស្អាង និង លើកស្ទួយយ៉ាងខ្លាំង » ។

*ម៉ារីអូ ឡូរ៉ែនស៍ ប្រទេស ក្វាតេម៉ាឡា*





# វដ្តនៃការថែទាំ

« ភរិយាខ្ញុំ និង ខ្ញុំបានដឹងថា វាគឺជាទំនួលខុសត្រូវចម្បងរបស់យើង ដើម្បីបង្រៀនកូនៗយើង ហើយពុំមែនជាទំនួលខុសត្រូវរបស់ថ្នាក់ដឹកនាំឡើយ ប៉ុន្តែយើងមានអំណរគុណចំពោះអ្វីដែលពួកគាត់បានធ្វើ ហើយពួកយើងជួយតាមដែលអាចធ្វើទៅបាន ។ វួដរបស់យើងមានថ្នាក់ដឹកនាំដ៏អស្ចារ្យ ដែលពិតជាយកចិត្តទុកដាក់លើយុវវ័យ និង កូនក្មេង ហើយធ្វើអ្វីៗដែលពួកគេអាចធ្វើបាន ដើម្បីជួយពួកគេឲ្យឃើញពីសក្តានុពលដ៏ពេញលេញរបស់ខ្លួន ដោយផ្តោតលើអ្វីដែលឪពុកម្តាយបានធ្វើ ។ ខ្ញុំបានជួបជាមួយប៊ីស្សពពីរបីដង ហើយខ្ញុំមានការសុន្ទនាដ៏ល្អ ជាមួយថ្នាក់ដឹកនាំយុវវ័យ ហើយជាញឹកញាប់ខ្ញុំសួរអំពីកូនៗខ្ញុំ និង ការរីកចម្រើនរបស់ពួកគេ ។ ជាញឹកញាប់ ភាពពិតនៃការជជែកគ្នាអំពីការរីកចម្រើនរបស់កូនៗយើង បានជួយយើងទាំងអស់គ្នាយល់ពីរបៀបដើម្បីជួយពួកគេម្នាក់ៗ » ។

*ជេសី អែន អារ៉ូម៉ូហ្គាម ប្រទេស អាហ្វ្រិកភាគខាងត្បូង*



# ការរៀនសូត្រនៅសាសនាចក្រ ៖
## គោលការណ៍ 10 យ៉ាងដែលគ្រូបង្រៀនម្នាក់ៗគួរយល់ដឹង

បន្ថែមលើការពង្រឹងឥទ្ធិពលនៃការរៀនសូត្រ និង ការបង្រៀននៅក្នុងគេហដ្ឋាន នោះយើងអាចពង្រឹងបទពិសោធន៍នៅថ្នាក់រៀននៅព្រះវិហារបានផងដែរ ។ នៅពេលគ្រូបង្រៀនអនុវត្តគោលការណ៍ទាំង 10 យ៉ាងនេះ នោះពួកគេនឹងចិញ្ចឹមបីបាច់ការប្រែចិត្តជឿនៅក្នុងជីវិតមនុស្សទាំងអស់ដែលពួកគេបង្រៀន ។

1. ប្រឹក្សាជាមួយឪពុកម្ដាយ ដែលជាអ្នកមានតួនាទីសំខាន់ដូចជាគ្រូបង្រៀន ដើម្បីស្វែងយល់ពីសេចក្ដីត្រូវការរបស់សមាជិកក្នុងថ្នាក់ ហើយបន្ទាប់មកបង្រៀនអ្នកដែលមានសេចក្ដីត្រូវការនោះ ។
2. រៀបចំ និង បង្រៀនដោយព្រះវិញ្ញាណ ។ ស្វែងរកសំណួរ ហើយសកម្មភាពរៀនសូត្រនានា ដែលនឹងផ្ដល់ការពិភាក្សាប្រកបដោយការដឹកនាំពីព្រះវិញ្ញាណ ហើយបីបាច់សមាជិកក្នុងថ្នាក់ខាងវិញ្ញាណ ។
3. បង្រៀនមនុស្ស ពុំមែនបង្រៀនមេរៀនទេ ។
4. ផ្ដោតយកចិត្តទុកដាក់លើខ្លឹមនៃគោលលទ្ធិនៃដំណឹងល្អ ។
5. បង្រៀនគោលការណ៍សំខាន់មួយ ឬ ពីរឲ្យស៊ីជម្រៅ ជាជាងព្យាយាមបង្រៀនគ្រប់ចំណុចទាំងអស់នៃមេរៀន ។
6. អញ្ជើញព្រះវិញ្ញាណ ដោយអនុញ្ញាតឲ្យមនុស្សគ្រប់គ្នាចូលរួម ( សូមមើលគ. និង ស.88:122) ។
7. រួមបញ្ចូលនូវការអញ្ជើញដ៏មានឥទ្ធិពលមួយដើម្បីអនុវត្ត—គឺមិនគ្រាន់តែទៅផ្ទះ ហើយអាននោះទេ ប៉ុន្តែគឺទៅផ្ទះហើយរស់នៅតាមវិញ ។
8. ថ្លែងទីបន្ទាល់របស់អ្នកអំពីគោលលទ្ធិ—នៅចុងបញ្ចប់នៃថ្នាក់រៀន និង នៅពេលណាក៏ដោយដែលព្រះវិញ្ញាណបំផុសគំនិតអ្នក ។
9. រស់នៅតាមដំណឹងល្អ ហើយ « តាំងឲ្យមានរបៀបរៀបរយ » នៅក្នុងគេហដ្ឋានផ្ទាល់របស់អ្នក ( សូមមើលគ. និង ស. 93:43–44, 50 ) ។ »
10. ស្វែងរកវិធីផ្សេងៗ ដើម្បីឲ្យការបង្រៀនបន្តមាន តាមរយៈឱកាសសាមញ្ញៗនៅក្នុងជីវិតប្រចាំថ្ងៃ ។

**កំណត់ចំណាំ**

1. *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* ( ឆ្នាំ 2010 ) ជំពូក 1.4 ។
2. ហ្គែរី អ៊ី ស្ទីវ៉ែនសុន នៅក្នុង« The Ward Council—We're All in This Together » ( ក្រុមប្រឹក្សាវួដ—យើងដោះស្រាយបញ្ហានេះទាំងអស់គ្នា » ) ( វីដេអូបំពាក់បំប៉នអង្គការជំនួយ ឆ្នាំ 2014 ) annualtraining.lds.org ។
3. ជែហ្វ្រី អ័រ ហូឡិន នៅក្នុង « Learning and Teaching in the Home and the Church—the Home" ( ការរៀនសូត្រ និង ការបង្រៀននៅក្នុងគេហដ្ឋាន និង សាសនាចក្រ—គេហដ្ឋាន ) ( វីដេអូបំពាក់បំប៉នអង្គការជំនួយ ឆ្នាំ 2014 ) annualtraining.lds.org ។



**ព្រះគ្រីស្ទបានបង្រៀននៅលើជើងភ្នំ និង នៅក្នុងផ្ទះជាច្រើន**

« ព្រះអង្គសង្គ្រោះ [ គឺជា ] គ្រូដ៏ឆ្នើមកំពូល ។ . . . យើងឃើញថាស្ទើរតែគ្រប់ការបម្រើរបស់ទ្រង់គឺជាបង្រៀន ។ ហើយមិនតែប៉ុណ្ណោះ ការបង្រៀនស្ទើរតែទាំងអស់ពុំបានធ្វើឡើងនៅក្នុងអគារសាសនាចក្រឡើយ ។ ទ្រង់បង្រៀននៅទីណាដែលមានមនុស្សនៅ ។ ការបង្រៀននោះគឺនៅលើផ្លូវ និង ផ្លូវកាត់ និង ជើងភ្នំ និង មាត់សមុទ្រ និង នៅក្នុងផ្ទះនានា » ។

**អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ នៅក្នុង « Learning and Teaching in the Home and the Church—the Home » ( ការរៀនសូត្រ និង ការបង្រៀននៅក្នុងគេហដ្ឋាន និង សាសនាចក្រ—គេហដ្ឋាន ) ( វីដេអូបំពាក់បំប៉នអង្គការជំនួយ ឆ្នាំ 2014 ) annualtraining.lds.org ។**

# ឥទ្ធិពលពីព្រះគម្ពីរ

« ការសិក្សាព្រះគម្ពីរជួយខ្ញុំឲ្យរៀនពីព្រះយេស៊ូវគ្រីស្ទ និង លក្ខណៈរបស់ទ្រង់ ដូច្នេះខ្ញុំអាចប្រែក្លាយកាន់តែដូចទ្រង់ ។ វាក៏ផ្ដល់ឲ្យខ្ញុំនូវព្រះវិញ្ញាណដ៏បរិបូរណ៍ ដែលដឹកនាំខ្ញុំ និង បង្រៀនខ្ញុំពីរបៀបដែលខ្ញុំអាចអនុវត្តអ្វីៗទាំងនោះដែលខ្ញុំបានរៀន ដូច្នេះខ្ញុំអាចត្រៀមខ្លួនទប់ទល់នឹងឧបគ្គសនានាក្នុងជីវិត និង ការល្បួងនានារបស់សាតាំង ដែលកើតលើរូបខ្ញុំ ។ បើគ្មានពរជ័យនេះក្នុងជីវិតរបស់ខ្ញុំទេ នោះខ្ញុំដឹងថា ខ្ញុំនឹងពុំអាចបំពេញសក្ដានុពលខ្ញុំក្នុងនាមជាបុត្រាម្នាក់របស់ព្រះឡើយ » ។

*ណាថាន រ៉ូដរ៉ៃ ប្រទេស អង់គ្លេស*



# នៅលើផ្ទៃទឹក

*ខ្ញុំបានធ្លាប់ទូលអង្វរព្រះវរបិតាសួគ៌ឲ្យដកយកការព្រួយបារម្ភ និង ភាពអស់សង្ឃឹមចេញពីខ្ញុំ ប៉ុន្តែបើគ្មានការសាកល្បងទាំងនេះទេ ខ្ញុំមិនអាចទៅដល់ « ដែនដីសន្យា » ដែលទ្រង់កំពុងតែដឹកនាំខ្ញុំទៅឡើយ ។*

**ដោយ ចូន វ៉ែនន័រ**

ប្រហែលជាប្រាំមួយខែបន្ទាប់ពីបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ខ្ញុំបានចាប់ផ្ដើមជួបនឹងការវាយប្រហារដ៏ខ្លាំងក្លា ការប្រយុទ្ធនឹងក្ដីព្រួយ និង រលកនៃការថប់បារម្ភ ។ ខ្ញុំមិនដឹងថាអារម្មណ៍ទាំងនេះមកពីណាទេ ប៉ុន្តែវាមានកម្លាំងខ្លាំងណាស់ក្លា ។

ខ្ញុំពិបាកនឹងផ្ដោតអារម្មណ៍ណាស់ ។ នៅកន្លែងធ្វើការ មានការងារថ្មីៗដែលនាំមកនូវការព្រួយបារម្ភបែបនេះ ធ្វើឲ្យខ្ញុំមិនអាចអង្គុយស្ងៀមបានឡើយ ។ គំនិតខ្ញុំមានភាពច្របូលច្របល់ ហើយបេះដូងខ្ញុំលោតយ៉ាងលឿនរហូតខ្ញុំបានគិតថាវានឹងលោតចេញមកក្រៅ ។ បញ្ហានេះបានបន្តអស់រយៈពេលជាច្រើនថ្ងៃ ហើយបន្ទាប់ពីត្រឡប់ពីកន្លែងធ្វើការមកផ្ទះវិញរាល់ថ្ងៃ ខ្ញុំបានទម្លាក់ខ្លួនចុះទៅលើសាឡុង ។ ពីមុនខ្ញុំបានដឹងខ្លួន ពេលល្ងាចបានកន្លងផុតទៅ ហើយថ្ងៃធ្វើការមួយទៀតបានមកដល់ ។

អារម្មណ៍ទាំងនេះបានបន្តអស់រយៈពេលជាច្រើនខែ សូម្បីតែបន្ទាប់ពីខ្ញុំរកបានការងារថ្មីមួយ ហើយរកជំនួយពីអ្នកឯកទេសក្ដី ។

ខ្ញុំបានអធិស្ឋាននៅរាល់ថ្ងៃតាមផ្លូវទៅធ្វើការទូលសូមកម្លាំងដើម្បីឆ្លងឲ្យផុតថ្ងៃនោះ ហើយត្រឡប់មកផ្ទះជួបនឹងភរិយា និង កូនស្រីខ្ញុំវិញ ។ ខ្ញុំមិនអាចមើលឃើញពីចុងបញ្ចប់ចំពោះបញ្ហារបស់ខ្ញុំឡើយ ហើយជារឿយៗខ្ញុំចង់ចុះចាញ់នឹងវា ។ ខ្ញុំបានទូលអង្វរទៅសួគ៌ាជាច្រើនថ្ងៃដើម្បីទូលសូមជំនួយទាំងទឹកភ្នែក ។ ខ្ញុំបានអធិស្ឋានដោយស្មោះជាងខ្ញុំធ្លាប់ធ្វើកាលពីមុនមក ដោយទូលអង្វរដល់ព្រះវរបិតាសួគ៌ឲ្យជួយខ្ញុំយល់ពីការសាកល្បងនេះ ហើយដកយកវាចេញពីខ្ញុំ ។

ខ្ញុំមានអារម្មណ៍ថាវង្វេងនៅក្នុងភាពងងឹត និង ភាពអស់សង្ឃឹម កាលខ្ញុំគ្មានអារម្មណ៍ពីព្រះវិញ្ញាណ ។ ប៉ុន្តែកាលព្រះវិញ្ញាណបានលើកខ្ញុំចេញពីភាពអស់សង្ឃឹមរបស់ខ្ញុំ ខ្ញុំបានមានទំនុកចិត្តដើម្បីបន្ត—រហូតដល់ការអធិស្ឋានរបស់ខ្ញុំលើកក្រោយទៀត ។ ខ្ញុំបានចាប់ផ្ដើមពឹងផ្អែកលើព្រះវរបិតាសួគ៌បន្ថែមទៀតលើសពីការគ្រាន់តែអធិស្ឋាននៅពេលហូបអាហារ ឬពេលចូលដេកនៅយប់ឡើយ ។ ជាលទ្ធផល ខ្ញុំកាន់តែខិតទៅជិតទ្រង់ ។

**បានបោកបក់នៅលើរលក**

នៅក្នុងភាពព្រួយបារម្ភ និង ភាពអស់សង្ឃឹមរបស់ខ្ញុំ ខ្ញុំបានអានឡើងវិញនូវដំណើររឿងរបស់សាសន៍យ៉ារេឌឆ្លងកាត់ « ទីជំរៅដ៏ធំ » ( អេធើរ 2:25 ) ។ ខ្ញុំអាចស្រមៃឃើញពីការដឹងជាមុនដ៏គួរឲ្យបារម្ភរបស់ពួកគេ កាលពួកគេចូលទៅក្នុងភេត្រារបស់ពួកគេ ។ ដំណើររបស់ពួកគេអាចនឹងមានគ្រោះថ្នាក់ ប៉ុន្តែពួកគេបានដឹងថា ពួកគេកំពុងឆ្ពោះទៅ « ដែនដីដ៏ជំរើសលើអស់ទាំងដែនដីឯទៀត » ( អេធើរ 2:15 ) ។

យើងបានអានពីដំណើររបស់ពួកគេថា ៖

« ព្រះអម្ចាស់ទ្រង់បានធ្វើឲ្យមានខ្យល់ដ៏ខ្លាំងមួយបក់នៅលើផ្ទៃសមុទ្រឆ្ពោះទៅឯដែនដីសន្យា ម្ល៉ោះហើយ ពួកគេត្រូវបក់បោកដោយខ្យល់នៅលើរលកសមុទ្រ ។

« ហើយហេតុការណ៍បានកើតឡើងថា ពួកគេត្រូវបានកប់នៅក្នុងជំរៅសមុទ្រជាច្រើនគ្រាច្រើនដង ពីព្រោះមកពីរលកទាំងឡាយដូចជាភ្នំដែលបានបោកមកលើពួកគេ ព្រមទាំងព្យុះដ៏ធំគួរឲ្យខ្លាចដែលបណ្ដាលមកពីសភាពខ្លាំងក្លានៃខ្យល់ ។

«. . . កាលពួកគេហ៊ុមព័ទ្ធជុំវិញដោយទឹកជាច្រើន នោះពួកគេបានអំពាវនាវទៅព្រះអម្ចាស់ ហើយបាននាំយកពួកគេឡើងមកលើទឹកវិញ ។

« ហើយហេតុការណ៍បានកើតឡើងថា ខ្យល់បក់មិនឈប់ឈរឆ្ពោះទៅដែនដីសន្យានៅពេលដែលពួកគេនៅលើទឹក ម្ល៉ោះហើយ ពួកគេត្រូវបានរុញទៅដោយខ្យល់ » ( អេធើរ 6:5–8 ) ។

បទគម្ពីរទាំងនេះបានធ្វើឲ្យខ្ញុំចូលចិត្តជាខ្លាំង ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំស្ថិតនៅក្នុងភេត្រារបស់ខ្ញុំ ដោយមានខ្យល់នៃភាពព្រួយបារម្ភបក់បោកមកលើខ្ញុំ ហើយរលកនៃភាពអស់សង្ឃឹមកំពុងតែគ្របដណ្ដប់ខ្ញុំ ហើយពន្លិចខ្ញុំចូលទៅក្នុងជម្រៅនៃភាពអស់សង្ឃឹម ។ កាលខ្ញុំត្រូវបាន « ហ៊ុមព័ទ្ធជុំវិញ » ហើយបានដង្ហោយហៅព្រះអម្ចាស់ នោះខ្ញុំបានរួចផុតពីបញ្ហា ប៉ុន្តែក្រោយមកត្រូវបានជួបវាម្ដងទៀត ។

ខ្ញុំបានអានខទី 8 សារជាថ្មី ៖ « ខ្យល់បក់មិនឈប់ឈរ*ឆ្ពោះទៅដែនដីសន្យា* . . . ម្ល៉ោះហើយ ពួកគេត្រូវបានរុញទៅដោយខ្យល់ » ( ការគូសបញ្ជាក់បានបន្ថែម ) ។ បន្ទាប់មកវាបានប៉ះដល់ចិត្តខ្ញុំ ។ ខ្យល់ដែលធ្វើឲ្យមានរលកដ៏ធំមកពន្លិចភេត្រានោះក៏ប្រទានពរដល់សាសន៍យ៉ារេឌនៅក្នុងការធ្វើដំណើររបស់ពួកគេដែរ ។ ខ្ញុំបានធ្លាប់ទូលអង្វរព្រះវរបិតាសួគ៌ដោយធ្វើឲ្យខ្យល់ និង រលកនោះស្ងប់ប៉ុន្តែបើគ្មានវាទេ ខ្ញុំមិនអាចទៅដល់ « ដែនដីសន្យា » ដែលទ្រង់កំពុងតែដឹកនាំខ្ញុំទៅឡើយ ។

បទគម្ពីរទាំងនេះបានផ្លាស់ប្ដូរទស្សនៈរបស់ខ្ញុំអំពីជីវិត ។ ភាពព្រួយបារម្ភ និង ភាពអស់សង្ឃឹមរបស់ខ្ញុំបានបង្កើតការពឹងផ្អែករបស់ខ្ញុំទៅលើព្រះវរបិតាសួគ៌ ។ បើគ្មានខ្យល់ និង រលកទេនោះ ខ្ញុំនឹងមិនបានស្គាល់ព្រះដូចជាពេលនេះឡើយ—ហើយសាសន៍យ៉ារេឌក៏មិនបានទៅដល់ដែនដីសន្យាដែរ ។

ក្នុងខណៈពេលនេះ ក្រោយពីបទពិសោធន៍នោះបានពីរបីឆ្នាំមក ខ្យល់នៃភាពព្រួយបារម្ភរបស់ខ្ញុំលែងបក់បោក ហើយរលកនៃភាពអស់សង្ឃឹមរបស់ខ្ញុំបានឈប់បោកពន្លិចខ្ញុំទៀតហើយ ។ ប៉ុន្តែប្រសិនបើខ្យល់ព្យុះនោះត្រឡប់មកវិញ ខ្ញុំនឹងអំពាវនាវទៅរកព្រះអម្ចាស់ ហើយថ្លែងអំណរគុណ ដោយដឹងថាសមុទ្រដ៏ស្ងប់មិនអាចនាំភេត្រាទៅកាន់ដែនដីសន្យាបានឡើយ—មានតែសមុទ្រដែលមានខ្យល់បក់បោកប៉ុណ្ណោះ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*



**កុំបោះបង់សេចក្ដីជំនឿ**

« តើអ្នកឆ្លើយតបបានល្អប៉ុណ្ណាទៅ ពេលបញ្ហាផ្លូវកាយ ឬអារម្មណ៍កើតមានចំពោះអ្នក និងមនុស្សដែលអ្នកស្រឡាញ់ ? ជាងនេះទៀត សូមកុំបោះបង់សេចក្ដីជំនឿលើព្រះវរបិតាគង់នៅស្ថានសួគ៌របស់អ្នក ដែលទ្រង់ស្រឡាញ់អ្នកលើសពីអ្នកគិតទៅទៀត ។ . . .

« សូមស្វែងរកការអនុវត្តដែលនាំព្រះវិញ្ញាណចូលមកក្នុងជីវិតអ្នកដោយស្មោះត្រង់។ ចូរស្វែងរកការប្រឹក្សាពីអ្នកដែលកាន់កូនសោសម្រាប់សុខុមាលភាពខាងវិញ្ញាណអ្នក ។ ចូរសូម ហើយឲ្យតម្លៃពរជ័យនៃបព្វជិតភាព ។ ចូរទទួលទានសាក្រាម៉ង់រាល់សប្ដាហ៍ ហើយកាន់ខ្ជាប់ទៅនឹងការសន្យាដ៏ឥតខ្ចោះនៃដង្វាយធួនរបស់ព្រះគ្រីស្ទ ។ . . .

« . . . ចិត្តដែលខ្ទេចខ្ទាំអាចព្យាបាលបានតាមរបៀបដូចគ្នានឹងការព្យាបាលឆ្អឹងបាក់ និង ការខូចចិត្តផងដែរ ។ កាលព្រះកំពុងធ្វើការព្យាបាលទាំងនោះ យើងទាំងអស់គ្នាអាចជួយដោយការមានក្ដីមេត្តា កុំវិនិច្ឆ័យ ហើយមានចិត្តសប្បុរស » ។

**អែលឌើរ ជេហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Like a Broken Vessel » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2013 ទំព័រ 40, 41 ។**

រូបថតដោយ ម៉ៅ ហាប៊ីន








# ការប្រែចិត្តជឿ និង ការផ្លាស់ប្តូរនៅក្នុង

# ប្រទេសស៊ីលី

*បុណ្យជ្រមុជទឹកដំបូងធ្វើឡើងនៅឆ្នាំ 1956 ។ ឥឡូវនេះសាសនាចក្រមានព្រះវិហារបរិសុទ្ធ 1 បេសកកម្ម 9 ស្តេក 74 និងសមាជិកជិត 600,000 នាក់នៅក្នុងប្រទេសស៊ីលី ។*

**ដោយ ណេស្ទ័រ ខើរបើរឡូ**
អ្នកប្រឹក្សាខាងប្រវត្តិសាស្ត្រសាសនាចក្រ តំបន់ខាងត្បូងនៃអាមេរិកខាងត្បូង

**អំ**ឡុង 58 ឆ្នាំនៃប្រវត្តិសាស្ត្ររបស់ពួកគេ សមាជិកសាសនាចក្រនៅប្រទេសស៊ីលីបានបង្ហាញសមត្ថភាពរបស់ពួកគេដើម្បីផ្លាស់ប្តូរផ្លូវ ធ្វើការកែសម្រួលនៅក្នុងជីវិតរបស់ពួកគេទៅរកទិសដៅដែលព្យាការីបានបង្ហាញ ។ ទង្វើនេះបានចូលរួមចំណែកដល់ការលូតលាស់ដ៏អស្ចារ្យរបស់សាសនាចក្រនៅទីនោះអំឡុងពេលពាក់កណ្តាលសតវត្សចុងក្រោយនេះ ។ សព្វថ្ងៃនេះ ប្រទេសមានសមាជិកជិត 600,000 នាក់ ដោយធ្វើឲ្យនៅក្នុងចំណោមប្រជាជនស៊ីលី 30 នាក់ មានប្រហែលជាម្នាក់គឺជាសមាជិកនៃសាសនាចក្រ ។[1]

## សាវកមួយរូបបានទៅទស្សនកិច្ចប្រទេសស៊ីលី

នៅឆ្នាំ 1851 អែលឌើរ ប៉ាលី ភី ប្រាត្ត ( 1807–1857 ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមកដល់ទីក្រុងវ៉ាល់ប៉ារ៉ៃសូ ព្រមជាមួយនឹងគោលបំណងនៃការស្ថាបនាសាសនាចក្រ ។ ប៉ុន្តែ លោក និង ដៃគូលោកមិនចេះនិយាយភាសាអេស្ប៉ាញ ពួកលោកមានប្រាក់កាក់បន្តិចបន្តួច ហើយប្រទេសនេះខ្វះនូវសេរីភាពខាងសាសនា ដូច្នេះពួកលោកមិនអាចស្ថាបនាសាសនាចក្របានឡើយ ។

អែលឌើរ ប្រាត្ត បានផ្តល់អនុសាសន៍ដល់ប្រធាន ព្រិកហាំ យ៉ង់ ( ឆ្នាំ 1801–77 ) ថា ៖ « ព្រះគម្ពីរមរមន និងការបោះពុម្ពមួយចំនួនដែលមានតម្លៃថោកគួរត្រូវបានបកប្រែជាភាសាអេស្ប៉ាញ ហើយបោះពុម្ព រួចកូនសោត្រូវ

រូបថតជាច្រើននៅក្នុងអត្ថបទនេះបានទទួលសិទ្ធិអនុញ្ញាតពីការយកពីណេស្ទ័រ ខើរបើរឡូ ។ ខាងឆ្វេង ផ្នែកខាងលើ រូបថតដោយ
FILIPEFRAZAO/ISTOCK/THINKSTOCK ។ ផ្នែកខាងក្រោម រូបថតដោយ KAVRAM/ISTOCK/THINKSTOCK



*ពួកគ្រូបង្រៀន និង សិស្សថ្នាក់ទីបួនរបស់ពួកគេនៅឯសាលារៀនរបស់សាសនាចក្រ ខូឡេហ្គីយ៉ូ អេ ឌី ផមមើរ ប្រហែលជាឆ្នាំ 1966 ។*

បានងាកទៅរកប្រជាជាតិទាំងនេះ កាលអមដោយបព្វជិតភាពជាមួយនឹងអ្វីមួយសម្រាប់ឲ្យពួកគេអាន—គឺជាការសរសេរទាំងនោះដែលមាននូវការសន្យារបស់ព្រះ ការអធិស្ឋាន និង សេចក្ដីជំនឿនៃមនុស្សកាលពីបុរាណ និង ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធដើម្បីធ្វើការជាមួយពួកគេនៅក្នុងការស្ដារវង្សអ៊ីស្រាអែលឡើងវិញ » ។[2]

**សាសនាចក្រត្រូវបានស្ថាបនាឡើង**

ទោះជាមានការសាកល្បងពីមុនរបស់អែលឌើរប្រាត្តក្ដី ច្រើនជាង 100 ឆ្នាំក្រោយមក ទើបសាសនាចក្រត្រូវបានស្ថាបនាឡើងជាអចិន្ត្រៃនៅក្នុងប្រទេសស៊ីលី ។ នៅឆ្នាំ 1956 អែលឌើរ យ៉ូសែប ប៊េនលី និង វើល អល់រេឌ ត្រូវបានបញ្ជូនពីបេសកកម្មអាហ្សង់ទីនទៅផ្សាយដំណឹងល្អនៅក្នុងប្រទេសស៊ីលី ដែលឥឡូវរីករាយនឹងការទទួលយកខាងសាសនាច្រើនជាងមុន ។ នៅសាន់ត្យាហ្គោ ពួកអ្នកផ្សព្វផ្សាយសាសនាទាំងនេះបានមានការគាំទ្រពីគ្រួសារហ្វូធើរីងហ្គាំ ជាសមាជិកដែលផ្លាស់មកពីប្រទេសប៉ាណាម៉ា ហើយដែលសង្ឃឹមថានឹងមានពួកអ្នកផ្សព្វផ្សាយសាសនាមក ។

បុណ្យជ្រមុជទឹកដំបូងត្រូវបានធ្វើឡើងនៅប្រទេសស៊ីលីគឺនៅថ្ងៃទី 25 ខែ វិច្ឆិកា ឆ្នាំ 1956 ក្នុងអាងទឹកនៅក្លឹបមួយក្នុងទីក្រុងសាន់ត្យាហ្គោ ។ អែលឌើរអល់រេឌបានថ្លែងថា « យើងបានទៅក្លឹបនោះពីមុនព្រះអាទិត្យរះ ហើយធ្វើកម្មវិធីមួយដោយមានការអធិស្ឋាន និង ការនិយាយខ្លីៗ ។ ខ្ញុំបានចូលទៅក្នុងទឹកជាមួយនឹងបងប្រុស ហ្គាសៀ ។ ខ្ញុំបានជ្រមុជទឹកគាត់មុន រួចហើយមនុស្សប្រាំបីនាក់ផ្សេងទៀតបន្ទាប់ពីគាត់ ។ នេះជាពេលមួយដ៏ពិសេសបំផុត ។ អារម្មណ៍ដែលយើងទាំងគ្នាមាននៅពេលនោះគឺមិនអាចបំភ្លេចបានឡើយ ។ . . . សមាជិកទាំងនេះនឹងក្លាយជាពួកអ្នកត្រួសត្រាយផ្លូវនៃសាសនាចក្រក្នុងប្រទេសស៊ីលី ហើយខ្ញុំជឿថា ពួកគេគ្រប់គ្នានឹងបន្តស្មោះត្រង់រហូតដល់ស្លាប់ ៖គ្រួសារហ្គាសៀ គ្រួសារសាលដាញ៉ូស និង បងស្រី ឡាន់ហ្សារ៉ូតទី » ។[3]

**ការហៅថ្នាក់ដឹកនាំ**

ក្នុងខែ កុម្ភៈ ឆ្នាំ 1959ស្ពែនសើរ ដបុលយូ ឃីមបឹល ( 1895–1985 ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមកទស្សនកិច្ចនៅប្រទេសស៊ីលី ហើយបានសង្កត់ធ្ងន់ពីសេចក្ដីត្រូវការសម្រាប់អភិវឌ្ឍន៍ថ្នាក់ដឹកនាំក្នុងមូលដ្ឋាន ។ អ្នកដឹកនាំដំបូងម្នាក់ក្នុងមូលដ្ឋានគឺ ខាឡូស ស៊ីហ្វូអង់តេស ដែលជាទីប្រឹក្សារបស់ប្រធានបេសកកម្ម រ៉ូប៊ឺត ប៊ើរតុន ។ អែលឌើរ ហ៊ូលីអូហារ៉ាមីឡូ ដែលក្រោយមកក្លាយជាពួកចិតសិបនាក់ប្រចាំតំបន់ និង ជាប្រធានព្រះវិហារបរិសុទ្ធ បានលើកឡើងពីបទពិសោធន៍នេះថា ៖ « ខ្ញុំបានទទួលការចាប់អារម្មណ៍ដំបូង

របស់ខ្ញុំចំពោះបងប្រុស ស៊ីហ្វអង់តេស កាលខ្ញុំបានអញ្ជើញទៅចូលរួមការប្រជុំបញ្ជិតភាពមួយបន្ទាប់ពីបុណ្យជ្រមុជទឹករបស់ខ្ញុំ ។ កាលការប្រជុំនោះបានចាប់ផ្ដើម គាត់បានឡើងមកកាន់វេទិការ ហើយរឿងតែមួយគត់ដែលខ្ញុំបានឃើញគឺក្រចកដៃខ្មៅកខ្វក់របស់គាត់ ។ ខ្ញុំបានគិតថា ‹ តើបុរសម្នាក់អាចដឹកនាំការប្រជុំមួយរួម ជាមួយប្រធានបេសកកម្មចូលរួមបានយ៉ាងដូចម្ដេចទៅ បើដៃគាត់កខ្វក់យ៉ាងនេះ ?› រហូតដល់គាត់បានចាប់ផ្ដើមនិយាយ ទើបខ្ញុំបានភ្លេចនូវអ្វីៗគ្រប់បែបយ៉ាង កាលខ្ញុំបានទទួលអារម្មណ៍នូវវិញ្ញាណរបស់គាត់ ។ ជាមួយនឹងពាក្យសម្ដីដ៏សាមញ្ញ គាត់បានបង្រៀនពីមនោភាពដ៏អស្ចារ្យដល់យើង ។ គាត់គឺជាជាងម៉ាស៊ីនធុនធ្ងន់ម្នាក់ ហើយនៅថ្ងៃសៅរ៍គាត់បានធ្វើការរហូតដល់យប់ រួចទើបលាងសម្អាតដៃគាត់ ប៉ុន្តែដោយមានធនធានបន្តិចបន្តួចនៅឯហាងរបស់គាត់ គាត់មិនអាចលាងសម្អាតខ្លាញ់ទាំងនោះឲ្យជ្រះបានឡើយ ។ នៅពេលនោះទើបខ្ញុំបានរៀនកុំឲ្យវិនិច្ឆ័យអ្នកឯទៀតតាមអាការៈខាងក្រៅ ប៉ុន្តែឲ្យតម្លៃដល់ពួកគេនូវអ្វីដែលពួកគេមានវិញ » ។[4]



*1851 ៖ អែលឌើរប៉ាលី ភី ប្រាត្ត ធ្វើដំណើរទៅទីក្រុងវ៉ាល់ប៉ារ៉ៃសូ ប៉ុន្តែមិនអាចស្ថាបនាសាសនាចក្រនៅប្រទេសស៊ីលីបានឡើយ*

*►1926 ៖ អែលឌើរ មេលវិន ជេ បាឡឺដនៅក្នុងប្រជុំថ្លែងទីបន្ទាល់មួយ បានព្យាករពីការរីកចម្រើន និង កម្លាំង នាពេលអនាគតនៃសាសនាចក្រក្នុងអាមេរិកខាងត្បូង*



*►1956 ៖ ពួកអ្នកផ្សព្វផ្សាយសាសនាដំបូង យ៉ូសែប ស៊ី ប៊េនលី និង វើល អិម អល់ឌឺឌ មក ដល់សាន់ត្យាហ្គោ បុណ្យជ្រមុជទឹកដំបូងបានកើតឡើង*



## ការពង្រីងជំនាន់កំពុងពេញវ័យ

អំឡុងទសវត្សរ៍ 1960 និង 1970 សាសនាចក្រនៅប្រទេសស៊ីលីត្រូវបានពង្រឹងមិនត្រឹមតែតាមរយៈការកើនឡើងនៃថ្នាក់ដឹកនាំក្នុងមូលដ្ឋានដែលមានបទពិសោធន៍ប៉ុណ្ណោះទេ ប៉ុន្តែក៏តាមរយៈសំណង់ថ្មី និង កម្មវិធីអប់រំផងដែរ ។ សំណង់ទាំងនេះរួមបញ្ចូលទាំងការសង់សាលាប្រជុំ រួមជាមួយការស្ថាបនាសាលាសាសនាចក្រ ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានផងដែរ ។

ក្នុងខែ មីនា ឆ្នាំ 1964 សាលាបឋមសិក្សាពីរកន្លែងដែលគ្រប់គ្រងដោយសាសនាចក្រត្រូវបានបង្កើតឡើងនៅប្រទេសស៊ីលី ។ នៅទីបំផុត សាលារៀនមួយចំនួនត្រូវបានបើក ហើយមានសិស្សចុះឈ្មោះចូលរៀនច្រើនជាង 2,600 នាក់ ។ គិតត្រឹមចុងទសវត្សរ៍ 1970 និង ដើមទសវត្សរ៍ 1980 ដោយសាលារៀនរបស់រដ្ឋមានកាន់តែច្រើន នោះសាសនាចក្របានប្រកាសបិទទ្វារសាលារបស់ខ្លួននៅប្រទេសស៊ីលី ។

អែលឌើរ អេឌុអាដូ អា ឡាម៉ាទីណេ ជាអតីតពួកចិតសិបនាក់ប្រចាំតំបន់ និង អ្នកប្រឹក្សាប្រវត្តិសាស្ត្រសាសនាចក្រនៅប្រទេសស៊ីលីបច្ចុប្បន្នបានថ្លែង អំពីកម្មវិធីអប់រំនោះថា « សាលារៀននៅប្រទេសស៊ីលីគឺជាឥទ្ធិពលមួយដ៏ធំនៅក្នុងការសិក្សា និង ការបំពាក់បំប៉នខាងវិញ្ញាណដល់យុវវ័យរាប់ពាន់នាក់ ហើយវាបានចូលរួមចំណែកដើម្បីរៀបចំថ្នាក់ដឹកនាំ និងពួកអ្នកផ្សព្វផ្សាយសាសនានៅឆ្នាំបន្ទាប់មកទៀត » ។[5]

កម្មវិធីថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានបានចាប់ផ្ដើមក្នុងប្រទេសស៊ីលីក្នុងឆ្នាំ 1972 ។ ដំបូង សិស្សបានចូលរួមនៅក្នុងកម្មវិធីសិក្សានៅផ្ទះជាមួយថ្នាក់ប្រចាំសប្ដាហ៍ ។ ក្រោយមក បន្តិចម្ដងៗថ្នាក់ជាច្រើនត្រូវបានរៀបចំឡើង ។ កម្មវិធីទាំងនេះបានប្រទានពរដល់យុវវ័យក្នុងប្រទេសនេះ ហើយបានជួយពួកគេរៀបចំខ្លួនបម្រើជាពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ។ អែលឌើរ អេឌ្វ័រដូ អាយ៉ាឡា ជាអតីតសមាជិកនៃពួកចិតសិបនាក់ គឺជាគ្រូបង្រៀនម្នាក់ក្នុងចំណោមគ្រូបង្រៀនថ្នាក់សិក្ខាសាលាដំបូងគេ ហើយក្រោយមកធ្វើការឲ្យប្រពន្ធ័

*ថ្នាក់វិទ្យាស្ថានសាសនាក្នុងតេមុកូ គឺជាថ្នាក់វិទ្យាស្ថានមួយក្នុងចំណោមថ្នាក់វិទ្យាស្ថានទាំង 50 កន្លែងនៅប្រទេសស៊ីលី ។*




ខាងឆ្វេង ៖ រូបថតដោយ ផ្ល័រ៉ា ឌេឃើរ ដូណាល់សុន ។ រូបថតរបស់អែលឌើរ មេលវិន ជេ បាឡឺដ ដោយ អេស ដបុលយូ អេយើរ © IRI



*ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី ថ្លែងទៅកាន់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅស៊ីលីចំនួន 48,000 នាក់ក្នុងឆ្នាំ 1996 នៅឯសន្និសីទមួយក្នុងសាន់ត្យាហ្គោ ។*

អប់រំសាសនាចក្រនៅប្រទេសស៊ីលី ។ លោកបានថ្លែងថា « ព្រះអម្ចាស់បានជ្រើសយុវវ័យដែលនៅទីនោះនៅពេលនោះ ហើយពួកគេជាច្រើនគឺជាពួកអ្នកផ្សព្វផ្សាយសាសនាដែលបានត្រឡប់មកវិញ និងជាថ្នាក់ដឹកនាំដ៏ឆ្នើមដែលមានក្រុមគ្រួសារល្អ ។ . . . ចំពោះខ្ញុំ ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនាគឺជាមធ្យោបាយនៃសេចក្ដីសង្គ្រោះក្នុងគ្រានៃការលំបាកយ៉ាងច្រើននៅក្នុងប្រទេសនេះ ហើយខ្ញុំមានអំណរគុណដែលខ្ញុំត្រូវបានហៅឲ្យធ្វើការជាមួយប្រព័ន្ធអប់រំ » ។[6]

## ស្តេកទីមួយ

នៅថ្ងៃទី 19 ខែ វិច្ឆិកា ឆ្នាំ 1972 អែលឌើរ ហ្គរដុន ប៊ី ហ៊ិងគ្លី ( 1910–2008 ) នៅពេលនោះស្ថិតនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានរៀបចំស្តេកស៊ីលីសាន់ត្យាហ្គោ ដោយមាន ខាឡូស ស៊ីហ្វូអង់តេស ជាប្រធាន ។

ការរៀបចំសម្រាប់ស្តេកបានបង្ហាញពីលក្ខណៈសម្បត្តិរបស់ពួកបរិសុទ្ធនៅប្រទេសស៊ីលី និង ឆន្ទៈរបស់ពួកគេដើម្បីធ្វើតាមពួកព្យាការី ។ អែលឌើរ ហ៊ិងគ្លី បានមកដល់ប្រទេសស៊ីលីពីរបីខែមុនដើម្បីរៀបចំស្តេកនោះ ។ ប៉ុន្តែបន្ទាប់ពីការធ្វើការសម្ភាសន៍មក វាត្រូវបានផ្អាក ។ នៅពេលនោះ មានមនុស្សជាច្រើនកំពុងមានបញ្ហាខាងហិរញ្ញវត្ថុ ហើយសមាជិកមួយចំនួនកំពុងជួបប្រទះនឹងការលំបាកនៅក្នុងការរស់នៅតាមច្បាប់ដង្វាយមួយភាគក្នុងដប់ ។

អែលឌើរ ហ៊ិងគ្លី បានពន្យល់ថា « ប្រាំមួយខែក្រោយមកខ្ញុំបានត្រឡប់មកវិញ ហើយកាលខ្ញុំធ្វើការសម្ភាស ខ្ញុំបានឃើញពីការកើនឡើងនៃសេចក្ដីជំនឿ ។ ជាថ្មីម្ដងទៀត ពួកគេបានដើរដោយស្មោះត្រង់ចំពោះព្រះអម្ចាស់ ស្តេកត្រូវបានរៀបចំឡើង ហើយចាប់តាំងពីពេលនោះមក ពួកគេបានរីកចម្រើន ហើយបរិបូរណ៍ » ។[7]

## ពួកអ្នកត្រួសត្រាយផ្លូវនៅតាមព្រំប្រទល់

សព្វថ្ងៃនេះមានស្តេកពីរនៅទីក្រុង អារីកា ជាទីក្រុងនៅភាគខាងជើងបំផុតក្នុងប្រទេសឈៀលី ។ ដំណើររឿងរបស់គ្លេឌីស និង ហ្វ៊ន ប៊ើណារីដេស្ស ជាពួកអ្នកប្រែចិត្តជឿដំបូងនៅអារីកា បង្ហាញពីវិញ្ញាណនៃអ្នកត្រួសត្រាយផ្លូវ និងឥទ្ធិពលដ៏ទេវភាពនៅក្នុងការស្ថាបនាសាសនាចក្រនៅក្នុងប្រទេសស៊ីលី ។

បងប្រុស ប៊ើណារីដេស្ស ត្រូវបានណែនាំឲ្យស្គាល់សាសនាចក្រក្នុងឆ្នាំ 1961 កាលខ្យល់បានបក់ក្រដាសមួយចំនួនទៅចំគាត់ ៖គាត់បានថ្លែងថា « ក្រដាសទាំងនេះជាទំព័រនៃទស្សនាវដ្ដី *Reader's Digest Selections* ដោយមានអត្ថបទដ៏ទូលំទូលាយមួយស្ដីពី « ពួកមរមន » ដោយរៀបរាប់ពីជីវិត និង ជំនឿរបស់ពួកគេ » ។

ក្រោយមកមិនយូរប៉ុន្មាន គាត់បានធ្លាក់ខ្លួនឈឺជាទម្ងន់ដែលតម្រូវឲ្យគាត់មានការព្យាបាលផ្នែកវេជ្ជសាស្ត្រនៅសាន់ត្យាហ្គោ ។ គាត់បានថ្លែងថា « កាលនៅទីនោះ ខ្ញុំបានទៅលេងបងស្រីខ្ញុំ ហើយបានដឹងថា គាត់បានក្លាយជាសមាជិកសាសនាចក្រ » ។ « នាងបានអញ្ជើញខ្ញុំទៅសន្និសីទពិសេសមួយ ។ កាលខ្ញុំបានស្ដាប់ការអធិស្ឋានបើក ហើយគិតពីពាក្យទាំងនោះ ខ្ញុំមានសេចក្ដីអំណរជាខ្លាំងសព្វសារពាង្គកាយខ្ញុំ ហើយស្គាល់ពីព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ នៅចុងបញ្ចប់នៃសន្និសីទនោះ ពួកអ្នកផ្សព្វផ្សាយសាសនាបាននាំខ្ញុំឡើងចាប់ដៃនឹងអ្នកមានសិទ្ធិអំណាចដែលមកទស្សនកិច្ចគឺ អែលឌើរ អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ( 1899–1994 ) នៅពេលនោះស្ថិតនៅក្នុងកូរ៉ុមនៃពួកដប់ពីរនាក់ » ។

បងប្រុស ប៉េណាវីដេស្ស បានត្រឡប់ទៅអារីការិញ ហើយបានចែកបទពិសោធន៍នេះនឹងមិត្តស្រីគាត់ឈ្មោះ គ្លេឌីស អាហ្គីឡា ដែលឥឡូវនេះជាភរិយារបស់គាត់ ។ ពីរបីថ្ងៃក្រោយមក គ្លេឌីស បានឃើញពួកអ្នកផ្សព្វផ្សាយសាសនាពីរនាក់ដើរកាត់តាមផ្ទះនាង ។ បងប្រុសប៉េណាវីដេស្សបានថ្លែងថា « យើងបានរូតរះដើររកពួកគេ » ។ « នៅថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 1961 យើងបានជ្រមុជទឹក រួមទាំងគ្រួសាររបស់ភរិយាខ្ញុំដែរ ។ សព្វថ្ងៃនេះ យើងមានកូន និងចៅនៅក្នុងសាសនាចក្រ ។ ខ្ញុំមានអំណរគុណជាខ្លាំងចំពោះព្រះអម្ចាស់ចំពោះខ្យល់នោះដែលបានបក់នាំយកព័ត៌មានអំពីសាសនាចក្រចូលមកក្នុងដៃខ្ញុំ » ។[8]

## គ្រានៃការសាកល្បង

ក្នុងការបោះឆ្នោតនាឆ្នាំ 1970 វេជ្ជ. សាលវ៉ាឌ័រ អាឡែនឌេ បានក្លាយជាប្រធានាធិបតី ហើយបានបង្កើតជារដ្ឋាភិបាលម៉ាក្សនិយមមួយ ។ សមាជិកសាសនាចក្របានរងការលំបាកដោយសារការខ្វះអាហារ និង ថ្នាំពេទ្យ មានការឃោឃើជាញឹកញាប់ដល់ពួកអ្នកផ្សព្វផ្សាយសាសនា និង មតិអវិជ្ជមានពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយ ។

ក្នុងឆ្នាំ 1973 វិបត្តិផ្នែកហិរញ្ញវត្ថុ និង សង្គមបានបង្កើតជារដ្ឋប្រហារខាងយោធា និង របបផ្ដាច់ការដែលបានបញ្ចប់រហូតដល់ឆ្នាំ 1990 ។ ទោះជាសព្វថ្ងៃ ប្រទេសស៊ីលីជាប្រទេសប្រជាធិបតេយ្យក្ដី ក៏រយៈពេលពីរទសវត្សរ៍នោះគឺជាពេលដ៏លំបាកមួយសម្រាប់សមាជិកដែរ ។ ក្រុមដែលប្រឆាំងនឹងរបបផ្ដាច់ការខាងយោធានោះបានវាយប្រហារមកលើសាលាប្រជុំ និង សមាជិកដោយសារពួកគេគិតថា សាសនាចក្រតំណាងផលប្រយោជន៍របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ។ អែលឌើរ អាយ៉ាឡា ជាប្រធានស្ដេកនៅពេលនោះ បានថ្លែងថា « យើងបានជួបនឹងពួកអ្នកមានសិទ្ធិអំណាចទូទៅ ហើយពួកលោកបានប្រាប់យើងថា ‹ សូមអនុវត្តការប្រើប្រាស់ប្រាជ្ញា អធិស្ឋានឲ្យច្រើន ធ្វើរឿងត្រឹមត្រូវ ដើម្បីសមាជិកអាចមានរបៀបរៀបរយនៅក្នុងក្រុមជំនុំ ›» ។[9]

ទោះជាយ៉ាងណាក្ដី ការលំបាកខាងហិរញ្ញវត្ថុរបស់ប្រទេសនេះ និង បដិបក្ខភាពខាងនយោបាយបានបំបែកសង្គមជនជាតិស៊ីលីនៅដើមទសវត្សរ៍ 1980 សាសនាចក្របានរីកចម្រើនយ៉ាងឆាប់រហ័ស ។ នៅចន្លោះឆ្នាំ 1970 និង 1985 ចំនួនសមាជិកក្នុងប្រទេសស៊ីលីបានកើនឡើងពី 15,728 ទៅ 169,361 នាក់ ។

## ព្រះវិហារបរិសុទ្ធសាន់ត្យាហ្គោ

ក្នុងឆ្នាំ 1980 ពួកបរិសុទ្ធត្រូវបានប្រទានពរឲ្យជាមួយនឹងការប្រកាសថា ព្រះវិហារបរិសុទ្ធមួយនឹងត្រូវសាងសង់នៅសាន់ត្យាហ្គោ ប្រទេស ស៊ីលី ។

*1957 ៖ សាសនាចក្រត្រូវបានរៀបចំជាផ្លូវការនៅប្រទេសស៊ីលី*

*1960 ៖ ការរញ្ជួយដីដ៏ធំមួយបានកើតឡើងនៅក្រុងសេពស៊ីយ៉ុង សាសនាចក្របានបញ្ជូនជំនួយផ្នែកមនុស្សធម៌*

*►1961 ៖ បេសកកម្មស៊ីលីត្រូវបានរៀបចំដោយអាសែល ឌេលប៊ឺត ផមមើរ ជាប្រធាន*



*1962 ៖ ពិធីសម្ពោធការសាងសង់សម្រាប់សាលាប្រជុំអិល.ឌី.អែស. ដំបូងបានធ្វើឡើងនៅសាន់ត្យាហ្គោ*



« កាលពីក្មេងអាយុ 12 ឆ្នាំ ខ្ញុំបានចាប់អារម្មណ៍ ហើយភ្លាមនោះបានស្គាល់សារលិខិតនៃដំណឹងល្អថាជាការពិត ។ ឥឡូវនេះរយៈពេលសែសិបប្រាំមួយឆ្នាំបានកន្លងផុតទៅជាពេលដែលខ្ញុំបានទទួលពរជ័យ ខ្ញុំសូមអរគុណចំពោះកិច្ចការដែលមានការលះបង់ពីសំណាក់ថ្នាក់ដឹកនាំជាច្រើនដែលបានធ្វើអស់ពីលទ្ធភាពរបស់ពួកគាត់ ។ ដោយចាប់ផ្ដើមស្គាល់ ហើយចែកចាយជាមួយនឹងជំនាន់ថ្មី ខ្ញុំមានអារម្មណ៍រីករាយ ហើយទុកចិត្តថា ព្រះអម្ចាស់នឹងបន្តប្រទានពរដល់ប្រទេសនេះ ដូចជាការនិមិត្តដែលពួកព្យាការីធ្លាប់មានទាក់ទងនឹងប្រទេសស៊ីលី » ។[12]

**អែលឌើរ ហ្វរហេ អេហ្វ ស៊ែប្បាលូស សមាជិកនៃពួកចិតសិបនាក់មកពីប្រទេសស៊ីលី**







នៅពេលប្រធាន ស្ពែនសើរ ដបុលយូ឵ ឃីមបឹលបានឧទ្ទិសឆ្លងទីលានព្រះវិហារបរិសុទ្ធនោះ លោកមានសុខភាពខ្សោយខ្លាំងណាស់ ប៉ុន្តែវត្តមានរបស់លោកនៅទីនោះបានបង្ហាញនូវសេចក្តីស្រឡាញ់របស់លោកចំពោះពួកបរិសុទ្ធនៃអាមេរិកខាងត្បូងដោយលោកបានធ្វើការជាមួយពួកគេចាប់តាំងពីឆ្នាំ 1959 មកម្ល៉េះ ។ បងស្រី អាឌ្រីយ៉ាណា ហ្គែរ៉ា ឌេ សេពុលវ៉េដា ដែលបានបកប្រែសម្រាប់ស៊ិស្ទើរ ឃីមបឹល នៅឯព្រឹត្តិការណ៍ បានថ្លែងថា « កាលខ្ញុំបានឃើញព្យាការី ជាមនុស្សតូចមានទឹកមុខដ៏រីករាយ ខ្ញុំបានចាប់ផ្តើមយំ ហើយរកពាក្យនិយាយទៅកាន់លោកមិនរួចឡើយ ។ វាជាលើកដំបូងហើយដែលខ្ញុំបាននៅក្បែរព្យាការីដែលកំពុងរស់នៅ ។ ដោយមើលឃើញអ្នកនាំពាក្យរបស់ព្រះអម្ចាស់នៅលើផែនដីនេះ និង នៅក្នុងប្រទេសរបស់ខ្ញុំ វាគឺជារឿងអស្ចារ្យណាស់ » ។[10]

ព្រះវិហារបរិសុទ្ធត្រូវបានឧទ្ទិសឆ្លងក្នុងឆ្នាំ 1983 ដោយក្លាយជាព្រះវិហារទីពីរក្នុងអាមេរិកខាងត្បូង និង ជាទីមួយនៅក្នុងប្រទេសដែលនិយាយភាសាអេស្ប៉ាញ ។

*1972 ៖ ស្តេកដំបូងនៅប្រទេសស៊ីលីត្រូវបានរៀបចំនៅសាន់ត្យាហ្គោ*

*1977 ៖ នៅសាន់ត្យាហ្គោ សន្និសីទប្រចាំតំបន់ដំបូងត្រូវបានធ្វើឡើងដោយមានវត្តមានរបស់ប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឹល និង ពួកអ្នកមានសិទ្ធិអំណាចទូទៅផ្សេងទៀត*



*◄1981 ៖ មជ្ឈមណ្ឌលអ្នកផ្សព្វផ្សាយសាសនាមួយត្រូវបានស្ថាបនាឡើងនៅសាន់ត្យាហ្គោ*



*◄1983 ៖ ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី បានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធស៊ីលីសាន់ត្យាហ្គោ*







## អែលឌើរជែហ្វ្រី អ័រ ហូឡិននៅក្នុងប្រទេសស៊ីលី

ក្នុងខែ សីហា ឆ្នាំ 2002 គណៈប្រធានទីមួយបានចាត់សមាជិកពីររូបនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដើម្បីធ្វើជាអធិបតីលើតំបន់សាសនាចក្រចំនួនពីរ ៖អែលឌើរ ដាល្លិន អេក អូក ត្រូវបានចាត់ទៅប្រទេសហ្វីលីពីន ហើយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន មកប្រទេសស៊ីលី ។ ការបម្រើ និង ឥទ្ធិពលរបស់អែលឌើរ ហូឡិន កាលនៅក្នុងប្រទេសស៊ីលីគឺមិនអាចវាស់វែងបានឡើយ ហើយឥទ្ធពលរបស់វានឹងបន្តនៅជាច្រើនជំនាន់ទៅមុខទៀត ។

ការគូសបញ្ជាក់ដំបូងរបស់អែលឌើរ ហូឡិន គឺផ្តល់គំរូនៃការដឹកនាំតាមរបៀបរបស់ព្រះអម្ចាស់ ។ លោកបានជួយបំពាក់បំប៉នថ្នាក់ដឹកនាំថ្មី និងគ្រប់គ្រងការរៀបចំឡើងវិញ ការបញ្ឈប់ និង ការដាក់បញ្ចូលនៃវួដរាប់រយ និង ស្តេកជាច្រើន ។ ការរៀបចំឡើងវិញ និង ការបំពាក់បំប៉ននេះគឺមានភាពចាំបាច់ដោយសារការរីកចម្រើនយ៉ាងឆាប់រហ័សរបស់សាសនាចក្រនៅក្នុងប្រទេសនេះ ។ ភាពជាអ្នកដឹកនាំរបស់លោកបានជួយពង្រឹងដល់អង្គភាពទាំងឡាយ ហើយរៀបចំសាសនាចក្រនៅក្នុងប្រទេសស៊ីលីសម្រាប់ពេលអនាគត ។

លើសពីនេះទៅទៀត អែលឌើរហូឡង់បានធ្វើការទំនាក់ទំនងដ៏សំខាន់មួយចំនួននៅក្នុងប្រទេសស៊ីលី ។ អែលឌើរ ខាល ប៊ី ប្រាត្ត នៃពួកចិតសិបនាក់ ជាទីប្រឹក្សានៅក្នុងគណៈប្រធានតំបន់នោះ បានរៀបរាប់ពីទំនាក់ទំនងដ៏



*ដោយឆ្លើយតបនឹងការរញ្ជួយដីនៅឆ្នាំ 2010 យុវវ័យ និង ពួកមជ្ឈិមវ័យស៊ីលី ដៃជំនួយមរមន បានរៀបចំឧបករណ៍អនាម័យរួមគ្នា ។*

**ការរីកចម្រើនរបស់សាសនាចក្រនៅប្រទេសឈៀលី**

| ឆ្នាំ | សមាជិក |
|---|---|
| 1960 | 614 |
| 1970 | 15,728 |
| 1980 | 87,960 |
| 1990 | 297,936 |
| 2000 | 509,592 |
| 2010 | 563,689 |
| 2013 | 583,359 |



**សាសនាចក្រនៅក្នុងប្រទេសស៊ីលី**

វួដ និង សាខា ៖ 622

ស្តេក ៖ 74

បេសកកម្ម ៖ 9

ព្រះវិហារបរិសុទ្ធ ៖1 ( ហើយមួយទៀតទើបបានប្រកាស )

មជ្ឈមណ្ឌលពង្សប្រវត្តិ ៖ 99



*◄1990 ៖ អែលឌើរ អេឌូអាដូ អាយ៉ាឡា មកពីប្រទេសស៊ីលី ត្រូវបានហៅនៅក្នុងកូរ៉ុមទីពីរនៃពួកចិតសិបនាក់*



*◄2002 ៖ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ត្រូវបានហៅជាប្រធានតំបន់ស៊ីលី*

*►2008 ៖ អែលឌើរ ហ្វួរហេ អេហ្វ ស្សៃបាលូស មកពីប្រទេសស៊ីលី ត្រូវបានហៅនៅក្នុងកូរ៉ុមទីមួយនៃពួកចិតសិបនាក់*



*2009 ៖ ព្រះវិហារបរិសុទ្ធស៊ីលីកុងសេពស៊ីយ៉ុងត្រូវបានប្រកាស*

សំខាន់មួយចំនួនថា ៖« អែលឌើរ ហូឡិន បានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធមួយជាមួយនឹង រីកាដូ ឡាហ្គូស [ ប្រធានាធិបតីស៊ីលី ] និងភរិយារបស់លោក ។ ពួកលោកបានបង្កើតគម្រោងជំនួយផ្នែកមនុស្សធម៌មួយចំនួន ។ អែលឌើរ ហូឡិន បានស្គាល់សាវក នុនស្យ៉ូ [ ជាមន្ត្រីកាតូលីកជាន់ខ្ពស់ម្នាក់ ] និងបុគ្គលសំខាន់ៗដទៃទៀតក្នុងប្រទេសស៊ីលី » ។[11]

## ទំនុកចិត្តលើអនាគត

កិច្ចខិតខំរបស់អែលឌើរ ប៉ាលី ភី ប្រាត្ត និង ជែហ្វ្រី អ័រ ហូឡិន ការលះបង់នៃពួកអ្នកផ្សព្វផ្សាយសាសនាដំបូងដែលមកដល់សាន់ត្យាហ្គោ ការស្មោះត្រង់របស់ថ្នាក់ដឹកនាំដូចជា ខាឡូស ស៊ីហ្វូអង់តេសនិងអ្នកត្រួសត្រាយផ្លូវពីមុនដទៃទៀតក្នុងប្រទេសស៊ីលី រួមជាមួយនឹងសេចក្តីជំនឿ និង ការលះបង់របស់មនុស្សរាប់រយរាប់ពាន់នាក់ដែលបានចូលរួមនឹងសាសនាចក្រច្រើនជាងកន្លះសតវត្សរ៍មកនេះបានស្ថាបនានូវគ្រឹះមួយដ៏រឹងមាំសម្រាប់សាសនាចក្រក្នុងប្រទេសស៊ីលី ។ សព្វថ្ងៃនេះ ប្រទេសនេះមានព្រះវិហារមួយ ( មួយទៀតទើបបានប្រកាស ) មជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាមួយ បេសកកម្ម 9 និង ស្តេក 74 ។ អនាគតមិនមានកំណត់នៅក្នុងកិច្ចការខាងវិញ្ញាណនៃការអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ ។ ■


**កំណត់ចំណាំ**

1. សូមមើល*Deseret News 2013 Church Almanac* ទំព័រ 454 ។
2. *Autobiography of Parley P. Pratt* និពន្ធដោយ Scot Facer Proctor និង Maurine Jensen Proctor ( ឆ្នាំ 2000 ) ទំព័រ 504 ។
3. ផើល អល់វេឌ នៅក្នុង ណេស្ត័រ ឃើរបេិទ្បូ *LDS in South America: Chile Sur* វ៉ុល 1 ( ឆ្នាំ 2008 ) ទំព័រ6 ។
4. ហ៊្វូលីអូ ហារ៉ាមីលទ្បូ នៅក្នុង ណេស្ត័រ ឃើរបេ ទ្បូ*LDS in South America: Chile* វ៉ុល 1 ( ឆ្នាំ 2006 ) ទំព័រ4–5 ។
5. អេឌ្វ័រដូ អាគ្រាន ទ្បាម៉ាទីណេ អាហ្គីទ្បា សេចក្តីសង្ខេបពីប្រវត្តិសាស្ត្របានផ្តល់ទៅអ្នកនិពន្ធនៅខែ វិច្ឆិកា ឆ្នាំ 2013 ។
6. អេឌ្វ័រអាដូ អាយ៉ាទ្បា នៅក្នុង ណេស្ត័រ ឃើរបេិទ្បូ *LDS in South America: Chile* វ៉ុល 1 ( ឆ្នាំ 2006 ) ទំព័រ44, 45 ។
7. ហ្គរដុន ប៊ី ហ៊ិងគ្លី នៅក្នុង រ៉ូដុលហ្វូ អាសេវ៉េដូ អា *Alturas Sagradas: Templo de Santiago de Chile* ទំព័រ 100 ។
8. ណេស្ត័រ ឃើរបេិទ្បូ « Blossoming in the Desert »*Church News* ថ្ងៃទី 9 ខែ វិច្ឆិកា ឆ្នាំ 1996 ទំព័រ 8–9 ។
9. អេឌ្វ័រអាដូ អាយ៉ាទ្បា នៅក្នុង ណេស្ត័រ ឃើរបេិទ្បូ *LDS in South America: Chile* វ៉ុល 1 ( ឆ្នាំ 2006 ) ទំព័រ 33 ។
10. អាឌ្រីយ៉ាណា ហ្គែរ៉ា ឌេ សេពុលវ៉េដា នៅក្នុង ណេស្ត័រ ឃើរបេិទ្បូ *LDS in South America: Chile* ( ឆ្នាំ 2006 ) ទំព័រ 16 ។
11. ខាល ប៊ី ប្រាត្ត នៅក្នុងណេស្ត័រ ឃើរបេិទ្បូ *Colombia:* investigación histórica វ៉ុល 1 ( ឆ្នាំ 2010 ) ទំព័រ16 ។
12. ហ្វូរហេ អេហ្វស្សៃបាលូស នៅក្នុងសំបុត្រមួយផ្ញើទៅអ្នកនិពន្ធនៅខែ មករា ឆ្នាំ 2014 ។


ខាងស្តាំ ៖ ក្រឡាចក្រដោយ ម៉ាសេឡូ ស៊ីលវ៉ា/ISTOCK/THINKSTOCK



**ដោយ ខារ៉ុល អេហ្វ ម៉ាកខន់ឃី**
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានយុវនារីទូទៅ

# ភាពក្លាហានដើម្បីជ្រើសយកភាពថ្លៃថ្នូរ



*តើយើងអាចបង្រៀនអ្វីខ្លះដល់កូនប្រុសស្រីយើង ដើម្បីជួយពួកគេឲ្យមានចិត្តក្លាហានជ្រើសយក ភាពថ្លៃថ្នូរ នៅក្នុងពិភពលោកមួយដែលសើច ចំអកពួកគេ សម្រាប់ជម្រើសដ៏គុណធម៌របស់ ពួកគេនោះ ?*



ហេតុអ្វីបានជាភាពថ្លៃថ្នូរមានសារៈសំខាន់ ? ហេតុអ្វីបានជាសំពត់ ក-អាវ ឬអាវយឺតសំខាន់ចំពោះព្រះអម្ចាស់ ? ខ្ញុំមានកូនស្រីប្រាំនាក់ និង កូនប្រុសពីរនាក់ ហើយដូចជាអ្នកអាចគិតឃើញហើយថា ប្រធានបទនៃភាពថ្លៃថ្នូរត្រូវបានលើកឡើងនៅក្នុងផ្ទះរបស់ខ្ញុំម្ដងម្កាល ។ ប៉ុន្តែអស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំបានដឹងថា ភាពថ្លៃថ្នូរត្រូវបានបង្រៀនយ៉ាងល្អបំផុត តាមរយៈការបង្រៀនគោលលទ្ធិ និង ការធ្វើជាគំរូវិជ្ជមានមួយ ។ គោលលទ្ធិនោះនឹងជួយកូនចៅយើង ឲ្យយល់ពីសារៈសំខាន់នៃភាពថ្លៃថ្នូរ ហើយគំរូរបស់យើងនឹងបង្ហាញពីពរជ័យនៃភាពថ្លៃថ្នូរតាមរបៀបដ៏រីករាយ ។

**តើភាពថ្លៃថ្នូរគឺជាអ្វីទៅ ?**

ភាពថ្លៃថ្នូរគឺជាគោលការណ៍មួយ ដែលព្រះបានប្រទានមក ដែលអាចជួយយើងឲ្យរៀនប្រើរូបកាយយើង ដោយភាពសមរម្យនៅក្នុងជីវិតរមែងស្លាប់នេះ ។ និយមន័យនៃភាពថ្លៃថ្នូរនៅក្នុង*ពិតចំពោះសេចក្ដីជំនឿ*គឺជា « អាកប្បកិរិយានៃការបន្ទាបខ្លួន និង ថ្លៃថ្នូរក្នុងការស្លៀកពាក់ ការតុបតែងខ្លួន ពាក្យសម្ដី និង ចរិយា » ។[1] ភាពថ្លៃថ្នូរពុំជារឿងឥតប្រយោជន៍ ឬ អួតអាងនោះទេ ។ មនុស្សថ្លៃថ្នូរមិនប្រើរូបកាយពួកគេ ឬ ឥរិយាបថរបស់ពួកគេដើម្បីស្វែងរកការអនុមតិពីពិភពលោកនេះ ឬទាញយកចំណាប់អារម្មណ៍ សម្រាប់ជោគជ័យដ៏ពិត ឬសន្ទត់របស់ពួកគេ ឬអាកប្បកិរិយាដែលពួកគេចង់បានឡើយ ។

សូមចងចាំថា គោលការណ៍នៃភាពថ្លៃថ្នូរដែលបានចែកចាយនៅទីនេះ អនុវត្តទាំងបុរស និង ស្ត្រី កូនប្រុស និង កូនស្រី សូមចងចាំថា សូម្បីតែនៅពេលយើងបង្រៀន ហើយធ្វើជាគំរូពីភាពថ្លៃថ្នូរក្ដី ក៏យើងមិនត្រូវថ្កោលទោសដល់ជនដែលជ្រើសស្លៀកពាក់សំពត់ខ្លី ឬ « មានសក់ច្រើនពណ៌ និង ពាក់ចិញ្ចៀនច្រើន » ឡើយ ។[2] ជានិច្ចកាល យើងធ្វើជាគំរូពីសេចក្ដីមេត្តាករុណា និង សេចក្ដីស្រលាញ់ដូចព្រះគ្រីស្ទដល់បុគ្គលនោះ កាលយើងបន្ដស្មោះត្រង់ចំពោះបទដ្ឋានដែលព្រះអម្ចាស់ដាក់ឲ្យយើង ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ការជ្រើសរើយដែលយើងធ្វើ ដែលមានទ្រង់ទ្រាយ ឬភាពថ្លៃថ្នូរ បង្ហាញនូវសារលិខិតដ៏អស្ចារ្យមួយថា យើងយល់ពីអត្តសញ្ញាណរបស់យើងក្នុងនាមជាបុត្រា និង បុត្រីនៃព្រះ ហើយថាយើងបានជ្រើសឈរនៅក្នុងទីបរិសុទ្ធ ។

ខ្ញុំចូលចិត្តបទគម្ពីរនេះថា ៖ « តើអ្នករាល់គ្នាមិនដឹងទេឬអីថាខ្លួនអ្នករាល់គ្នាជាព្រះវិហារនៃព្រះ ហើយថាព្រះវិញ្ញាណនៃព្រះទ្រង់សណ្ឋិតក្នុងអ្នករាល់គ្នា ? . . . ព្រះវិហារនៃព្រះជាវត្ថុដ៏បរិសុទ្ធ គឺជាខ្លួនអ្នករាល់គ្នានេះឯង » ( កូរិនថូសទី 1 3:16–17 ) ។ រូបកាយយើងគឺជាព្រះវិហារបរិសុទ្ធនៃវិញ្ញាណយើង ដោយសារតែព្រះវិហារបរិសុទ្ធខាងរូបកាយនេះហើយ ទើបយើងអញ្ជើញភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ។ ខ្ញុំជឿថា កាលយើងជ្រើសស្លៀកពាក់ថ្លៃថ្នូរ ហើយធ្វើអត្តចរិតឲ្យថ្លៃថ្នូរ *យើងស្លៀកពាក់ ហើយរស់នៅតាមទីបន្ទាល់របស់យើង*អំពីព្រះជាព្រះវរបិតាដ៏អស់កល្បជានិច្ច និង ពីព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។ យើងនឹងឃើញថាយើងគឺជាសិស្សនៃព្រះគ្រីស្ទ ហើយថាយើងរស់នៅតាមដំណឹងល្អទ្រង់គឺតាមរយៈរូបរាងខាងក្រៅរបស់យើង ។

**ហេតុអ្វីបានជាភាពថ្លៃថ្នូរមានសារៈសំខាន់ ?**

យើងរស់នៅក្នុងពិភពលោកមួយដែលមានអំពើល្អ និង អំពើអាក្រក់ ហើយរូបកាយអាចត្រូវបានប្រើប្រាស់សម្រាប់ទាំងគោលបំណងសុចរិត ឬ ទុច្ចរិត ។ ប៉ុន្តែយើងដឹងថា រូបកាយដ៏មានតម្លៃរបស់យើង គឺជាអំណោយទានមួយមកពីព្រះសម្រាប់យើងម្នាក់ៗ ។ វាពិសិដ្ឋ ។ អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « ចំពោះជនដែលដឹង ហើយយល់ពីផែនការនៃសេចក្ដីសង្គ្រោះ ការប្រមាថលើរូបកាយគឺជាទង្វើមួយនៃការបះបោរ [ សូមមើល ម៉ូសាយ 2:36–37 ] និងជាការបដិសេធចំពោះអត្តសញ្ញាណដ៏ពិតរបស់យើងក្នុងនាមជាបុត្រាបុត្រីនៃព្រះ » ។[3] យើងជ្រើសដើម្បីមើលថៃ ហើយការពាររូបកាយយើង ដើម្បីយើងអាចក្លាយជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះ នៅក្នុងការសម្រេចព្រះរាជបំណងដ៏រុងរឿងរបស់ទ្រង់ ( សូមមើល អាលម៉ា 26:3 ) ។ ប្រសិនបើយើងមានបំណងប្រាថ្នាដើម្បីឈរជាតំណាងឲ្យព្រះអង្គសង្គ្រោះ ហើយធ្វើកិច្ចការរបស់ទ្រង់ យើងត្រូវសួរខ្លួនឯងថា ប្រសិនបើព្រះអង្គសង្គ្រោះទ្រង់ស្ថិត



នៅក្បែរយើង តើយើងមានភាពស្រណុកក្នុងចិត្តចំពោះសំលៀកបំពាក់ដែលយើងពាក់ដែរឬទេ ?

ភាពថ្លៃថ្នូរនៅក្នុងការស្លៀកពាក់ រូបរាងខាងក្រៅ គំនិត និង ឥរិយាបថគឺជាការបង្ហាញថា យើងយល់ថាសេចក្តីសញ្ញាដែលយើងបានធ្វើ ប្រទានពរដល់យើង ការពារយើង ហើយផ្តល់អនុភាពដល់យើងនៅក្នុងការរៀបចំខ្លួនដើម្បីត្រឡប់ទៅកាន់វត្តមានទ្រង់វិញ ។ នៅពេលយើងជ្រមុជទឹក យើងបានឈានជើងចេញពីពិភពលោកនេះ ហើយចូលទៅក្នុងនគរព្រះ ។ អ្វីៗគ្រប់យ៉ាងត្រូវតែមានភាពខុសប្លែកចំពោះយើង ។ អែលឌើរ រ៉ូបឺត ឌី ហែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « តាមរយៈការជ្រើសរស់នៅក្នុងនគរទ្រង់ យើងគ្រាន់តែញែក—មិនមែនផ្តាច់ខ្លួន—យើងចេញពីពិភពលោកនេះទេ ។ សំលៀកបំពាក់យើងនឹងមានភាពថ្លៃថ្នូរ គំនិតយើងត្រូវបរិសុទ្ធ ពាក្យសម្តីយើងត្រូវស្អាតស្អំ » ។[4]

ភាពថ្លៃថ្នូរគឺជាគោលការណ៍មួយ ដែលនឹងជួយរក្សាយើងឲ្យមានសុវត្ថិភាពនៅលើផ្លូវនៃសេចក្តីសញ្ញា កាលយើងរីកចម្រើនឆ្ពោះទៅកាន់វត្តមានរបស់ព្រះ ។ ភាពថ្លៃថ្នូរក្នុងការស្លៀកពាក់ និង រូបរាងខាងក្រៅ ព្រមទាំងគំនិត និង ឥរិយាបថ នឹងជួយរៀបចំយើងឲ្យធ្វើ ហើយរក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ ។ ដើម្បីប្រទានពរ ហើយការពារដល់អ័ដាម និង នាងអេវ៉ា ព្រះបានប្រទានអាវស្បែកដល់ពួកគាត់ ដើម្បីបិទបាំងខ្លួន មុនបញ្ជូនពួកគាត់ចេញពីសួនច្បារ ។ តាមរបៀបដូចគ្នានេះដែរ ព្រះបានប្រទានដល់យើងនូវសំលៀកបំពាក់នៃសេចក្តីសញ្ញាមួយនៅក្នុងជីវិតរមែងស្លាប់នេះ វាតំណាងដោយខោអាវពិសិដ្ឋរបស់យើងនៅក្នុងព្រះវិហារបរិសុទ្ធ ។

## តើពរជ័យនៃភាពថ្លៃថ្នូរមានអ្វីខ្លះ ?

តើយើងអាចបង្រៀនអ្វីខ្លះដល់កូនប្រុសស្រីយើង ដើម្បីជួយពួកគេឲ្យមានចិត្តក្លាហានជ្រើសយកភាពថ្លៃថ្នូរនៅក្នុងពិភពលោកមួយ ដែលសើចចំអកពួកគេសម្រាប់ជម្រើសដ៏មានគុណធម៌របស់ពួកគេនោះ ? តើពួកគេមើលឃើញយើងប្រើរូបកាយយើងដើម្បីទាញយកចំណាប់អារម្មណ៍ ឬដើម្បីថ្វាយសិរីល្អដល់ព្រះដែរឬទេ ?

ភាពថ្លៃថ្នូរនៅក្នុងគំនិត ពាក្យសម្តី រូបរាងខាងក្រៅ និង ឥរិយាបថជួយយើងទទួលបានពរជ័យដ៏អស្ចារ្យ ហើយថ្លៃថ្នូរចំនួនបី ។

1. ភាពថ្លៃថ្នូរអញ្ជើញភាពជាដៃគូដ៏ខ្ជាប់ខ្ជួននៃព្រះវិញ្ញាណបរិសុទ្ធ ។ អែលឌើរ ហែល ធ្លាប់បង្រៀនថា « ភាពថ្លៃថ្នូរគឺជាកត្តាដ៏សំខាន់ចំពោះការមានភាពសក្តិសមនឹងព្រះវិញ្ញាណ » ។[5]

ចូរយើងជួយកូនចៅយើងឲ្យយល់ ដើម្បីពួកគេមិនធ្វើអ្វីមួយបដិសេធខ្លួនពួកគេពី « អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធដែលពុំអាចពិពណ៌នាបាន » ( គ. និង ស. 121:26 ) ។ សូមជួយពួកគេឲ្យដឹងថា អំណោយទានវិញ្ញាណដ៏មានតម្លៃ ហើយអស្ចារ្យកើតមានជាមួយនឹងភាពជាដៃគូដ៏ពិសិដ្ឋរបស់ទ្រង់ ។ ព្រះបានសន្យាថា « យើងនឹងរំលែកដល់អ្នកនូវព្រះវិញ្ញាណរបស់យើង ដែលនឹងបំភ្លឺគំនិតរបស់អ្នក ដែលនឹងបំពេញព្រលឹងរបស់អ្នកដោយសេចក្តីអំណរ . . . ដោយការណ៍នេះ អ្នកនឹងដឹងគ្រប់ទាំងអស់ដែលអ្នកមានបំណងចង់បានពីយើង ដែលទាក់ទងទៅនឹងការណ៍ទាំងឡាយនៃសេចក្តីសុចរិត គឺដោយនូវសេចក្តីជំនឿ » ( គ. និង ស.11:13–14 ) ។ ចំណេះដឹង ប្រាជ្ញា និង ទីបន្ទាល់ សេចក្តីអំណរ សេចក្តីសុខសាន្ត និង សុភមង្គល—ទាំងនេះគឺជាពរជ័យដ៏ធំមួយចំនួនដែលយើងអាចសន្យាដល់កូនចៅយើង នៅពេលយើងអញ្ជើញពួកគេ ឲ្យរស់នៅដោយថ្លៃថ្នូរ ហើយមានភាពសក្តិសមនឹងព្រះវិញ្ញាណបរិសុទ្ធ ។

ឧបសគ្គមួយនៃការស្លៀកពាក់ថ្លៃថ្នូរគឺថា ការរចនាម៉ូដសំលៀកបំពាក់ និង ឥរិយាបថដែលទទួលយកដោយសង្គមមានការផ្លាស់ប្តូរជានិច្ចនោះ ។ បទដ្ឋានរបស់ព្រះអម្ចាស់មិនផ្លាស់ប្តូរទេឡើយ ។ សូមបង្រៀនយុវជនយុវនារីឲ្យផ្តោតចិត្តទៅលើព្រះវិញ្ញាណ កាលពួកគេធ្វើការសម្រេចចិត្តអំពីអ្វីដែលត្រូវស្លៀកពាក់ និយាយ និង ធ្វើ ។ កាលពួកគេរស់នៅជិតនឹងព្រះវិញ្ញាណ នោះពួកគេមិនត្រូវការធ្វើដូចជាពិភពលោកនោះទេ ។

កូនចៅយើងបានទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ហើយពួកគេកំពុងធ្វើដំណើរលើផ្លូវនៃសេចក្តីសញ្ញាដែលនាំទៅរកព្រះវិហារបរិសុទ្ធ ហើយនឹងធ្វើឲ្យពួកគេត្រឡប់ទៅវត្តមានរបស់ព្រះវិញ ។ ពួកគេត្រូវការយើងឲ្យបញ្ជាក់ដល់ពួកគេ ហើយធ្វើជាគំរូដល់ពួកគេថា ពួកគេនឹងត្រូវបានដឹកនាំ ការពារ លួងលោម ហើយធ្វើឲ្យបរិសុទ្ធ កាលពួកគេរស់នៅដោយសក្តិសមនឹងព្រះវិញ្ញាណបរិសុទ្ធ ។

2. យើងអាចបង្រៀនកូនប្រុសស្រីយើងថា រូបរាងខាងក្រៅនិង ឥរិយាបថថ្លៃថ្នូរជួយការពារយើងពីឥទ្ធិពលដ៏បំផ្លិចបំផ្លាញនៃពិភពលោក ។ យុទ្ធសាស្ត្រដ៏បោកបញ្ឆោតមួយដែលត្រូវបានប្រើប្រឆាំងនឹងយើងរាល់គ្នា គឺជាឥរិយាបថដែលបានទទួលយកដោយសង្គមថា សីលធម៌គឺជារឿងហួសសម័យ ។ ភាពថ្លៃថ្នូរគឺ



*សូមបង្រៀនយុវជនយុវនារីឲ្យគិតពីព្រះវិញ្ញាណកាលពួកគេធ្វើការសម្រេចចិត្តអំពីអ្វីដែលត្រូវស្លៀកពាក់ និយាយ និង ធ្វើ ។ កាលពួកគេរស់នៅជិតនឹងព្រះវិញ្ញាណ ពួកគេមិនត្រូវការធ្វើដូចជាពិភពលោកនេះទេ ។*

ជាការការពារមួយពីឥទ្ធិពលអាក្រក់បែបនេះ និងជាការការពារមួយនៃភាពបរិសុទ្ធ និង គុណធម៌ ។ សូមស្តាប់ពាក្យទាំងនេះនៅក្នុង*ដើម្បីកម្លាំងនៃយុវជន* ៖ « ពីមុនពេលរៀបអាពាហ៍ពិពាហ៍ . . . ចូរកុំធ្វើអ្វីដែលដាស់ឡើងនូវចំណង់ខាងផ្លូវភេទ » ។[6] រូបរាង និង ឥរិយាបថមិនថ្លៃថ្នូរ ជារឿយៗនឹងបង្កើតឲ្យមានអារម្មណ៍ខាងផ្លូវភេទ ហើយនឹងបំបែករបាំងការពារ ហើយអញ្ជើញឲ្យការល្បួងដើម្បីរំលងច្បាប់ព្រហ្មចារីភាពមានការកើនឡើង ។

អែលឌើរ ហែលបានបង្រៀនថា ៖ « ភាពថ្លៃថ្នូរគឺជាកត្តាដ៏សំខាន់នៃការមានភាពបរិសុទ្ធ និង គុណធម៌ ទាំងនៅក្នុងគំនិត និង ទង្វើ ។ ដូច្នេះហើយដោយសារវាដឹកនាំ ហើយជះឥទ្ធិពលដល់គំនិត ឥរិយាបថ និង ការសម្រេចចិត្តរបស់យើង ភាពថ្លៃថ្នូរគឺជាកត្តាដ៏សំខាន់នៃចរិតលក្ខណៈរបស់យើង » ។[7] សូមបង្រៀន ហើយធ្វើជាគំរូពីភាពថ្លៃថ្នូរដើម្បីជួយយុវជនយុវនារីរបស់យើងរៀបចំខ្លួនដើម្បីគាំទ្រ ហើយការពារដល់អំណាចនៃការបង្កបង្កើតនៅក្នុងខ្លួនរបស់ពួកគេ ។ សូមជួយពួកគេគ្រប់គ្រង ហើយរក្សាការបង្ហាញសេចក្តីស្រឡាញ់រវាងស្វាមី និងភរិយាសម្រាប់អាពាហ៍ពិពាហ៍ឲ្យមានភាពពិសិដ្ឋ ។

3. ភាពថ្លៃថ្នូរអាចជួយយើងឲ្យ « ឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល » ( ម៉ូសាយ 18:9 ) ។ ព្រះអង្គសង្គ្រោះបានបង្រៀនថា ៖ « ចូរលើកពន្លឺរបស់អ្នករាល់គ្នាឡើង ប្រយោជន៍ឲ្យបានភ្លឺដល់មនុស្សលោក ។ មើលចុះ យើងជាពន្លឺដែលអ្នករាល់គ្នានឹងលើកឡើង » ( នីហ្វៃទី 3 18:24 ) ។ ព្រះបានត្រាស់បង្គាប់យើងឲ្យធ្វើជាបង្គោលភ្លើងមួយសម្រាប់ពិភពលោក បង្ហាញសេចក្តីអំណរពីការរស់នៅតាមដំណឹងល្អ បង្រៀនពីសេចក្តីសុចរិត ហើយស្ថាបនានគរព្រះនៅលើផែនដី ។ យើងម្នាក់ៗមាននូវពន្លឺនៃព្រះគ្រីស្ទ កាលយើងមានភាពថ្លៃថ្នូរ និងភាពបរិសុទ្ធ ហើយរក្សាព្រះបញ្ញត្តិ ។ ភាពថ្លៃថ្នូរគឺជាសាក្សីមួយពីទីបន្ទាល់របស់យើងស្តីពីព្រះអង្គសង្គ្រោះ និង ពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

ឱ ជនដែលត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធមានភាពអស្ចារ្យ ហើយមានពរអ្វីម្ល៉េះ ជាអ្នកដែលការពារខ្លួនពីលោកិយ៍ និង ជាអ្នកដែលឈរជាសាក្សីពីព្រះដល់ពិភពលោក ។ ហើយមានពរហើយដល់អស់អ្នកណាដែលធ្វើជាគំរូ ហើយបង្រៀនគោលលទ្ធិពីភាពថ្លៃថ្នូរទៅដល់បុត្រាបុត្រីទាំងអស់នៃទីក្រុងស៊ីយ៉ូន ។

កាលយើងបានចុះសេចក្តីសញ្ញាដើរតាមព្រះអង្គសង្គ្រោះ ហើយប្រាថ្នាចង់ទទួលបានពរជ័យដ៏ពេញលេញនៃដង្វាយធួនរបស់ទ្រង់នៅក្នុងជីវិតយើង នោះមានតែសំលៀកបំពាក់តែមួយគត់ដែលសំខាន់ ។ មរ៉ូណៃកត់ត្រាថា « ចូរភ្ញាក់ឡើង និងចូរក្រោកឡើងពីធូលីដី . . . មែនហើយ ឱកូនស្រីនៃក្រុងស៊ីយ៉ូនអើយ ចូរប្រដាប់ដោយ*សំលៀកបំពាក់ដ៏រុងរឿងរបស់អ្នក* . . .ដើម្បីឲ្យសេចក្តីសញ្ញានៃព្រះវរបិតាដ៏នៅអស់កល្បជានិច្ចដែលធ្វើដល់អ្នកអាចបានបំពេញ » ( មរ៉ូណៃ 10:31 ការគូសបញ្ជាក់បានបន្ថែម ) ។

សំលៀកបំពាក់បរិសុទ្ធដ៏រុងរឿងគឺជារ៉ូបនៃសេចក្តីសុចរិត ពាក់ដោយជនដែលរក្សាសេចក្តីសញ្ញារបស់ខ្លួន ។ តើយើងកំពុងរៀបចំកូនចៅយើងឲ្យស្លៀកពាក់សំលៀកបំពាក់បរិសុទ្ធដ៏រុងរឿងទាំងនេះដែរឬទេ ?

ខ្ញុំសូមថ្លែងទីបន្ទាល់ថា សេចក្តីសង្គ្រោះគឺស្ថិតនៅក្នុងព្រះគ្រីស្ទ ហើយថា ជនដែលបានរក្សាសេចក្តីសញ្ញារបស់ខ្លួននឹង « មានដំរិះដ៏ឥតខ្ចោះពីការសប្បាយរបស់គេ និងពីសេចក្តីសុចរិតរបស់គេ បំពាក់ដោយសេចក្តីបរិសុទ្ធ មែនហើយ គឺដោយអាវនៃសេចក្តីសុចរិត » ( នីហ្វៃ 2 9:14 ) ។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលធ្វើឡើងនៅថ្ងៃទី 2 ខែ ឧសភា ឆ្នាំ 2013 ក្នុងសន្និសីទរបស់ស្ត្រីនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ។*

**កំណត់ចំណាំ**

1. *ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងដំណឹងល្អ* ( ឆ្នាំ 2004 ) ទំព័រ 148 ។
2. ជែហ្វ្រី អ័រ ហូឡិន « អ៊ីស្រាអែលអើយព្រះកំពុងហៅ » ការប្រជុំធម្មនិដ្ឋានប្រពន្ធ័អប់រំសាសនាចក្រ ថ្ងៃទី 9 ខែ កញ្ញា ឆ្នាំ 2012 cesdevotionals.lds.org ។
3. ដេវីដ អេ បែដណា « We Believe in Being Chaste » *Liahona* ខែ ឧសភា ឆ្នាំ 2013 ឆ្នាំ 43 ។
4. រ៉ូប៊ឺត ឌី ហែល « The Covenant of Baptism: To Be in the Kingdom and of the Kingdom » *Liahona* ខែ មករា ឆ្នាំ 2001 ទំព័រ 8 ។
5. រ៉ូប៊ឺត ឌី ហែល « Modesty: Reverence for the Lord » Liahona, ខែ សីហា ឆ្នាំ 2008 ទំព័រ 20 ។
6. *ដើម្បីកម្លាំងនៃយុវជន* ( ឆ្នាំ 2011 ) ទំព័រ 36 ។
7. រ៉ូប៊ឺត ឌី ហែល *Liahona* ខែ សីហា ឆ្នាំ 2008 ទំព័រ 19 ។

# ការអធិស្ឋានរបស់ខ្ញុំនៅសមុទ្រខាងជើង

កាលខ្ញុំអាយុ 17 ឆ្នាំ យើងបានរស់នៅលើកោះមួយភាគខាងត្បូងប្រទេសន័រវ៉េសដែលហៅថា អាន់ដាប៉េទ្បូយ ។ ឪពុកខ្ញុំបានប្រែចិត្តជឿលើសាសនាចក្រនៅអាន់ដាប៉េទ្បូយ ហើយខ្ញុំបានជ្រមុជទឹកនៅទីនោះក្នុងសមុទ្រ ។

នៅពេលនោះ ខ្ញុំជាអ្នកនេសាទត្រី ហើយមានបទពិសោធន៍ជាច្រើននៅក្នុងការជិះទូក ។ ឪពុកខ្ញុំបានឲ្យខ្ញុំមើលខុសត្រូវបររត់ទូកតាមសមុទ្ររបស់យើងសម្រាប់មនុស្សដែលរស់នៅទីនោះ ។

មានថ្ងៃមួយនោះ ក្នុងឆ្នាំ 1941 យើងបានទទួលទូរសព្ទពីវេជ្ជបណ្ឌិតម្នាក់នៅ ផ្លេកកេហ្វជ័ដ នៅភាគខាងជើង ។ មានស្ត្រីម្នាក់ដែលរស់នៅប្រមាណជាពីរម៉ោងតាមផ្លូវទឹក ត្រូវការការព្យាបាលជាបន្ទាន់ ។ វេជ្ជ. ហ័ហ្វមិន បានសួរថា តើខ្ញុំអាចជូនគាត់ទៅមើលស្ត្រីនោះបានដែរឬទេ ប៉ុន្តែឪពុកម្ដាយខ្ញុំបានព្រួយបារម្ភពីព្យុះមួយដែលកំពុងបោកបក់នៅសមុទ្រភាគជើង ។ យើងបានសម្រេចចិត្តអធិស្ឋាន ទូលសូមដល់ព្រះវរបិតាសួគ៌ពីអ្វីដែលត្រូវធ្វើ ។ យើងបានទទួលចម្លើយមួយថា ខ្ញុំគួរតែទៅ ។

នៅពេលខ្ញុំស្រាយ*ទ្រីគ*ជាទូកនេសាទត្រីរបស់ខ្ញុំប្រវែង 10 ម. ចូលទៅក្នុងសមុទ្រ អាកាសធាតុកាន់តែអាប់អួរ ហើយមានរលកធំៗ ។ បន្ទាប់ពីទៅយកលោកវេជ្ជបណ្ឌិតរូបនោះមក ខ្ញុំបានបើកទូកចេញទៅឆ្លងកាត់ដែសមុទ្រចូលទៅក្នុងផ្ទៃសមុទ្រដ៏ធំល្វឹងល្វើយ ។ យើងត្រូវធ្វើដំណើរទៅសហគមន៍មួយនៅភាគខាងជើងលីស្តា ដែលមានទីតាំងនៅលើឆ្នេរភាគខាងត្បូងតំបន់ភ្នំរបស់ប្រទេសន័រវ៉េស—ជាកន្លែងដែលសម្បូរទៅដោយព្យុះ និង ការលេចនាវាជាច្រើន ។

ខ្ញុំសម្លឹងមើលព្យុះនោះមិនដាក់ភ្នែកសោះ រហូតយើងទៅដល់ដែសមុទ្រប្រមាណជា 12 ម. ដែលដឹកនាំទៅកាន់គោលដៅរបស់យើង ។ កម្ពស់ទឹករលកខ្ពស់ខ្លាំងណាស់ ខ្ញុំមិនអាចបញ្ជាទូកឲ្យឆ្លងកាត់ដែសមុទ្រនោះបានទេ ហើយរលកបោកចូលមកក្នុងដែសមុទ្រនោះ ហើយប៉ះទៅនឹងថ្ម ។

« តើយើងគួរធ្វើយ៉ាងម៉េចទៅ ? » លោកវេជ្ជបណ្ឌិតបានសួរនៅពេលមានខ្យល់បោកបក់យ៉ាងខ្លាំង ។

ខ្ញុំបានតបថា « ខ្ញុំត្រូវអធិស្ឋានសួរពីរឿងនេះសិន » ។

ខ្ញុំបានឈប់ ហើយអធិស្ឋាន ដោយទូលព្រះវរបិតាសួគ៌សូមការដឹកនាំ ។ កាលខ្ញុំពោលពាក្យអាម៉ែនភ្លាម ខ្ញុំបានទទួលចម្លើយមួយយ៉ាងច្បាស់ ។ រំពេចនោះខ្ញុំបាននឹកឃើញពីដំណើររឿង



រចនាដោយ ប្រេដលី អេច ខ្លាក

មួយដែលអ្នកនេសាទវ័យចំណាស់ម្នាក់ធ្លាប់ប្រាប់ខ្ញុំ ។ គាត់ធ្លាប់បាននេសាទត្រីនៅតំបន់នេះ ក្នុងអំឡុងពេលមានព្យុះមួយដ៏ធំ ហើយមិនអាចទៅដល់ឆ្នេរបាន ។ កាលគាត់រង់ចាំឲ្យព្យុះនោះស្ងប់ នោះគាត់បានសង្កេតឃើញពីលំនាំមួយនៅក្នុងទឹករលកដែលនឹងបោកបក់ចូលមក ។ បន្ទាប់ពីរលកបីធំៗបានបោកបក់មក នោះផ្ទៃទឹកបានស្ងប់ក្នុងរយៈពេលមួយខ្លី—គឺល្មមគ្រប់គ្រាន់ឲ្យគាត់បើកចូលទៅក្នុងដៃសមុទ្រ ។

ខ្ញុំធ្លាប់ធ្វើការនេសាទត្រីជាច្រើនដងនៅតំបន់នេះ ប៉ុន្តែមិនធ្លាប់សង្កេតពីលំនាំនៃទឹករលកឡើយ ។ ថ្វីបើដូច្នោះក្ដី ខ្ញុំបានបើកទូកទៅខាងមុខដៃសមុទ្រនោះ ហើយរង់ចាំមើលកាលរលកបីធំៗបោកបក់ចូលមក ។ ពិតណាស់ ភាពស្ងប់បានកើតឡើងតាមក្រោយ។ ខ្ញុំបានបើកទូកឆ្ពោះទៅផ្ទៃទឹកស្ងប់នៃដៃសមុទ្រខាងក្នុង ហើយនាំវេជ្ជ. ហ័ហ្វមិន ទៅដល់ឆ្នេរដោយសុវត្ថិភាព ។ គាត់បានប្រញាប់ប្រញាល់ទៅរកស្ត្រីដែលមានជំងឺនោះ កាលខ្ញុំរង់ចាំគាត់នៅលើទូក អរគុណដល់ព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានខ្ញុំ ។

កាលលោកវេជ្ជបណ្ឌិតបានត្រឡប់មកវិញប្រហែលជាមួយម៉ោងក្រោយមក គាត់បានប្រាប់ថា « យើងជួយសង្គ្រោះជីវិតគាត់បានហើយ ! »

ដោយបានធូរចិត្តពេលឮដំណឹងនេះ ហើយអាកាសធាតុបានប្រសើរឡើង ខ្ញុំបានបើកទូកមកផ្ទះវិញដោយគ្មានបញ្ហាសោះឡើយ ។

ខ្ញុំសូមថ្លែងជាសាក្សីថា ពេលយើងត្រូវការជំនួយ យើងគួរតែអធិស្ឋាន ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌នឹងឆ្លើយតប ។ ■

អូឡាហ្វ ឌ័រលីហ្វ ជេនសិន រដ្ឋយូថាហ៍ ស.រ.អ.

កម្ពស់ទឹករលកខ្ពស់ខ្លាំងណាស់ ខ្ញុំមិនអាចបញ្ជាទូកឲ្យឆ្លងកាត់ដៃសមុទ្រនោះបានទេ ។



# ទ្រង់ស្រឡាញ់អ្នក

ខ្ញុំបានអង្គុយនៅជ្រុងម្ខាងនៃបន្ទប់សេឡេស្ទាលក្បែរព្យាណូខ្យល់អំឡុងពេលការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ ម៉ិមហ្វីសថែនណេសី ។ ប្រធាន ជែមស៍ អ៊ី ហ្វោស្ត ( 1920–2007 ) ជាសមាជិកមួយរូបក្នុងគណៈប្រធានទីមួយពីឆ្នាំ 1995 ដល់ 2007 បានមកឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនេះ ។ លោក និង ថ្នាក់ដឹកនាំមួយចំនួនផ្សេងទៀតបានអង្គុយនៅពីក្រោយមីក្រូហ្វូន ។ មានក្រុមចម្រៀងរបស់សាសនាចក្រក្នុងមូលដ្ឋានមួយក្រុមបានដើរចូលមកក្នុងបន្ទប់ ហើយឈរនៅពីក្រោយពួកលោក ។

មានយុវនារីម្នាក់ដែលខ្ញុំបានបង្រៀនសួរសុខទុក្ខគឺជាសមាជិកម្នាក់នៅក្នុងក្រុមចម្រៀងនោះ ។ ខ្ញុំបានអធិស្ឋានពេញក្នុងការប្រជុំនោះទូលសុំថា នាងនឹងទទួលបាននូវអ្វីដែលនាងបានលះបង់មកកាន់ទីនេះ ។ នាងធ្លាប់ប្រាប់ខ្ញុំថា នាងមកកាន់ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនៅថ្ងៃនោះ ដើម្បីចង់ដឹងអំពីជំហរខាងវិញ្ញាណរបស់នាងចំពោះព្រះអម្ចាស់ ។ នាងធ្លាប់ប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរកាលពីមុន ហើយទោះជានាងធ្លាប់បានប្រែចិត្តក្ដី ក៏នាងនៅតែគ្មានអារម្មណ៍ល្អចំពោះខ្លួនឯង ហើយថែមទាំងគ្មានអារម្មណ៍ល្អពីការច្រៀងនៅក្នុងក្រុមចម្រៀងនោះដែរ ។

ខ្ញុំបានមើលទៅប្រធាន ហ្វោស្ត ដោយមានអារម្មណ៍ថា ក្នុងនាមជាអ្នកតំណាងមួយរូបរបស់ព្រះអម្ចាស់នៅក្នុងគណៈប្រធានទីមួយ លោកគួរតែមានលទ្ធភាពដើម្បីធ្វើនូវអ្វីមួយ ។ ប៉ុន្តែតើខ្ញុំអាចប្រាប់ដល់លោកតាមរបៀបណា ហើយតើលោកអាចធ្វើអ្វីមួយតាមរបៀបណាបាន ? បន្ទាប់ពីការប្រជុំនោះ លោកបានដើរចេញពីបន្ទប់តាមផ្លូវដែលលោកបានដើរចូលមក ហើយដោយគ្មានការណែនាំការចាប់ដៃ និងការនិយាយឆ្លើយឆ្លងឡើយ ។ ខ្ញុំបានយល់ថា លោកមានភាពមមាញឹក ហើយមានការធ្វើដំណើរដែលបានរៀបចំទុក ប៉ុន្តែខ្ញុំនៅតែអធិស្ឋាន ។

ដោយគិតនៅក្នុងចិត្ត ប្រធាន ហ្វោស្តមើលមុខខ្ញុំមួយសន្ទុះ—ដោយជ្រួញចិញ្ចើម ។ កាលការប្រជុំនោះបានបញ្ចប់ ពន្លឺនៃអារម្មណ៍រីករាយបានលេចឡើងនៅផ្ទៃមុខរបស់លោក ។

លោកបានមើលមុខខ្ញុំម្ដងទៀត រួចរំពេចនោះបានក្រោកឈរ ហើយងាកក្រោយដោយឈោងដៃរបស់លោកតាមដែលលោកអាចធ្វើបាន ។ លោកបានចង្អុលទៅមិត្តខ្ញុំ ។ រួចលោកបានថ្លែងឮៗដោយភាពម៉ឺងម៉ាត់ថា « ព្រះអម្ចាស់ស្រឡាញ់អ្នក ! »

សញ្ញាបង្ហាញរបស់ប្រធានហ្វោស្តយ៉ាងតូច ហើយសាមញ្ញ ប៉ុន្តែវាមានឥទ្ធពលដ៏អស្ចារ្យដែលអាចកើតមានតែតាមរយៈព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ដោយប្រាប់ដល់លោកនូវអ្វីដែលខ្ញុំមិនអាចប្រាប់បាន ។ ពាក្យប៉ុន្មានម៉ាត់នោះបានប្រទានពរដល់មិត្តខ្ញុំ ហើយបានបន្តពង្រឹងដល់សេចក្ដីជំនឿរបស់ខ្ញុំថា ព្រះអម្ចាស់គិតគូរគ្រប់ជ្រុងជ្រោយពីជីវិតរបស់យើង ហើយ « ដោយកិច្ចការតូចតាច និងងាយ ទើបនាំឲ្យកើតកិច្ចការធំៗបាន » ( អាលម៉ា 37:6 ) ។ ■

អាលីស វិចតូរីយ៉ា វ៉េស្តុន-ឈើរួដ រដ្ឋអាខាន់សាស ស.រ.អ.

# យើងស្ដាប់ដល់កុមារ

ជំងឺបាក់ទឹកចិត្តគឺជាអ្វីមួយដែលខ្ញុំមិនចង់ជួបប្រទះទៀតឡើយ ។ ប៉ុន្តែក្រោយពីខ្ញុំបានជាសះស្បើយបាន 12 ឆ្នាំ ខ្ញុំបានមានវាម្ដងទៀត ។

ខ្ញុំមានការភ័យខ្លាច ហើយព្រួយបារម្ភ ។ ខ្ញុំសួរព្រះវរបិតាសួគ៌ ហើយបានអធិស្ឋានសូមកម្លាំងដើម្បីឆ្លងកាត់ការសាកល្បងរបស់ខ្ញុំ ។ ខ្ញុំក៏បានទូលអង្វរទ្រង់សូមកុំឲ្យជំងឺបាក់ទឹកចិត្តរបស់ខ្ញុំអូសបន្លាយរហូតដល់ប្រាំឆ្នាំ ដូចកាលពីលើកមុនទៀតឡើយ ។

ស្វាមីខ្ញុំ និង ខ្ញុំមានកូនបីនាក់ ប្រុសពីរ ស្រីមួយ ហើយយើងមានចៅ 13 នាក់ ។ ដោយដឹងពីភាពអស់សង្ឃឹមដែលខ្ញុំមាន កូនស្រីខ្ញុំបានរៀបចំថ្ងៃមួយសម្រាប់ការតមអាហារ និង ការអធិស្ឋានជាគ្រួសារ ។ ចៅទាំងអស់ចាប់ពីអាយុ 1 ឆ្នាំរហូតដល់ 10 ឆ្នាំ ចង់អធិស្ឋានឲ្យលោកយាយ ហើយមានចៅបីនាក់ដែលបានជ្រមុជទឹករួចហើយចង់ធ្វើការតមអាហារផងដែរ ។ វាជាការលួងលោមចិត្តមួយដោយដឹងថា ស្វាមីខ្ញុំ កូនខ្ញុំ និង ចៅខ្ញុំបានតមអាហារ ហើយអធិស្ឋានឲ្យខ្ញុំ ។

លុះស្អែកឡើង កាលខ្ញុំក្រោកពីសម្រាកបានមួយស្របក់ អារម្មណ៍នៃការបាក់ទឹកចិត្តហាក់ដូចជាបានធូរស្រាលបន្តិច ។ លុះថ្ងៃបន្ទាប់ទៀត វាកាន់តែធូរស្រាលថែមទៀត ។ លុះដល់ថ្ងៃទីប្រាំ ការបាក់ទឹកចិត្តរបស់ខ្ញុំបានធូរស្រាលទាំងស្រុង ។ នៅល្ងាចនោះ កាលខ្ញុំកំពុងគិតថា តើអព្ភូតហេតុនេះកើតឡើងយ៉ាងម៉េចបាន នោះមានសំឡេងមួយបានមកប៉ះនឹងព្រលឹងខ្ញុំ ហើយថ្លែងមកកាន់ខ្ញុំថា « យើងស្ដាប់ព្ធកុមារ » ។ ព្រះវរបិតាសួគ៌បានស្ដាប់ព្ធពួកគេ ដោយសារភាពបរិសុទ្ធរបស់ពួកគេ ហើយបានឆ្លើយតបការអធិស្ឋានដ៏រាបសារ មានសេចក្ដីជំនឿ ហើយមានសេចក្ដីស្រឡាញ់របស់ពួកគេ ។

ព្រះអម្ចាស់បានបង្រៀនថា ៖

« បើអ្នករាល់គ្នាមិនផ្លាស់គំនិតដូចជាកូនតូចនេះ នោះនឹងចូលទៅក្នុងនគរស្ថានសួគ៌ពុំបានឡើយ ។

« ដូច្នេះ អ្នកណាដែលបន្ទាបខ្លួនឲ្យបានដូចកូនតូចនេះ អ្នកនោះឯងឈ្មោះថាធំជាងគេក្នុងនគរស្ថានសួគ៌ហើយ » ( ម៉ាថាយ 18:3–4 ) ។

ខ្ញុំមានទំនាក់ទំនងជាមួយនឹងចៅៗខ្ញុំ ហើយអរគុណដល់ពួកគេចំពោះការតមអាហារ និង អធិស្ឋានឲ្យខ្ញុំ ។ ខ្ញុំបានប្រាប់ពួកគេថា ខ្ញុំស្រឡាញ់ពួកគេខ្លាំងណាស់ ។ ខ្ញុំបានប្រាប់ពួកគេថា ព្រះវរបិតាសួគ៌បានស្ដាប់ព្ធពួកគេ ហើយឆ្លើយតបការអធិស្ឋានពួកគេ ។

កាលចៅៗខ្ញុំបានធំឡើងនៅក្នុងដំណឹងល្អ ខ្ញុំសង្ឃឹមថា ពួកគេនឹងចងចាំពីគ្រាដែលព្រះវរបិតាសួគ៌បានមានបន្ទូលមកកាន់លោកយាយរបស់ពួកគេថា « យើងស្ដាប់ព្ធកុមារ » ។ ហើយខ្ញុំសង្ឃឹមថា បទពិសោធន៍នោះនឹងពង្រឹងដល់ទីបន្ទាល់ពួកគេ ហើយជួយពួកគេឲ្យបន្តរឹងមាំនៅក្នុងដំណឹងល្អ ។ ■

ចយ គ្រូម៉ា រដ្ឋកាលីហ្វ័រញ៉ា ស.រ.អា.

ចៅទាំងអស់ចាប់ពីអាយុ 1 ឆ្នាំរហូតដល់ 10 ឆ្នាំ ចង់អធិស្ឋានឲ្យលោកយាយ ហើយមានចៅបីនាក់ដែលបានជ្រមុជទឹករួចហើយចង់ធ្វើការតមអាហារ ។



# ថ្នាំបំពុលដែលទាក់ទាញបំផុត

កាលខ្ញុំចេញតាមទ្វារខាងមុខផ្ទះទៅយកសារព័ត៌មាន ខ្ញុំបានឃើញរឿងមួយដែលធ្វើឲ្យចិត្តខ្ញុំសៅហ្មង ។ ពំនូកដីដែលស្រមោចភ្លើងបានពូនឡើងពីយប់មិញ ដោយមានផុសចេញមកពីស្នាមប្រេះនៅវាលស្មៅមុខផ្ទះ និង ផ្លូវដើរ ។

ទោះជាស្វាមីខ្ញុំ និង ខ្ញុំមិនធ្លាប់រស់នៅរដ្ឋតិចសាស ស.រ.អា. ក្ដីក៏ខ្ញុំបានដឹងពីបទពិសោធន៍ដ៏ឈឺចាប់នៃការខាំទិចរបស់ស្រមោចនេះដែរ ឈ្មោះរបស់វាមិនមែនត្រូវបានគេឲ្យដោយសារតែពណ៌របស់វានោះទេ ។ ខ្ញុំរត់ទៅកន្លែងដាក់ឡានជាកន្លែងដែលយើងទុកថ្នាំសម្លាប់សត្វល្អិតនៅទីនោះ ។ រួចខ្ញុំបានអានការណែនាំនៅលើនោះ ។

វាសរសេរថា « [ ថ្នាំសម្លាប់សត្វល្អិតនេះ ] គឺទាក់ទាញបំផុតដល់ស្រមោចភ្លើង » ។ « វានឹងនាំថ្នាំនោះចូលទៅក្នុងពំនូកមេវាស៊ី ហើយហ្វូងស្រមោចនោះនឹងស្លាប់ » ។ ស្លាកណែនាំនោះបានប្រាប់ខ្ញុំឲ្យរោយថ្នាំនោះមួយចំនួនលើពំនូកនោះ និងជុំវិញពំនូកវា ។ ហ្វូងស្រមោចនឹងធ្វើការបន្ទាប់ទៀត ។

ខ្ញុំមានចិត្តសង្ស័យខ្លះ ។ ចំពោះខ្ញុំ ស្រមោចភ្លើងហាក់ដូចជាឈ្លាសវៃ អាចសង់ពំនូកដ៏ខ្ពស់តែក្នុងរយៈពេលមួយយប់ប៉ុណ្ណោះ ។ ខ្ញុំសង្ស័យថា វានឹងមិនស៊ីថ្នាំពុលនោះទេ ប៉ុន្តែខ្ញុំនៅតែរោយវាចោល ។

មួយសន្ទុះក្រោយមក ខ្ញុំបានឃើញពំនូកនោះមានភាពច្របូកច្របល់ ។ ខ្ញុំបានឈរឲ្យឆ្ងាយ ប៉ុន្តែបានឱនមើលភាពច្របូកច្របល់នោះ ។ វាបានរត់ច្រួលច្រាលចេញខាងក្រៅដូចជានំម៉ាណាធ្លាក់ពីលើមេឃដូច្នោះដែរ ។ វាបានទាញកន្ត្រាក់គ្រាប់ថ្នាំសៗទាំងនោះជាមួយនឹងដង្កាបដ៏តូចរបស់វា ហើយប្រញាយគ្នាប្រញាប់នាំយកថ្នាំបំពុលនោះចូលទៅក្នុងពំនូករបស់វា ។

ខ្ញុំបានមើលទាំងភាពភ្ញាក់ផ្អើលជាខ្លាំង ។ វាសុខចិត្តយកថ្នាំបំពុលចូលទៅក្នុងសំបុកវា ។ ពិតណាស់ពាក្យថា « ទាក់ទាញបំផុត » នោះគឺមិនបានបំផ្លើសឡើយ ។ ក្រុមហ៊ុនថ្នាំសម្លាប់សត្វល្អិតនេះ អាចធ្វើឲ្យអ្វីមួយដែលអាក្រក់—គឺសាហាវបំផុត—មើលទៅដូចជារឿងល្អណាស់ ។

ខ្ញុំមិនធ្លាប់ឃើញគំរូដ៏អស្ចារ្យជាក់ច្បាស់មួយ ពរបៀបដែលរឿងអាក្រក់អាចធ្វើឲ្យមើលទៅថាហាក់ដូចល្អពីមុនឡើយ ។ វាបានធ្វើឲ្យខ្ញុំគិតពីរបៀបដែលសាតាំងធ្វើនូវរឿងដូចគ្នានេះ ។ ខ្ញុំត្រូវបានលួងលោមឲ្យដឹងថា ទោះជាវាអាចរោយថ្នាំបំពុលរបស់វាជុំវិញផ្ទះខ្ញុំក្ដី ក៏វាមិនអាចនាំយកថ្នាំនោះចូលមកខាងក្នុងផ្ទះបានឡើយ—លុះត្រាតែខ្ញុំអនុញ្ញាតឲ្យវាចូល ។ អញ្ចឹងតើខ្ញុំការពារកុំឲ្យវាចូលមកតាមរបៀបណា ?

បទគម្ពីរមួយដែលខ្ញុំចូលចិត្តបានផុសឡើងក្នុងគំនិតខ្ញុំ ៖ « ត្បិតមើលចុះ ព្រះវិញ្ញាណនៃព្រះគ្រីស្ទត្រូវបានប្រទានដល់មនុស្សគ្រប់រូប ដើម្បីឲ្យគេអាចដឹងខុសត្រូវ » ។ ដោយមានព្រះវិញ្ញាណនោះ មរមនពន្យល់ថា យើង « អាចដឹងដោយដំរិះដ៏ឥតខ្ចោះ » ថារឿងមួយណាមកពីព្រះ ឬ សាតាំង ( ម៉ូរ៉ូណៃ 7:16 ) ។

បទពិសោធន៍នៃការមើលហ្វូងស្រមោចដ៏មានវាសនាអាក្រក់ទាំងនោះធ្វើឲ្យខ្ញុំមានអំណរគុណថា ស្វាមីខ្ញុំ និង ខ្ញុំអាចវិនិច្ឆ័យ ហើយដឹងដោយប្រាកដពីមុនអនុញ្ញាតឲ្យអ្វីមួយចូលមកក្នុងផ្ទះរបស់យើង ។ កិច្ចការយើងគឺត្រូវបង្រៀនកូនចៅយើងឲ្យធ្វើតាមព្រះវិញ្ញាណនៃព្រះគ្រីស្ទ ដើម្បីពួកគេអាចស្គាល់ពីថ្នាំបំពុល កាលពួកគេជួបប្រទះនឹងវាផងដែរ ។

កាលខ្ញុំឱនមើលសត្វល្អិតទាំងនោះដឹកជញ្ជូនគ្រាប់ថ្នាំទាំងអស់ចូលទៅក្នុងពំនូករបស់វា ខ្ញុំបានសច្ចាអស់ពីចិត្តខ្ញុំដើម្បីការពារថ្នាំបំពុលមិនឲ្យចូលក្នុងផ្ទះរបស់ខ្ញុំឡើយ ។ ■

អាលីសុន អិល បេនឌល រដ្ឋ យូថាហ៍ ស.រ.អា.

> ស្លាកណែនាំនោះបានប្រាប់ខ្ញុំឲ្យហោយថ្នាំនោះមួយចំនួនលើពំនូកនោះ និងជុំវិញវា ។ ហ្វូងស្រមោចនឹងធ្វើការបន្ទាប់ទៀត ។



# ការឈរការពារ អ្វីដែល យើងជឿ

យើងរស់នៅក្នុងពិភពលោកមួយដែលមានមនុស្សជាច្រើន មើលឃើញរឿងអាក្រក់ថាជារឿងល្អ ហើយរឿងល្អថាជារឿងអាក្រក់ ហេតុដូច្នេះហើយយើងត្រូវតែឈរការពាររឿងល្អ ។ ទីបន្ទាល់ខាងក្រោមនេះគឺមកពីពួកមជ្ឈិមវ័យ វ័យក្មេងដែលបានឈរការពារអ្វីដែលពួកគេជឿ ។ ពួកគេមិនបានឈ្លោះប្រកែក ឬបញ្ចេញប្រតិកម្មដោយកំហឹង ឬធ្វើអសប្បុរសធម៌ឡើយ ។ ពួកគេបានបង្ហាញ « ទាំងភាពក្លាហាន និង សុភាវធម៌ »[1] ហើយជាលទ្ធផល ពួកគេបានពង្រឹងដល់អ្នកដទៃទៀត ( សូមមើល នីហ្វៃទី 3 12:44–45 ) ។







## ប្អូនប្រុសខ្ញុំបានបដិសេធមិនផឹកស្រាសុំប៉ាញ

នៅប្រទេសបារាំង ការបម្រើទ័ពគឺជាកាតព្វកិច្ចចាំបាច់មួយ ។ ប្អូនប្រុសខ្ញុំអាយុ 20 ឆ្នាំ ឈ្មោះ ឡូអ៊ីក បានសម្រេចចិត្តទៅសាលារៀនមន្ត្រីបម្រុងដើម្បីក្លាយជាអនុសេនីមួយរូប ។ នៅពេលគាត់បានបញ្ចប់ពីសាលានោះ មាននូវពិធីសច្ចាប្រណិធានមួយសម្រាប់មន្ត្រីថ្មី ។ ពួកគេម្នាក់ៗបានផ្លាស់គ្នាសូត្រពាក្យស្លោកនៃកងវរសេនាធំ ។ រួចពួកគេត្រូវផឹកស្រាសុំប៉ាញមួយកែវដែលមានដាក់ផ្កាកូលាប—ក្នុងនោះ ។ ទំនៀមទម្លាប់នេះបានដោយផ្តើមជាមួយនឹងណាប៉ូឡេអុង បូណាប៉ាត ហើយចាប់តាំងពីពេលនោះមកគ្មានមន្ត្រីណាម្នាក់បដិសេធមិនចូលរួមឡើយ ។

ឡូអ៊ីក បានប្រាប់ទៅវរសេនីយ៍ឯកនោះថា គោលការណ៍សាសនារបស់គាត់មិនអនុញ្ញាតឲ្យគាត់ផឹកគ្រឿងស្រវឹងទេ ។ ភាពស្ងប់ស្ងាត់មួយខុសពីធម្មតាបានកើតឡើងបន្ទាប់ពីសំណើរបស់ឡូអ៊ីកឲ្យមានការលើកលែង ។ វរសេនីយ៍ឯកនោះបានក្រោកឈរឡើង ។ ជាជាងការបង្ខំឡូអ៊ីកឲ្យផឹកស្រាសុំប៉ាញនោះ គាត់បានអបអរដល់ឡូអ៊ីកដែលបានរក្សាគោលការណ៍របស់ខ្លួនទោះជាមានការដាក់សម្ពាធក្តី ដោយថ្លែងថា គាត់មានមោទនភាពដើម្បីស្វាគមន៍បុរសដ៏មានសេចក្តីទៀងត្រង់ម្នាក់នេះចូលទៅក្នុងកងវរសេនាធំរបស់គាត់ ។ ពួកគេបានប្តូរស្រាសុំប៉ាញ ហើយឡូអ៊ីកបានចូលរួមនៅក្នុងពិធីសច្ចាប្រណិធាននោះ ។

ព្យែរ អង់ធីយ៉ាន ប្រទេសបារាំង

## ខ្ញុំត្រូវបានអញ្ជើញទៅពិធីជប់លៀងមួយដ៏រញ៉េរញ៉ៃ

បន្ទាប់ពីបញ្ចប់មហាវិទ្យាល័យ បងស្រីខ្ញុំឈ្មោះ ហ្រ្គេស និង ខ្ញុំបានធ្វើការឲ្យក្រុមហ៊ុនមួយដែលមានពួកបរិសុទ្ធថ្ងៃចុងក្រោយពីរបីនាក់ផ្សេងទៀត ។ និយោជករបស់យើងពុំមែនជាសមាជិកសាសនាចក្រទេ ។ នៅពេលបងស្រីបានភ្ជាប់ពាក្យ និយោជករបស់យើងបានរៀបចំពិធីជប់លៀងសម្រាប់កូនក្រមុំមួយដ៏ភ្ញាក់ផ្អើលឲ្យគាត់ ។ ខ្ញុំបានសង្ឃឹមថា គាត់នឹងគោរពដល់បទដ្ឋានរបស់យើង ប៉ុន្តែផ្ទុយទៅវិញគាត់បញ្ជាទិញគ្រឿងស្រវឹង អ្នករាំប្រុសម្នាក់ និង វីដេអូអាស្រូវ ។

ពីមុនពិធីជប់លៀងសម្រាប់កូនក្រមុំនោះ ខ្ញុំបានទទួលអារម្មណ៍ខ្សឹបប្រាប់ពីព្រះវិញ្ញាណបរិសុទ្ធនៅក្នុងខ្លួន ដោយលើកទឹកចិត្តខ្ញុំឲ្យរំឭកដល់មេរបស់ខ្ញុំពីបទដ្ឋានរបស់យើង ។ ខ្ញុំបានយកមេដាយយុវនារីរបស់ខ្ញុំ ហើយបានគិតពីរាល់កិច្ចខិតខំ និង ការលះបង់ដែលខ្ញុំបានធ្វើ កាលខ្ញុំនៅជាវ័យជំទង់ដើម្បីបំពេញការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារីរបស់ខ្ញុំ ។ ខ្ញុំបានអធិស្ឋានថា ខ្ញុំនឹងទទួលបានការដឹកនាំឲ្យឈរយ៉ាងរឹងមាំនៅពេលនេះ ។ ខ្ញុំបានផ្ញើសារទៅនិយោជកនោះពីកង្វល់របស់ខ្ញុំ ដោយគិតថាគាត់នឹងមានការអាក់អន់ចិត្ត ។ ប៉ុន្តែបំណងប្រាថ្នាដ៏ធំបំផុតរបស់ខ្ញុំគឺធ្វើឲ្យព្រះវរបិតាសួគ៌មានព្រះទ័យរីករាយ ។

នៅពេលពិធីជប់លៀងនោះបានចាប់ផ្តើម ចៅហ្វាយខ្ញុំមិនបាននិយាយ ឬ ញញឹមរកខ្ញុំទេ ។ ប៉ុន្តែគាត់បានលុបចោលកម្មវិធីអ្នករាំ និង វីដេអូ ។

បន្ទាប់ពីពិធីជប់លៀងនោះមកជាច្រើនថ្ងៃ ចៅហ្វាយខ្ញុំមិនបាននិយាយ និងសើចរកខ្ញុំដូចដែលគាត់ធ្លាប់មានកាលពីមុនពិធីជប់លៀងនោះឡើយ ។ ប៉ុន្តែខ្ញុំមានអារម្មណ៍ស្រណុកក្នុងចិត្ត ដោយសារខ្ញុំបានដឹងថា ព្រះមានព្រះទ័យរីករាយនឹងអ្វីដែលខ្ញុំបានធ្វើ ។ ប្រមាណជាមួយសប្តាហ៍ក្រោយមក ទំនាក់ទំនងរបស់ខ្ញុំនឹងចៅហ្វាយខ្ញុំបានត្រឡប់មកដូចជាធម្មតាវិញ ។ ខ្ញុំដឹងថា ព្រះបានបន្ទន់ចិត្តគាត់ ហើយបានជួយគាត់ឲ្យដឹងថា ខ្ញុំបានរស់នៅតាមអ្វីដែលខ្ញុំជឿ ។

ឡេមី ឡាប៊ីតាក់ កាហ្គាយ៉ាន វ៉ាលី ប្រទេសហ្វីលីពីន



## ខ្ញុំបានឮពាក្យសម្ដីជេរប្រមាថនៅក្នុងថ្នាក់

កាលខ្ញុំអាយុប្រហែលជា 18 ឆ្នាំ ខ្ញុំបានចូលរៀនក្នុងថ្នាក់ដេរប៉ាក់មួយ ។ នៅថ្ងៃមួយមានក្មេងស្រីបីនាក់នៅចម្ងាយពីខ្ញុំពីរទៅបីម៉ែត្របានចាប់ផ្ដើមប្រើពាក្យសម្ដីជេរប្រមាថ ។ ខ្ញុំមិនដឹងថាខ្ញុំគួរតែកុំអើរពើរនឹងពួកគេដើម្បីកុំឲ្យមានការឈ្លោះប្រកែកគ្នា ឬខ្ញុំគួរតែឈរការពារបទដ្ឋានរបស់ខ្ញុំ ហើយសុំឲ្យពួកគេឈប់និយាយពាក្យទាំងនោះ ។ នៅទីបំផុត ខ្ញុំបាននិយាយពាក្យល្អៗតាមដែលខ្ញុំអាចធ្វើបានថា « អត់ទោស សូមអ្នកទាំងអស់គ្នាមេត្តាប្រើពាក្យសម្ដីឲ្យសមរម្យបានទេ ?

ក្មេងស្រីដែលធំជាងគេបានមើលមុខខ្ញុំ ហើយតបថា « យើងនិយាយអ្វីស្រេចតែយើង » ។

ខ្ញុំក៏តបថា « តែឯងត្រូវតែប្រើពាក្យជេរដោយខានមិនបានឬ ? វារំខានដល់ចិត្តខ្ញុំណាស់ » ។

នាងតបថា « អញ្ចឹងកុំស្ដាប់អី » ។

ខ្ញុំបានចាប់ផ្ដើមរកាំចិត្ត ហើយតបថា « មិនឲ្យខ្ញុំស្ដាប់យ៉ាងម៉េចបាន បើឯងនិយាយឮៗបែបនេះ » ។

នាងតបថា « អញ្ចឹងទ្រាំទៅ » ។

ខ្ញុំបានចុះចាញ់ ។ ខ្ញុំបានខឹងនឹងក្មេងស្រីទាំងនោះ ជាពិសេសគឺខឹងនឹងខ្លួនឯង ។ ខ្ញុំមិនចង់ជឿថា ខ្ញុំនិយាយចាញ់គេសោះ ។ ក្មេងស្រីទាំងនោះនៅតែបន្តប្រើពាក្យជេរប្រមាថ ហើយនៅពេលនេះយើងទាំងអស់គ្នាចាប់ផ្ដើមខឹង ។

បន្ទាប់ពីខ្ញុំបានស្ងប់ចិត្ត ខ្ញុំបានឃើញថា ក្មេងស្រីទាំងនោះកំពុងមានបញ្ហាជាមួយនឹងម៉ាស៊ីនដេររបស់ពួកគេ ។ ខ្ញុំបានដឹងថាវាខូចអ្វី ដោយសារខ្ញុំធ្លាប់មានបញ្ហាដូចគ្នាកាលពីមុន ។ ដូច្នេះខ្ញុំបានបង្ហាញពួកគេពីរបៀបជួសជុលវា ។ ខ្ញុំបានឃើញទឹកមុខរបស់ក្មេងស្រីដែលធំជាងគេបានផ្លាស់ប្ដូរ ។ នាងនិយាយថា « នែ ! ឲ្យពួកយើងសុំទោស » ។ ខ្ញុំមិនចង់ជឿទេ—នាងបានសុំទោស ។ ខ្ញុំបានប្រាប់នាងថា « ខ្ញុំក៏សុំទោសដែរ » ។ « ខ្ញុំមិនគួរខឹងបែបនោះទេ » ។

ខ្ញុំបានដើរត្រឡប់ទៅម៉ាស៊ីនដេររបស់ខ្ញុំវិញ ហើយមិនបានឮពាក្យជេរប្រមាថទៀតឡើយ ។ បទពិសោធន៍នោះបានបង្រៀនខ្ញុំថា ពាក្យសម្ដីយើងប្រហែលជាមិនអាចផ្លាស់ប្ដូរឥរិយាបថរបស់អ្នកដទៃបានឡើយ ប៉ុន្តែសេចក្ដីសប្បុរស និង ការបម្រើជារឿយៗអាចធ្វើឲ្យវាកើតឡើងបាន ។

យេធី ផែក រដ្ឋយូថាហ៍ ស.រ.អា.







## ខ្ញុំបានការពារការបម្រើបេសកកម្ម

ខ្ញុំបានចូលក្នុងសាសនាចក្រកាលខ្ញុំអាយុ 19 ឆ្នាំ ខ្ញុំជាកូនប្រុសទីពីរក្នុងចំណោមកូនប្រុសបីនាក់ ហើយជាពួកបរិសុទ្ធថ្ងៃចុងក្រោយតែម្នាក់គត់ក្នុងគ្រួសារខ្ញុំ ។ ក្រោយពីបុណ្យជ្រមុជទឹកមិនយូរប៉ុន្មាន ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍ពីបំណងប្រាថ្នាដើម្បីបម្រើបេសកកម្ម ។ មួយឆ្នាំក្រោយមក ព្រះវិញ្ញាណមានបន្ទូលប្រាប់ខ្ញុំថា ខ្ញុំគួរតែទៅ ។ ខ្ញុំបាននិយាយនឹងម្ដាយខ្ញុំ ដែលគាត់មានអារម្មណ៍ថាខ្ញុំមិនគួរទៅទេ ។ ខ្ញុំបានពន្យារពេលមួយឆ្នាំទៀត ប៉ុន្តែបំណងប្រាថ្នាបម្រើបេសកកម្មមិនដែលរសាយចេញពីចិត្តខ្ញុំឡើយ ។ នៅឆ្នាំនោះ ខ្ញុំបានសិក្សាព្រះគម្ពីរ សន្សំប្រាក់ រៀបចំឯកសារ ធ្វើការពិនិត្យសុខភាព ហើយ—បន្ទាប់ពីអ្វីៗគ្រប់យ៉ាងបានធ្វើអស់ហើយ—ខ្ញុំបានរង់ចាំព្រះអម្ចាស់ ។ មិនយូរប៉ុន្មាន ខ្ញុំបានទទួលការហៅមួយឲ្យបម្រើនៅបេសកកម្មកំពីណាស់ ប្រទេសប្រេស៊ីល ។

ឪពុកម្ដាយខ្ញុំនៅតែជំទាស់ ។ ខ្ញុំបានតមអាហារ ហើយបានអធិស្ឋានដោយឥតលាក់លាម ដោយប្រាប់ទៅព្រះវរបិតាសួគ៌នូវរាល់ការភ័យខ្លាចរបស់ខ្ញុំ ។ ខ្ញុំបានសូមទ្រង់ឲ្យបន្ទន់ចិត្តឪពុករបស់ខ្ញុំ ។ ទ្រង់បានធ្វើមែន ។ គួរឲ្យភ្ញាក់ផ្អើល ឪពុកខ្ញុំបានចូលរួមក្នុងពិធីជប់លៀងលាគ្នាដែលមិត្តខ្ញុំបានរៀបចំសម្រាប់ខ្ញុំនៅថ្ងៃសៅរ៍ពីមុនខ្ញុំចាកចេញទៅ ។ ហើយនៅថ្ងៃច័ន្ទ ឪពុកខ្ញុំបានជូនខ្ញុំទៅអាកាសយានដ្ឋាន ។

នៅក្នុងបេសកកម្មរបស់ខ្ញុំ ខ្ញុំបានទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ព្រះ កាលខ្ញុំបានប្រកាសពីដំណឹងល្អ ។ ម្ដាយខ្ញុំនៅតែបន្តធ្វើម្ដាយដ៏ល្អ ហើយកាលខ្ញុំបានត្រឡប់មកផ្ទះវិញ គាត់គឺជាមនុស្សដំបូងគេដែលបានឱបខ្ញុំ ។

ខ្ញុំបានរៀនថា ការបម្រើបេសកកម្មគឺមានតម្លៃលើសពីកាតព្វកិច្ចមួយទៅទៀត វាគឺជាឯកសិទ្ធិ និង ជាគ្រាដ៏អស្ចារ្យមួយនៃការរីកចម្រើន និង ការរៀនសូត្រ ។

ក្លេសុង វែលីងតុន អាម៉ូរីម ប្រ៊ីតូ ប៉ាប៉ា ប្រទេសប្រេស៊ីល

## ខ្ញុំបានថ្លែងទីបន្ទាល់ពីព្រះ

ក្នុងនាមជានិស្សិតថ្មីម្នាក់នៅក្នុងសាកលវិទ្យាល័យដ៏ល្អបំផុតរបស់ប្រទេសយើង ខ្ញុំទទួលនូវសម្ពាធដើម្បីធ្វើឲ្យអស់ពីលទ្ធភាពរបស់ខ្ញុំ ។ ការបៀតបៀនបានកើតឡើង ហើយខ្ញុំបានចាប់ផ្ដើមសួរពីជំនឿរបស់ខ្ញុំលើដំណឹងល្អ កាលសាស្ត្រាចារ្យរបស់ខ្ញុំជាច្រើនបានពន្យល់ពីអ្វីដែលពួកគាត់ហៅថា « ជីវិតពិត » ។ មិត្តរួមថ្នាក់ខ្ញុំជាច្រើនឲ្យតម្លៃថាវាអស្ចារ្យ ។ បរិយាកាសនេះបានធ្វើឲ្យមានការពិបាកក្នុងការប្រកាន់ខ្ជាប់នូវគុណតម្លៃជាគ្រីស្ទាន ។ ខ្ញុំបានគិតពីការឈប់ ប៉ុន្តែខ្ញុំបានសម្រេចចិត្តថាវាជាការប្រសើរដើម្បីបន្តរស់នៅតាមគុណតម្លៃនោះ ។ ហើយខ្ញុំសួរខ្លួនឯងថា ប្រសិនបើមានតែមនុស្សប៉ុន្មាននាក់ប៉ុណ្ណោះដែលមានលក្ខណៈសម្បត្តិចូលមកក្នុងសាកលវិទ្យាល័យនេះ ហើយក្នុងចំណោមមនុស្សប៉ុន្មាននាក់នោះមានពួកបរិសុទ្ធថ្ងៃចុងក្រោយតែពីរបីនាក់ប៉ុណ្ណោះ ដូច្នេះខ្ញុំគួរបន្ត ហើយឈរការពារសេចក្ដីពិត ។

សាស្ត្រាចារ្យផ្នែកជីវវិទ្យារបស់ខ្ញុំ ជាអ្នកដែលមិនជឿលើព្រះ បានបង្រៀនពីវិទ្យាសាស្ត្រដោយគ្មានជំនឿណាមួយទៅលើព្រះឡើយ ។ ប៉ុន្តែកាលខ្ញុំស្ដាប់កាន់តែច្រើន វាបញ្ជាក់ប្រាប់ខ្ញុំថាមានព្រះដ៏ខ្ពស់បំផុតមួយអង្គ—ជាព្រះវរបិតាយើង—ដែលបានបង្កើតវត្ថុសព្វសារពើ ។ អ្នកដទៃទៀតបានប្រកែកថាគំនិតនេះមិនសមហេតុផលទេ ។ ការពិភាក្សារបស់យើងកាន់តែមានភាពតានតឹង ។ ខ្ញុំមានចិត្តបារម្ភដើម្បីលើកដៃខ្ញុំឡើង ហើយពន្យល់ថាខ្ញុំជឿលើព្រះជាព្រះដ៏បង្កបង្កើត ។

ពេលផ្ដល់មតិបានមកដល់ ។ នៅឯសាលារបស់ខ្ញុំ វាជារឿងធម្មតាដើម្បីទះដៃអបអរ ស្រែក ឬ សម្ដែងការមិនពេញចិត្តដល់អ្នកដែលបង្ហាញពីគំនិតរបស់ពួកគេ ។ ខ្ញុំបានឈរយ៉ាងម៉ឺងម៉ាត់ ហើយនិយាយយ៉ាងច្បាស់ទៅដល់ក្រុមជំទាស់ថា ៖ « ការជឿលើព្រះប្រហែលជាមិនសមហេតុផលសម្រាប់អ្នកនៅពេលនេះ ប៉ុន្តែថ្ងៃនោះនឹងមកដល់ ជាពេលដែលនឹងសមហេតុផលចំពោះអ្នកយ៉ាងច្បាស់ដូចជាខ្ញុំនៅពេលនេះដែរ » ។

ចាប់ពីពេលនោះមក ខ្ញុំមិនដែលទទួលការស្រែកជំទាស់ណាមួយ ពេលខ្ញុំក្រោកឈរការពារជំនឿរបស់ខ្ញុំឡើយ ។ ពេលក្រោយមកទៀត ខ្ញុំបានរីកចម្រើនទាំងខាងការអប់រំសង្គម និង ខាងវិញ្ញាណ ។ ខ្ញុំបានចាប់ផ្ដើមសកម្មនៅក្នុងសកម្មភាពរបស់សិស្ស ហើយបានត្រូវបានផ្ដល់ឲ្យនូវមុខតំណែងនៅសាលាមួយចំនួន ។

ខ្ញុំបានរៀនថា ការឈរការពារសេចក្ដីពិតសូម្បីតែម្ដង វាជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ការសម្រេចចិត្តពេលអនាគតរបស់យើង ។

វីនស៍ អេ. ម៉ូឡេចាន់ ជុញ៉ូរ, មីនដាណៅ ប្រទេសហ្វីលីពីន

**កំណត់ចំណាំ**

1. សូមមើល ជែហ្វ្រី អ័រ ហូឡិន « The Cost—and Blessings —of Discipleship » *Liahona* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 6 ។

# ទីបន្ទាល់រួមគ្នាតែមួយរបស់ខ្ញុំ

ដោយ អាយរី ណុច

**ចំពោះខ្ញុំ សេចក្ដីពិតដ៏ពេញលេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និង សេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរមរមនគឺរួមគ្នាតែមួយ ។ ប្រសិនបើដំណឹងល្អពិត នោះព្រះគម្ពីរមរមនពិត ។**

ពួកអ្នកផ្សព្វផ្សាយសាសនាបង្រៀនគ្រួសារខ្ញុំពីដំណឹងល្អក្នុងផ្ទះរបស់យើងក្នុងប្រទេសសិង្ហបុរី ។ ឪពុកខ្ញុំមិនបានចូលក្នុងសាសនាចក្រទេ ប៉ុន្តែម្ដាយខ្ញុំបានចូល ។ គាត់បានបង្រៀនយើងពីព្រះយេស៊ូវគ្រីស្ទ និងពីដំណឹងល្អរបស់ទ្រង់ ។ សូម្បីតែកាលពីក្មេង ខ្ញុំបានប្រាប់ដល់មិត្តខ្ញុំដោយមោទនភាពថា ខ្ញុំជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ខ្ញុំតែងទុកចិត្តលើការបង្រៀនរបស់ម្ដាយខ្ញុំ ។ ប៉ុន្តែកាលខ្ញុំធំក្នុងវ័យជាមជ្ឈិមវ័យវ័យក្មេង មានអ្នកផ្សព្វផ្សាយសាសនាម្នាក់បានសួរខ្ញុំថា ខ្ញុំបានអានព្រះគម្ពីរមរមនប៉ុន្មានដងហើយ ។ ខ្ញុំធ្លាប់ត្រូវបានគេសួរសំណួរនេះពីមុន ប៉ុន្តែពេលនេះខ្ញុំបានដឹងថា ដោយសារខ្ញុំមិនបានអានព្រះគម្ពីរមរមន ខ្ញុំមិនដឹងថាវាពិតដែរឬអត់នោះទេ ។

## ការពិតមួយដែលមិនអាចបដិសេធបាន

ខ្ញុំមិនអាចគេចវេសពីការពិតមួយដែលមិនអាចបដិសេធបានថា ៖ សេចក្ដីពិតដ៏ពេញលេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និង សេចក្ដីពិតដ៏ពេញលេញនៃព្រះគម្ពីរមរមនគឺរួមគ្នាតែមួយ ។ ប្រសិនបើដំណឹងល្អពិត នោះព្រះគម្ពីរមរមនពិត ។ ដោយសារខ្ញុំមិនដឹងថាព្រះគម្ពីរមរមនពិតដែរឬអត់ ឥឡូវនេះខ្ញុំមានអារម្មណ៍សង្ស័យចំពោះអ្វីៗគ្រប់យ៉ាងដែលខ្ញុំបានជឿតាំងពីក្មេងមក ។ គំនិតខ្ញុំពោរពេញដោយភាពច្របូកច្របល់ ហើយសំណួរដែលថា— « តើព្រះគម្ពីរមរមនពិតដែរឬទេ ? » —បានបន្តមាននៅក្នុងដួងចិត្តខ្ញុំ ។

ការកើនឡើងនូវទំនាក់ទំនងនឹងព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ក៏បានដឹងនាំខ្ញុំឲ្យចង់បានសេចក្ដីពិតផងដែរ ។ នៅថ្ងៃដែលខ្ញុំបានដឹងថា ខ្ញុំមិនរៀនពីព្រះយេស៊ូវគ្រីស្ទបានពេញលេញឡើយ ប្រសិនបើគ្មានការអានព្រះគម្ពីរមរមនដោយយកចិត្តទុកដាក់នោះ គឺជាថ្ងៃដែលខ្ញុំចង់ដឹងយ៉ាងខ្លាំងថាតើព្រះគម្ពីរនោះពិតដែរឬអត់ ។

## បានហៅជាគ្រូបង្រៀន

ខ្ញុំបានអធិស្ឋានសូមការដឹកនាំ ។ នៅពេលនេះប្រធានសាខាខ្ញុំបានហៅខ្ញុំឲ្យបង្រៀនពីព្រះគម្ពីរមរមននៅក្នុងថ្នាក់បង្រៀនគោលលទ្ធិដំណឹងល្អ ។ ខ្ញុំបានទទួលយកការហៅនោះ ដោយសារខ្ញុំមានអារម្មណ៍ថាវាអាចជាចម្លើយរបស់ព្រះអម្ចាស់ ដើម្បីជួយខ្ញុំឲ្យដឹងពីសេចក្ដីពិតនៃព្រះគម្ពីរមរមន ហើយខិតជិតនឹងព្រះអង្គសង្គ្រោះ ។

ការបង្រៀនមានការលំបាកណាស់ ។ បន្ទាប់ពីពីរបីសប្ដាហ៍ដំបូងមក ខ្ញុំបានដឹងថា ខ្ញុំការបង្រៀនរបស់ខ្ញុំនឹងគ្មានប្រសិទ្ធភាពឡើយរហូតដល់ខ្ញុំជឿលើព្រះគម្ពីរមរមន ។

**ដំណើររឿងបានបើកសម្ដែងមួយជំពូកម្ដងៗ**

ខ្ញុំបានចាប់ផ្ដើមសិក្សាព្រះគម្ពីរមរមនរាល់សប្ដាហ៍ ហើយមិនយូរប៉ុន្មានបានរកឃើញនូវសេចក្ដីអំណរនៅក្នុងការអានរបស់ខ្ញុំ ។ ដំណើររឿងនៅក្នុងព្រះគម្ពីរមរមនបានបើកសម្ដែងមួយជំពូកម្ដងៗ ហើយបាននាំខ្ញុំខិតទៅជិតព្រះយេស៊ូវគ្រីស្ទ ។

ខ្ញុំបានអានពីការប្រសូតរបស់ព្រះគ្រីស្ទដែលនីហ្វៃបានឃើញនៅក្នុងការនិមិត្តមួយថា ៖

« ហើយខ្ញុំបានឃើញភូមិណាសារ៉ែត ហើយនៅភូមិណាសារ៉ែត ខ្ញុំបានឃើញនាងព្រហ្មចារីម្នាក់ ហើយនាងស្រស់ល្អ ហើយសដ៏លើសលប់ ។ . . .

« ហើយទេវតាមានបន្ទូលមកខ្ញុំថា ៖ មើលចុះ នាងព្រហ្មចារីដែលអ្នកឃើញនោះគឺជាមាតានៃព្រះរាជបុត្រានៃព្រះ ស្របតាមខាងឯសាច់ឈាម » ( នីហ្វៃទី 1 11:13, 18 ) ។

ខ្ញុំបានអានពីផែនការនៃសុភមង្គល ហើយបានរៀនថា សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទគឺជាចាំបាច់ចំពោះសេចក្ដីសង្គ្រោះយើង ។ អាមូលេកបានបង្រៀនថា ៖

« ខ្ញុំដឹងថាព្រះគ្រីស្ទនឹងយាងមកក្នុងចំណោមកូនចៅមនុស្ស ដើម្បីទទួលយកនូវអំពើរំលងទាំងឡាយនៃប្រជារាស្ត្ររបស់ទ្រង់ ហើយថាទ្រង់នឹងធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក ព្រោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

« . . . ត្បិតស្របតាមផែនការដ៏មហិមានៃព្រះដ៏នៅអស់កល្បជានិច្ច នោះត្រូវតែមានដង្វាយធួនមួយកើតឡើង បើពុំនោះសោតទេ មនុស្សលោកទាំងអស់នឹងពុំអាចចៀសផុតពីសេចក្ដីវិនាសបានឡើយ » (អាលម៉ា 34:8–9) ។

ខ្ញុំបានអានពីព្រះយេស៊ូវគ្រីស្ទបម្រើដល់រាស្ត្រផ្សេងទៀតរបស់ទ្រង់នៅទ្វីបអាមេរិកសម័យបុរាណ ហើយខ្ញុំបានដឹងថា ទ្រង់គឺជាព្រះនៃគ្រប់ជាតិសាសន៍ ។ ទ្រង់មានបន្ទូលប្រាប់ទៅសាសន៍នីហ្វៃថា ៖ « អ្នករាល់គ្នាគឺជាពួកអ្នកដែលយើងបាននិយាយថា ៖ យើងក៏មានចៀមឯទៀតដែលមិននៅក្នុងក្រោលនេះនៅឡើយ ត្រូវតែយើងនាំចៀមទាំងនោះមកដែរ ហើយវានឹងស្ដាប់តាមសំឡេងយើង នោះនឹងមានក្រោលតែមួយ និងអ្នកគង្វាលតែមួយវិញ » ( នីហ្វៃទី 3 15:21 ) ។

**ទីបន្ទាល់ខ្ញុំកើតមានបន្តិចម្ដងៗ**

កាលខ្ញុំអានព្រះគម្ពីរមរមន សេចក្ដីជំនឿរបស់ខ្ញុំលើព្រះយេស៊ូវគ្រីស្ទបានភ្លឺ ហើយការយល់ដឹងរបស់ខ្ញុំស្ដីពីផែនការរបស់ទ្រង់បានកើនឡើង ( សូមមើល អាលម៉ា 32:28 ) ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះគម្ពីរមរមនគឺជាមូលដ្ឋាននៃសាសនារបស់យើង ។ ព្រះវិញ្ញាណបរិសុទ្ធបានបើកបង្ហាញដល់ខ្ញុំថា យ៉ូសែបស្ម៊ីធ គឺជាព្យាការីពិតមួយរូបដែលបានស្ដារសាសនាចក្រព្រះឡើងវិញនៅលើផែនដីនេះ និងជាអ្នកដែលបានបកប្រែព្រះគម្ពីរមរមនចេញពីផ្ទាំងចំណារមាសនោះ ។ ព្រះគម្ពីរមរមនថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ហើយធ្វើការទន្ទឹមគ្នានឹងព្រះគម្ពីរប៊ីប ។ ព្រះគម្ពីរទាំងពីរនេះថ្លែងទីបន្ទាល់រួមគ្នាថា ព្រះយេស៊ូវគ្រីស្ទគឺពិតជាព្រះរាជបុត្រានៃព្រះ ហើយថាទ្រង់គឺជាព្រះនៃ*គ្រប់*ជាតិសាសន៍ មិនមែនតែមួយនោះទេ ។ ■

*អ្នកនិពន្ធរស់នៅប្រទេសសិង្ហបុរី ។*



**មូលដ្ឋាននៃសាសនារបស់យើង**

« ដូចជាក្លោងទ្វារនឹងត្រូវបាក់ធ្លាក់ចុះ បើសិនជាសិលាគ្រឹះ ឬមូលដ្ឋានត្រូវដកចេញដូចគ្នានេះដែរ សាសនាចក្រនឹងឈរ ឬលិចចុះដោយសារសេចក្ដីពិតពេញលេញនៃព្រះគម្ពីរមរមន ។ . . . បើព្រះគម្ពីរមរមនពិត—ហើយមនុស្សរាប់លាននាក់ក្នុងបច្ចុប្បន្ននេះបានធ្វើទីបន្ទាល់ថាពួកគេមានសាក្សីពីព្រះវិញ្ញាណថា ព្រះគម្ពីរមរមនគឺពិតយ៉ាងប្រាកដ—ដូច្នេះនោះមនុស្សម្នាក់ត្រូវតែទទួលយកនូវការអះអាងនៃការស្ដារឡើងវិញ និងអ្វីៗទាំងអស់ដែលមានជាប់ទាក់ទងនឹងវាផងដែរ » ។

ប្រធាន អែសរ៉ា ថាហ្វ បែនសឹន (1899–1994) នៅក្នុង*ប្រកាសដំណឹងល្អទ្រង់ ៖ សៀវភៅណែនាំសម្រាប់ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ 2004 ) ទំព័រ 106 ។

# ~~សិទ្ធិសេរីភាពជ្រើសរើស~~ ឬ សិទ្ធិជ្រើសរើសខាងសីលធម៌ ?

*ការប្រើប្រាស់សិទ្ធិជ្រើសរើសដោយឆ្លាតវៃ ធ្វើឲ្យការជ្រើសរើសយើងមានភាពទំលំទូលាយ ហើយអភិវឌ្ឍសមត្ថភាពយើងដើម្បីជ្រើសរើសដោយត្រឹមត្រូវ ។*

**ដោយ ម៉ែគល អរ ម៉ូរីស**
ទស្សនាវដ្ដីសាសនាចក្រ



ខ្ញុំនៅចាំពីការព្រួយបារម្ភដែលខ្ញុំមាន កាលខ្ញុំរៀបចំខ្លួនជួបនឹងប៊ីស្សពរបស់ខ្ញុំអំពីការបម្រើបេសកកម្ម ។ ខ្ញុំបានងឿងឆ្ងល់ថាតើខ្ញុំល្អគ្រប់គ្រាន់ហើយឬនៅ ។ ដូចជាព្យាការី យ៉ូសែប ស្ម៊ីធដែរ ខ្ញុំគ្មាន « ទោសដ៏ធំ ឬបាបដ៏ធ្ងន់នោះឡើយ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:28 ) ប៉ុន្តែខ្ញុំមានការព្រួយបារម្ភដូចគ្នា ។



ខ្ញុំព្រួយដោយសារខ្ញុំចេះតែគិតពីមិត្តរបស់ខ្ញុំឈ្មោះខេននី ( ឈ្មោះត្រូវបានផ្លាស់ប្ដូរ ) ។ អស់រយៈពេលជាច្រើនឆ្នាំ ខេននី បាននិយាយពីអារម្មណ៍ដែលគាត់ទន្ទឹងរង់ចាំយ៉ាងអន្ទះសារចំពោះការបម្រើបេសកកម្មមួយ ។ ប៉ុន្តែវាបានផ្លាស់ប្ដូរ បន្ទាប់ពីគាត់បានជួបនឹងប៊ីស្សព ។

ដោយសារខេននីបានធ្វើនូវឥរិយាបថដែលមិនសក្ដិសមជាមួយនឹងយុវនារីមួយចំនួន ដែលក្រោយមកគាត់បានប្រាប់ខ្ញុំ នោះគាត់គ្មានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីបម្រើជាអ្នកផ្សាយសាសនាពេញម៉ោងឡើយ ។ គាត់លែងមានសិទ្ធិជ្រើសរើសបម្រើបេសកកម្មទៀតហើយ ។

នៅក្នុងប្រសាសន៍របស់ប្រធាន ប៊យដ៏ ឃេ ផាកកឺ ជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ខេននីបានធ្លាក់ទៅក្នុងការល្បួងរបស់សាតាំង « ដោយប្រើសិទ្ធិជ្រើសរើសខាង



សីលធម៌ [ របស់គាត់ ] ខុស » ។[1]

សេរីភាពពិត ដូចដែល*ដើម្បីកម្លាំងនៃយុវជន*បង្រៀន កើតឡើងនៅពេលយើងប្រើសិទ្ធិជ្រើសរើសរបស់យើងដើម្បីជ្រើសយកការគោរពប្រតិបត្តិ ។ ការបាត់បង់សេរីភាព ដូចដែលឌេននីបានរៀន កើតឡើងពីការជ្រើសមិនគោរពប្រតិបត្តិ ។

« ខណៈពេលដែលអ្នកមានសេរីភាពដើម្បីជ្រើសរើសទង្វើរបស់អ្នក នោះអ្នកពុំមានសេរីភាពដើម្បីជ្រើសរើសលទ្ធផលវាទេ ។ ទោះបីជាល្អ ឬអាក្រក់ក្តី លទ្ធផលនឹងកើតមានតាមក្រោយ ជាលទ្ធផលពីធម្មជាតិមួយនៃជម្រើសដែលអ្នកបានរើស » ។[2]

## ភ្នាក់ងារចំពោះខ្លួនយើង

ដោយសារព្រះគម្ពីរបង្រៀនថា យើងមាន « សិទ្ធិនឹងរើសយក » « សេរីភាពដើម្បីធ្វើអ្វីៗ » និងសេរីភាពដើម្បីធ្វើរឿងទាំងឡាយ « តាមបំណងចិត្ត [ របស់យើង ] » ( នីហ្វៃទី 2 2:27, 10:23, គ. និង ស. 58:27, ហេលេមិន 14:30 ) ជារឿយៗ យើងប្រើពាក្យថា « សេរីភាពជ្រើសរើស » ។

ប៉ុន្តែតើអ្នកដឹងទេថាឃ្លា « សេរីភាពជ្រើសរើស » គ្មាននៅក្នុងព្រះគម្ពីរដែរទេ ? ផ្ទុយទៅវិញ ព្រះគម្ពីរបង្រៀន « ថាមនុស្សគ្រប់រូបអាចប្រព្រឹត្តនូវគោលលទ្ធិ និង គោលការណ៍ . . . តាម*សិទ្ធិជ្រើសរើសខាងសីលធម៌*ដែលយើងបានប្រទានដល់គេ ប្រយោជន៍ឲ្យមនុស្សគ្រប់រូបអាចបានទទួលការខុសត្រូវចំពោះអំពើបាបទាំងឡាយរបស់ខ្លួននៅថ្ងៃជំនុំជំរះ » (គ. និង ស. 101:78 ការគូសបញ្ជាក់បានបន្ថែម ) ។

អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « ពាក្យថា *សិទ្ធិជ្រើសរើស*មាន [ នៅក្នុងព្រះគម្ពីរ ] ដាច់ដោយឡែកតែឯង ឬផ្សំជាមួយនឹងពាក្យ *សីលធម៌* ។ . . . ពេលយើងប្រើពាក្យ *សិទ្ធិជ្រើសរើសខាងសីលធម៌*យើងកំពុងគូសបញ្ជាក់ដោយសមរម្យនូវទំនួលខុសត្រូវដែលគឺជាផ្នែកមួយដ៏សំខាន់នៃអំណោយទានដ៏ទេវភាពនៃសិទ្ធិជ្រើសរើស ។ យើងគឺជាមនុស្សដែលមានសីលធម៌ ហើយជាភ្នាក់ងារចំពោះខ្លួនយើង មានសេរីភាពនឹងជ្រើសរើស ប៉ុន្តែយើងក៏ទទួលខុសត្រូវចំពោះការជ្រើសរើសរបស់យើងផងដែរ » ។[3]

ប្រធាន ផាកកឺ បានបន្ថែមថា « សិទ្ធិជ្រើសរើសត្រូវបានឲ្យនិយមន័យនៅក្នុងព្រះគម្ពីរថាជា « សិទ្ធិជ្រើសរើសខាងសីលធម៌ » ដែលមានន័យថា យើងអាចជ្រើសយករវាងល្អ និង អាក្រក់ » ។[4] អំណោយទានដែលព្រះបានប្រទានឲ្យនេះមានន័យថា យើងមាន « សេរីភាពរើសយកឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះជាអ្នកសង្រ្គោះដ៏ធំរបស់មនុស្សលោកទាំងអស់ ឬ ក៏រើសយកការជាប់ឃុំឃាំង និង ការស្លាប់ស្របតាមការជាប់ឃុំឃាំង និង អំណាចរបស់អារក្ស » ( នីហ្វៃទី 2 2:27 ) ។

## សង្គ្រាមរបស់សាតាំងប្រឆាំងនឹងសិទ្ធិជ្រើសរើស

ដោយសារសិទ្ធិជ្រើសរើសខាងសីលធម៌ដើរតួយ៉ាងសំខាន់នៅក្នុងផែនការសង្គ្រោះ សាតាំងបានខិតខំដើម្បីបំផ្លាញវានៅពិភពមុនឆាកជីវិតនេះ ។ វាត្រូវបានបណ្តេញចេញដោយសារការបះបោរ ហើយឥឡូវនេះវាខិតខំ « ដើម្បីបញ្ឆោត ហើយដើម្បីធ្វើឲ្យមនុស្សខ្វាក់ ហើយដើម្បីដឹកពួកគេយកទៅជាឈ្លើយ » ( ម៉ូសេ 4:3–4 ) ។

សាតាំងចង់ឲ្យយើងធ្វើការជ្រើសរើសដែលកំណត់នូវសេរីភាពរបស់យើង ដឹកនាំទៅរកទម្លាប់អាក្រក់ និង ការញៀន ហើយធ្វើឲ្យយើងគ្មានអំណាចដើម្បីតតាំងនឹងការល្បួងរបស់វា ។ ភាពស្រស់ស្អាតនៃដំណឹងល្អគឺថាដំណឹងល្អធ្វើឲ្យយើងដឹងពីការជ្រើសរើសរបស់យើង និងលទ្ធផលនៃការជ្រើសរើសទាំងនោះ ។ ការប្រើប្រាស់សិទ្ធិជ្រើសរើសដោយឆ្លាតវៃធ្វើឲ្យការជ្រើសរើសយើងមានភាពទំលំទូលាយ ហើយអភិវឌ្ឍសមត្ថភាពយើងដើម្បីជ្រើសរើសដោយត្រឹមត្រូវ ។

## គំរូរបស់ព្រះអង្គសង្គ្រោះ

នៅពេលផែនការសង្គ្រោះត្រូវបានបង្ហាញនៅក្នុងក្រុមប្រឹក្សាដ៏ធំនៅស្ថានសួគ៌ ព្រះអង្គសង្គ្រោះបានបង្ហាញយើងពីរបៀបប្រើសិទ្ធិជ្រើសរើសខាងសីលធម៌របស់យើងឲ្យបានត្រឹមត្រូវ ។ ទ្រង់បានមានបន្ទូលថា « ព្រះវរបិតាអើយ សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេច ហើយសូមឲ្យសិរីល្អរបស់ព្រះអង្គបានជារបស់ផងព្រះអង្គរហូត » ( ម៉ូសេ 4:2 ) ។ ដោយសារទ្រង់មានឆន្ទៈធ្វើតាមព្រះទ័ររបស់ព្រះវរបិតានៅពេលនោះ ហើយក្រោយមកទៀតនៅសួនច្បារគែតសេម៉ានី និងនៅលើឈើឆ្កាង ( សូមមើល ម៉ាថាយ 26:39, លូកា 22:42) នោះព្រះយេស៊ូវបានបង់ថ្លៃសម្រាប់ការជ្រើសរើសមិនល្អរបស់យើង ហើយផ្តល់ផ្លូវសម្រាប់យើងដើម្បីទទួលបានការអត់ទោសតាមរយៈការប្រែចិត្ត ។

ប្រសិនបើយើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះជំនួសឲ្យការនិយាយថា « ខ្ញុំធ្វើអ្វីដែលខ្ញុំចង់ធ្វើ » នោះយើងនឹងប្រកាសថា « ខ្ញុំធ្វើអ្វីដែលព្រះវរបិតាសព្វព្រះទ័យ » ។[5] ការប្រើសិទ្ធិជ្រើសរើសខាងសីលធម៌តាមរបៀបនេះនឹងនាំយកសេរីភាព និងសុភមង្គលមកឲ្យយើង ។

កាលខ្ញុំបានទៅជួបនឹងប៊ីស្សពរបស់ខ្ញុំសម្រាប់ការសម្ភាសលើកដំបូងរបស់ខ្ញុំសម្រាប់បេសកកម្ម ខ្ញុំមានអំណរគុណដែលខ្ញុំបានធ្វើការជ្រើសរើសល្អៗ ។ ប៉ុន្មានខែក្រោយមក ខ្ញុំកំពុង តែបម្រើព្រះអម្ចាស់នៅប្រទេសឃ្វាតេម៉ាឡា—ដោយបង្រៀនដល់មនុស្សដទៃទៀតពីផែនការសង្គ្រោះ និង តួនាទីដ៏សំខាន់របស់សិទ្ធិជ្រើសរើសខាងសីលធម៌នៅក្នុងផែនការនោះ ។ ■

**កំណត់ចំណាំ**

1. ប៊ យដ៏ ឃេ ផាកកឺ « These Things I Know » *Liahona* ខែ ឧសភា ឆ្នាំ 2013 ទំព័រ 8 ។
2. *ដើម្បីកម្លាំងនៃយុវជន* ( ឆ្នាំ 2011 ) ទំព័រ 2 ។
3. ថត គ្រីស្តូហ្វឺសិន « Moral Agency » *Ensign* ខែ មិថុនា ឆ្នាំ 2009 ទំព័រ 47 ។
4. ប៊ យដ៏ ឃេ ផាកកឺ « These Things I Know » ទំព័រ 8 ។
5. សូមមើល វហ្វហ្គេង អេជ ផល « The Gift of Agency » *Liahona* ខែ ឧសភាព ឆ្នាំ 2006 ទំព័រ 35 ។



រចនារូបភាពដោយ ប្រាយអិន ប៊ីច

# « ខ្ញុំកំពុងព្យាយាមគ្រប់គ្រងគំនិតរបស់ខ្ញុំ ប៉ុន្តែមានការល្បួងច្រើនពេក ។ តើខ្ញុំអាចសម្អាតគំនិតខ្ញុំបានដោយរបៀបណា ? »

ការគ្រប់គ្រងគំនិតរបស់អ្នកគឺជារឿងពិបាកណាស់ ប៉ុន្តែវា*អាច*ធ្វើទៅបាន ហើយនាំមកនូវពរជ័យ ៖ « កាលអ្នករៀនគ្រប់គ្រងគំនិតរបស់អ្នក អ្នកអាចយកឈ្នះទម្លាប់នានា សូម្បីតែវាប៉ះពាល់ដល់ទម្លាប់ផ្ទាល់ខ្លួនក្តី ។ អ្នកអាចទទួលបានទំនុកចិត្ត យកឈ្នះលើការភ័យខ្លាច ហើយមានជីវិតមួយដ៏រីករាយ » ។[1] ក៏សូមពិចារណាពីពរជ័យទាំងនេះដែរ ៖

- គំនិតស្អាតស្អំនឹងជួយអ្នកឲ្យ « មានចិត្តក្លាហានឡើងនៅចំពោះវត្តមាននៃព្រះ » ហើយ « ព្រះវិញ្ញាណបរិសុទ្ធនឹងទៅជាគូកនអ្នក » ( គ. និង ស. 121:45–46 ) ។
- គំនិតស្អាតស្អំនឹងជួយអ្នកឲ្យស្គាល់ពីការបំផុសគំនិត ដោយសារព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលទៅកាន់ចិត្ត និង គំនិតរបស់អ្នក ( សូមមើលគ. និង ស. 8:2–3 ) ។
- គំនិតស្អាតស្អំនឹងជួយអ្នកឲ្យគោរពប្រតិបត្តិតាមបទបញ្ញត្តិធំទីមួយ ៖ ដើម្បីស្រឡាញ់ព្រះឲ្យអស់ពីចិត្ត ពីព្រលឹង និង*គំនិត*របស់អ្នក ( សូមមើល ម៉ាថាយ 22:37 ) ។

មានរឿងជាច្រើនដែលអ្នកអាចធ្វើដើម្បីមានគំនិតកាន់តែស្អាតស្អំ ដូចដែលអ្នកនឹងឃើញគំនិតទាំងនោះនៅលើទំព័រទាំងនេះ ។ ប៉ុន្តែរឿងដ៏សំខាន់បំផុតមួយដែលអ្នកអាចធ្វើ—ហើយដែលវាដំណើរការបន្តិចម្តងៗ—គឺការយកឈ្នះលើ « មនុស្សខាងសាច់ឈាម » ។ បុរសឬស្ត្រីខាងសាច់ឈាមប្រៀបដូចជាគំនិតមិនស្អាតស្អំដូច្នោះដែរ ។ នេះជារបៀបដើម្បីយកឈ្នះវា ៖ « មនុស្សខាងសាច់ឈាមជាសត្រូវដល់ព្រះ . . . ហើយនឹងនៅយ៉ាងនេះជារៀងដរាបតទៅ លើកលែងតែគេព្រមធ្វើតាមសេចក្តីទូន្មាននៃព្រះវិញ្ញាណបរិសុទ្ធ ហើយសម្រាតភាពខាងសាច់ឈាមចេញ ហើយក្លាយទៅជាអ្នកបរិសុទ្ធវិញ តាមរយៈដង្វាយធួននៃព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ហើយក្លាយទៅដូចជាកូនក្មេងងាយប្រដៅ ស្លូតបូត ទាបរាបសា អត់ឱន ពោរពេញទៅដោយសេចក្តីស្រឡាញ់ » ( ម៉ូសាយ 3:19 ) ។

តើរឿងមួយដែលអ្នកអាចធ្វើនៅថ្ងៃនេះដើម្បីអញ្ជើញដង្វាយធួនរបស់ព្រះអង្គសង្គ្រោះឲ្យនាំមកនូវការផ្លាស់ប្តូរជីវិតនេះ របស់អ្នកគឺជាអ្វីទៅ ?

**កំណត់ចំណាំ**

1. ប៊ែយដ៏ ខេ ផាកកឺ « Worthy Music, Worthy Thoughts » *Liahona* ខែមេសា ឆ្នាំ 2008 ទំព័រ 31 ។



**ប្រព័ន្ធផ្សព្វផ្សាយ និង មិត្តភក្តិ**

ចំណុចចាប់ផ្តើមដ៏សំខាន់បំផុតមួយគឺការជ្រើសរើសខ្សែភាពយន្តតន្ត្រី និង អត្ថបទល្អៗ ។ ជ្រើសមិត្តភក្តិដែលអ្នកអាចរក្សាឲ្យមានការសន្ទនាដ៏សក្តិសម និង សកម្មភាពសុចរិត ។ កាលអ្នកមានរឿងល្អកាន់តែច្រើនដើម្បីគិត នោះអ្នកនឹងមានភាពងាយស្រួលបន្តិចម្តងៗដើម្បីបំបាត់នូវគំនិតអាក្រក់ ហើយជារឿយៗនឹងមានតិចទៅៗ ។

*អែមបើរ អេស អាយុ 18 ឆ្នាំ កូឡុំប៊ីអង់គ្លេស ប្រទេសកាណាដា*

**ការអធិស្ឋាន**

ការអធិស្ឋាននាំខ្ញុំឲ្យខិតជិតព្រះវរបិតាសួគ៌យើង ហើយជួយខ្ញុំឲ្យគិតពីគំនិតល្អៗ ។ ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃពង្រឹងទំនុកចិត្តខ្ញុំក្នុងការយកឈ្នះលើការល្បួង ។ នៅក្នុងព្រះគម្ពីរអាចឃើញពីគំរូនៃពួកសិស្សដ៏ស្មោះត្រង់របស់ព្រះគ្រីស្ទ ។ ការថ្លែងទីបន្ទាល់របស់ខ្ញុំក៏ជួយខ្ញុំឲ្យរក្សាគំនិតខ្ញុំបានស្អាតស្អំផងដែរ ។

*ដាស្យា អិម អាយុ 17 ឆ្នាំ កៀវ ប្រទេសអ៊ុយក្រែន*



**ព្រះគម្ពីរ**

ការអានព្រះគម្ពីររាល់ព្រឹកពីមុនទៅសាលាអាចជួយបាន ។ នៅពេលខ្ញុំមានគំនិតមិនល្អ ខ្ញុំបានប្តូរវាចេញភ្លាមជាមួយនឹងអ្វីមួយដែលប្រសើរជាង ។ ជាជាងការដែលគ្រាន់តែនិយាយថា « កុំគិតពីរឿងនោះអី » ( ដែលជារឿងល្អមួយដែលត្រូវធ្វើ ) សូមប្តូរវាជាមួយនឹងគំនិតល្អមួយ ។ សូមចងចាំថា អ្នកអាចគ្រប់គ្រងគំនិតរបស់អ្នកបាន ពុំមែនរបស់សាតាំងនោះទេ ។ យើងគឺជាបុត្រាបុត្រីដ៏ក្លាហានរបស់ព្រះវរបិតាសួគ៌ ហើយយើងមានបេសកកម្មយ៉ាងខ្ជាប់ខ្ជួនមួយដើម្បីធ្វើឲ្យខ្លួនយើងបានប្រសើរឡើង។

*នីក ស៊ី អាយុ 16 ឆ្នាំ អាកាន់សាស ស.រ.អា.*



*ចម្លើយទាំងឡាយគឺមានបំណងទុកជាជំនួយ និង ជាទស្សនវិស័យ មិនមែនជា ការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*



**គិតពីរឿងទាំងនេះ**

« ពេលខ្លះនៅក្នុងដំណើរឆ្លងកាត់ជីវិតរមែងស្លាប់ដ៏គ្រោះថ្នាក់នេះ ក៏សូមឲ្យយើងធ្វើតាមការទូន្មានមកពីសាវកប៉ុលផងដែរ ដែលវានឹងជួយការពារយើងឲ្យមានសុវត្ថិភាព ហើយស្ថិតនៅលើផ្លូវនោះ ៖ ‹ ឯសេចក្ដីណាដែលពិត សេចក្ដីណាដែលគួរពប់អាន សេចក្ដីណាដែលសុចរិត សេចក្ដីណាដែលបរិសុទ្ធ សេចក្ដីណាដែលគួរឲ្យស្រឡាញ់ សេចក្ដីណាដែលមានឈ្មោះល្អ បើមានសគុណណា ឬជាសេចក្ដីសរសើរណា នោះចូរពិចារណាពីសេចក្ដីទាំងនោះចុះ › [ ភីលីព 4:8 ] » ។

**ប្រធាន ថូម៉ាស អេស ម៉នសុន « Looking Back and Moving Forward »** ***លីអាហូណា*** **ខែ ឧសភា ឆ្នាំ 2008 ទំព័រ 90 ។**



**ល្អ ឬ ត្រឹមត្រូវ ?**

អ្នកមិនអាចគ្រប់គ្រងគំនិតមួយនឹងផុសចេញមកនោះឡើយ ប៉ុន្តែអាចមានលទ្ធភាពដើម្បីលុបវាចេញ ឬទុកវាឲ្យនៅបាន ។ អ្នកអាចចោទសួរថា ៖ តើគំនិតនេះនឹងមានផលល្អដល់ខ្ញុំដែរឬទេ ? តើវានឹងជួយខ្ញុំឲ្យដើរនៅលើផ្លូវត្រូវដែរឬទេ ? នៅពេលមានគំនិតល្បួងមួយផុសឡើង សូមច្រៀងចម្រៀងល្អមួយ គិតពីអនុស្សាវរីយល្អមួយ ឬអធិស្ឋាន ។ សំខាន់បំផុតគឺការប្ដូរគំនិតអាក្រក់ជាមួយនឹងអ្វីមួយដែលល្អ ។

*លីស្សា ភី អាយុ 17 ប្រទេស ដាណឺម៉ាក*



**គំរូរបស់លីហៃ**

នៅក្នុងនីហ្វៃទី 1 15:27 នីហ្វៃប្រាប់ដល់ពួកបងប្រុសគាត់ថា ឪពុកពួកគេបានហ៊ុមព័ទ្ធដោយភាពកខ្វក់ នៅក្នុងការនិមិត្តរបស់គាត់អំពីដើមឈើជីវិត ។ ប៉ុន្តែលីហៃមិនបានមើលឃើញពីភាពកខ្វក់នោះទេ ដោយសារ « ចិត្តលោករវល់តែគិតដល់រឿងផ្សេងទៀត » ។ ការណ៍នេះនៅតែពិតចំពោះយើងសព្វថ្ងៃ ។ ប្រសិនបើយើងមានបំណងប្រាថ្នាចង់បាននូវសេចក្ដីសុចរិត សូមអធិស្ឋាន ហើយផ្ដោតលើរឿងសុចរិត នោះគំនិតយើងនឹងពោរពេញដោយសេចក្ដីសុចរិត និង គុណធម៌ហេតុដល់គំនិតអាក្រក់មានអាចនៅបាន ។

*ហាទី ដបុលយូ អាយុ 16 ឆ្នាំ អារីហ្សូណា ស.រ.អា.*

**ទំនុកតម្កើង**

ទំនុកតម្កើងអាចជួយយើងឲ្យមានគំនិតស្អាតស្អំ ។ តន្ត្រីល្អលើកតម្កើងដល់វិញ្ញាណ ។ នៅពេលខ្ញុំស្ដាប់ទំនុកតម្កើង វាតែងលើកតម្កើងខ្ញុំឲ្យស្ថិតនៅក្នុងបរិយាកាសស្ងប់ ហើយសេលេស្ងាល ។ វាជួយខ្ញុំឲ្យចងចាំពីសេចក្ដីស្រឡាញ់ដែលព្រះវរបិតាសួគ៌

មានចំពោះយើងម្នាក់ៗ ហើយវាងាយដើម្បីចៀសវាងពីការល្បួង ។

*អាម៉ែនដា អេ អាយុ 18 ឆ្នាំ អាម៉ាហ្សូណាស ប្រទេសប្រេស៊ីល*

**ការសិក្សាគម្ពីរជាគ្រួសារ**

នៅពេលគំនិតអាក្រក់កើតមាននៅក្នុងគំនិតខ្ញុំ ខ្ញុំព្យាយាមចងចាំបទគម្ពីរដែលគ្រួសារខ្ញុំ និងខ្ញុំបានអាននៅពេលព្រឹក ។ រាល់ព្រឹកម៉ោង 6:00 គ្រួសារខ្ញុំអានព្រះគម្ពីរជាមួយគ្នា ។ វាព្រលឹមមែន ប៉ុន្តែវាជាពរជ័យមួយ ហើយធ្វើឲ្យមានអារម្មណ៍ខ្ញុំកាន់តែរឹងមាំនៅក្នុងថ្ងៃនោះ ។

*អេឡេណា ដបុលយូ អាយុ 16 ឆ្នាំ ប្រទេស ស្វីស*



**ពិធីសាក្រាម៉ង់**

ការអធិស្ឋានពិធីសាក្រាម៉ង់ចែងថា ប្រសិនបើយើងលើកដាក់មកលើខ្លួននូវព្រះនៃព្រះគ្រីស្ទ គោរពព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយចងចាំទ្រង់ជានិច្ច នោះយើងនឹងមានព្រះវិញ្ញាណរបស់ទ្រង់គង់ជាមួយយើងជាដរាប ។ តាមរយៈការចងចាំដល់ទ្រង់ យើងបានខិតខំរុញច្រានគំនិតខាងលោកិយចេញ ហើយផ្ដោតទៅលើគំនិតដ៏អស់កល្ប ។ នៅពេលយើងចងចាំទ្រង់ជានិច្ច គំនិត បំណងប្រាថ្នា និង ទង្វើយើងនឹងផ្លាស់ប្ដូរទៅរកភាពប្រសើរឡើង ។

*មិកយេ អិម អាយុ 18 ឆ្នាំ រដ្ឋ យូថាហ៍ ស.រ.អា*

## សំណួរចេញលើកក្រោយ

« នៅពេលម្ដាយខ្ញុំមានជំងឺយើងបានតមអាហារ ហើយអធិស្ឋានឲ្យគាត់ ប៉ុន្តែគាត់បានទទួលមរណភាព ។ តើខ្ញុំអាចមានសេចក្ដីសុខសាន្តចំពោះរឿងនេះតាមរបៀបណា ? »

ប្រសិនបើអ្នកមានបំណង សូមផ្ញើចម្លើយរបស់អ្នក និង រូបថតច្បាស់មួយសន្លឹកត្រឹមថ្ងៃទី 15 ខែ វិច្ឆិកា ឆ្នាំ 2014 នៅliahona.lds.org ( សូមចុច « Submit Your Work » តាមអ៊ីម៉ែលទៅ liahona@ldschurch.org ឬផ្ញើសំបុត្រ ( សូមមើលអាសយដ្ឋាននៅទំព័រទី 3 ) ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ (1) ឈ្មោះពេញ (2) ថ្ងៃខែឆ្នាំកំណើត (3) វួដ ឬ សាខា (4) ស្តេក ឬ មណ្ឌល (5) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានអាយុក្រោម 18 ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកជាលាយលក្ខណ៍អក្សរ ( អ៊ីម៉ែល អាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ បើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

មេរៀនទាំងឡាយនៅថ្ងៃអាទិត្យ

ប្រធានបទក្នុងខែនេះ ៖
ការប្រែក្លាយកាន់តែដូចជាព្រះគ្រីស្ទ

# របៀបសួរសំណួរដែលសំខាន់ៗ

*ការសួរសំណួរដ៏ត្រឹមត្រូវអាចជួយបើកដួងចិត្តមនុស្សទៅរកទីបន្ទាល់មួយនៃសេចក្ដីពិត ។*

**ដោយ ដេវីឌ អេ អេដួដ**
ទស្សនាវដ្ដីសាសនាចក្រ

អ្នកមានឱកាសដើម្បីបង្រៀនមនុស្សទាំងអស់ដែលនៅជុំវិញអ្នក មិនថានៅក្នុងការសន្ទនារយៈពេលតែមួយនាទីនៅលើរថយន្តក្រុង ក្នុងមេរៀននៅឯព្រះវិហារ ឬការពិភាក្សាសីជម្រៅតទល់គ្នាជាមួយនឹងមិត្តម្នាក់ឡើយ ។

ដូច្នេះនេះគឺជាព័ត៌មានជំនួយមួយសម្រាប់ការបង្រៀនដ៏មានប្រសិទ្ធភាពនៅគ្រប់ស្ថានភាព ៖ សួរសំណួរ ។

សំណួរល្អៗនាំទៅរកការរៀនសូត្រដ៏ល្អ ហើយបើសំណាងល្អ ការសួរសំណួរល្អៗគឺជាអ្វីមួយដែលអ្នកអាចសិក្សា អនុវត្ត ហើយរៀនធ្វើឲ្យល្អបំផុត ។ នេះជារបៀប ។

## សួរសំណួរដែលសំខាន់

សំណួរដែលសំខាន់ៗគឺជាសំណួរដែលធ្វើឲ្យអ្នកគិត ពិចារណាយ៉ាងជ្រាលជ្រៅ ជាសំណួរដែលនាំអ្នកទៅរកសេចក្ដីពិត ទីបន្ទាល់ ហើយផ្លាស់ប្ដូរ ។ វាអាចពាក់ព័ន្ធនឹងប្រធានបទជាច្រើន ប៉ុន្តែជាធម្មតាវាមានរឿងមួយចំនួនដូចគ្នា ៖ (1) វាពុំមែនជាសំណួរដែលស្មាក់ស្មើរ ឬពិតតែម្យ៉ាងនោះទេ ( ប៉ុន្តែវាអាចជាការតាមដានមួយចំពោះសំណួរដែលពិត ) (2) វាមានការតភ្ជាប់មួយចំនួនទៅនឹងជីវិតប្រចាំថ្ងៃរបស់យើង ហើយ (3) វាធ្វើឲ្យយើងមានការខិតខំជាជាងការឆ្លើយតបដែលបានគិតទុកជាមុន ។



## ចងចាំពីហេតុផលដែលយើងសួរសំណួរ

សំណួរទាំងឡាយធ្វើឲ្យយើងចូលរួមតាមរយៈការណែនាំនូវចន្លោះមួយដែលគំនិតរបស់យើងនៅពេលនោះចង់បំពេញ ។ ជាពិសេស ការសួរសំណួរដែលឆ្លុះបញ្ចាំងពីរឿងផ្ទាល់ខ្លួនភ្លាមៗអាចអនុញ្ញាតឲ្យដំណើរការដូចខាងក្រោមនេះកើតមាន ៖

1. មនុស្សចាប់ផ្ដើមមានចំណាប់អារម្មណ៍ចំពោះអ្វីដែលអ្នកកំពុងតែនិយាយ ។
2. ពួកគេប្រើសិទ្ធិជ្រើសរើសរបស់ពួកគេដើម្បីគិត ហើយឆ្លើយនូវសំណួរមួយ ។
3. ការប្រើសិទ្ធិជ្រើសរើសនេះអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់ពីសេចក្ដីពិតដល់ពួកគេ ។[1]

ដោយមានដំណើរការនេះនៅក្នុងគំនិត អ្នកនឹងដឹងថា សំណួរប្រភេទណាដែលត្រូវសួរ និងសំណួរប្រភេទណាដែលត្រូវចៀសវាង ។

**ឧទាហរណ៍ ៖** ជំនួសឲ្យការដែលគ្រាន់តែសួរថា « ហេតុអ្វីបានជាការអានព្រះគម្ពីរមានសារៈសំខាន់ ? » អ្នកអាចសួរថា « តើការសិក្សាព្រះគម្ពីរបានធ្វើឲ្យជីវិតអ្នកមានភាពខុសប្លែកយ៉ាងណាដែរ ?»

## សូមចងចាំថា អ្នកកំពុងបង្រៀនមនុស្ស ពុំមែនជាមេរៀនតែម្យ៉ាងនោះទេ

ប្រសិនបើស្គាល់មនុស្សដែលអ្នកកំពុងបង្រៀន ហើយគិតពីសេចក្ដីត្រូវការរបស់ពួកគេ អ្នកនឹងជ្រើសសំណួរដែលមានគោលបំណងដើម្បីជួយពួកគេ ពុំមែនគ្រាន់តែលើកឡើងនូវគំនិតដ៏ជាក់លាក់នានានោះឡើយ ។

**ឧទាហរណ៍ ៖** ជាជាងការគ្រាន់តែសួរថា « តើជំហាននៅក្នុងដំណើរការនៃការប្រែចិត្តមានអ្វីខ្លះ ? » អ្នកអាចសួរថា « តើអ្នករៀងទាំងឡាយឲ្យត្រឹមត្រូវតាមរបៀបណានៅពេលអ្នកដឹងថាអ្នកបានធ្វើអ្វីមួយដែលខុសនោះ ? »



## សិក្សា ហើយគិតឲ្យស៊ីជម្រៅ

ដើម្បីរៀបចំខ្លួនបង្រៀនដំណឹងល្អ សូមសិក្សាព្រះគម្ពីរ និងការបង្រៀនរបស់ព្យាការី និង សាវកទាំងឡាយនាសម័យបច្ចុប្បន្ន ហើយសូមអធិស្ឋានដើម្បីឲ្យព្រះវិញ្ញាណបរិសុទ្ធអាចគង់ជាមួយអ្នក និងមនុស្សដែលអ្នកបង្រៀន ( សូមមើល គ. និង ស. 42:14, 50:21–22 ) ។

ប្រសិនបើអ្នកចង់សួរសំណួរដែលពិតជាធ្វើឲ្យពួកគេសញ្ជឹងគិតអ្នកក៏ត្រូវធ្វើការគិតដូចគ្នាដោយខ្លួនអ្នកផ្ទាល់ផងដែរ ។ ពិចារណាពីអ្វីដែលអ្នកសិក្សា ។ អ្នកនឹងឃើញថាសំណួរដែលធ្វើឲ្យអ្នកគិតច្រើនបំផុតគឺជាសំណួរដែលអ្នកបានសួរដល់ខ្លួនឯង ។ សូមផ្ដោតលើប្រភេទសំណួរដែលធ្វើឲ្យអ្នកសញ្ជឹងគិត ។ ទាំងនេះគឺជាសំណួរដែលនាំទៅរកចំណេះដឹង និង ទីបន្ទាល់ដ៏ធំធេង ជាប្រភេទសំណួរដូចគ្នាដែលអ្នកអាចសួរនៅពេលអ្នកកំពុងជួយដល់អ្នកដទៃឲ្យរៀនពីដំណឹងល្អដែរ ។

**ឧទាហរណ៍ ៖** ជាជាងការសួរថា « តើយើងទទួលបានសេចក្ដីសប្បុរសតាមរបៀបណា ? » អ្នកអាចសួរថា « តើអ្នកគិតថា វាមានន័យយ៉ាងណាដែរ នៅក្នុងមរ៉ូណៃ 7:48 ដែលបានចែងថា ឲ្យអធិស្ឋានសូមសេចក្ដីសប្បុរស ‹ ដោយអស់ពីកម្លាំងចិត្ត › នោះ? »

រូបភាពនៃស៊ីឡូហ្វេនដោយ SERGEY MARKOV/HEMERA/THINKSTOCK ។ រូបភាពក្បាលដោយ JOHAVEL/ISTOCK/THINKSTOCK



## សួរសំណួរជ្រៅៗនៅក្នុងជំហានងាយៗ

ពេលខ្លះវាគឺជារឿងល្អបំផុត ដើម្បីសួរសំណួរដែលតម្រូវឲ្យមានគំនិត ហើយការគិតពីខ្លួនឯងយ៉ាងច្រើន នៅក្នុងជំហានងាយៗ ដូច្នេះអ្នកគួរតែសួរសំណួរចាប់ផ្ដើមមួយដែលងាយឆ្លើយរួចតាមដានវាជាមួយនឹងសំណួរមួយ ឬច្រើនដែលនាំទៅរកចម្លើយដែលមានការគិតគូរយ៉ាងខ្លាំង ។ នេះគឺជាឧទាហរណ៍ដ៏សាមញ្ញាមួយចំនួន ៖

| សំណួរចាប់ផ្ដើម | សំណួរតាមដាន |
|---|---|
| តើយ៉ូសែប ស៊្មីធមានអាយុប៉ុន្មានឆ្នាំ នៅពេលលោកចូលទៅក្នុងព្រៃពិសិដ្ឋ ? | តើអ្នកធ្លាប់អធិស្ឋានទៅព្រះវរបិតាសួគ៌ដោយមានបំណងស្មោះដូចជាយ៉ូសែបបានធ្វើនៅពេលណា ? |
| តើអ្នកជឿលើព្រះដែរទេ ? | តើព្រះបានដើរតួអ្វីខ្លះនៅក្នុងជីវិតអ្នក ? |
| តើមានអ្វីខ្លះដែលអ្នកបានធ្វើដើម្បីបម្រើដល់អ្នកដទៃក្នុងពេលថ្មីៗនេះ ? | តើការដឹងថាយើងទាំងអស់គ្នាជាកូនចៅនៃព្រះបានផ្លាស់របៀបដែលអ្នកគិតអំពីការបម្រើបែបណាដែរ ? |

ប្រសិនបើអ្នកស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកសួរសំណួរ អ្នកនឹងសួរសំណួរដែលត្រឹមត្រូវនៅក្នុងពេលដ៏សមរម្យ ។ យើងមិនអាចសន្មត់បានទេ ។ វាអាចផ្លាស់ប្ដូរជីវិតរបស់មនុស្សម្នាក់ ។ ■

### កំណត់ចំណាំ

1. « អ្នកត្រូវតែអនុវត្តសិទ្ធិជ្រើសរើសរបស់អ្នកដើម្បីអនុញ្ញាតឲ្យព្រះវិញ្ញាណបង្រៀនដល់អ្នក » ( រីឆាដ ជី ស្កុត «To Acquire Spiritual Guidance » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2009 ទំព័រ 8 ) ។

### ព័ត៌មានជំនួយសម្រាប់ការសួរសំណួរ

- រង់ចាំការឆ្លើយតប ។
- ប្រើសំណួរតាមដានដើម្បីបង្កើតឲ្យមានការសញ្ជឹងគិតកាន់តែជ្រៅ ។
- ចៀសវាងសំណួរដែលបង្កើតការខ្វែងគំនិត ឬបង្កើតឲ្យមានការប្រកែកគ្នា ។
-ម្ដងម្កាល សូមសួរសំណួរដែលធ្វើឲ្យមានការសញ្ជឹតគិតដោយស្ងៀមស្ងាត់ ។

សម្រាប់ព័ត៌មានជំនួយបន្ថែមទៀត សូមមើល *Teaching, No Greater Call: A Resource Guide for Gospel Teaching* ( ឆ្នាំ 1999 ) ទំព័រ 69–70 ។

## ចូលរួមក្នុងការសន្ទនា

### រឿងដើម្បីពិចារណាសម្រាប់ថ្ងៃអាទិត្យ

- តើមាននរណាម្នាក់ធ្លាប់សួរអ្នកនូវសំណួរដែលធ្វើឲ្យអ្នកចង់ដឹងបន្ថែមទៀតពីដំណឹងល្អ ឬផ្លាស់ប្ដូរជីវិតរបស់អ្នកតាមរបៀបមួយចំនួនដែរឬទេ ?
- តើព្រះអង្គសង្គ្រោះបានប្រើសំណួរ នៅពេលទ្រង់បង្រៀនតាមរបៀបណា ?

### រឿងទាំងឡាយដែលអ្នកអាចធ្វើ

- នៅពេលអ្នកសិក្សាព្រះគម្ពីរនៅសប្ដាហ៍នេះ សូមធ្វើជាបញ្ជីសំណួរមួយចំនួនដែលបានគិតឃើញ ។
- នៅក្នុងព្រះវិហារ សូមសួរសំណួរមួយ ជាផ្នែកនៃការពិភាក្សានៅក្នុងថ្នាក់ ។

រូបភាពដោយ ILYAST/ISTOCK/THINKSTOCK



**ដោយ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន**
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

# របៀប ស្វែងរកកម្លាំង និង ជោគជ័យ

អ្នករាល់គ្នាមួយចំនួនដឹងពីអ្វីដែលអ្នកចង់ប្រែក្លាយ និងពីអ្វីដែលអ្នកចង់ធ្វើនៅក្នុងជីវិតរបស់អ្នក ហើយមានអ្នកមួយចំនួនទៀតមិនបានដឹងពីបញ្ហានេះទេ ។ អ្នករាល់គ្នាមួយចំនួនទំនងដូចជាមានពរជ័យ និង ជម្រើសដ៏អស្ចារ្យយ៉ាងច្រើននៅចំពោះមុខ ។ នៅពេលខ្លះ និងដោយហេតុផលអ្វីក៏ដោយ អ្នករាល់គ្នាខ្លះទៀតមានអារម្មណ៍ថាឥតសំណាង ហើយមានផ្លូវល្អៗតិចតួចដែលបានដាក់នៅចំពោះមុខ ។

ប៉ុន្តែទោះអ្នកជាមនុស្សប្រភេទណា ហើយមិនថាអ្នករកឃើញថា អ្នកស្ថិតនៅកន្លែងណាក្នុងខណៈពេលដែលអ្នកស្វែងរកផ្លូវរបស់អ្នកនៅក្នុងជីវិតនេះ ខ្ញុំសូមផ្ដល់ដល់អ្នកនូវ « ផ្លូវ សេចក្ដីពិត និងជីវិត » ( យ៉ូហាន 14:6 ) ។ មិនថាអ្នកគិតថាអ្នកអាចនឹងទៅកន្លែងផ្សេងមួយទៀតដែរឬអត់នោះទេ ខ្ញុំសូមឲ្យអ្នក « មករកទ្រង់ » ( សូមមើលម៉ាថាយ 11:28–30 ) ជាជំហានដ៏សំខាន់ដំបូងបង្អស់នៅក្នុងការទៅដល់ទីនោះ ក្នុងការស្វែងរកសុភមង្គល និង កម្លាំង ព្រមទាំងជោគជ័យផ្ទាល់ខ្លួនរបស់អ្នក ។

នៅពេល អនទ្រេ និង ភីលីព បានឮព្រះគ្រីស្ទមានបន្ទូលជាលើកដំបូង ពួកគេមានចិត្តរំភើបជាខ្លាំងដែលមិនអាចថ្លែងបាន រហូតពួកគេបានដើរតាមទ្រង់ កាលទ្រង់យាងចេញពីហ្វូងមនុស្ស ។ ដោយមានអារម្មណ៍ថា ទ្រង់មានគេតាម នោះព្រះគ្រីស្ទបានងាក ហើយសួរទៅបុរសទាំងពីរនាក់នោះថា « អ្នកមករកអី ? » យ៉ូហាន 1:38 ។ ការបកប្រែផ្សេងទៀតបង្ហាញឃ្លានោះដោយសាមញ្ញថា « តើអ្នកចង់បានអី ? »

ពួកគេបានតបថា « តើលោកនៅឯណា ? » ឬ « តើលោករស់នៅឯណា ? »

ហើយព្រះគ្រីស្ទមានបន្ទូលតបថា « ចូរតាមខ្ញុំទៅមើល » ។ បន្តិចក្រោយមក ទ្រង់បានហៅពេត្រុស និង អ្នកផ្សេងទៀតជាផ្លូវការឲ្យធ្វើជាសាវកថ្មីជាមួយនឹងការអញ្ជើញដូចគ្នានេះ « ចូរមកតាមខ្ញុំ » ( សូមមើល ម៉ាថាយ 4:19 ) ។

រីឯចំពោះខ្ញុំវិញ អត្ថន័យដ៏សំខាន់បំផុតនៃជីវិតរបស់យើង គឺត្រូវបានមើលឃើញនៅក្នុងកត្តាដ៏សង្ខេបទាំងពីរនេះ ក្នុងឆាកចាប់ផ្ដើមនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ។ កត្តាទីមួយគឺជាសំណួរមួយឃ្លានោះចំពោះយើងគ្រប់គ្នា « អ្នកមករកអី ? តើអ្នកចង់បានអ្វី ? » ទីពីរគឺជាចម្លើយរបស់ទ្រង់ពីរបៀបទទួលបានវត្ថុនោះ ។ « ចូរមកតាមខ្ញុំ » ។ចូរមកមើលអ្វីដែលយើងធ្វើ និងពីរបៀបដែលយើងចំណាយពេលវេលារបស់យើង ។ រៀនពីយើង ធ្វើតាមយើង ហើយនៅក្នុងដំណើរការនេះ យើងនឹងផ្ដល់ចម្លើយដល់អ្នកការអធិស្ឋានរបស់អ្នក ហើយឲ្យព្រលឹងអ្នកបានសម្រាក ។

មិត្តយុវវ័យជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំដឹងថា គ្មានផ្លូវឯណាទៀតដែលអ្នកអាចទទួលបានជោគជ័យ ឬមានភាពរីករាយ ឬមានសុវត្ថិភាពឡើយ ។ ខ្ញុំដឹងថា គ្មានផ្លូវឯណាទៀតដែលអ្នកអាចទម្លាក់ទម្ងន់បន្ទុករបស់អ្នក ឬរកឃើញនូវអ្វីដែលយ៉ាកុបបានហៅថា « សុភមង្គលដែលបានរៀបចំឡើងសម្រាប់ពួកបរិសុទ្ធ » នោះឡើយ ( នីហ្វៃទី 2 9:43 ) ។ នោះជាហេតុផលដែលយើង ធ្វើសេចក្ដីសញ្ញាដ៏ធំផ្អែកទៅលើពលិកម្មធួនរបស់ព្រះគ្រីស្ទ ហើយនោះជាហេតុផលដែលយើង លើកដាក់មកលើខ្លួនយើងនូវព្រះនាមរបស់ទ្រង់ ។

ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ ។ នេះគឺជាសាសនាចក្រដែលពិតហើយសកម្មរបស់ទ្រង់ ។ ទ្រង់ចង់ឲ្យយើងមករកទ្រង់ ធ្វើតាមទ្រង់ ទទួលការលួងលោមពីទ្រង់ ។ រួចទ្រង់ចង់ឲ្យយើង ផ្ដល់ការលួងលោមដល់អ្នកដទៃ ។ សូមឲ្យយើងមានសេចក្ដីជំនឿគ្រប់គ្រាន់ដើម្បី ទទួលយកសេចក្ដីល្អរបស់ព្រះ និងសេចក្ដីមេត្តាករុណានៃព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ ។ សូមឲ្យយើងមករកទ្រង់ និងដំណឹងល្អរបស់ទ្រង់ ហើយបានជាសះស្បើយ ។ ■

*ដកស្រង់ចេញពីការប្រជុំពិសេសនៅសាកលវិទ្យាល័យព្រិកហាំយ៉ង់ធ្វើឡើងនៅថ្ងៃទី 2 ខែ មិនា ឆ្នាំ 1997*

## តើអ្នកធ្លាប់អនុវត្តគោលការណ៍ដោយរបៀបណា ?

« ព្រះយេស៊ូវគ្រីស្ទសព្វព្រះទ័យឲ្យយើងដើរតាមទ្រង់ ។ យើងត្រូវជួយអ្នកដទៃ ហើយត្រូវចាំថា ទ្រង់មិនដែលបំភ្លេចយើងឡើយ » ។

***សេសីលីយ៉ា អ៊ី ប្រទេស ហ្វីលីពីន***

« ដើម្បីមករកព្រះអង្គសង្គ្រោះ យើងត្រូវខិតខំរស់នៅឲ្យអស់ពីលទ្ធភាពស្របតាមគំរូរបស់ទ្រង់ ហើយអនុញ្ញាតឲ្យទ្រង់គង់នៅជាមួយនឹងយើងជានិច្ចគ្រប់ពេលវេលាទាំងអស់ » ។

***អាលីសុន អិល អារ៉េហ្សូណា ស.រ.អា.***



—ពង្សប្រវត្តិ—

# ខ្ញុំកំពុងធ្វើកិច្ចការនេះ

*ការចាប់ផ្ដើមអាចជារឿងដ៏ងាយ ហើយសប្បាយ ។ យុវវ័យនៅជុំវិញពិភពលោកកំពុងធ្វើពង្សប្រវត្តិ ហើយធ្វើឲ្យមានការផ្លាស់ប្ដូរមួយ ។*

តើចាប់ផ្ដើមពីត្រង់ណា ? អ្នកប្រហែលជាគិតថា សាច់ញាតិរបស់អ្នកបានធ្វើនូវរាល់កិច្ចការដែលចាំបាច់អស់ហើយ ។ ឬអ្នកប្រហែលជាមនុស្សថ្មីចំពោះពង្សប្រវត្តិ ហើយវាហាក់ដូចជាមានភាពលើសលប់ណាស់ ។ មិនថាអ្នកចាប់ផ្ដើមដោយរក្សាកំណត់ហេតុផ្ទាល់ខ្លួន រៀបចំឈ្មោះសម្រាប់ព្រះវិហារបរិសុទ្ធ ឬរៀនពីសាច់ញាតិអ្នកដែលនៅរស់នោះទេ *អ្នក*អាចចូលរួមក្នុងពង្សប្រវត្តិតាមរបៀបដែលសប្បាយ ហើយពោរពេញដោយអត្ថន័យ ។

## ការរក្សាកំណត់ហេតុផ្ទាល់ខ្លួន ៖ ការចងចាំពីពរជ័យរបស់យើង

ការរក្សាកំណត់ហេតុពុំមែនជារឿងងាយស្រួលឡើយ ។ ជារឿយៗ យើងប្រាប់ខ្លួនឯងថា យើងរវល់ពេក ឬអស់កម្លាំងពេក ឬថាជីវិតគ្មានភាពរំភើបរីករាយគ្រប់គ្រាន់ដែលត្រូវកត់ត្រាទុកនោះទេ ។ ប៉ុន្មានឆ្នាំមុន ខ្ញុំបានដឹងថា ការរក្សាកំណត់ហេតុមិនគួរជារឿងដ៏លំបាកនោះទេ ហើយរហូតដល់ខ្ញុំអាចចាប់ផ្ដើមចូលចិត្តកិច្ចការនេះបាន ។

ខ្ញុំបានចាប់ផ្ដើមដោយសរសេររឿងមួយក្នុងមួយថ្ងៃ វាមិនចាំបាច់ថាជាការសរសេរមួយយ៉ាងវែងអន្លាយ ឬរំភើបនោះទេ ខ្ញុំគ្រាន់តែសរសេរពីអ្វីដែលខ្ញុំមានក្នុងគំនិត ឬអ្វីដែលកើតឡើងនៅថ្ងៃនោះ ។ វាបានប្រទានពរដល់ជីវិតខ្ញុំ ។

នៅថ្ងៃមួយមានមនុស្សម្នាក់នៅក្នុងគ្រួសារបានប្រទះនឹងបញ្ហា ហើយខ្ញុំមិនដឹងថាត្រូវនិយាយអ្វីទៅកាន់គាត់សោះ ប៉ុន្តែបន្តិចក្រោយមកខ្ញុំត្រូវបានបំផុសឲ្យអានផ្នែកមួយនៃកំណត់ហេតុរបស់ខ្ញុំឲ្យគាត់ស្ដាប់ ។ ខ្ញុំអាចចែកចាយផ្នែកតូចមួយរបស់ខ្ញុំដែលខ្ញុំបានកត់ត្រានៅក្នុងទិនានុប្បវត្តិពណ៌ខ្មៅតូចនោះ ហើយខ្ញុំបានឃើញពីរបៀបដែលវាបានជួយបន្ធូរចិត្តរបស់គាត់ ។

ខ្ញុំសូមធានាអះអាងថា ប្រសិនបើអ្នកចាប់ផ្ដើមសរសេររឿងមួយក្នុងមួយថ្ងៃ នោះវានឹងប្រទានពរដល់ជីវិតអ្នក ។ ទោះបីតូចតាច ឬធំក្ដី ការសរសេរពីពរជ័យនៅក្នុងជីវិតរបស់អ្នកអាចជួយអ្នកឲ្យចងចាំពរជ័យទាំងនោះ ។

*ជេនទ្រី ដបុលយូ យូថាហ៍ ស.រ.អា.*



## ការស្វែងរកសេចក្ដីអំណរនៅក្នុងពង្សប្រវត្តិ ៖ ការស្រាវជ្រាវរកជីដូនជីតា

នៅពេលខ្ញុំជ្រមុជទឹក ខ្ញុំបានឮយ៉ាងច្រើនពីពង្សប្រវត្តិ ប៉ុន្តែខ្ញុំមិនដឹងពីរបៀបដើម្បីចាប់ផ្ដើម ឬពីរបៀបដែលខ្ញុំអាចធ្វើវាបានដែរឬអត់នោះទេ ។ ខ្ញុំបានសម្រេចចិត្តអធិស្ឋានពីរឿងនោះ ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរចាប់ផ្ដើមធ្វើវាភ្លាម ។ ខ្ញុំមានអារម្មណ៍ថា ជីដូនជីតារបស់ខ្ញុំចង់ឲ្យខ្ញុំចាប់ផ្ដើម ហើយថាពួកគាត់នឹងជួយខ្ញុំរកព័ត៌មានចាំបាច់ដើម្បីធ្វើពិធីបរិសុទ្ធទាំងឡាយ ។

ខ្ញុំបានចាប់ផ្ដើមចូលរៀនវគ្គសិក្សាថ្នាក់ពង្សប្រវត្តិ ហើយមិនយូរប៉ុន្មានក្រោយមក ខ្ញុំត្រូវបានហៅឲ្យធ្វើជាអ្នកផ្ដល់ប្រឹក្សាខាងពង្សប្រវត្តិ ។ ខ្ញុំមានការព្រួយបារម្ភដោយសារខ្ញុំមិនសូវដឹងពីកិច្ចការនេះប៉ុន្មានទេ ប៉ុន្តែខ្ញុំបានទទួលយកការហៅនោះ ។

មានថ្ងៃមួយ ខ្ញុំបានទៅលេងប្អូនស្រីជីដូនរបស់ខ្ញុំ ដែលគាត់មានឯកសារអំពីជីដូនទួតរបស់ខ្ញុំ ។ គាត់មិនចង់ចែកចាយព័ត៌មានច្រើនទេ ដោយសារវាជាទំនៀមទម្លាប់មួយនៃការមិនឲ្យនិយាយពីសាច់ញាត់ដែលបានចែកឋានទៅ ។ គាត់បានប្រាប់ថា ថ្ងៃស្អែកគឺជាថ្ងៃខួបដែលជីដូនទួតចែកឋាន របស់ខ្ញុំ ហើយគាត់នឹងដុតឯកសារនោះចោល ។ ខ្ញុំសួរប្រសិនបើខ្ញុំអាចសូមព័ត៌មានមួយចំនួនពីឯកសារទាំងនោះជាមុនសិន ហើយគាត់បានអនុញ្ញាត ។ នៅពេលនោះខ្ញុំដឹងថា ព្រះវរបិតាសួគ៌នឹងជួយខ្ញុំបន្តការស្វែងរករបស់ខ្ញុំ ។

កាលខ្ញុំបម្រើនៅក្នុងមជ្ឈមណ្ឌលពង្សប្រវត្តិក្បែរព្រះវិហារបរិសុទ្ធ ខ្ញុំបានបន្តស្វែងរកគ្រួសាររបស់ខ្ញុំ បន្ថែមទៀត ។ ខ្ញុំបានដឹងថា ជីដូនជីតារបស់ជីដូនទួតខ្ញុំគឺជាជនអន្តោប្រវេសន៍ជនជាតិអ៊ីតាលីដែលមានកសិដ្ឋានមួយនៅក្បែរសៅផូឡូ ប្រទេសប្រេស៊ីល ។ គ្រួសារខ្ញុំបានបាត់ទំនាក់ទំនងនឹងសាច់ញាតិនៅកសិដ្ឋាននោះ ប៉ុន្តែបានរកឃើញបងប្អូនជីដូនមួយម្នាក់ដែលបានសរសេរសៀវភៅមួយអំពីពង្សាវតាររបស់គ្រួសារយើង ។ គាត់បានឲ្យសៀវភៅនោះដល់ខ្ញុំ ដែលគាត់បានចំណាយពេលប្រាំបួនឆ្នាំដើម្បីសរសេរវា ។ គាត់បាននិយាយថា គាត់មិនដឹងថាហេតុអ្វីគាត់គួរសរសេរវានោះទេ ប៉ុន្តែមានអារម្មណ៍ថាវានឹងជួយដល់មនុស្សណាម្នាក់នៅពេលអនាគត ។ ខ្ញុំដឹងថា វាគឺជាវិញ្ញាណរបស់អេលីយ៉ាដែលបំផុសគំនិតដល់គាត់ ។

បទពិសោធន៍របស់ខ្ញុំបានបង្រៀនខ្ញុំថា យើងកំពុងធ្វើកិច្ចការមួយដ៏ពិសិដ្ឋ ។ ជីដូនជីតារបស់យើងកំពុងរង់ចាំការជួយរបស់យើង ហើយបាននៅក្បែរយើងដើម្បីជួយយើង ។

*ហ្វាប្រៀល ឌី ប្រទេសប្រេស៊ីល*





## ការធ្វើកិច្ចការព្រះវិហារបរិសុទ្ធ ៖ ពិធីបរិសុទ្ធដ៏ពិសិដ្ឋ

ខ្ញុំគឺជាអ្នកប្រែចិត្តជឿម្នាក់ ហើយជាសមាជិកសាសនាចក្រតែម្នាក់គត់នៅក្នុងគ្រួសារខ្ញុំ ។ ខ្ញុំបានដឹងថា ពិធីបរិសុទ្ធដ៏ពិសិដ្ឋមួយគឺពិធីបុណ្យជ្រមុជទឹកសម្រាប់អ្នកស្លាប់ ។ ខ្ញុំបានដើរមើលព្រះវិហារបរិសុទ្ធមួយ ហើយកាលកំពុងស្ដាប់អ្នកដឹកនាំក្រុមនិយាយអំពីពិធីបរិសុទ្ធនានា ខ្ញុំមានអារម្មណ៍នូវសំឡេងតូចរហៀងប្រាប់ខ្ញុំឲ្យទៅមជ្ឈមណ្ឌលពង្សប្រវត្តិដើម្បីដាក់ស្នើសំណើរសម្រាប់ពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធសម្រាប់ម្ដាយរបស់ខ្ញុំដែលបានទទួលមរណភាពទៅ ។ ខ្ញុំមានចិត្តរីករាយខ្លាំងណាស់ នៅពេលគណនីកម្មវិធី FamilySearch បានបញ្ជាក់ក្រោយមកថា កិច្ចការព្រះវិហារបរិសុទ្ធរបស់គាត់ត្រូវបានធ្វើរួចរាល់ហើយ ។ វាបានពង្រឹងដល់ទីបន្ទាល់ខ្ញុំ ហើយខ្ញុំដឹងថា ហេតុផលមួយដែលយើងនៅលើផែនដីនេះ គឺដើម្បីជួយជីដូនជីតាយើងឲ្យទទួលដំណឹងល្អពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។

*ម៉ារីន អេស ប្រទេស ហ្វីលីពីន*

## ការធ្វើតាមការបំផុសគំនិត ៖ ការរៀនពីសាច់ញាតិដែលនៅរស់

បន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យ ខ្ញុំមានអារម្មណ៍ចង់ទៅលេងលោកតាលោកយាយខ្ញុំទាំងបួនរូប ។ ខ្ញុំមានពេលទំនេរខ្លះៗ ហើយខ្ញុំបានដឹងថា ខ្ញុំអាចនឹងគ្មានឱកាសបែបនេះម្ដងទៀតឡើយ ដូច្នេះខ្ញុំបានចំណាយពេលមួយសប្ដាហ៍ជាមួយនឹងពួកគាត់មួយគូៗម្ដង ។

ខ្ញុំបានចំណាយពេលរកមើលប្រអប់ចាស់ៗ អានសំបុត្រចាស់ៗ និង មើលរូបភាពចាស់ៗ ។ ខ្ញុំបានកត់ទុកអំពីដំណើរជីវិតរបស់លោក

តាលោកយាយខ្ញុំ ដើរជុំវិញទីលានបញ្ចុះសព ហើយទៅលេងកន្លែងដែលលោកតាលោកយាយខ្ញុំ និង សាច់ញាតិគាត់ធ្លាប់រស់នៅ ហើយធ្វើការ ។ វាសប្បាយណាស់ ! ខ្ញុំបានរៀនយ៉ាងច្រើនអំពីជីដូនជីតាខ្ញុំ លោកតាលោកយាយខ្ញុំ ឪពុកម្ដាយខ្ញុំ និង រូបខ្ញុំផ្ទាល់ ។ ខ្ញុំបានដឹងថា ខ្ញុំនឹងគ្មានជីវិតដែលខ្ញុំមាននៅពេលនេះឡើយ បើគ្មានជីដូនជីតារបស់ខ្ញុំនោះ ។

បន្ទាប់ពីការធ្វើដំណើររបស់ខ្ញុំមក ខ្ញុំបានត្រឡប់មកវិញជាមួយនឹងឈ្មោះរបស់ជីដូនជីតាខ្ញុំប្រមាណជា 1,000 ឈ្មោះ ហើយខ្ញុំបានធ្វើកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ពួកគេជាច្រើន ។ ការធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ និងការទៅលេងលោកតាលោកយាយខ្ញុំគឺជាការសម្រេចចិត្តមួយដ៏ល្អបំផុតដែលខ្ញុំពុំធ្លាប់មានពីមុនមកឡើយ ។

*ស្បេនលី ភី កាលីហ្វ័រញ៉ា ស.រ.អា.*



**ចូលរួមនៅក្នុងអ្វីមួយដែលអស់កល្បជានិច្ច**

« តើអ្នកធ្លាប់អធិស្ឋានពីកិច្ចការរបស់ជីដូនជីតាអ្នកទេ ? សូមទុករឿងដែលមិនសំខាន់នៅក្នុងជីវិតទាំងឡាយរបស់អ្នកមួយអន្លើរសិន ។ សូមសម្រេចចិត្តធ្វើអ្វីមួយដែលនឹងផ្ដល់ជាលទ្ធផលអស់កល្បជានិច្ច ។ . . .

« មិនថាអ្នកនៅទីណាក្នុងពិភពលោកនេះទេ ដោយមានការអធិស្ឋាន សេចក្ដីជំនឿ ការតាំងចិត្ត ការព្យាយាម និង ពលិកម្មខ្លះ នោះអ្នកអាចចូលរួមមួយដ៏ខ្លាំងក្លា ។ សូមចាប់ផ្ដើមឥឡូវនេះ ។ ខ្ញុំសូមសន្យានឹងអ្នកថា ព្រះអម្ចាស់នឹងជួយអ្នកឲ្យរកឃើញផ្លូវមួយ ។ ហើយវានឹងធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងអស្ចារ្យក្នុងដួងចិត្ត » ។

អែលឌើរ រីឆាដ ជី ស្កុត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « **The Joy of Redeeming the Dead** » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2012 ទំព័រ 95 ។

## ការមានអារម្មណ៍ដូចនៅក្នុងផ្ទះ ៖ ការយកឈ្មោះទៅព្រះវិហារបរិសុទ្ធ

កាលខ្ញុំស្នើបសួររកគំនិតខាងពង្សប្រវត្តិពីឪពុករបស់ខ្ញុំដើម្បីបញ្ចប់ការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារីរបស់ខ្ញុំ នោះគាត់បានពន្យល់ថា គាត់បានរកឃើញឈ្មោះគ្រួសារមួយចំនួនកាលពីប៉ុន្មានឆ្នាំមុន ប៉ុន្តែមិនអាចធ្វើឲ្យឈ្មោះនោះរួចរាល់ដើម្បីយកទៅព្រះវិហារបរិសុទ្ធដោយខ្លួនគាត់ផ្ទាល់បានឡើយ ដោយសារគាត់មានជាប់រវល់ខ្លាំងពេក ។ ជំនួយរបស់ខ្ញុំអាចធ្វើឲ្យសមាជិកគ្រួសារទាំងនេះទទួលពរជ័យក្នុងព្រះវិហារបរិសុទ្ធបាន ។

សម្រាប់ប៉ុន្មានខែក្រោយមក ខ្ញុំបានចំណាយពេលរៀងរាល់រសៀល និង ពេលល្ងាចនៅថ្ងៃអាទិត្យដើម្បីបញ្ចូលឈ្មោះទៅក្នុងកុំព្យូទ័រ ហើយរៀនពីដំណើររឿងគ្រួសារពីឪពុកខ្ញុំ ។ យើងថែមទាំងបញ្ជាទិញមីក្រូហ្វីមដើម្បីរកព័ត៌មានបន្ថែមទៀត ។ ពេលខ្លះ កាលមានការលំបាកដើម្បីអានហ្វីលចាស់ៗ ខ្ញុំបានធ្វើការអធិស្ឋានក្នុងចិត្ត រួចយកក្រដាសចេញមកដើម្បីដានរូបភាព ។ ឈ្មោះបានលេចចេញមកពីភាពស្រពិចស្រពិលនោះ ។

នៅទីបំផុតខ្ញុំបានប្រមូលឈ្មោះគ្រួសារដ៏ច្រើន ហើយយុវវ័យនៅក្នុងវួដរបស់យើងបានជួយធ្វើពិធីបុណ្យជ្រមុជទឹក ។ រួចឪពុកម្ដាយខ្ញុំ និង សមាជិកវួដដទៃទៀតបានយកប័ណ្ណឈ្មោះនោះទៅធ្វើពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធផ្សេងទៀត ។

វាហាក់ដូចជារយៈពេលមួយដ៏ខ្លី ពីមុនខ្ញុំបានដឹងថាខ្លួនឯងកំពុងរៀបចំខ្លួនទៅព្រះវិហារបរិសុទ្ធសម្រាប់អំណោយទានពិសិដ្ឋផ្ទាល់ខ្លួនរបស់ខ្ញុំ ។ ខ្ញុំមានចិត្តរីករាយ ប៉ុន្តែក៏ភ័យផងដែរ ។

នៅពេលធ្វើដំណើរទៅព្រះវិហារបរិសុទ្ធ ឪពុកខ្ញុំបានពន្យល់ថា គាត់បានរកឃើញប័ណ្ណឈ្មោះគ្រួសារមួយចំនួនដែលខ្ញុំបានរៀបចំសម្រាប់គម្រោងការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារីរបស់ខ្ញុំ ។ មានប័ណ្ណមួយចំនួនបានបាត់ ដូច្នេះគាត់បានយកប័ណ្ណឈ្មោះទាំងនោះសម្រាប់ម្ដាយខ្ញុំ គូដណ្ដឹងខ្ញុំ និងគាត់ដើម្បីបញ្ចប់វា ។ គាត់បានចែកចាយឈ្មោះអ្នកទាំងនោះជាមួយខ្ញុំ ហើយខ្ញុំបានចងចាំពួកគាត់នៅក្នុងគម្រោងរបស់ខ្ញុំ ។

កាលខ្ញុំបានធ្វើសេចក្ដីសញ្ញាដ៏ពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធ ខ្ញុំមានអារម្មណ៍ថាខ្ញុំត្រូវបានហ៊ុមព័ទ្ធដោយមនុស្សជាទីស្រឡាញ់នៅផ្នែកទាំងសង្ខាងនៃវាំងនន ។ ខ្ញុំមានអាម្មណ៍នូវសេចក្ដីសុខសាន្តយ៉ាងខ្លាំងដោយដឹងថា ខ្ញុំអាចរួមរស់នឹងគ្រួសាររបស់ខ្ញុំដ៏នៅអស់កល្បជានិច្ចបាន ។ ■

*ហូលី ភី អែដាហូ ស.រ.អា.*



**ចែកចាយបទពិសោធន៍របស់អ្នក**

សូមចែកចាយបទពិសោធន៍របស់អ្នកស្ដីពីពង្សប្រវត្តិនៅlds.org/youth/family-history/experiences ។


រចនារូបភាពដោយ ដេវ ស្តូរី
ស្វែងយល់ពីពួកគេ
ស្វែងយល់ពីខ្លួនឯង
ជីវិតរបស់អ្នកត្រូវបានបង្កបង្កើតឡើងជាច្រើនតំណ ។
សូមស្វែងរកពីចំណុចដែលដំណើររឿងរបស់បានអ្នកចាប់ផ្ដើម ។
សូមចូលទៅ FamilySearch.org ។

បន្ទាប់ពីសម្ភាសខ្ញុំដើម្បីទៅបម្រើបេសកកម្ម ប្រធានស្តេករបស់ខ្ញុំបានថ្លែងថា « រឿងដ៏ចម្លែកនឹងកើតឡើងនៅក្នុងជីវិតអ្នក ដើម្បីព្យាយាមទាក់ទាញអ្នកផ្លាស់ប្តូរគំនិតអ្នក » ។

# ឧបសគ្គធំទាស់ នឹងបេសកកម្មខ្ញុំ



ដោយ អាល់សេនៀ ដេ ស៊ូស្សា

ខ្ញុំបានចូលរួមក្នុងសាសនាចក្រកាលខ្ញុំមានវ័យ 15 ឆ្នាំ ហើយបួនឆ្នាំក្រោយមកខ្ញុំបានដាក់ពាក្យសុំធ្វើជាអ្នកផ្សព្វផ្សាយសាសនារបស់ខ្ញុំ ។ នៅក្នុងការសម្ភាសប្រធានស្តេករបស់ខ្ញុំ គាត់បានសរសើរខ្ញុំចំពោះការសម្រេចចិត្តបម្រើព្រះអម្ចាស់ជាអ្នកផ្សាយសាសនាពេញម៉ោង ។ រួចអ្នកដឹកនាំដ៏បំផុសគំនិតរូបនោះបានថ្លែងនូវអ្វីមួយដែលបានធ្វើឲ្យខ្ញុំមានចំណាប់អារម្មណ៍ជាខ្លាំង ៖ « ប្អូនប្រុស ចាប់ពីពេលនេះទៅ រឿងដ៏ចម្លែកនឹងកើតឡើងនៅក្នុងជីវិតប្អូន ដើម្បីព្យាយាមទាក់ទាញឲ្យប្អូនផ្លាស់គំនិតពីការសម្រេចចិត្តរបស់ប្អូនបម្រើដល់ព្រះអម្ចាស់ » ។

កាលកំពុងរង់ចាំការហៅឲ្យចេញបេសកកម្មរបស់ខ្ញុំ ខ្ញុំបានធ្វើការសិក្ខាកាមម្នាក់នៅ ក្រុមហ៊ុនហ្សេីរ៉ក់ ។ ការងារនេះអាចធ្វើឲ្យខ្ញុំទទួលបានអ្វីៗមួយចំនួនដែលខ្ញុំត្រូវការសម្រាប់បេសកកម្មខ្ញុំ ហើយជួយម្តាយខ្ញុំសម្រាប់ការចំណាយនានានៅក្នុងផ្ទះ ។ អ្វីៗគ្រប់យ៉ាងបានដំណើរការទៅល្អណាស់ ។

ជាអកុសល « រឿងចម្លែក » បានចាប់ផ្តើមកើតឡើង ។ ដំបូង ម្តាយខ្ញុំត្រូវបានគេវាយធ្វើបាប ហើយស្ទើរតែបាត់បង់ជីវិតដោយសាររបួសរបស់គាត់ ប៉ុន្តែព្រះវរបិតាសួគ៌ដ៏មានព្រះទ័យសណ្តោសប្រណីបានជួយដល់ជីវិតគាត់ដោយអស្ចារ្យ ។



នៅពេលនោះ ម្តាយខ្ញុំ ប្អូនស្រីពីរនាក់ ហើយនិងខ្ញុំកំពុងរស់នៅផ្ទះជួលមួយ ។ យើងរស់នៅដោយសារប្រាក់ចំណូលរបស់ខ្ញុំ និងអត្ថប្រយោជន៍មួយចំនួនតូចដែលម្តាយខ្ញុំបានទទួលដោយសារមរណភាពរបស់ឪពុកខ្ញុំជាច្រើនឆ្នាំមុនមក ។ មានមនុស្សមួយចំនួន រួមទាំងសមាជិកសាសនាចក្របានសួរថា « តើឯងនឹងមានហ៊ានដើម្បីទុកម្តាយឯងទាំងបែបនេះ ហើយទៅបេសកកម្មបានមែនឬ ? » ការស្តាប់ឮសំណួរនេះម្តងហើយម្តងទៀតបានចាប់ផ្តើមបង្កើតភាពសង្ស័យនៅក្នុងចិត្តខ្ញុំ ។

មានថ្ងៃមួយ ប្រធានស្តេករបស់ខ្ញុំបាន



ទូរស័ព្ទប្រាប់ខ្ញុំថា ការហៅឲ្យចេញបេសកកម្មរបស់ខ្ញុំបានមកដល់ហើយ ហើយបានសុំឲ្យខ្ញុំមកកាន់ការិយាល័យគាត់នៅល្ងាចនោះ ដើម្បីគាត់អាចឲ្យខ្ញុំនូវកញ្ចប់សំបុត្រដែលខ្ញុំបានរង់ចាំយ៉ាងយូរពីទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ ។ ខ្ញុំភ័យផង អរផង ពេលបានឮដំណឹងនោះ ។

នៅថ្ងៃដដែលនោះ នាយករបស់ខ្ញុំនៅកន្លែងធ្វើការបានសុំជួបខ្ញុំពីមុនម៉ោងបាយថ្ងៃត្រង់ ។ កាលខ្ញុំចូលទៅក្នុងការិយាល័យគាត់ គាត់បានទទួលខ្ញុំដោយរាក់ទាក់ ហើយយើងបាននិយាយគ្នាពីរបីនាទីអំពីការបំពាក់បំប៉នរបស់ខ្ញុំ និង អ្វីដែលខ្ញុំបានរៀននៅក្នុងក្រុមហ៊ុននេះ ។ រួចបុរសដ៏មានអំណាចម្នាក់នៅក្នុងក្រុមហ៊ុននោះបានថ្លែងនូវអ្វីមួយដែលដូចជាបំណងចង់បានរបស់មនុស្សភាគច្រើននៅក្នុងទីក្រុង ៖ « ឯងធ្វើការបានល្អណាស់ក្នុងនាមជាសិក្ខាកាមម្នាក់ ហើយយើងចង់ជួលឯងឲ្យធ្វើការ ហើយទុកឯងឲ្យនៅក្នុងក្រុមនេះ។ តើឯងគិតយ៉ាងណាដែរ ? »



នេះគឺជាការសម្រេចចិត្តមួយដ៏លំបាកបំផុតនៅក្នុងជីវិតខ្ញុំ ។ រឿងទីពីរគឺមានអារម្មណ៍ហាក់ដូចជាគ្មានថ្ងៃបញ្ចប់ឡើយ ។ វាហាក់ដូចជាខ្ញុំអាចស្ដាប់ឮមនុស្សសួរខ្ញុំថា តើខ្ញុំនឹងបោះបង់ម្ដាយខ្ញុំដោយគ្មានការផ្គត់ផ្គង់ខាងហិរញ្ញវត្ថុ ហើយទៅបេសកកម្មមែនទេ ។

ប៉ុន្តែ ខ្ញុំបានចងចាំនូវរឿងដែលខ្ញុំបានរៀនពីព្រះគម្ពីរ និង ថ្នាក់ដឹកនាំសាសនាចក្ររបស់ខ្ញុំ និងតាមរបៀបដ៏ពិសិដ្ឋមួយ ខ្ញុំបានដឹងយ៉ាងប្រាកដថា ព្រះសព្វព្រះទ័យឲ្យខ្ញុំបម្រើជាអ្នកផ្សាយសាសនាពេញម៉ោងនៃសាសនាចក្ររបស់ទ្រង់ ។ ខ្ញុំបានដឹងថា ទ្រង់នឹងមើលថែទាំគ្រួសារខ្ញុំ ថាខ្ញុំអាចទុកចិត្តលើទ្រង់បាន ហើយថាអ្វីៗគ្រប់យ៉ាងនឹងបានប្រសើរឡើង ។

ខ្ញុំបានពន្យល់ប្រាប់នាយករបស់ខ្ញុំពីស្ថានភាពនោះ ហើយគាត់បានស្រែកដាក់ខ្ញុំថា ៖ « ខ្ញុំបានគិតថា ឯងជាយុវជនម្នាក់ដែលមានការគិតគូរវែងឆ្ងាយ ហើយមើលចុះឯងកំពុងតែបោះចោលនូវឱកាសក្នុងជីវិតរបស់ឯងហើយ » ។

ខ្ញុំបានអរគុណគាត់ដោយអស់ពីចិត្តចំពោះឱកាសដែលគាត់ផ្ដល់ឲ្យ ហើយ 28 ថ្ងៃក្រោយមកខ្ញុំបានទៅបង្ហាញមុខនៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាក្នុងសៅផាឡូ ប្រទេសប្រេស៊ីល ។

ក្នុងបេសកកម្មខ្ញុំ ព្រះអម្ចាស់បានបំពេញសេចក្ដីត្រូវការរបស់គ្រួសារខ្ញុំតាមរយៈមិត្តក្នុងសាសនាចក្រ និង តាមរបៀបដ៏អស្ចារ្យជាច្រើន ។ សុខភាពម្ដាយខ្ញុំបានប្រសើរឡើងវិញ ហើយប្អូនស្រីខ្ញុំទាំងពីរ និង គាត់បានមានការងារធ្វើថ្មី ។

« រឿងចម្លែក » ពិតជាបានកើតឡើងមែនពេលយើងសម្រេចចិត្តបម្រើព្រះអម្ចាស់ ។ ប៉ុន្តែខ្ញុំសូមបន្ថែមទីបន្ទាល់ខ្ញុំដោយរាបសាទៅនឹងទីបន្ទាល់នៃមនុស្សរាប់ពាន់នាក់ផ្សេងទៀតដែលបានចូលរួមនៅក្នុងការបម្រើរបស់ព្រះថា ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាបានជះឥទ្ធិពលមកលើជីវិតខ្ញុំយ៉ាងខ្លាំង ។ ■

*អ្នកនិពន្ធរស់នៅម៉ាណាអុស ប្រទេសប្រេស៊ីល*





**កុំរាថយ**

« ឧបសគ្គកើតឡើងស្ទើរតែគ្រប់ទីកន្លែងដែលរឿងល្អមួយបានកើតឡើង ។ វាអាចកើតឡើងពេលអ្នកកំពុងសិក្សា ។ វាអាចកើតមានចំពោះអ្នក បន្ទាប់ពីខែដំបូងរបស់អ្នកនៅក្នុងតំបន់បេសកកម្មថ្មីរបស់អ្នក ។ . . .

« ជាមួយនឹងការសម្រេចចិត្តដ៏ធំនានា នោះមាននូវបម្រាម និង ការសម្រេចចិត្តដែលត្រូវធ្វើ ប៉ុន្តែនៅពេលការបំភ្លឺបានកើតឡើង សូមប្រយ័ត្ននឹងការល្បួងដែលអូសទាញឲ្យឃ្លាតឆ្ងាយពីរឿងល្អ ។ ប្រសិនបើវាត្រឹមត្រូវ ពេលអ្នកអធិស្ឋាន ហើយទុកចិត្ត ហើយរស់នៅតាម វាជាត្រូវពេលនេះហើយ ។ សូមកុំរាថយនៅពេលសម្ពាធមានការកើនឡើងឡើយ » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Cast Not Away Therefore Your Confidence » *Liahona* ខែ មិថុនា ឆ្នាំ 2000 ទំព័រ 38 ។

រចនារូបភាពដោយ ក្រេហ្គ ញ៉ូវបូល



# ការរៀនសូត្របន្ថែម ទៀតពី អ្វីដែលមាន

*យុវវ័យនៅអូស្លូ ប្រទេសន័រវែស បានចំណាយពេលមួយថ្ងៃរៀបចំខ្លួនសម្រាប់ជីវិតជាអ្នកផ្សាយសាសនាពេញម៉ោង ។*

ដោយខាទ្រីន អាពេលសេដ្ឋ-អាណេនសេន និង រីឆាត អិម រ៉មនី

ចាប់តាំងពីប្រធានថូម៉ាស អេស ម៉នសុន បានប្រកាសពីការផ្លាស់ប្ដូរអាយុសម្រាប់ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា យុវវ័យនៅក្នុងសាសនាចក្រទាំងមូលបានឆ្លើយតបយ៉ាងរីករាយ មិនគ្រាន់តែការអញ្ជើញឲ្យបម្រើប៉ុណ្ណោះទេ ប៉ុន្តែការអញ្ជើញឲ្យ*រៀបចំខ្លួន*បម្រើផងដែរ ។ ហើយរបៀបមួយដើម្បីរៀបចំខ្លួនគឺរៀនបន្ថែមទៀតពីអ្វីដែលមាន ពេលពួកគេក្លាយជាអ្នកផ្សាយសាសនាពេញម៉ោង ។

យុវវ័យមួយចំនួននៅប្រទេសន័រវែសបានធ្វើបែបនេះពេញមួយថ្ងៃក្នុងកម្មវិធី « បទពិសោធន៍ជាអ្នកផ្សព្វផ្សាយសាសនា » ដោយធានាឡើងដោយវួដហ្វ្រេឌ្រីកស្តាដក្នុងស្តេកអូស្លូន័រវែស ។

## ការចូលទៅក្នុង « MTC »

យុវវ័យបានប្រមូលផ្តុំគ្នានៅឯងសាលាប្រជុំក្នុងបន្ទប់មួយដែល តំណាងឲ្យមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ។ យ៉ាកុប អ័រ មកពីវួដមូសបានថ្លែងថា « យើងបានទទួលចំណាត់ការមួយឲ្យរៀនពីប្រទេសមួយ » ។ « វាធ្វើឲ្យយើងមានអារម្មណ៍ពីការទទួលការហៅឲ្យបម្រើបេសកកម្មមួយ ហើយដឹងថា អ្នកត្រូវបានហៅទៅកន្លែងមួយដែលខុសប្លែកពីកន្លែងដែលអ្នកធ្លាប់រស់នៅ » ។

## ការជួបនឹង « ប្រធានបេសកកម្ម »

ស៊ីម៉ូន ដបុលយូ មកពីវួដមូសបានថ្លែងថា « រួចយើងបានទៅបន្ទប់ក្បែរនោះជួបនឹងអ្នកដែលត្រឡប់មកពីបេសកកម្មម្នាក់ដែលកំពុងដើរតួជាប្រធានបេសកកម្ម » ។ អ្នកត្រឡប់មកពីបេសកកម្មម្នាក់នោះ និង អ្នកត្រឡប់មកពីបេសកកម្មផ្សេងទៀតបាននិយាយពីអ្វីកើតមាននៅក្នុងការបម្រើបេសកកម្ម ។ ស៊ីម៉ូនបានថ្លែងថា « ខ្ញុំគិតថាវាជាការល្អណាស់ដើម្បីរៀនពីអ្នកត្រឡប់មកពីបេសកកម្មវិញ នូវអ្វីដែលកើតឡើងនៅក្នុងបេសកកម្មពេញម៉ោង » ។ អ្នករៀនក៏បានទទួលនូវស្លាកឈ្មោះមួយ មានដៃគូ ហើយបានណែនាំឲ្យនៅជាមួយដៃគូគ្រប់ពេល ។

## ការអភិវឌ្ឍជំនាញ

សិក្ខាសាលាជាច្រើនបានបង្រៀនយុវវ័យពីការអភិវឌ្ឍខាងវិញ្ញាណ ប៉ុន្តែរួមទាំងការគ្រប់គ្រងខាងតម្រូវការខាងសាច់ឈាមផងដែរ ដូចជា ការបោកសំលៀកបំពាក់ ការចំណាយតាមថវិកា

រូបភាពស៊ើបដោយ LUKAS_ZB/ISTOCK/THINKSTOCK



និង ការបន្តមានរូបកាយរឹងមាំ ។

អ៊ីងហ្គើរ សូហ្វី ជេ មកពីអូស្លូវដបានថ្លែងថា « ខ្ញុំរីករាយជាខ្លាំងជាមួយនឹងសិក្ខាសាលាស្ដីពីរបៀបចាប់ផ្ដើមការសន្ទនាពីដំណឹងល្អ » ។ « នោះគឺជាអ្វីមួយដែលខ្ញុំចាប់ផ្ដើមធ្វើឥឡូវនេះបាន » ។

ខាល ហ្វ្រេឌើរីក អូ មកពីវួដហ្វ្រេឌ្រីកស្ដាដ បានថ្លែងថា « ខ្ញុំរីករាយនឹងពិភាក្សាពីរបៀបប្រើ *ប្រកាសដំណឹងល្អរបស់យើង* » ។ « ខ្ញុំតែងគិតជានិច្ចថា ពួកអ្នកផ្សព្វផ្សាយសាសនាមានបញ្ជីបទគម្ពីរផ្ទាល់ខ្លួនដែលពួកគេត្រូវរៀន ប៉ុន្តែខ្ញុំបានដឹងថា អ្វីដែលខ្ញុំកំពុងធ្វើនៅក្នុងថ្នាក់សិក្ខាសាលានឹងជួយខ្ញុំក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ហើយនិងអ្វីដែលខ្ញុំកំពុងសិក្សានៅក្នុង*ប្រកាសដំណឹងល្អរបស់យើង*ផងដែរ ។ »

មានយុវជនជាច្រើនបានថ្លែងថា សិក្ខាសាលាដ៏គួរឲ្យចងចាំបំផុតមួយគឺមានរួមនូវការបទពិសោធន៍នៃការអ៊ុតអាវពណ៌សមួយ ។ យ៉ាកុបបានថ្លែងថា « វារំឭកខ្ញុំថា មានជំនាញចាំបាច់ជាច្រើនទៀតដែលខ្ញុំអាចរៀនដើម្បីរៀបចំខ្លួនសម្រាប់បេសកកម្មពេញម៉ោង » ។

សារ៉ា អ័រ មកពីវួដសេនវីកា បានថ្លែងថា « ខ្ញុំបានរៀនថា មានរឿងជាច្រើនដែលខ្ញុំអាចធ្វើនៅពេលនេះដើម្បីចូលរួមនឹងពួកអ្នកផ្សព្វផ្សាយសាសនាដែលបម្រើនៅទីនេះ ដើម្បីយើងស្ថិតនៅក្នុងក្រុមតែមួយ » ។ « សមាជិកក៏ជាអ្នកផ្សព្វផ្សាយសាសនាដែរ » ។

ជាការរំឭកមួយថា ពួកអ្នកផ្សព្វផ្សាយសាសនាដែលបម្រើនៅជុំវិញពិភពលោក អាហារត្រូវបានរៀបចំឡើងតាមមុខម្ហូបមកពីប្រទេសខុសៗគ្នា ។ « វាបានរំឭកខ្ញុំថា ខ្ញុំគួរសាកល្បងអាហារថ្មីនៅពេលនេះ ដើម្បីអាចឲ្យខ្ញុំសាកល្បងនូវអ្វីដែលខ្ញុំពុំធ្លាប់ហូបពីមុនមក ។ ស៊ីម៉ូនបានថ្លែងថា « វានឹងជួយឲ្យខ្ញុំសម្របខ្លួនបានយ៉ាងលឿនប្រសិនបើខ្ញុំត្រូវបានហៅទៅកន្លែងមួយដែលពួកគេហូបអាហារដែលខ្ញុំពុំធ្លាប់ហូប » ។

## ការរៀចំខ្លួនជាស្រេច

លីស អាន់ឡៅ អូ មកពីវួដហ្វ្រេឌ្រីកស្ដាដ បានថ្លែងថា « នៅចុងបញ្ចប់នៃថ្ងៃនោះ បន្ទាប់ពីស្ដាប់ពួទីបន្ទាល់របស់យុវវ័យពីរនាក់ និងអ្នកត្រឡប់មកពីបេសកកម្មថ្មីៗពីរនាក់ យើងបានច្រៀងទំនុកតម្កើងបទ ‹ Called to Serve ( បានហៅឲ្យបម្រើ )› » ។ « ខ្ញុំមានអារម្មណ៍ថា បើខ្ញុំបន្តច្រៀងទំនុកតម្កើងនេះគ្រប់ពេល ខ្ញុំនឹងមានការរំឭកជាទៀងទាត់មួយថា នៅពេលយើងជាពួកអ្នកផ្សព្វផ្សាយសាសនា យើងកំពុងបម្រើព្រះវរបិតាសួគ៌ ហើយទ្រង់នឹងប្រទានពរដល់យើង » ។

លុះថ្ងៃនោះបានបញ្ចប់ទៅ យុវវ័យនៅក្នុងស្ដេកនោះបានយល់ថា ពួកគេមិនគ្រាន់តែកំពុងរៀបចំខ្លួនសម្រាប់បទពិសោធន៍ជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងប៉ុណ្ណោះទេ ប៉ុន្តែពួកគេអាចមានបទពិសោធន៍ជាអ្នកផ្សព្វផ្សាយសាសនានៅពេលនេះ និង ពេញមួយជីវិតរបស់ពួកគេបាន ។ ■

*អ្នកនិពន្ធរស់នៅទីក្រុងអូស្លូ ប្រទេសន័រវេស*

*តើជីវិតជាអ្នកផ្សព្វផ្សាយសាសនាមានទិដ្ឋភាពយ៉ាងណាដែរ ?*

*សូមស្រាវជ្រាវបន្ថែមទៀតពីការរៀបចំខ្លួនសម្រាប់ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាជាមួយនឹងវីដេអូ ធនធានផ្សេងទៀត និងចម្លើយចំពោះសំណួរដែលបានសួរជាញឹកញាប់នៅ youth.lds.org ( សូមចុច « Missionary Preparation » ) ។*



### ការរៀបចំខ្លួនដ៏សំខាន់បំផុត

« រឿងដ៏សំខាន់តែមួយគត់ដែលអ្នកអាចធ្វើដើម្បីរៀបចំខ្លួនសម្រាប់ការហៅបម្រើមួយ គឺការ*ប្រែក្លាយជា*អ្នកផ្សព្វផ្សាយសាសនាម្នាក់ពីមុនអ្នកចេញទៅបេសកកម្ម » ។

អែលឌើរ ដាវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Becoming a Missionary » *លេអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2005 ទំព័រ 45 ។









# ការបម្រើនៅពេលនេះ ដើម្បីបម្រើនៅពេលក្រោយ



**ដោយ មិចឈី បារបូសា**

ផ្អែកទៅលើដំណើររឿងពិតមួយ

« *ឲ្យគោរពប្រតិបត្តិដល់ទ្រង់ឲ្យអស់ពីចិត្តចុះ* » ( *សាំយូអែលទី 1 12:20* ) ។

« បងនឹងរត់ប្រណាំងជាមួយឯងទៅព្រះវិហារ ! » មរមនបានពោល ដោយចង្អុលទៅកំពូលព្រះវិហារដែលលេចចេញមកពីលើដើមត្នោត ។ រួចគាត់បានខំរត់យ៉ាងលឿនដើម្បីរត់នាំមុខប្អូនប្រុសគាត់ឈ្មោះម៉ូរៀន ។

ក្មេងប្រុសទាំងពីរ និង ឪពុកម្ដាយពួកគេបានដើរប្រមាណលើសពីមួយគីឡូម៉ែត្រពីផ្ទះរបស់ពួកគេ ប៉ុន្តែមរមន និង ម៉ូរៀននៅតែប្រឹងប្រែងរត់ប្រណាំងគ្នា នៅពេលពួកគេបានមកដល់ច្រកទ្វារដែកខាងក្រៅសាលាប្រជុំនៃវួដរបស់ពួកគេ ។ ពួកគេបានឈប់ដើម្បីដកដង្ហើម ។

ពីមុនពួកគេអាចសម្រេចថានរណាជាអ្នករត់ឈ្នះ នោះមានក្មេងប្រុសម្នាក់បានស្រែកទៅពួកគេថា « តើឯងលេង*បាល់ទាត់*ទេ ? »

មរមនចូលចិត្តលេង*បាល់ទាត់*ណាស់ ប៉ុន្តែគាត់ និង គ្រួសារគាត់នឹងទៅសម្អាតអគារវួដដើម្បីឲ្យវាបានស្អាតសម្រាប់ព្រះវិហារនៅថ្ងៃស្អែក ។

មរមនបានគ្រវីក្បាល ។ « ឥឡូវខ្ញុំលេងអត់បានទេ—ចាំពេលក្រោយចុះ ! » គាត់បានស្រែកប្រាប់ទៅវិញ ។

រំពេចនោះមរមន និង ម៉ូរៀនបានខិតខំធ្វើការ ។ មរមនបានលើកកៅអី ហើយបោសឥដ្ឋជាមួយឪពុកគាត់ កាលម៉ូរៀនជូតឥដ្ឋជាមួយម្ដាយគាត់ ។

ក្រោយមកទៀតក្មេងប្រុសទាំងពីរបានជូតកញ្ចក់ក្នុងបន្ទប់ទឹកជាមួយគ្នា ។ ម៉ូរៀនបានពោលថា « ខ្ញុំមិនបានគិតថា ខ្ញុំពេញចិត្តនឹងសម្អាតព្រះវិហារទេ ប៉ុន្តែវាសប្បាយមែន » ។ « ចុះបងវិញ មរមន ? នោះជាហេតុផលដែលបងមិនទៅលេង*បាល់ទាត់*មែនទេ ? »





មរមនបានគិតពីឪពុករបស់គាត់ ។ គាត់ជាប៊ីស្សពក្នុងវួដពួកគេ ប៉ុន្តែគាត់នៅចំណាយពេលជួយសម្អាតសាលាប្រជុំ ។

មរមនតបថា « បងនៅទីនេះដោយសារបងចង់ធ្វើដូចជាប៉ា » ។

រួចគាត់បានគិតពីពួកអ្នកផ្សព្វផ្សាយសាសនានៅក្នុងវួដ ។ ពួកគេខំដើរគោះទ្វារ ហើយចែកព្រះគម្ពីរមរមនជាមួយនឹងអ្នកដទៃ ។ ពួកគេបានអញ្ជើញមនុស្សឲ្យមកព្រះវិហារ ជាអគារដែលក្មេងប្រុសទាំងពីរកំពុងសម្អាត ។

មរមនបានគិតថា « ខ្ញុំនៅទីនេះ ដោយសារនៅថ្ងៃណាមួយ ខ្ញុំក៏ចង់បម្រើបេសកកម្មដែរ » ។ « ខ្ញុំអាចជួយពួកអ្នកផ្សព្វផ្សាយសាសនាដោយការរៀបចំព្រះវិហារឲ្យរួចរាល់ » ។

មរមនបានគិតពីថ្ងៃស្អែក ក្នុងពេលដែលគាត់ និង ប្អូនប្រុសគាត់ត្រូវក្រោកឡើងនៅវេលាម៉ោង 6:00 ព្រឹក ដើរទៅព្រះវិហារដោយមានពាក់អាវពណ៌-ស និង ក្រវ៉ាត់-ក ហើយរៀបចំកៅអី និង សៀវភៅចម្រៀងក្នុងបន្ទប់កុមារ ។

គាត់បានគិតថា « ខ្ញុំនៅទីនេះ ដោយសារខ្ញុំចង់បម្រើក្នុងមុខងារក្នុងសាសនាចក្រ » ។

មរមនបានគិតពីរបៀបដែលគាត់នឹងក្លាយជាឌីកុនម្នាក់ក្នុងពេលឆាប់ៗ ។ គាត់នឹងចែកសាក្រាម៉ង់ ហើយបំពេញភារកិច្ចជាច្រើនផ្សេងៗទៀតដើម្បីបម្រើ ។

« ខ្ញុំនៅទីនេះ ដោយសារឆ្នាំក្រោយខ្ញុំនឹងទទួលបព្វជិតភាព ហើយខ្ញុំដឹងធ្វើអ្វីៗគ្រប់យ៉ាងដែលខ្ញុំអាចរៀបចំខ្លួនពីឥឡូវនេះ » ។

មរមនបានបំពេញកាតព្វកិច្ចនានារួចរាល់ដើម្បីរៀបចំខ្លួនទទួលបព្វជិតភាពរួចទៅហើយ ៖ គាត់បានទទួលរង្វាន់របស់គាត់សម្រាប់សេចក្ដីជំនឿលើទ្រង់ ។ គាត់រៀនរួចហើយដើម្បីរស់នៅតាមដំណឹងល្អ និងបម្រើដល់អ្នកដទៃ ។

នៅទីបំផុត គាត់បានមើលរូបគាត់នៅក្នុងកញ្ចក់ ហើយញញឹម ។

គាត់បានពោលថា « ខ្ញុំនៅទីនេះដោយសារខ្ញុំស្រឡាញ់ព្រះអម្ចាស់ ហើយដោយសារការបម្រើនៅពេលនេះនឹងជួយខ្ញុំឲ្យត្រៀមខ្លួនជាស្រេច ដើម្បីបម្រើនៅពេលក្រោយ » ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា.*

## ការរៀបចំខ្លួនសម្រាប់បព្វជិតភាព



ព័ត៌មានជំនួយពីដាវីឌ អិល បេក ប្រធានយុវជនទូទៅ ៖

- អញ្ជើញព្រះវិញ្ញាណចូលមកក្នុងជីវិតអ្នក ហើយជ្រើសយកមិត្តភក្តិដែលជួយអ្នកឲ្យរើសផ្លូវត្រូវ ។ រស់នៅតាមបទដ្ឋាននៅក្នុង *ដើម្បីកម្លាំងនៃយុវជន ។*
- រៀនពីកាតព្វកិច្ចការរបស់អ្នកក្នុងនាមជាឌីកុនម្នាក់ ។ សូមអានអំពីបព្វជិតភាពនៅក្នុង *ការបំពេញកាតព្វកិច្ចរបស់ខ្ញុំចំពោះព្រះ* និង *ពិតចំពោះសេចក្ដីជំនឿ ។* ចូលរួមក្នុងប្រជុំបព្វជិតភាពក្នុងវួដ ឬសាខារបស់អ្នក ។
- រៀបចំខ្លួនទៅព្រះវិហារបរិសុទ្ធដើម្បីធ្វើបុណ្យជ្រមុជទឹកសម្រាប់មនុស្សស្លាប់ ។
- មានចិត្តរីករាយចំពោះសកម្មភាព និង ការប្រជុំ ជាមួយនឹងយុវវ័យផ្សេងទៀត ។
- ដឹងថាព្រះវរបិតាសួគ៌ទុកចិត្តអ្នក ហើយពឹងផ្អែកលើអ្នក ។ ស្វែងរកថាតើអ្នកអាចធ្វើបានប៉ុណ្ណាដោយមានជំនួយរបស់ទ្រង់ !



# ម៉ាធីលដេ
## រៀបចំខ្លួនជាស្រេច សម្រាប់ថ្នាក់យុវនារី

ដោយ ជេន វិលកស៍ រដ្ឋយូថាហ៍ ស.រ.អា.

ម៉ាធីលដេ មានចិត្តរំភើបពីការចូលរៀនក្នុងថ្នាក់យុវនារីក្នុងពេលឆាប់ៗនេះ ប៉ុន្តែនាងក៏មិនដឹងថានឹងមានអ្វីកើតឡើងដែរ ។ ដូច្នេះនាងបានពិភាក្សានឹងលោកយាយនាង ។ លោកយាយនាងគឺ សិស្ទើរ បូនី អូស្ការសុន ជាប្រធានយុវនារីទូទៅ ។ គាត់មានដំទូន្មានដ៏ល្អមួយចំនួនដើម្បីចែកចាយរំលែក !

សូមសួរដល់ម្ដាយ ឬលោកយាយអ្នក ឬស្ត្រីម្នាក់នៅក្នុងវួដរបស់អ្នកពីអ្វីដែលពួកគាត់ចងចាំពីយុវនារី ។ អ្នកអាចនឹងរកឃើញរឿងសប្បាយៗមួយចំនួន ។

**ស្ថានភាពសប្បាយ**

ម៉ាធីលដេ ហៅលោកយាយនាងថា « ម៉ូ » ជាពាក្យកាត់នៃ *ម៉ូរ៉េើ*ជាពាក្យថាម្ដាយនៃភាសាស៊ុយអែត ។



## នៅពេលនោះ . . .



កាលសិស្ទើរអូស្ការសុននៅក្នុងថ្នាក់យុវនារី គាត់ទទួលបានស្លាកសម្រេចគម្រោងផ្សេងៗគ្នា ។ គាត់បានដេរវាជាប់នឹងក្រណាត់ពិសេសមួយ ដោយមានដាក់ផ្កាមួយទង ដើម្បីតំណាងឲ្យសេចក្ដីស្មោះត្រង់ ។







## ព័ត៌មានជំនួយរបស់ស៊ិស្ទើរអូស្កាសុនសម្រាប់ការរៀបចំខ្លួន !

- អភិវឌ្ឍទំនាក់ទំនងមួយជាមួយនឹងព្រះវរបិតាសួគ៌របស់អ្នកតាមរយៈការអធិស្ឋាន និងការអានព្រះគម្ពីរ ។
- ស្វែងយល់ពីកម្មវិធីការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារី ។
- អានព្រះគម្ពីរ *កម្លាំងដើម្បីយុវជន* និង *លីអាហូណា* ។
- ចាប់ផ្ដើមរៀនពីបាវចនានៃយុវនារី ។ អ្នកនឹងសូត្រវារាល់សប្ដាហ៍ជាមួយនឹងយុវនារីទាំងអស់ ។


ពួកយើងគឺជាបុត្រីនៃព្រះវរបិតាសួគ៌ ទ្រង់ស្រឡាញ់យើង
ហើយយើងក៏ស្រឡាញ់ព្រះអង្គ ។ យើងនឹង « ឈរជាសាក្សីដល់ព្រះ
នៅគ្រប់ពេល និង គ្រប់សេចក្ដី និងគ្រប់ទីកន្លែង »
នៅពេលយើងព្យាយាមរស់នៅតាមគុណ
សម្បត្តិរបស់ក្រុមនារីដែលមាន ៖

សេចក្ដីជំនឿ , និស្ស័យនៃព្រះ
តម្លៃផ្ទាល់ខ្លួន , ចំណេះវិជ្ជា
ការជ្រើសរើស និង ការទទួលខុសត្រូវ
កិច្ចការល្អ , សេចក្ដីទៀងត្រង់
និង គុណធម៌

យើងជឿថា នៅពេលយើងរៀនទទួល
និងធ្វើតាមគុណសម្បត្តិទាំងនេះ យើងនឹងត្រៀមខ្លួន
ដើម្បីពង្រឹងផ្ទះ និង គ្រួសារ ចុះ និង រក្សាសេចក្ដីសញ្ញាដ៏ពិសិដ្ឋ
ទទួលពិធីការទាំងឡាយនៃព្រះវិហារបរិសុទ្ធ
និងត្រេកអរជាមួយនឹងពរជ័យនៃការលើកដំកើង ។

*(សូមមើល ម៉ូសាយ 18:9)*



### ការចាប់ផ្ដើមថ្មី

ម៉ាធីលដេ បានទៅសកម្មភាពពិសេសមួយហៅថា ការចាប់ផ្ដើមថ្មី ។ ពួកគេបានរៀនមេរៀនមួយដ៏សប្បាយ ហើយរៀនពីការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារី ។

ម៉ាធីលដេក៏កំពុងខិតខំធ្វើកម្មវិធីរង្វាន់សេចក្ដីជំនឿលើព្រះរបស់នាង ហើយទន្ទេញមាត្រានៃសេចក្ដីជំនឿផងដែរ ។

### ម៉ាធីលដេមិនអាចរង់ចាំបានឡើយ . . .

- សម្មភាពរាល់សប្ដាហ៍
- រៀនស្គាល់ក្មេងស្រីដទៃទៀតក្នុងថ្នាក់យុវនារី ។
- ទៅការបោះជំរំសម្រាប់យុវនារី ។

## . . . ហើយឥឡូវនេះ



ខ្សែកនេះនឹងរំឭកអ្នកឲ្យធ្វើជាពន្លឺដល់អ្នកដទៃ ហើយឈរការពារសេចក្ដីពិត និង សេចក្ដីសុចរិត ។

អ្នកក៏នឹងទទួលបានបូរ-ជាច្រើនដោយការបញ្ចប់គម្រោង និង បទពិសោធន៍នៃការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារីផងដែរ ។

បន្ទាប់មកអ្នកនឹងទទួលមេដាយសម្រាប់យុវនារី ។

### អនុស្សាវរីយ៍មួយដ៏ពិសេស

ម៉ាធីលដេ និង បងប្អូនជីដូនមួយរបស់នាងជាច្រើនអ្នកបាននៅក្នុងមជ្ឈមណ្ឌលសន្និសីទ កាលពីថ្ងៃទី 6 ខែ មេសា ឆ្នាំ 2013 ។ ប៉ុន្តែពួកគេមិនបានដឹងថាហេតុអ្វីបានជាលោកយាយពួកគេ អញ្ជើញពួកគេទាំងអស់គ្នាទៅសន្និសីទទូទៅនោះទេ ។ ពួកគេមានការភ្ញាក់ផ្អើល ហើយរំភើបចិត្តនៅពេលគាត់ត្រូវបានគាំទ្រជាប្រធានអង្គការនៃក្រុមយុវនារី !




ស៊ុមដោយ AMILOSLAVA/ISTOCK/THINKSTOCK

# គ្រាយើងត្រូវលើកពន្លឺឡើង

ទំនុកចម្រៀងដោយ ជេន ភីនប្ល៉ាហ្ម
ទំនុកភ្លេង ដោយជេននីស ខាប ផើរ




សិទ្ធិអ្នកនិពន្ធ © 2013 ដោយ ជេន ភីនប្ល៉ាហ្ម និង ចេននីស ខាប ភើរី រក្សាសិទ្ធិគ្រប់យ៉ាង
ចម្រៀងនេះអាចថតចម្លងប្រើប្រាស់តែក្នុងសាសនាចក្រ ឬគេហដ្ឋានប៉ុណ្ណោះ ពុំអាចប្រើប្រាស់ដើម្បីធ្វើអាជីវកម្មឡើយ ។
សេចក្ដីជូនដំណឹងនេះត្រូវដាក់សម្គាល់នៅគ្រប់សំណៅដែលថតចម្លង ។



រូបថតដោយ SZE FEI WONG/ISTOCK/THINKSTOCK

សាក្សីពិសេស



ដោយ អែលឌើរ
ឃ្វីនធិន អិល ឃុក
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សមាជិកកូរ៉ុមនៃពួកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*

# តើខ្ញុំអាចជួយកិច្ចការពង្សប្រវត្តិតាមវិធីណា ?

*អែលឌើរ ឃុក ណែនាំឲ្យមានការប្រជុំពីកម្មវិធី Family Tree ។ នេះជារបៀប !*



សូមឲ្យមនុស្សគ្រប់គ្នាក្នុងគ្រួសាររបស់អ្នកយកប្រវត្តិ ដំណើររឿង និងរូបថតគ្រួសារ ។ រួមទាំងវត្ថុពិសេសដែលជាកម្មសិទ្ធិរបស់ជីដូនជីតា និង ឪពុកម្ដាយរបស់អ្នក ។

វាជារឿងដ៏រំភើបដើម្បីរៀនពីជីវិតនៃសមាជិកគ្រួសារ—ពីស្រុកកំណើត និងរបៀបដែលពួកគាត់បានរស់នៅ ។

ចូររកមើលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធណាមួយដែលត្រូវធ្វើ ហើយចាត់តាំងការងារសម្រាប់កិច្ចការព្រះវិហារបរិសុទ្ធ ។

ជួយស្កេន ហើយផ្ទុកដំណើររឿង និង រូបថតទាំងនេះក្នុង Family Tree នៅ Family-Search.org ។

*ដកស្រង់ចេញពី « Roots and Branches » លីអាហូណា ខែ ឧសភា ឆ្នាំ 2014 ទំព័រ 47 ។*

# « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » មកពីព្រះដើម្បីជួយក្រុមគ្រួសារខ្ញុំ




**ដោយ អេរីន សាន់ឌើរសុន និង ជីន ប៊ីងហាំ**

កុមារមាននូវអំណាចជាច្រើន—ជាអំណាចដើម្បីធ្វើឲ្យមានការផ្លាស់ប្ដូរមួយនៅក្នុងក្រុមគ្រួសារ ! ក្រុមគ្រួសារទាំងអស់មិនដូចគ្នាទេ ប៉ុន្តែគ្រួសារគ្រប់រូបគឺសំខាន់ចំពោះព្រះវរបិតាសួគ៌ ។ ទ្រង់សព្វព្រះទ័យឲ្យក្រុមគ្រួសារយើងបានរឹងមាំ ដូច្នេះទ្រង់បានប្រទានឲ្យយើងនូវ « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ដើម្បីជួយយើង ។ ព្រះវរបិតាសួគ៌ជ្រាបថា អ្នកអាចជួយពង្រឹងគ្រួសារអ្នក ។

អ្នកគឺជាផ្នែកនៃគ្រួសារអស់កល្បជានិច្ចមួយដែលត្រូវការជំនួយរបស់អ្នក ។

អ្នកអាចនាំមកនូវសុភមង្គល សេចក្ដីសប្បុរស និងសេចក្ដីស្រឡាញ់ដល់គ្រួសារអ្នក ។

អ្នកអាចស្ដាប់គ្នាទៅវិញទៅមក ធ្វើការ ហើយលេងជាមួយគ្នា អភ័យទោស ហើយជួយគ្នាទៅវិញទៅមក ។

អ្នកអាចអានព្រះគម្ពីរជាមួយនឹងគ្រួសារអ្នក ។

អ្នកអាចធ្វើគំរូល្អដល់គ្រួសារអ្នក ពេលអ្នកអធិស្ឋាន ហើយគោរពព្រះបញ្ញត្តិ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា.*

រូបភាពដោយ ជេរី ធូរស៍ ។ រូបថតកំប៉ុងដោយ ISTOCK/THINKSTOCK

## ព្រះគម្ពីរ

- យ៉ូហាន 15:11

## គំនិតយោបល់សម្រាប់ការនិយាយក្នុងគ្រួសារ

ព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យក្រុមគ្រួសារទាំងអស់រឹងមាំ ហើយត្រឡប់ទៅកទ្រង់វិញ ។ សូមពិភាក្សាពីអ្វីដែលសមាជិកគ្រួសារម្នាក់ ៗ អ្វី ៗដែលគេអាចធ្វើដើម្បីជួយគ្រួសារអ្នកឲ្យរឹងមាំ ។

ខ្ញុំអាចពង្រឹងគ្រួសារខ្ញុំតាមរយៈ

ខ្ញុំអាចពង្រឹងគ្រួសារខ្ញុំតាមរយៈ

ខ្ញុំអាចពង្រឹងគ្រួសារខ្ញុំតាមរយៈ

ខ្ញុំអាចពង្រឹងគ្រួសារខ្ញុំតាមរយៈ

ខ្ញុំអាចពង្រឹងគ្រួសារខ្ញុំតាមរយៈ

ខ្ញុំអាចពង្រឹងគ្រួសារខ្ញុំតាមរយៈ

ខ្ញុំអាចពង្រឹងគ្រួសារខ្ញុំតាមរយៈ

ខ្ញុំអាចពង្រឹងគ្រួសារខ្ញុំតាមរយៈ

## អ្នកអាច !



តុបតែងកំប៉ុងទទេរស្អាតមួយដោយដាក់ស្លាកពាក្យនេះ ( នៅខាងស្ដាំ ) និងរូបថត ឬគំនូរមួយចំនួន ។ សូមបំពេញពាក្យជាចម្រៀកជាមួយគំនិតស្ដីពីរបៀបដែលអ្នកអាចពង្រឹងដល់គ្រួសារអ្នក ។ សូមកាត់ពាក្យជាចម្រៀកនោះចេញ ហើយដាក់វានៅក្នុងកំប៉ុង ។ ជារៀងរាល់ថ្ងៃ សូមជ្រើសយកពាក្យជាចម្រៀកមួយពីកំប៉ុងនោះ ហើយធ្វើតាមអ្វីដែលវាបានប្រាប់ ។ នៅពេលអ្នកព្យាយាមរស់នៅតាមគំនិតរបស់អ្នក អ្នកអាចធ្វើឲ្យមានការផ្លាស់ប្ដូរមួយនៅក្នុងគ្រួសារអ្នកបាន !



# ខ្ញុំឈ្មោះបាបារ៉ាមកពីប្រទេសស៊ីលី

ដកស្រង់ពីការសម្ភាសមួយ ដោយអាមី ជេន លីវិត

បាបារ៉ារស់នៅក្នុងប្រទេសស៊ីលី ជាប្រទេសមួយនៅឆ្នេរសមុទ្រភាគខាងលិចនៃអាមេរិកខាងត្បូង ។ វាមានរាងទ្រវែង ហើយតូចដូចជាខ្សែបូ ។ តំបន់ខ្លះក្ដៅ ហើយស្ងួត ( ដូចជាឆ្នេរខ្សាច់អាតាកាម៉ា ) ហើយខ្លះទៀតជាតំបន់ត្រូពិត ហើយសើម ( ដូចជាកោះអ៊ីសស្ទើរ ) ។ នាងរស់នៅក្នុងរាជធានីរបស់ប្រទេសស៊ីលីឈ្មោះថា សាន់ត្យាហ្គោ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា.*




*ខ្ញុំជាសមាជិកសាសនាចក្រតែម្នាក់គត់នៅក្នុងថ្នាក់រៀនរបស់ខ្ញុំ ។ ការណ៍នេះផ្ដល់ឱកាសឲ្យខ្ញុំប្រាប់ដល់មិត្តភក្ដិរបស់ខ្ញុំពីព្រះយេស៊ូវគ្រីស្ទ និង ព្រះគម្ពីរមរមន ។ ពេលមួយ មានមិត្តសម្លាញ់ខ្ញុំម្នាក់បានសុំឲ្យខ្ញុំបង្រៀននាងពីរបៀបអធិស្ឋាន ។ ដូច្នេះខ្ញុំក៏បានបង្រៀនដល់នាង ។ រួចយើងទាំងពីរនាក់បានអធិស្ឋាននៅពេលបាយថ្ងៃត្រង់នៅឯសាលារៀន ។*



*ខ្ញុំមានអាយុប្រាំបួនឆ្នាំ ហើយមានប្អូនប្រុសពីរនាក់ ។ ខ្ញុំព្យាយាមធ្វើជាបងស្រីដ៏ល្អម្នាក់ ហើយជួយមើលថែពួកគេ ហើយលេងជាមួយនឹងពួកគេ ។ ខ្ញុំចូលចិត្តមើលថែក្មេង។ ខ្ញុំចង់ក្លាយជាគ្រូបង្រៀនពេលខ្ញុំធំឡើង ។*



*ក្នុងឆ្នាំ 2013 ខ្ញុំមានអាយុប្រាំបីឆ្នាំ ហើយទទួលពិធីបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ដោយឪពុករបស់ខ្ញុំ ។ ខ្ញុំរីករាយខ្លាំងណាស់ ! វាជាបទពិសោធន៍ដ៏ពិសេសមួយដែលខ្ញុំនឹងចងចាំវាជានិច្ច ។*

# អូឡា អាមីហ្គូស !*

* « សួស្ដី មិត្តភក្តិទាំងឡាយ ! » ជាភាសាអេស្ប៉ាញ



*យើងអបអរថ្ងៃបុណ្យឈប់សម្រាកដ៏រីករាយនៅប្រទេសស៊ីលី ។ ថ្ងៃទី 18 ខែ កញ្ញា គឺជាថ្ងៃបុណ្យឯករាជ្យ ហើយថ្ងៃទី 19 គឺជាថ្ងៃបុណ្យទិវាកងទ័ព ។ អំឡុងពេលពីរថ្ងៃនេះ យើងរាំរបាំជាតិរបស់យើងហៅថា « ឡាគូអេកា » ហើយបរិភោគនំស្នូលសាច់ដ៏ឈ្ងុយឆ្ងាញ់មួយយ៉ាងហៅថា នំចំណិត ។*







## ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ

ព្រះវិហារបរិសុទ្ធស៊ីលីសាន់ត្យាហ្គោគឺជាព្រះវិហារបរិសុទ្ធដំបូងដែលបានសង់នៅក្នុងប្រទេសដែលនិយាយភាសាអេស្ប៉ាញ ។ វាត្រូវបានឧទ្ទិសឆ្លងនៅថ្ងៃទី 15 ខែ កញ្ញា ឆ្នាំ 1983 ។ វាគឺជាព្រះវិហារបរិសុទ្ធទីពីរដែលបានសង់នៅអាមេរិកខាងត្បូង ។



*នៅចុងសប្ដាហ៍ គ្រួសារខ្ញុំចូលចិត្តដើរ និងជិះម៉ូតូកង់បួនឡើងភ្នំនៅក្បែរផ្ទះរបស់យើង ។ យើងក៏ចូលចិត្តទៅលេងមាត់សមុទ្រដែរ ។*



## ត្រៀមខ្លួនហើយឬនៅ!

កាបូបរបស់បាបារ៉ាត្រូវបានដាក់ទៅដោយរបស់របរមួយចំនួនដែលនាងចូលចិត្ត ។ តើរបស់ណាខ្លះ អ្នកចង់ដាក់ក្នុងកាបូបរបស់អ្នក ?



*យើងមានអាហារដ៏ពិសេសមួយសម្រាប់បុណ្យគ្រីស្ទម៉ាស—គឺប៉េងប៉ោះលាយជាមួយត្រីធូណា ។ នៅប្រទេសស៊ីលី សាន់តាក្លូសបានមកនៅពាក់កណ្ដាលអាធ្រាត្រក្នុងយប់មុនបុណ្យគ្រីស្ទម៉ាស ។ យើងបាននៅចាំរហូតដល់គាត់បានមក !*



ខាងស្តាំ ៖ រចនាគំនូរដោយអ៊ែមស៊ី អេស អាល

# ទំព័ររបស់យើង



មានថ្ងៃមួយ ពីមុនពេលខ្ញុំធ្វើបុណ្យជ្រមុជទឹកបន្តិច ខ្ញុំបាននៅផ្ទះលោកយាយរបស់ខ្ញុំ កាលគាត់បានចុះទៅជាន់ក្រោមដីទៅយកអ្វីមួយ ។ គាត់បានជំពប់ជើងដួល ហើយក្រោកមិនរួច ។ គាត់បានស្រែកហៅខ្ញុំ ប៉ុន្តែខ្ញុំកំពុងមើលទូរទស្សន៍ ហើយមិនបានឮគាត់ហៅទេ ។ ប្រមាណជា 10 នាទី ក្រោយមកខ្ញុំបានឮសំឡេងតិចៗហៅឈ្មោះខ្ញុំថា « ចម ! » ខ្ញុំបានទៅរកមើលគាត់ ហើយបានឃើញគាត់ដេកស្តូកនៅនឹងឥដ្ឋ ។ ខ្ញុំគ្មានកម្លាំងគ្រប់គ្រាន់ដើម្បីជួយលើកគាត់ឡើងទេ ដូច្នេះក៏បានរត់ទៅផ្ទះអ្នកជិតខាង ។ គាត់បានមកជួយលើកលោកយាយខ្ញុំឡើង ។

លោកយាយខ្ញុំបានប្រាប់ថា « ចម សំឡេងដែលចៅបានឮនោះគឺជាព្រះវិញ្ញាណបរិសុទ្ធ ។ យាយនៅឆ្ងាយពីចៅណាស់ ដើម្បីចៅអាចស្តាប់យាយឮ » ។

ខ្ញុំដឹងថា នោះជាព្រះវិញ្ញាណបរិសុទ្ធដែលបានខ្សឹបប្រាប់ខ្ញុំ ។ ឥឡូវនេះខ្ញុំបានជ្រមុជទឹក ហើយខ្ញុំរីករាយដោយទទួលបានអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។

**ចម អ័រ អាយុ 8 ឆ្នាំ ប្រទេស អាល្លឺម៉ង់**



**ឡូ សុី អាយុ 7 ឆ្នាំ ប្រទេសអេក្វាទ័រ**






**ណាតាលីយ៉ា អេ អាយុ 10 ឆ្នាំ ប្រទេស កូឡុំប៊ី**



***ធារី អិម អាយុ 7 ឆ្នាំ មកពីប្រទេសប្រេស៊ីល ចូលចិត្តចូលរៀនថ្នាក់កុមារ ហើយច្រៀងទំនុកតម្កើង ។ នាងដឹងថា ព្រះវិហារបរិសុទ្ធគឺជាដំណាក់របស់ព្រះអម្ចាស់ ។***





***អូលីវីយ៉ា អាយ អាយុ 8 ឆ្នាំ មកពីប្រទេសរូម៉ានី ចូលចិត្តជួយម្តាយនាងសម្អាតផ្ទះ ។ ម្តាយនាងបង្រៀននាង និងមិត្តនាង 13 នាក់ទៀត ហើយពេលពួកគេសម្រាកនាងចូលចិត្តធ្វើជាគ្រូបង្រៀន ។ នាងចូលចិត្តទៅធ្វើដំណើរជាមួយនឹងឪពុកម្តាយនាង ហើយចំណាយពេលជាមួយលោកតាលោកយាយនាង ។ នៅពេលនាងបានជ្រមុជទឹក នាងមានអារម្មណ៍ខិតជិតនឹងព្រះវរបិតាសួគ៌ ហើយនាងមានអំណរគុណដែលនាងអាចមានព្រះវិញ្ញាណបរិសុទ្ធដើម្បីជួយនាងធ្វើការសម្រេចចិត្ត ។ ចម្រៀងថ្នាក់កុមារដែលនាងចូលចិត្តគឺបទ « Follow the Prophet ( ធ្វើតាមព្យាការី ) » ( Children's Songbook ទំព័រ 110 ) ។***

អ្នកអាចដាក់ស្នើរូបគំនូរ រូបថត ឬបទពិសោធន៍របស់អ្នកតាមអ៊ិនធើរណែត នៅliahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ដោយដាក់ « Our Page » ក្នុងប្រអប់ប្រធានបទ ឬផ្ញើជាសំបុត្រទៅកាន់ ៖ ។

*Liahona,* Our Page
50 E. North Temple St., Rm. 2420
Salt Lake City, UT 84150-0024, USA

រាល់ការផ្ញើមកត្រូវតែមានឈ្មោះពេញរបស់កុមារ ភេទ និង អាយុ (អាយុចាប់ពី 3 ឆ្នាំ ដល់ 11 ឆ្នាំ) រួមទាំងឈ្មោះពេញរបស់ឪពុកម្តាយ វួដ ឬ សាខា ស្តេក ឬ មណ្ឌល និង សំបុត្រអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុកម្តាយផងដែរ ដើម្បីប្រើប្រាស់រូបថត និង ឯកសាររបស់កុមារដែលបានបញ្ជូនមក ( អ៊ីម៉ែលក៏អាចទទួលយកបានដែរ ) ។ ការដាក់ស្នើអាចនឹងត្រូវធ្វើការកែសម្រួលដើម្បីឲ្យត្រូវនឹងទំហំ ឬ ភាពច្បាស់លាស់ ។



ដោយអែលឌើរ អេគ្រាន អូឆារ
នៃពួកចិតសិបនាក់

# សម្លឹងមើលទៅលើ



*« ចូរចាំយាមចុះ ហើយអធិស្ឋានជានិច្ច » ( លូកា 21:36 ) ។*

កាលអាយុប្រាំបីឆ្នាំ ខ្ញុំ និងបងប្អូនជីដូនមួយខ្ញុំពីរនាក់ទៀត ត្រូវបានឲ្យទៅទិញម្ហូបក្នុងក្រុងមួយក្បែរនោះ ។ ពេលមើលទៅក្រោយវិញ ខ្ញុំស្ងើចចំពោះទំនុកចិត្ត ដែលលោកយាយ និងពូមីងខ្ញុំមានចំពោះយើង ។ យើងបានចាកចេញទៅដោយជិះលើសេះតូចបីក្បាល នៅក្រោមផ្ទៃមេឃភ្លឺស្រឡះនាព្រឹកព្រលឹម ។

នៅចំកណ្ដាលវាលស្មៅដ៏ធំមួយ យើងបានសម្រេចចិត្ត ចុះពីលើសេះលេងបាញ់ឃ្លី ។ យើងបានវក់នឹងល្បែង ភ្លេចសម្លឹងមើលទៅលើឃើញដុំពពកខ្មៅកំពុងតែបិទបាំងផ្ទៃមេឃ ។ ទម្រាំតែយើងដឹងថា មានអ្វីកើតឡើង យើងគ្មានពេលច្រើនជិះសេះយើងឡើយ ។ មានភ្លៀងនិងព្រិលដ៏ខ្លាំងបានធ្លាក់មកប៉ះយើង ហើយអ្វីដែលយើងអាចគិតឃើញគឺ ដោះកែបសេះចេញ ហើយយកភួយនៅក្រោមកែបតូចនោះចេញមកដណ្ដប់ខ្លួន ។ រួចសេះយើងក៏រត់ទៅបាត់ ។

យើងបានបន្តដំណើរដោយគ្មានសេះ ទាំងខ្លួនរងារ ទទឹកជោគ ដែលឥឡូវនេះព្យាយាមដើរយ៉ាងលឿនតាមដែលយើងអាចធ្វើបានទៅកាន់ទីក្រុងមួយក្បែរនោះ ។ ពេលយើងរកឃើញផ្ទះមួយ ហើយបានទៅគោះទ្វារ នោះវាយប់ជ្រៅទៅហើយ ។ គ្រួសារដ៏ល្អនោះបានជូតខ្លួនឲ្យយើង ធ្វើប៊ើរីតូសណ្ដែកយ៉ាងឆ្ងាញ់ឲ្យយើងហូប រួចដាក់យើងដេកក្នុងបន្ទប់មួយដែលមានតែឥដ្ឋសុទ្ធតែដី ។

បងប្អូនជីដូនមួយខ្ញុំ និង ខ្ញុំបានក្រោកនៅពេលព្រឹកនៅក្រោមពន្លឺព្រះអាទិត្យដ៏ភ្លឺ និងផ្ទៃមេឃដ៏ស្រស់ស្អាត ។ មានបុរសម្នាក់បានគោះទ្វាររកក្មេងប្រុសបាត់ខ្លួនបីនាក់ ។ ខ្ញុំពុំដែលភ្លេចពីអ្វីដែលខ្ញុំបានឃើញនៅតាមផ្លូវត្រឡប់មកផ្ទះវិញឡើយ—ពីចំនួនមនុស្សដ៏ច្រើនដែលកំពុងស្វែងរកយើងពេញមួយយប់ ។ នៅពីមុខពួកគេគឺលោកយាយ និងពូមីងជាទីស្រឡាញ់របស់ខ្ញុំ ។ ពួកគេបានឱបយើង ហើយក៏យំ ដោយក្ដីរីករាយដែលពួកគាត់បានឃើញពួកយើង ។

ព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់យើងមានព្រះទ័យខ្វល់ខ្វាយពីយើង ។ ទ្រង់រង់ចាំយើងត្រឡប់មកផ្ទះវិញដោយអន្ទះសារ ។ មានទីសម្គាល់នៃព្យុះខាងវិញ្ញាណកំពុងកើតឡើងនៅជុំវិញយើង ។ ចូរយើងសម្លឹងមើលទៅលើ ហើយរៀបចំខ្លួន ដោយពង្រឹងទីបន្ទាល់យើងជារៀងរាល់ថ្ងៃ ។ ■

គំនូរដោយ ឌីណា ធេនវី

*ដកស្រង់ចេញពី « Look Up » លីអាហូណា ខែ វិច្ឆិកា ឆ្នាំ 2013 ទំព័រ 102 ។*



# ក្រុមក្នុងគ្រួសារ

*វាងាយនឹងទទួលបានជោគជ័យ នៅពេលមនុស្សគ្រប់គ្នាធ្វើការរួមគ្នា ។*

**ដោយស្តេរ៉ាលី ហាឌី**
ផ្អែកទៅលើដំណើររឿងពិតមួយ

« *When we're helping, we're happy* » ( Children's Songbook *ទំព័រ 198* ) ។

អាំម៉ូនបានដកដង្ហើមធំនៅពេលគាត់ និង ឪពុកគាត់ចាកចេញពីការប្រកួតកីឡាបាល់ទាត់ ។ គាត់បានពោលថា « កូនមិនយល់ទេ » ។ « យើងមានកីឡាករល្អៗជាច្រើន ។ ហេតុអ្វីបានជាយើងមិនអាចរកពិន្ទុបានដូច្នេះ ? »

ឪពុកធ្លាប់ជាកីឡាករបាល់ទាត់ម្នាក់ដ៏ល្អ ។ ប្រហែលជាគាត់អាចជួយឆ្លើយបាន ។

ឪពុកបានតបថា « ប៉ាគិតថាកូនត្រូវរៀនធ្វើការជាក្រុម » ។ « អ្នកទាំងអស់គ្នាចង់រកបានពិន្ទុមែនទេ ? »

អាំម៉ូនបានតបថា « បាទ » ។

« ប៉ុន្តែយើងទាំងអស់គ្នាមិនអាចជាមនុស្សតែម្នាក់ឯងដែលទាល់បាល់បញ្ចូលទីនោះទេ ។ ប៉ាចង់មានន័យដូច្នេះមែនទេ ? »

ប៉ាបានងក់ក្បាលយល់ព្រម ។ « កូនមិនអាចទាត់បាល់បញ្ចូលទីតែម្នាក់ឯងបានទេ ។ ដំបូង ខ្សែការពារត្រូវដណ្តើមបាល់ពីក្រុមម្ខាងទៀតមែនទេ ? »

អាំម៉ូនបានសើច ។ « វាពិបាកនឹងទាត់បាល់បញ្ចូលទីណាស់បើយើងគ្មានបាល់នោះ » ។

ឪពុកបានតបថា « ត្រឹមត្រូវហើយ » ។ « រួចខ្សែការពារប៉ះបាល់ទៅកីឡាករម្នាក់ដែលអាចទាត់បាល់បញ្ចូលទីបាន ។ គ្មាននរណាម្នាក់អាចទាត់បាល់បញ្ចូលទីតែម្នាក់ឯងនោះទេ » ។

អាំម៉ូនបានតបថា « កូនក៏គិតអញ្ចឹងដែរ » ។

នៅពេលពួកគេទៅដល់ផ្ទះវិញ ម្តាយគាត់កំពុងបីកូនតូចបណ្តើរធ្វើអាហារពេលល្ងាចបណ្តើរ ។

រូបភាពដោយ ម៉ាត ដាវ៉ែន



« តើការប្រកួតយ៉ាងម៉េចដែរ ? » គាត់បានសួរ ។

អាំម៉ូនតបថា « យើងចាញ់ទៀតហើយ » ។ « តែយើងនឹងធ្វើឲ្យបានល្អនៅលើកក្រោយ » ។

ម្ដាយតបថា « នោះជាគំនិតដ៏ល្អ » ។

« កូនឃ្លានណាស់ ! » មីកែលបានស្រែកនៅពេលគាត់ សាំយ៉ូអែល និងលូកាសបានរត់ចូលមក ។

« កូនៗ តើកូនអាចជួយរៀបចំតុ និងប្រដាប់ប្រដារលេងទុកបានទេ ? » ម្ដាយបានសួរ ។

ក្មេងប្រុសទាំងបួនបានថ្ងូរ ។

សាំយូអែលបានតបថា « តែកូនមិនបានលេងប្រដាប់ប្រដារនោះទេ » ។

« វាត្រូវចំណាយពេលយូរណាស់ ! » មីកែលបានស្រែកទ្រហោយំ ។

ឳពុកបានសើច ។ « ប៉ាគិតថាគ្រួសារយើងមានបញ្ហាដូចគ្នានឹងក្រុមរបស់អាំម៉ូនដែរ » ។

« នោះជាអ្វីទៅ ? » សាំយ៉ូអែលបានសួរ ។

អាំម៉ូនបានតបថា « យើងមិនធ្វើការរួមគ្នា » ។ « យើងទាំងអស់គ្នាចង់ហូបអាហារពេលល្ងាច ។ ប៉ុន្តែយើងទុកឲ្យម៉ាក់ធ្វើវាតែម្នាក់ឯង » ។

« ត្រូវហើយ ! » ឳពុកបានពោល ។ « តើយើងអាចធ្វើការជាក្រុមតាមរបៀបណា ? »

អាំម៉ូនមានគំនិតមួយ ។ « ចុះបើសាំយូអែល និងខ្ញុំរៀបចំតុវិញយ៉ាងម៉េចដែរ ? រីឯអ្នកផ្សេងទៀតអាចប្រមូលប្រដាប់ប្រដារលេង » ។

« គំនិតល្អណាស់ ! » ឳពុកបានតប ។

មិនយូរប៉ុន្មាន អាហារពេលល្ងាចបានរួចរាល់ ។ អាំម៉ូនបានឱបដៃគាត់អធិស្ឋាន ។ គាត់មានចិត្តរីករាយដែលគ្រួសារគាត់បានធ្វើការរួមគ្នា ។ គាត់សង្ឃឹមថា ក្រុមបាល់ទាត់របស់គាត់អាចធ្វើដូចគ្នាផងដែរ ។ ■



ដោយ អែលឌើរ អិម រ័សុល បាឡឺដ
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# សេចក្ដីបំភាន់



រដូវស្លឹកឈើជ្រុះជារដូវដ៏រំភើបមួយសម្រាប់អ្នកស្ទូចត្រី ដ្បិតវាជាពេលដែលត្រីត្រៅត៍ត្រូវតាមប្រម៉ាញ់ចំណី ដោយភាពស្រេកឃ្លានពុំចេះស្កប់ស្កល់ ដើម្បីទ្រទ្រង់រាងកាយរបស់វា ក្នុងការទប់ទល់នឹងភាពខ្វះចំណីនារដូវរំហើយ ។

គោលបំណងរបស់អ្នកស្ទូចត្រីគឺដើម្បីចាប់ត្រីស្រដៀងត្រីនោះតាមរយៈការដាក់បញ្ឆោតដ៏ស្ទាត់ជំនាញ ។ អ្នកស្ទូចត្រីដ៏ស្ទាត់ជំនាញសិក្សាពីអាកប្បកិរិយា អាកាសធាតុ និងផ្ទៃទឹករបស់ត្រីស្រដៀងត្រីនោះហើយនិងសត្វល្អិតដែលត្រីនោះស៊ី ព្រមទាំងពេលដែលសត្វល្អិតទាំងនោះចេញផងដែរ ។ ជាញឹកញាប់ គាត់នឹងប្រើនុយឆ្នៃប្រឌិតធ្វើវាជានុយ ។ គាត់ដឹងថា សត្វល្អិតក្លែងក្លាយទាំងនេះត្រូវបង្កប់ជាមួយនឹងផ្លែសន្ទូចដ៏តូច សត្វល្អិតទាំងនោះត្រូវធ្វើជាអ្នកបញ្ឆោតដ៏ឥតខ្ចោះ ពីព្រោះត្រីស្រដៀងត្រីនោះនឹងដឹងសូម្បីតែខុសបន្តិច ហើយវានឹងមិនស៊ីឡើយ ។

វារីករាយណាស់នៅក្នុងការមើលត្រីនោះលោតត្របាក់នុយ ហើយខំប្រឹងហែលត្រឡប់ទៅវិញរហូតអស់កម្លាំង ទើបរវៃនុយមកវិញ ។ ការប្រកួតប្រជែងក្នុងការសាកល្បងជំនាញ និង ចំណេះដឹងរបស់អ្នកស្ទូចត្រីដ៏ល្អស្លូតបូតនោះ ។

ការប្រើប្រាស់នុយក្លែងក្លាយដើម្បីបញ្ឆោតចាប់ត្រីគឺជាគំរូមួយពីរបៀបដែលលូស៊ីហ្វើរល្បួង បញ្ឆោត ហើយព្យាយាមទាក់ទាញយើងជាញឹកញាប់ ។

ដូចជាអ្នកស្ទូចត្រីដែលដឹងថា ត្រីនោះត្រូវបានប្រម៉ាញ់ដោយភាពស្រេកឃ្លានលូស៊ីហ្វើរដឹងពី « ភាពស្រេកឃ្លាន » ឬភាពទន់ខ្សោយរបស់យើង និងល្បួងយើងដោយនុយក្លែងក្លាយដែលអាចអូសទាញជីវិតរបស់យើងឲ្យធ្លាក់ចូលទៅក្នុងឥទ្ធិពលដែលគ្មានសេចក្ដីមេត្តាករុណារបស់វា ប្រសិនបើធ្វើតាម ។ ពុំដូចជាអ្នកស្ទូចត្រីដែលចាប់ហើយប្រលែងត្រីចូលទៅក្នុងទឹកវិញដោយគ្មានគ្រោះថ្នាក់នោះទេ លូស៊ីហ្វើរនឹងមិនប្រលែងយើងដោយងាយនោះឡើយ ។ គោលដៅរបស់វាគឺធ្វើឲ្យជនរងគ្រោះរបស់វារងទុក្ខវេទនាដូចជាវាដែរ ។

មធ្យោបាយដ៏ចម្បងមួយដែលវាប្រើទាស់នឹងយើងគឺសមត្ថភាពរបស់វាក្នុងការភូតកុហក បោកបញ្ឆោតយើងឲ្យជឿថា សេចក្ដីអាក្រក់ជាសេចក្ដីល្អ ហើយថាសេចក្ដីល្អទៅជាសេចក្ដីអាក្រក់ទៅវិញ ។ ចាប់តាំងពីដំបូងមកម្ល៉េះនៅក្នុងការប្រជុំប្រឹក្សាដ៏ធំក្រៃលែងនៅលើស្ថានសួគ៌ សាតាំង « បានខំរកបំផ្លាញសិទ្ធិជ្រើសរើសរបស់មនុស្ស ដែលយើងជាព្រះអម្ចាស់ដ៏ជាព្រះបានប្រទានដល់វា » ( ម៉ូសេ 4:3 ) ។

ចម្បាំងដ៏សាហាវដែលព្រះបានផ្ដល់សិទ្ធិជ្រើសរើសដល់មនុស្ស នៅតែបន្តដល់សព្វថ្ងៃនេះ ។ សាតាំង និង ពលបរិវាររបស់វាកំពុងដាក់នុយរបស់ពួកវានៅជុំវិញយើង ដោយរំពឹងថា យើងនឹងធ្លាក់ចុះ ហើយស៊ីនុយរបស់វា ដើម្បីឲ្យវាអាចឃុំឃាំងយើងតាមរយៈមធ្យោបាយបោកបញ្ឆោតនានា ។

បងប្អូនប្រុសស្រី សូមឲ្យយើងម្នាក់ៗតែងតែប្រយ័ត្នចំពោះនុយក្លែងក្លាយដែលបានដាក់នៅចំពោះមុខយើង ដោយជននេសាទមនុស្សក្លែងក្លាយ លូស៊ីហ្វើរ ។ សូមឲ្យយើងមាននូវប្រាជ្ញា និង ចក្ខុវិស័យខាងវិញ្ញាណដើម្បីចេះវែកញែករវាងខុស និងត្រូវ ហើយបដិសេធនូវការផ្ដល់ឲ្យដ៏គ្រោះថ្នាក់ជាច្រើនរបស់វា ។



ហើយចំពោះអស់អ្នកដែលត្រូវបានធ្លាក់ទៅជាចំណីក្នុងការញៀនគ្រប់ប្រភេទ វាមាននូវក្ដីសង្ឃឹម ដោយសារព្រះស្រឡាញ់កូនចៅទាំងអស់របស់ទ្រង់ ហើយដោយសារតែដង្វាយធួន និង សេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ធ្វើឲ្យអ្វីៗទាំងអស់អាចកើតឡើងបាន ។ ■

*ដកស្រង់ចេញពី « O That Cunning Plan of the Evil One » លីអាហូណា ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 108–110 ។*

រូបភាព ដោយ ជេ ខេន ស្ពៀរើ

# ការយល់ដឹង



## តើខ្ញុំជាអ្នកត្រួសត្រាយផ្លូវនៅសព្វថ្ងៃនេះមែនទេ ?

« កាលយើងឲ្យកិត្តិយសដល់ពួកអ្នកត្រួសត្រាយផ្លូវទាំងនោះដែលបានដើរឆ្លងកាត់ទីវាលទៅកាន់ជ្រលងភ្នំសលត៍ លេក ក៏មានពួកអ្នកត្រួសត្រាយផ្លូវជាច្រើនទៀតដែលកំពុងរស់នៅសព្វថ្ងៃនេះដែរ ។ ពួកគេមិនបានរុញរទេះទេ ប៉ុន្តែពួកគេមានស្ថានភាពដូចគ្នាតាមរបៀបជាច្រើន ៖ ពួកគេបានស្តាប់ឮសំឡេងរបស់ព្រះអម្ចាស់តាមរយៈព្រះគម្ពីរមរមន និងតាមរយៈការអធិស្ឋានផ្ទាល់ខ្លួនរបស់ពួកគេ ។ ដោយមានសេចក្តីជំនឿ និង ការប្រែចិត្តពួកគេបានឈានជើងចូលទៅក្នុងទឹកនៃបុណ្យជ្រមុជទឹក ហើយឈរយ៉ាងរឹងមាំនៅក្នុងដំណឹងល្អដ៏ប្រពៃ ។ ក្នុងនាមជាពួកសិស្សនៃព្រះគ្រីស្ទ ពួកគេសុខចិត្តលះបង់ចំពោះអ្វីដែលត្រឹមត្រូវ ហើយពិត ។ ហើយដោយមានអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ពួកគេកំពុងឈរយ៉ាងរឹងមាំនៅលើផ្លូវរបស់ពួកគេ ឆ្ពោះទៅជីវិតដ៏នៅអស់កល្បជានិច្ច » ។

**អែលឌើរ នែល អិល អាន់ឌើរសិន** នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Come unto Him » *Liahona* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 80 ។

# កំមាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់មជ្ឈិមវ័យវ័យក្មេង



ទំព័រ 44

### ការឈរការពារអ្វីដែលយើងជឿ

ពួកមនុស្សពេញវ័យវ័យក្មេងប្រាំនាក់ចែកចាយពីរបៀបដែលពួកគេបានការពារសេចក្ដីជំនឿ ក្នុងអំឡុងពេលប្រឈមមុខនឹងឧបសគ្គ ។

## សម្រាប់យុវវ័យ

### របៀបសួរសំណួរដែលសំខាន់ៗ

សំណួរទាំងឡាយអាចជាឧបករណ៍បង្រៀនដ៏អស្ចារ្យ—ប្រសិនបើអ្នកប្រើវាតាមរបៀបត្រឹមត្រូវ ។ អត្ថបទនេះនឹងបង្ហាញអ្នកពីរបៀបដើម្បីសួរសំណួរ ។



ទំព័រ 54

## សម្រាប់កុមារ



ទំព័រ 68

### ស្វាគមន៍មកកាន់ថ្នាក់យុវនារី

ស៊ិស្ទើរ ប៊ូនី អិល អូស្ការសុន និង ចៅស្រីរបស់គាត់ ម៉ាធីលដេ ចែកចាយរឿងមួយចំនួនដែលអ្នកអាចរំពឹងចង់បានសម្រាប់ថ្នាក់យុវនារី ។

CAMBODIAN
4 02109 90258 0

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ